# កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន

[CITIZENS’ RATING REPORT-CRR]

ការលើកស្ទួយអភិបាលកិច្ចមូលដ្ឋានល្អ, គណនេយ្យភាព និង

ការផ្តល់សេវាកម្មសង្គមមូលដ្ឋានប្រកបដោយប្រសិទ្ធភាពនៅជនបទកម្ពុជា

## សៀវភៅសំរាប់វគ្គបណ្តុះបណ្តាល



ការបោះពុម្ពផ្សាយរបស់

គំរោងគាំទ្រក្រុមប្រឹក្សាឃុំ

**ភ្នំពេញ, ខែមិថុនា ឆ្នាំ ២០០៧**

មតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ត្រូវបានគ្រប់គ្រងដោយ

**គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់** ក្រោមការឧបត្ថម្ភរបស់ **CAFOD**.

ច្បាប់ចម្លង ឬព័ត៌មានបន្ថែមចំពោះសៀវភៅនេះអាចរកបានពី

**គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់** ដូចខាងក្រោម :


ជាន់ទី១, វិទ្យាស្ថានបំរើអ្នកសម្របសម្រួលការងារអភិវឌ្ឍន៍ (VBNK), ផ្ទះលេខ ២៨,

ផ្លូវកែងលេខ ៨០ និង ៧៥, សង្កាត់ស្រះចក, ខណ្ឌដូនពេញ

ប្រអប់សំបុត្រលេខ ៥០, ភ្នំពេញ, កម្ពុជា

ទូរសព្ទ័ និងទូរសារលេខ : (៨៥៥ ២៣) ៤២៧ ១៩៧

អ៊ីម៉ែល : ccsp.info@online.com.kh

វ៉ិបសាយ : www.ccspcambodia.org

លោក **ម៉ូរ៉ារី អាប់ផេឌីយ៉ៀ**

នាយកប្រតិបត្តិ

**គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់**

អ៊ីម៉ែល : ccsp.ed@online.com.kh

លោក **ឆាន់ សុធា**

ទីប្រឹក្សាថ្នាក់ជាតិ

អ៊ីម៉ែល : sotheacam@gmail.com



**គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់** ត្រូវបានសហគ្រប់គ្រងដោយអង្គការ Church World Service, COMFREL, Concern World Wide, DPA, NGO Forum, Oxfam GB, PACT Cambodia, SEDOC and World Vision Cambodia.

ខែ មិថុនា ឆ្នាំ ២០០៧

ភ្នំពេញ, កម្ពុជា

# ពាក្យបម្រួញ និងពាក្យដទៃទៀត

| | |
|---|---|
| **BATF** | ចលនាររបៀបវារៈការងារបឹងហ្គាឡូ |
| **BDA** | អាជ្ញាធរអភិវឌ្ឍន៍បឹងហ្គាឡូ |
| **BESCOM** | ក្រុមហ៊ុនអគ្គិសនីបឹងហ្គាឡូ |
| **BMP** | សាជីវកម្មរដ្ឋធានីបឹងហ្គាឡូ |
| **BMTC** | សាជីវកម្មដឹកជញ្ជូននៃរដ្ឋធានីបឹងហ្គាឡូ |
| **BSNL** | ទូរគមនាគមន៍បឹងហ្គាឡូ |
| **BWSSB** | គណៈក្រុមប្រឹក្សាផ្គត់ផ្គង់ទឹក និងប្រពន្ធ័លូបង្ហូរទឹកស្អុយបឹងហ្គាឡូ |
| **CAR** | ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល |
| **CBO** | អង្គការសហគមន៍មូលដ្ឋាន |
| **CC** | ក្រុមប្រឹក្សាឃុំ |
| **CCSP** | គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់ |
| **CDP** | ផែនការអភិវឌ្ឍន៍ឃុំ |
| **CDRI** | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា |
| **CIP** | កម្មវិធីវិនិយោគឃុំ |
| **CRR** | កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន |
| **CRT** | ក្រុមស្រាវជ្រាវឃុំ |
| **CSO** | អង្គការសង្គមស៊ីវិល |
| **D&D** | វិមជ្ឈការ និង វិសហមជ្ឈការ |
| **Deika** | សេចក្តីសំរេចចិត្ត/បទបញ្ញត្តិ |
| **DoLA** | នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន |
| **GAP** | ផែនការសកម្មភាពអភិបាលកិច្ច |
| **ICT** | បច្ចេកវិជ្ជាព័ត៌មាន និងប្រាស្រ័យទាក់ទង |
| **LAMC** | ច្បាប់រដ្ឋបាលនិងគ្រប់គ្រងឃុំ-សង្កាត់ |
| **LDC** | ក្រុមប្រឹក្សាអភិវឌ្ឍន៍មូលដ្ឋាន |
| **MDG** | គោលដៅអភិវឌ្ឍន៍សហសវត្ស |
| **MEF** | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| **MOU** | អនុស្សរណៈយោគយល់ |
| **NCDD** | ក្រុមប្រឹក្សាជាតិដើម្បីការងារគ្រប់គ្រងវិមជ្ឈការ និងវិសហមជ្ឈការ |
| **NCSC** | គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់ |
| **NGO** | អង្គការក្រៅរដ្ឋាភិបាល |
| **NPAR** | កម្មវិធីជាតិដើម្បីកំណែទម្រង់រដ្ឋបាល |

| | |
|---|---|
| **NPRS** | យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ |
| **NSDP** | ផែនការយុទ្ធសាស្ត្រជាតិដើម្បីអភិវឌ្ឍន៍ |
| **PAC** | មជ្ឈមណ្ឌលការងារសាធារណៈ |
| **PIP** | ផែនការកែលំអការងារ |
| **PLAU** | ផ្នែករដ្ឋបាលមូលដ្ឋានថ្នាក់ខេត្ត |
| **PMG** | ក្រុមបេសកកម្មអាទិភាព |
| **PPA** | ការប៉ាន់ប្រមាណពីភាពក្រីក្រដោយមានការចូលរួម |
| **Prakas** | បទបញ្ជាចេញដោយរដ្ឋមន្ត្រី |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **SMEs** | សហគ្រាសខ្នាតតូច និងមធ្យម |
| **ToT** | វគ្គបណ្តុះបណ្តាលគ្រូបង្គោល |
| **UNDP** | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| **USAID** | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការងារអភិវឌ្ឍន៍អន្តរជាតិ |

# បុព្វកថា

ក្នុងការផ្សាភ្ជាប់ទៅនឹងបេសកកម្មរបស់ខ្លួនក្នុងការពង្រឹងសមត្ថភាពសង្គមស៊ីវិល ដើម្បីមានឥទ្ធិពល និងចូលរួមនៅក្នុងដំណើរការកំណែទម្រង់អភិបាលកិច្ចមូលដ្ឋាននិងវិមជ្ឈការ គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់ នៅក្នុងឆ្នាំ ២០០៤ បានត្រួស ត្រាយការអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ដើម្បីធ្វើឱ្យប្រជាពលរដ្ឋឈានកាន់តែគៀកទៅរកអភិបាល កិច្ច តាមរយៈការចូលរួមផ្ទាល់របស់ពួកគេនៅក្នុងការត្រួតពិនិត្យសេវាកម្មទាំងឡាយនៅថ្នាក់ឃុំ និងដើម្បីផ្តល់ការរួម ចំណែកផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងការធ្វើសេចក្តីសំរេចចិត្តនៅក្នុងក្រុមប្រឹក្សាឃុំ និងនៅក្នុងអត្តសញ្ញាណទាំងឡាយ ផ្សេងទៀតនៅថ្នាក់ក្រោមជាតិ ។

រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងឆ្នាំ ២០០៥ បានសំរេចចិត្តជ្រើសយកក្របខណ្ឌយុទ្ធសាស្ត្រដើម្បីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។ ការណ៍នេះបានផ្តល់នូវឱកាសថ្មីមួយសំរាប់ការចូលរួមរបស់សង្គមស៊ីវិលកាន់តែកើនឡើងនៅក្នុងដំណើរការអភិបាលកិច្ចមូលដ្ឋាន ។ គោលការណ៍គ្រឹះរបស់យុទ្ធសាស្ត្រនេះ គឺស្វែងរកការលើកស្ទួយយន្តការនៃការត្រួតពិនិត្យពីប្រជាពលរដ្ឋ ដើម្បីជំរុញឱ្យមានតម្លាភាពនៅរដ្ឋអំណាចមូលដ្ឋាន និងគណនេយ្យភាពសង្គមទាំងមូល ។

ឱកាសថ្មីនេះបានបញ្ជាក់បន្ថែមទៀត នូវភាពជាប់ទាក់ទងនិងសារសំខាន់នៃការបន្តការងាររបាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋនេះ ។ ថ្វីបើលទ្ធផលជាវិជ្ជមានគួរឱ្យកត់សំគាល់នៅក្នុងការងារអនុវត្តកន្លងមកក៏ដោយក៏កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន នេះតម្រូវឱ្យមានការវាយតំលៃឯករាជ្យ ដើម្បីប៉ាន់ប្រមាណពីភាពសមស្របនៃវិធី សាស្ត្រគំរោង និងផលសំរេច ។ ដូចគ្នានេះដែរ វាសំខាន់ណាស់ដែលកម្មវិធីសិក្សាដែលមានការរៀបចំបានល្អ និងការគ្រោងវគ្គបណ្តុះបណ្តាលត្រូវបានអភិវឌ្ឍឡើង ដើម្បីសម្របសម្រួលការ ធ្វើឡើងវិញនេះឱ្យកាន់តែប្រសើរនោះ ។

ដូចនេះ គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់ នៅខែ កុម្ភៈ ឆ្នាំ ២០០៧ បានរៀបចំកិច្ចសន្យាជាមួយលោក **ផាន់ សុធា** ជាទីប្រឹក្សាឯករាជ្យ ដើម្បីអនុវត្តការវាយតំលៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ដើម្បីសិរិតសំរាងឡើងវិញ នូវវិធីសាស្ត្រកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ដោយប្រើអនុសាសន៍ចេញពីការសិក្សាវាយតំលៃ ហើយដើម្បីបង្កើតជាសៀវភៅក្បួនសំរាប់វគ្គបណ្តុះបណ្តាល ដែលអនុវត្តបន្តដោយអង្គការក្រៅរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលដទៃផ្សេងទៀត ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក ផាន់ សុធា ក្នុងការបញ្ចប់រួចរាល់ជាស្ថាពររបស់គាត់នូវសៀវភៅក្បួនសំរាប់វគ្គបណ្តុះបណ្តាលកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន និងសូមបង្ហាញពីការដឹងគុណ ដ៏ស្មោះស្ម័គ្ររបស់ខ្ញុំចំពោះអង្គការ CAFOD នៃចក្រភពអង់គ្លេស ដែលបានគាំទ្រធនធានមិនអាចកាត់ថ្លៃបាន សំរាប់ការងារដ៏មានសារៈសំខាន់នេះ ។

ប្រជាជនជាច្រើន រួមទាំងមេឃុំ ក្រុមប្រឹក្សាឃុំ សមាជិកទាំងឡាយនៃដៃគូជាអង្គការក្រៅរដ្ឋាភិបាលដែលកំពុងអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន សមាជិកទាំងឡាយរបស់ក្រុមស្រាវជ្រាវឃុំ តំណាងរបស់អង្គការផ្សេងៗ នៅទីក្រុងភ្នំពេញ និងប្រជាពលរដ្ឋនៅតាមបណ្តាឃុំ បានចូលរួមយ៉ាងពេញទំហឹង ក្នុងន័យធ្វើឱ្យខ្លឹមសារ

នៃសៀវភៅក្បួនសំរាប់វគ្គបណ្តុះបណ្តាលកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាននេះ កាន់តែប្រសើរឡើង ដោយការចែករំលែកដោយសេរី និងស្មោះត្រង់នូវយោបល់ និងគោលទស្សនៈរបស់ពួកគេ ។ ខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីបង្ហាញពីការសាទរយ៉ាងស្មោះស្ម័គ្រ និងដឹងគុណចំពោះការងារទាំងអស់នេះ ។

សំខាន់ជាងនេះទៅទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះបុគ្គលិកគំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់ លោក **យុក សេខឡុង** លោកស្រី **យិន សុន្ទរីណែត** និងលោកស្រី **ចក់ សុលីណែត** ចំពោះការងារដ៏ឈ្លាសវៃ និងការគាំទ្រផ្នែកខាងការរៀបចំចាត់ចែងនានា ដើម្បីបញ្ចប់គំរោងសៀវភៅកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាននេះ ប្រកបដោយជោគជ័យ ។

លោក **ម៉ូរ៉ារី អាប់ផេឌីយៀ**
នាយកប្រតិបត្តិ

ភ្នំពេញ, ខែ មិថុនា ឆ្នាំ ២០០៧

# មាតិកាអត្ថបទ

ពាក្យបម្រួញ និងពាក្យដទៃទៀត.....i

បុព្វកថា.....iii

សេចក្តីផ្តើម ..... 1

**ម៉ូឌុល ១ : ការស្វែងយល់ពីវិមជ្ឈការ និងក្រុមប្រឹក្សាឃុំ-សង្កាត់** ..... 9

**1.1** ស្ថានភាពបច្ចុប្បន្ននៃវិមជ្ឈការក្នុងប្រទេសកម្ពុជា ..... 9

**1.2** អត្ថន័យនៃពាក្យវិមជ្ឈការ ..... 12

**1.3** គោលបំណងរបស់វិមជ្ឈការ និង វដ្ឋបាលនិងការគ្រប់គ្រងឃុំ..... 19

**1.4** អំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់..... 21

**1.5** រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់..... 24

**1.6** តួនាទី និងការទទួលខុសត្រូវរបស់តួអង្គសំខាន់ៗនៅក្នុងការអភិវឌ្ឍឃុំ ..... 25

**1.7** បណ្តាញគាំទ្រឃុំ-សង្កាត់..... 29

**1.8** ការងារសំខាន់ៗរបស់ក្រុមប្រឹក្សា-សង្កាត់..... 32

**ម៉ូឌុល ២ : ក្របខណ្ឌស្របច្បាប់សំរាប់សេវាកម្មសាធារណនៅក្នុងប្រទេសកម្ពុជា**..... 44

**2.1** គោលទស្សនះរដ្ឋាភិបាលចំពោះការផ្តល់សេវាកម្មសាធារណះ..... 45

**2.2** គោលនយោបាយរដ្ឋាភិបាលចំពោះការផ្តល់សេវាកម្មសាធារណះ..... 47

**2.3** ការប្រឈមមុខចំបងៗ នៅក្នុងការផ្តល់សេវាកម្មសាធារណះនៅថ្នាក់មូលដ្ឋាន..... 65

**ម៉ូឌុល ៣ : អ្វីទៅជាកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន?**..... 67

**3.1** សេចក្តីផ្តើម..... 67

**3.2** បទបញ្ញត្តិច្បាប់សំរាប់គណនេយ្យភាពសង្គម និងការផ្តល់សេវាកម្ម

ជាមូលដ្ឋាននានា នៅថ្នាក់ឃុំ ........ 70
3.3 កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន........ 72
3.4 គោលគំនិត និងយុទ្ធសាស្ត្រនៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន........ 74
3.5 គោលបំណង លទ្ធផល និងវិធីសាស្ត្រ ........ 77

**ម៉ូឌុល ៤ : ការអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន**........ 87
4.1 ដំណើរការកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន........ 88
4.2 តើត្រូវអនុវត្តសកម្មភាពនិមួយៗ យ៉ាងដូចម្តេច? ........ 89
សកម្មភាព ទី១ : ការប៉ាន់ប្រមាណភ្លាមៗទៅលើឃុំ ចំពោះភាពសមស្របសំរាប់ កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ........ 90
សកម្មភាព ទី ២ : អត្តសញ្ញាណកម្ម និងការជ្រើសរើសឃុំគោលដៅ........ 91
សកម្មភាព ទី ៣ : ការចរចារ និងការបញ្ចុះបញ្ចូលដើម្បីការយល់ព្រម និងការចាប់ផ្តើម........ 92
សកម្មភាព ទី ៤ : អត្តសញ្ញាណកម្ម ការជ្រើសរើស និងវាយតំលៃលើសេវាកម្មចំបងៗ........ 96
សកម្មភាព ទី ៥ : គ្រោងបញ្ជីរសំណួរ ........ 97
សកម្មភាព ទី ៦ : ការជ្រើសរើសអង្គការអនុវត្តនៅមូលដ្ឋាន........ 99
សកម្មភាព ទី ៧ : ការចាត់ចែងក្រុមស្រាវជ្រាវថ្នាក់ឃុំ........ 100
សកម្មភាព ទី ៨ : ការរៀបចំអនុស្សរណយោគយល់ និងកិច្ចសន្យាជាផ្លូវការ ........ 101
សកម្មភាព ទី ៩ : បណ្តុះបណ្តាលគ្រូបង្គោលលើគោលគំនិត និងវិធីសាស្ត្រ........ 102
សកម្មភាព ទី ១០ : ការជំរុញកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន នៅក្នុងឃុំ និងនៅសាធារណៈ ........ 103
សកម្មភាព ទី ១១ : រៀបចំផែនការសកម្មភាពសំរាប់ការវាស់វែងវាយតំលៃនៅ មូលដ្ឋាន........ 104
សកម្មភាព ទី ១២ : ការយកសំណាកនៃអ្នកឆ្លើយតប ........ 105
សកម្មភាព ទី ១៣ : បណ្តុះបណ្តាល បង្វឹក និងណែនាំពីការងារ........ 106
សកម្មភាព ទី ១៤ : អនុវត្តការវាស់វែងនៅមូលដ្ឋាន........ 109

សកម្មភាព ទី ១៥ : ផ្ទៀងផ្ទាត់ វិភាគ និងរៀបចំរបាយការណ៍........................................ 110

សកម្មភាព ទី ១៦ : ការត្រួតពិនិត្យ និងជំនួយបច្ចេកទេសបន្ត........................................ 111

សកម្មភាព ទី ១៧ : ការប្រជុំជាមួយក្រុមប្រឹក្សា-សង្កាត់ និងអ្នកផ្តល់សេវាកម្ម................... 111

សកម្មភាព ទី ១៨ : ការតស៊ូមតិ.................................................................................. 113

សកម្មភាព ទី ១៩ : ការបង្កើត និងការពង្រឹងបណ្តាញមូលដ្ឋាន
និងរក្សានិរន្តរភាព........................................................................ 116

សកម្មភាព ទី ២០ : សកម្មភាពវាយតំលៃ ............................................................... 116

សកម្មភាព ទី ២១ : ការផ្សព្វផ្សាយ និងអនុវត្តន៍បន្ត .................................................. 117

4.3 ឱវាទមួយចំនួនដើម្បីការជោគជ័យ................................................................... 119

**ម៉ូឌុល ៥ : ការបកស្រាយនៅក្នុងគណនេយ្យភាពសង្គម**....................................... 122

ការបកស្រាយ ទី ១ : គោលគំនិតនៃគណនេយ្យភាពសង្គម ................................................. 124

ការបកស្រាយ ទី ២ : គណនេយ្យភាពសង្គមគឺជាអ្វី?........................................................ 125

ការបកស្រាយ ទី ៣ : ការបង្កើតរនាំងនៃគណនេយ្យភាព.................................................... 126

ការបកស្រាយ ទី ៤ : ទំហំនៃគណនេយ្យភាពសង្គម........................................................... 130

ការបកស្រាយ ទី ៥ : គណនេយ្យភាព : កត្តាជាយុទ្ធសាស្ត្រសំរាប់ការជោគជ័យ.......................... 132

ការបកស្រាយ ទី ៦ : ឧបករណ៍ជំរុញគណនេយ្យភាព......................................................... 136

ការបកស្រាយ ទី ៧ : បទពិសោធន៍ពីប្រទេសផ្សេងៗ......................................................... 139

ការបកស្រាយ ទី ៨ : ករណីសិក្សា : ប៊ីងហ្គាឡូ ប្រទេសឥណ្ឌា។ ប័ណ្ណព័ត៌មានសហគមន៍ ................ 143

ការបកស្រាយ ទី ៩ : បរិបទគណនេយ្យភាពសង្គមនៅប្រទេសកម្ពុជា ជាអ្វី?............................... 157



## សេចក្តីផ្តើម

ច្បាប់រដ្ឋបាលនិងគ្រប់គ្រងឃុំ-សង្កាត់ ក្របខណ្ឌយុទ្ធសាស្រ្តសំរាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងគោលនយោបាយផ្សេងៗទៀត គឺកំណត់ការងារគ្រប់គ្រងឃុំ-សង្កាត់ទាំងអស់ នៅក្នុងប្រទេសកម្ពុជា។ ច្បាប់នេះ បានចែងថា ក្រុមប្រឹក្សាឃុំ-សង្កាត់និមួយៗគួរតែត្រូវបានគេធ្វើអភិបាលកិច្ចនៅក្នុងរបៀបមួយ ដែលមាន គណនេយ្យភាពដល់ប្រជាពលរដ្ឋទាំងអស់ ហើយគួរតែលើកកំពស់និងសម្របសម្រួលយ៉ាងសកម្ម នូវដំណើរការប្រជាធិបតេយ្យ ដោយបង្កើតឡើងនូវដំណើរការពិគ្រោះយោបល់ជាមួយប្រជាជន សង្គមស៊ីវិល និងសមាជិកសហគមន៍ ជាពិសេស នៅក្នុងការបែងចែកការផ្តល់សេវាកម្មសង្គមជាមូលដ្ឋាននានា ប្រកបដោយតម្លាភាព និងគណនេយ្យភាពរឹងមាំ។ នៅជំហានដំបូងនៃដំណើរការធ្វើផែនការអភិវឌ្ឍន៍ឃុំ ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវតែប៉ាន់ប្រមាណពីកំរិតបច្ចុប្បន្ននៃការទទួលយកនូវសេវាសង្គមសំខាន់។ នៅចុងបញ្ចប់នៃបំណាច់ដើមឆ្នាំនីមួយៗ ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវពិនិត្យឡើងវិញ និងរាយការណ៍ពីបញ្ហាដែលជួបប្រទះ នៅក្នុងការផ្តល់សេវាសង្គមជាមូលដ្ឋាន ដល់ប្រជាពលរដ្ឋនៅក្នុងឃុំ ព្រមទាំងផ្តល់អនុសាសន៍ដើម្បីកែលំអ ការផ្តល់សេវាសង្គមសំខាន់ៗនេះ។

ដោយការចូលរួមចំណែកដល់ការអនុវត្តគោលនយោបាយវិមជ្ឈការ និងស្របទៅតាមអាណត្តិរបស់ខ្លួន ដើម្បី ពង្រឹងសង្គមស៊ីវិលនិងការចូលរួមរបស់ប្រជាពលរដ្ឋ និងធ្វើឱ្យមានឥទ្ធិពលនៅក្នុងវិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន **គាំទ្រគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់** បានត្រួសត្រាយការអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។ ការងារនេះប្រើប្រាស់វិធីសាស្រ្តមួយ ដែលបានធ្វើជាគំរូទៅលើប័ណ្ណព័តិមានសហគមន៍ អបអរសារទជាអន្តរជាតិ ត្រូវបានអនុវត្តជាលើកដំបូងនៅក្នុងទីក្រុងបឹងហ្គាឡូ ប្រទេសឥណ្ឌា និងនៅក្នុងការស្ទង់មតិអំពី ការពេញចិត្តរបស់ប្រជាពលរដ្ឋ ដែលបានធ្វើឡើងក្នុងប្រទេស**ហ្វីលីពីន**។ កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ត្រូវបានតស៊ូមតិដោយ **គាំទ្រគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់** ដែលគឺជា យុទ្ធសាស្រ្តកែច្នៃមួយដើម្បីបង្កើនឥទ្ធិពលរបស់ប្រជាពលរដ្ឋ ដើម្បីលើកកំពស់ការឆ្លើយតបរបស់ ទីភ្នាក់ងារផ្តល់សេវាកម្មនិងធានាឱ្យកាន់តែប្រសើរថែមទៀត ចំពោះគណនេយ្យភាពរបស់រដ្ឋាភិបាល ដែលចាប់ផ្តើមនៅថ្នាក់ឃុំ។ យន្តការមួយដែលអាចធ្វើទៅបាន គឺការស្វែងយល់អំពីតម្រូវការនិងកង្វល់ នៅមូលដ្ឋាន ការឆ្លុះបញ្ចាំងនិងពិនិត្យពិច័យលើវិស័យដើម្បីលើកកំពស់ការជំរុញឱ្យមានការចូលរួមរបស់ប្រជាជន ការលើកកំពស់ឱ្យមានការពិភាក្សាស៊ីជម្រៅនៅមូលដ្ឋាន និងប្រភពគួរឱ្យជឿទុកចិត្ត និងកំណែន សំរាប់ក្រុមសាធារណៈជនដែលមានចំណាប់អារម្មណ៍ និងប្រជាពលរដ្ឋទូទៅ ដើម្បីសម្របសម្រួលការបញ្ចេញយោបល់របស់ប្រជាពលរដ្ឋក្នុងការតស៊ូមតិឱ្យមានការផ្តល់សេវាកម្មសាធារណៈសំខាន់ៗ ឱ្យកាន់តែមានភាពល្អប្រសើរឡើង។ កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន បានធ្វើឱ្យមានផលប៉ះពាល់ដល់អ្នកពាក់ពន្ធ័ផ្សេងៗទៀតជាច្រើន ដូចជា អង្គការអនុវត្តថ្នាក់មូលដ្ឋាន អ្នកទទួលផល និងក្រុមគោលដៅ ខាងតស៊ូមតិ។

ដើម្បីអាចបន្តការអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន និងវិធីសាស្ត្រឡើងវិញ អង្គការក្រៅរដ្ឋាភិបាល ដែលពាក់ពន្ធ័និងក្រុមទាំងឡាយរបស់ប្រជាពលរដ្ឋ គួរតែអាចទទួលយកចំណេះដឹង និងការកសាងសមត្ថភាព ប្រកបដោយប្រសិទ្ធភាព។ នៅក្នុងការស្វែងរកគោលដៅនេះ ភាពចាំបាច់ក្នុងការគ្រោងឧបករណ៍កសាងសមត្ថភាព ត្រូវបានគេកំណត់ដោយការប្រមូលព័ត៌មានដែលពាក់ពន្ធ័ និងព័ត៌មានលំអិតនៃដំណើរការ និងនីតិវិធីជាក់ស្តែងសំរាប់ការអនុវត្តន៍នូវកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។

## គោលបំណងរបស់សៀវភៅនេះ

គោលបំណងតំបូងរបស់សៀវភៅនេះ គឺដើម្បីកសាងសមត្ថភាពរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងក្រុមប្រជាជន ដើម្បីឱ្យអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានប្រកាបដោយប្រសិទ្ធភាព ដើម្បី ទ្រមទារអភិបាលកិច្ចដែលមានភាពទទួលខុសត្រូវនៅមូលដ្ឋាន បង្កើនការចូលរួមរបស់ប្រជាជន និងដើម្បី លើកកំពស់ការផ្តល់សេវាកម្មសង្គមសំខាន់ៗប្រកបដោយប្រសិទ្ធភាព ដែលផ្តល់ផលប្រយោជន៍ចំពោះប្រជា ពលរដ្ឋទាំងអស់ស្មើៗគ្នា។

## ហេតុអ្វីបានជាត្រូវបង្កើតសៀវភៅនេះឡើង?

សៀវភៅក្បួននេះត្រូវបានគិតគូរ និងបង្កើតឡើងដោយ **គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់**។ នៅក្នុងទិដ្ឋភាពនយោបាយសង្គមរបស់កម្ពុជាបច្ចុប្បន្ន បញ្ហាគណនេយ្យភាពសង្គម កំពុងតែកើនឡើងការយកចិត្តទុកដាក់ពីសំណាក់ទាំងតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ។ រាជរដ្ឋាភិបាលកម្ពុជាបាន ប្តេជ្ញាចិត្តម្តងទៀតដើម្បីបង្កើតនិងជំរុញយន្តការត្រឹមត្រូវក្នុងការពង្រឹង និងធានាឱ្យមានគណនេយ្យភាព សង្គមក្នុងការផ្តល់សេវាកម្មសង្គមសំខាន់ៗ ដល់ប្រជាពលរដ្ឋ និងសញ្ញាណនៃអភិបាលកិច្ចដែលមានការទទួលខុសត្រូវ។ រាជរដ្ឋាភិបាលកម្ពុជាក៏ទទួលស្គាល់ផងដែរថា ការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធិភាព គឺជាការឆ្លើយតបយ៉ាងសំខាន់ចំពោះតម្រូវការជាក់ស្តែង សំរាប់អភិបាលកិច្ចល្អ ហើយក៏វាអាចឆ្លើយតបជាក់ស្តែងតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ។

សៀវភៅក្បួននេះ គឺជាការឆ្លើយតបទាន់ពេលមួយ ចំពោះតម្រូវការបច្ចុប្បន្នសំរាប់កសាងសហគមន៍ និងសមត្ថភាពប្រជាពលរដ្ឋ ដើម្បីអនុវត្តការត្រួតពិនិត្យយ៉ាងសកម្ម លើការងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអ្នកផ្តល់សេវាកម្មថ្នាក់មូលដ្ឋាន។ សៀវភៅនេះ គឺជាឧបករណ៍ដ៏សំខាន់មួយដែលបង្កើតឡើងជាការណែនាំជាក់ស្តែងសំរាប់អ្នកទាំងឡាយណាដែលមានបំណងចង់លើកកំពស់អភិបាលកិច្ច ដែលមានការទទួលខុសត្រូវនៅថ្នាក់មូលដ្ឋាន។

លើសពីនេះ សៀវភៅក្បួននេះត្រូវបានបង្កើតឡើង ដើម្បីចងក្រងជាឯកសារនូវបទពិសោធន៍រៀនសូត្រពីដំណាក់កាលសាកល្បងរបស់កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន និងដាក់បញ្ចូលទាំងការកែសម្រួលឡើងវិញ នៅក្នុងវិធីសាស្ត្រនិងគោលការណ៍ណែនាំរបស់ កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។ សំរាប់បញ្ហានេះ ការសិក្សាឯករាជមួយត្រូវបានធ្វើឡើងដើម្បីវាយតំលៃ ភាពត្រឹមត្រូវនៃវិធីសាស្ត្រ ដែលយកមកប្រើ និងលទ្ធផលដំបូងនៃគំរោងសាកល្បងនេះ។ ការវាយតំលៃនេះបានផ្តល់បណ្តុំនៃអនុសាសន៍មួយចំនួន ដែលជាប់ទាក់ទងនឹងវិធីសាស្ត្រ និងគោលការណ៍ណែនាំនៃការអនុវត្តរបាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋ។ ផ្អែកទៅតាមអនុសាសន៍ទាំងនេះ កម្មវិធីបណ្តុះបណ្តាល និងការរៀបចំវគ្គបណ្តុះបណ្តាល ត្រូវបានគេបង្កើតឡើងដើម្បីសម្របសម្រួល កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ឱ្យកាន់តែល្អប្រសើរ និងការអនុវត្តបន្តកាន់តែ ទូលំទូលាយនៅក្នុងពេលដ៏មានសារៈសំខាន់នេះ។

## តើសៀវភៅក្បួននេះត្រូវបានបង្កើតឡើងយ៉ាងដូចម្តេច?

ការវាយតំលៃឯករាជមួយត្រូវបានធ្វើឡើងដើម្បីប៉ាន់ប្រមាណលទ្ធផលតំបូង វិធីសាស្ត្រ និងដំណើរការដំបូង។ ការវាយតំលៃនេះ គឺផ្អែកទៅតាមការយល់ឃើញជាសាធារណៈនៅថ្នាល់មូលដ្ឋាន។ ការវាយតំលៃនេះ ក៏បានប៉ាន់ប្រមាណផងដែរចំពោះភាពពេញចិត្ត និរន្តរភាព និងភាពត្រឹមត្រូវតាមច្បាប់នៃការសាកល្បងកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន វិធីដែលទិន្នន័យបានលើកយកមកវិភាគ និងបង្ហាញទៅដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអ្នកផ្តល់សេវាកម្ម ការបង្កើតក្រុមស្រាវជ្រាវឃុំ និងការឧបត្ថម្ភជំនួយគំរោងដល់អង្គការអនុវត្តជាដៃគូ និងក្រុមស្រាវជ្រាវឃុំ ពោលគឺសមត្ថភាព និងសម្ភារៈប្រតិបត្តិការផ្សេងៗ។

សៀវភៅនេះ ត្រូវបានបង្កើតឡើងដោយផ្អែកទៅលើលទ្ធផលការរកឃើញ និងអនុសាសន៍នៃការវាយតំលៃ ជាពិសេស ការយល់ឃើញ និងយោបល់របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ចំពោះរបៀបអនុត្តគំរោងនេះឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។ សៀវភៅក្បួននេះ ក៏បានលើកឡើងផងដែរនូវចំណុចខ្សោយដែលបានរកឃើញក្នុងអំឡុងពេលវាយតំលៃ។ ចំណេះដឹងដែលទាក់ទងទៅនឹងកិច្ចការនៅមូលដ្ឋាន ត្រូវបានលើកមកគិតគូរពិចារណា និងការមើលសារឡើងវិញឱ្យបានយល់គ្រប់ជ្រុងជ្រោយនៅការិយាល័យ ដោយរួមបញ្ចូលទាំងការពិនិត្យឡើងវិញ នូវគោលនយោបាយរបស់រដ្ឋាភិបាល ត្រូវបានគេប្រើប្រាស់ជាការគាំទ្រដល់ការបង្កើតសៀវភៅក្បួននេះ។

## តើសៀវភៅនេះ សំរាប់អ្នកណាប្រើបាស់?

ខ្លឹមសារនៃសៀវភៅក្បួននេះ បានមកពីចំណេះដឹង និងបទពិសោធន៍របស់បុគ្គលម្នាក់ៗជាច្រើន

ដែលបានចូលរួមដោយផ្ទាល់ក្នុងការបំពេញការងារជំហានសាកល្បង នៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន បានមកពីគោលនយោបាយនិងបទបញ្ញាដែលជាប់ពាក់ព័ន្ធផ្សេងៗរបស់រដ្ឋាភិបាល និងបទពិសោធន៍បានពីប្រទេសផ្សេងៗ។ សៀវភៅក្បួននេះត្រូវបានគ្រោងដំបូង សំរាប់អ្នកទាំងឡាយណាដែលមានចំណាប់អារម្មណ៍ ក្នុងការលើកកំពស់ ការផ្តល់សេវាកម្មនៅក្នុងក្របខណ្ឌនៃអភិបាលកិច្ចមូលដ្ឋានដែលទទួលខុសត្រូវ ប៉ុន្តែមិនសំរាប់អ្នកទាំងឡាយណាដែលមិនមានការយល់ដឹងស៊ីជំម្រៅលើគោលគំនិត គោលការណ៍ណែនាំ ដំណើរការ ឬធនធានដែលត្រូវការ មាននៅក្នុងប្រទេសកម្ពុជាទេ។ វាផ្តល់នូវការយកចិត្តទុកដាក់តែចំពោះបរិបទមួយ ដែលកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានអាចប្រតិបត្តិបានប៉ុណ្ណោះ។ ចំពោះអ្នកទាំងឡាយណាដែលមានចំណេះដឹងរួចជាស្រេច អំពីប្រធានបទ និងបទពិសោធន៍នៅក្នុងវិស័យនេះ សៀវភៅនេះ គឺផ្តល់នូវធនធានសំរាប់ការស្រាវជ្រាវបន្ថែម និងពិនិត្យឡើងវិញ នូវមូលដ្ឋាននៃដំណើរការអនុវត្តន៍កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។

## តើសៀវភៅនេះ នឹងធ្វើអ្វីខ្លះ?

សៀវភៅក្បួននេះត្រូវបានគេរំពឹងថា ធ្វើឱ្យសាយភាយ ធ្វើសារជាថ្មីឡើងវិញ និងបញ្ជាក់ឡើងវិញចំពោះចំណាប់អារម្មណ៍ក្នុងនៅគណនេយ្យភាពសង្គម។ ដើម្បីធ្វើការងារនេះបាន ការបកស្រាយលំអិតអំពីសកម្មភាពត្រូវបានគេផ្តល់ដើម្បីជួយបង្កើតឱ្យមានការយល់ដឹងរួមគ្នាអំពីយុទ្ធវិធីសមស្រប។ សៀវភៅក្បួននេះ ក៏បានផ្តល់បន្ថែមនូវគន្លឹះជុំវិញការអនុវត្តនិងឱកាសសំរាប់បត់បែន ដំណើរការដែលអាចកែសំរួល និងអនុវត្តទៅតាមឱកាសផ្សេងៗរបស់អ្នក។ តាមរយៈការអាន និងការរៀនសូត្រសៀវភៅក្បួននេះ អ្នកនឹងអាចមានលទ្ធភាព :

- យល់ដឹងពីខ្លឹមសាររបស់កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន
- ស្រាវជ្រាវពីលក្ខខណ្ឌដែលគាំទ្រការអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន
- ពន្យល់ពីដំណើរការនៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន
- ពន្យល់ពីអ្វីដែលសំខាន់ ដើម្បីអាចធ្វើឱ្យមានតម្រូវការប្រកបដោយប្រសិទ្ធិភាព សំរាប់កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន
- កំណត់អំពីបញ្ហារួមគ្នាបំផុត ដែលកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានប្រឈមមុខដំបូងបង្អស់
- ពន្យល់ពីរបៀបដែលបញ្ហាទាំងនេះគេអាចដោះស្រាយបានតាមបទពិសោធន៍កន្លងមក
- យល់ដឹងពីយន្តការ និងឧបករណ៍ដើម្បីរៀបចំគំនិតផ្តួចផ្តើមឆ្លើយតបរបស់ប្រជាពលរដ្ឋ
- យល់ដឹងអំពីគណនេយ្យភាពសង្គម និងរបៀបដែលប្រជាពលរដ្ឋចូលរួម។

## តើសៀវភៅនេះ នឹងមិនធ្វើអ្វីខ្លះ?

សៀវភៅក្បួននេះមានបំណងផ្ដល់តែនូវលក្ខណៈសាមញ្ញ និងងាយអនុវត្តន៍សំរាប់ជនសាមញ្ញ ប៉ុន្តែសំរាប់ប្រជាពលរដ្ឋដែលមានការយល់ដឹង ដើម្បីចេះត្រួតពិនិត្យនូវការផ្ដល់សេវាកម្មសង្គមជាមូលដ្ឋាននៅក្នុងបរិបទសង្គមកម្ពុជា។ វាមិនផ្ដល់ការទទួលខុសត្រូវផ្នែកចំណេះដឹងក្រៅពីប័ណ្ណព័ត៌មានសហគមន៍ និងឧបករណ៍គណនេយ្យភាពសង្គមផ្សេងទៀតនោះទេ។

## តើមានអ្វីខ្លះនៅក្នុងសៀវភៅក្បួននេះ?

សៀវភៅក្បួននេះ រួមមាន ៥ ម៉ូឌុល ដែលបកស្រាយអំពីចំណេះដឹងជាមូលដ្ឋាននៃវិមជ្ឈការ គោលនយោបាយ សេវាកម្មសាធារណៈ កម្មវិធីមតិប្រជាពលរដ្ឋស្ដីពីអភិបាលកិច្ចមូលដ្ឋាន និងដំណើរការអនុវត្តរបស់វា និងបទពិសោធន៍ ក្នុងការទាមទារឱ្យមានគណនេយ្យភាពសង្គម និងការផ្ដល់សេវាកម្ម។ ម៉ូឌុលទាំង ៥ នេះមាន ៖

### ម៉ូឌុល ១ ៖ ការស្វែងយល់ពីវិមជ្ឈការ និងក្រុមប្រឹក្សាឃុំ

ម៉ូឌុលនេះរៀបរាប់អំពីស្ថានភាពបច្ចុប្បន្ននៃវិមជ្ឈការក្នុងប្រទេសកម្ពុជា អត្ថន័យនៃពាក្យវិមជ្ឈការ គោលបំណងនិងគោលនយោបាយផ្សេងៗដែលពាក់ព័ន្ធនឹងកិច្ចការនៅមូលដ្ឋាន។ ចំណេះដឹងទាំងនេះ នឹងផ្ដល់ឱ្យអ្នកចូលរួមនូវការយល់ដឹងនៃបរិបទជុំវិញការអនុវត្តគំរោង។ ការយល់ដឹងអំពីអំណាច តួនាទី មុខងារ និងកិច្ចការសំខាន់ៗរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងវចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ នឹងផ្ដល់ដល់សិក្ខាកាមនូវចំណេះដឹងមូលដ្ឋាន ដើម្បីឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់គិតគូរពិចារណា និងយកចិត្តទុកដាក់ចំពោះតម្រូវការនៅមូលដ្ឋាន។ តួនាទីរបស់អ្នកពាក់ព័ន្ធផ្សេងៗទៀត និងបណ្ដាញគាំទ្រនានា ត្រូវបានពិពណ៌នាដើម្បីជួយឱ្យសិក្ខាកាមបង្កើនការយល់ដឹងបន្ថែមទៀត និងដើម្បីបង្កើតសមត្ថភាពក្នុងការទាមទារការបំពេញការងារក្រុមប្រឹក្សាឃុំ-សង្កាត់ ចំពោះប្រជាជនឱ្យកាន់តែល្អប្រសើរថែមទៀត។

### ម៉ូឌុល ២ ៖ ក្របខណ្ឌស្របច្បាប់ សំរាប់ការផ្ដល់សេវាកម្មសាធារណៈនៅក្នុងប្រទេសកម្ពុជា

ម៉ូឌុលទីពីរនេះ ផ្ដល់នូវចំណេះដឹងអំពីក្របខណ្ឌស្របច្បាប់ ដែលទាក់ទងនឹងការផ្គត់ផ្គង់សេវាកម្មសាធារណៈ។ វាពិនិត្យឡើងវិញនូវគោលទស្សនៈរបស់រដ្ឋាភិបាលស្ដីពីគោលនយោបាយ និងសេវាកម្មសាធារណៈ និងការគ្រោងយន្តការសំរាប់ការផ្គត់ផ្គង់សេវាកម្មសាធារណៈ។ វាក៏ព្យាយាមប៉ាន់ប្រមាណឧបសគ្គសំខាន់ៗ ក្នុងការផ្គត់ផ្គង់សេវាកម្មសាធារណៈនៅថ្នាក់មូលដ្ឋានក្នុងប្រទេសកម្ពុជា។ ជាទូទៅ ម៉ូឌុលទីនេះ មានបំណងធ្វើឱ្យប្រជាជនទូទៅយល់ដឹងអំពីការគិតគូររបស់រដ្ឋាភិបាលចំពោះការលើកកំពស់ ការផ្គត់ផ្គង់សេវាកម្មសាធារណៈ។

### ម៉ូឌុល ៣ : អ្វីទៅជាកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន?

ម៉ូឌុលនេះ ប្រាប់សិក្ខាកាមអំពីថាតើមានអ្វីខ្លះនៅក្នុងកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។ វាពិនិត្យឡើងវិញនូវការផ្តល់ស្របច្បាប់សំរាប់គណនេយ្យភាពសង្គម និងនីតិវិធីនៃការផ្តត់ផ្គង់សេវាកម្មជាមូលដ្ឋាននានា នៅថ្នាក់ឃុំក្នុងប្រទេសកម្ពុជា និងអធិប្បាយពីគោលគំនិតទាំងនេះ ដោយលំអិតថាហេតុអ្វីជាកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន មានសារៈសំខាន់ និងចង្អុលបង្ហាញនូវអ្វីដែលកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានចង់ធ្វើ។ សិក្ខាកាមនឹងអាចពន្យល់ ហើយបកស្រាយបានចំពោះរូបភាពទាំងមូលនៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។

### ម៉ូឌុល ៤ : ការអនុវត្តន៍កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន

ម៉ូឌុលនេះ ណែនាំអំពីដំណើរការទាំងមូល និងសកម្មភាពរបស់ កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន និងពន្យល់លំអិតអំពីរបៀបនៃសកម្មភាពនីមួយៗដែលនឹងដំណើរការជាក់ស្តែង។ ការអធិប្បាយរបស់សកម្មភាពទាំង ២១ នឹងបង្ហើកសិក្ខាកាមឱ្យយល់ដឹងអំពីរបៀបប្រតិបត្តិកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន និងកត់ចំណាំសកម្មភាពនីមួយៗដើម្បីជៀសវាងកំហុស ឆ្គងក្នុងពេលអនុវត្តន៍។ វាក៏ផ្តល់នូវព័តិមានសំខាន់មួយចំនួនដែលពាក់ព័ន្ធដើម្បីជួយគាំទ្រដល់ ការប្រតិបត្តិសកម្មភាពរបស់កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ក៏ដូចជាគូសបញ្ជាក់លើខ្លឹមសារសំខាន់ៗនៃការណែនាំដល់ប្រជាពលរដ្ឋសាមញ្ញ កំណែនបណ្តាញផ្សព្វផ្សាយព័តិមាន និង ការតស៊ូមតិបន្តនៅតាមមូលដ្ឋានផងដែរ។

### ម៉ូឌុល ៥ : ការបកស្រាយនៅក្នុងគណនេយ្យភាពសង្គម និងការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធិភាព

ម៉ូឌុលចុងក្រោយនេះ នាំមកនូវទស្សនៈគណនេយ្យភាពសង្គម និងឧបករណ៍ដើម្បីលើកកំពស់គណនេយ្យភាព និងការផ្តត់ផ្គង់សេវាកម្មសង្គម។ ម៉ូឌុលនេះ ព្យាយាមបង្ហាញបទពិសោធន៍អន្តរជាតិ ហើយជាពិសេស បង្ហាញករណីសិក្សាដែលអាចយល់បានស្តីពី កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានក្នុងទីក្រុងបឹងហ្គាឡូ នៃប្រទេសឥណ្ឌា ដើម្បីសិក្សាអំពីបទពិសោធន៍រៀនសូត្រ។ ជាចុងក្រោយ ម៉ូឌុលនេះវិភាគអំពីបរិបទច្បាប់នៃគណនេយ្យភាពសង្គមក្នុងប្រទេសកម្ពុជា។

## តើសៀវភៅនេះ ប្រើប្រាស់យ៉ាងដូចម្តេច?

សៀវភៅក្បួននេះ ពណ៌នាអំពីចំណេះដឹងគ្រឹះ និងជំនាញអនុវត្តជាក់ស្តែងសំរាប់ប្រមូលនូវរាល់មតិត្រឡប់ពី

ប្រជាពលរដ្ឋ លើការផ្តត់ផ្គង់សេវាកម្មនៅមូលដ្ឋាន និងការតស៊ូមតិដើម្បីការផ្លាស់ប្តូរ។ ការដកស្រង់សំណួមពរផ្សេងៗ បទពិសោធន៍រៀនសូត្រ និងព័ត៌មានគន្លឹះដែលគេបានអភិវឌ្ឍឡើង ដើម្បីប្រតិបត្តិកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានឱ្យមានប្រសិទ្ធិភាព ត្រូវបានគេធ្វើជាប់ទាក់ទងគ្នាទៅវិញទៅមក។ ម៉ូឌុលទាំងនេះ ភាគច្រើននិយាយអំពីតម្រូវការសំខាន់ៗមួយចំនួន សំរាប់ប្រតិបត្តិការកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ដូចជាលើកកំពស់ការយល់ដឹងផ្សេងៗ ការណែនាំការងារ ការបណ្តុះបណ្តាល ការប្រជុំ សិក្ខាសាលា ការស្រាវជ្រាវ ការពិភាក្សាជាសាធារណៈ និងកំណែនបណ្តាញផ្សព្វផ្សាយព័ត៌មាន ក៏ដូចជាការងារតស៊ូមតិថ្នាក់មូលដ្ឋាននានា ដូចជាការជជែកវែកញែក ការវិភាគ និងការបង្ហាញពីលទ្ធផលរកឃើញ ការធ្វើផែនការ និងការចាត់ចែងការងារ។

សកម្មភាពទាំងឡាយអាចទាមទារឱ្យមានភាពបត់បែន ប៉ុន្តែយ៉ាងហោចណាស់ ការពិនិត្យឡើងវិញនូវជំហានជាយុទ្ធសាស្ត្រចំបងៗ និងការណែនាំនូវចំណុចគន្លឹះមួយចំនួន អាចផ្តល់នូវមូលដ្ឋានល្អ ដល់ការអនុវត្តន៍នូវកម្មវិធីនេះ។ វិធីមួយចំនួនដែលស្នើឡើងសំរាប់ អនុវត្តសកម្មភាពកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន គឺមានលក្ខណៈអនុវត្តន៍ជាក់ស្តែងច្រើន ដើម្បីកាន់តែងាយក្នុងការអនុវត្ត សំរាប់អ្នកទាំងឡាយណា ដែលមិនធ្លាប់ទទួលការបណ្តុះបណ្តាលណាមួយ ប្រហាក់ប្រហែលនេះ ឬធ្លាប់ចូលរួមអនុវត្តសកម្មភាពគំរោងដូចនេះពីមុនមក។ ដូចនេះ ការបណ្តុះបណ្តាល គួរតែផ្អែកទៅលើសកម្មភាពទាំងស្រុង។ នៅក្នុងវគ្គបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាលទាំងអស់គួរតែ សំរេចចិត្តអំពីរបៀបសម្របសម្រួល និងកែសម្រួល ខ្លឹមសាររបស់ម៉ូឌុលនីមួយៗ ឱ្យសមស្របទៅតាមកំរិតយល់ដឹងរបស់សិក្ខាកាម។ គ្រូបណ្តុះបណ្តាលអាចជ្រើសរើសផ្នែកខ្លះពីម៉ូឌុលនីមួយៗ ដែលគេគិតថាមានសារៈសំខាន់ចំពោះការយកចិត្តទុកដាក់ជាពិសេស។

វាមិនចាំបាច់បង្រៀនសិក្ខាកាមឱ្យយល់ដឹងរាល់ព័ត៌មាន និងចំណេះដឹងទាំងអស់ដែលមាននៅក្នុងសៀវភៅក្បួននេះនៅក្នុងវគ្គសិក្សាតែមួយនោះបានទេ ក្រៅពីម៉ូឌុលទីបួន ដែលមានដំណាក់កាលអនុវត្តជាក់ស្តែងសំរាប់ធ្វើតាមក្នុងពេលប្រតិបត្តិកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន គ្រូបណ្តុះបណ្តាលអាចដកស្រង់តែផ្នែកណាដែលមានលក្ខណៈសំខាន់ និងចាំបាច់តែប៉ុណ្ណោះ។

សៀវភៅនេះមិនមែនគ្រាន់តែធ្វើឡើងសំរាប់តែការបណ្តុះបណ្តាលនោះទេ វាមានប្រយោជន៍ស្មើគ្នាដូចទៅនឹងឯកសារយោងភ្លាមៗក្នុងពេលប្រតិបត្តិផងដែរ។ ដូច្នេះ សិក្ខាកាមទាំងអស់ដែលចូលរួមក្នុងការប្រតិបត្តិកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ត្រូវបានផ្តល់ជាជំនូន្ទានឱ្យយកសៀវភៅមួយក្បាលនេះជាប់ជាមួយនឹងពួកគេជានិច្ច។

ម៉ូឌុលនីមួយៗ បង្ហាញអំពីការពិពណ៌នាគោលបំណង និងលទ្ធផលរំពឹងទុករបស់វា។ ហេតុដូចនេះហើយ វាជួយឱ្យគ្រូបណ្តុះបណ្តាលដើម្បីត្រួតពិនិត្យប្រសិទ្ធភាពនៃការបណ្តុះបណ្តាល ឆ្ពោះទៅសំរេចគោលបំណងដែលចង់បាន និងការសំរេចលទ្ធផល។ ដោយសារសៀវភៅនេះ មានផ្ទុកនូវគុណសម្បត្តិផ្នែកព័ត៌មានជាពិសេសព័ត៌មាននៃគោលនយោបាយរបស់រដ្ឋាភិបាលស្តីអំពីវិមជ្ឈការ និងការផ្តល់សេវាកម្មសាធារណៈពីប្រភពផ្សេងៗ ដូចនេះ គេបានផ្តល់ដំបូន្មានយ៉ាងមាំមួនថា គ្រូបណ្តុះបណ្តាលទាំងអស់ត្រូវតែកាន់សៀវភៅនេះនៅក្នុងអំឡុងពេលវគ្គបណ្តុះ បណ្តាល ដើម្បីធ្វើជាឯកសារយោង។

ការបណ្តុះបណ្តាលនេះ គួរត្រូវបានរៀបចំធ្វើឡើងតាមបែបចូលរួម។ ជាងនេះទៅទៀត ប្រសិនបើសិក្ខាកាមចូលរួមមកពីសមាសភាពចំរុះផ្សេងៗ រួមមានដូចជា ប្រជាពលរដ្ឋក្នុងសហគមន៍ បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាលថ្នាក់មូលដ្ឋាន នោះវានឹងអាចលេចឡើងនូវវិវាទនឹងគ្នា។ ដូចនេះត្រូវតែធ្វើឱ្យប្រាកដថា គ្រូបណ្តុះបណ្តាលត្រូវតែមានជំនាញក្នុងការពន្យល់ និងសម្របសម្រួលគ្រប់គ្រាន់ និងមានជំនួយព័ត៌មានផ្នែកចំណេះដឹងផងដែរ។ គ្រូបណ្តុះបណ្តាលគួរតែផ្តល់ផងដែរ នូវឱកាសចូលរួមស្មើភាពគ្នាដល់សិក្ខាកាមទាំងអស់ ដើម្បីឱ្យបង្ហាញពីខ្លួនរបស់គេ។

ចូរចងចាំថា អាចមានសិក្ខាកាមខ្លះដែលអានសៀវភៅនេះ មានគោលទស្សនៈមួយផ្សេងទៀត។ ប្រសិនបើមានករណីនេះមែន ពួកគេអាចបដិសេធ ជាមួយនឹងអ្វីដែលកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ឬសៀវភៅនេះ ចង់សំរេចឱ្យបាន។ គ្រូបណ្តុះបណ្តាលម៉ូឌុលនៃការគ្រោងស្របច្បាប់ និងធ្វើឱ្យពួកគេ ពិនិត្យមើលលទ្ធភាពដែលអាចធ្វើទៅបាន។

រាល់ដំណាក់កាលតូចៗ និងរាល់ការខំប្រឹងប្រែងដែលបានធ្វើ នឹងអាចមានការយល់ខុស។ សូម្បីតែនៅពេលដែលគ្រូបណ្តុះបណ្តាលសង្កេតឃើញដែនកំណត់របស់សិក្ខាកាមក្នុងការរៀនសូត្រក៏ដោយ គ្រូត្រូវតែអត់ធ្មត់ ពីព្រោះវាទាមទារពេលវេលា ដើម្បីណែនាំគំនិត និងវិធីសាស្រ្តថ្មីៗ ដូចជាកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។ សូមបើកចិត្តឱ្យទូលាយ ព្រោះនេះគឺជាគោលគំនិតផ្អែកទៅតាមដំណើរការដែលបានប្រព្រឹត្តិ ឧទាហរណ៍ទាំងឡាយដែលបានរៀបរាប់ក្នុងម៉ូឌុលទីប្រាំ បានបង្ហាញយ៉ាងច្បាស់ថា វាអាចដំណើរការបានដើម្បីណែនាំឱ្យដឹងពីផ្នែកផ្សេងៗ ដែលយន្តការនៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន មិនបានពង្រីកសមត្ថភាពការិយាល័យរបស់អ្នក ដើម្បីឱ្យសមស្របទៅតាមលក្ខខណ្ឌរបស់វា និងដោយមិនចាំបាច់ចំណាយថ្លៃខ្ពស់ និងនីតិវិធីកាន់តែលំបាកច្រើនជាងអ្វីដែលអ្នកអាចធ្វើបាន។

**នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល សូមជំរាប់ដល់សិក្ខាកាមថា សៀវភៅណែនាំនេះ នឹងមិនអាចធ្វើអ្វីទៅបានទេ ប្រសិនបើអ្នកមិនធ្វើវា !**







# ម៉ូឌុលទី ១

# ការស្វែងយល់ពីវិមជ្ឈការ និងក្រុមប្រឹក្សាឃុំ-សង្កាត់

ការស្វែងយល់ពីវិមជ្ឈការ និងក្រុមប្រឹក្សាឃុំ-សង្កាត់

## គោលបំណងរបស់ម៉ូឌុល

ដើម្បីផ្តល់ចំណេះដឹងជាមូលដ្ឋានដល់សិក្ខាកាមអំពីវិមជ្ឈការ និងក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលអាចឱ្យពួកគេមើលឃើញនូវរូបភាពទាំងមូលនៃការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

## ការរំពឹងទុករបស់ម៉ូឌុល

គេរំពឹងថា នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងមានការយល់ដឹងជាមូលដ្ឋានអំពី :

- អត្ថន័យវិមជ្ឈការ និងគោលបំណងដែលបង្កើតសំរាប់ការធ្វើវិមជ្ឈការ និងការគ្រប់គ្រងនិងរដ្ឋបាលឃុំ-សង្កាត់
- អំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់
- រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងតួនាទីនិងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធសំខាន់ៗដើម្បីការអភិវឌ្ឍឃុំ-សង្កាត់
- បញ្ហាដែលជាប់ពាក់ព័ន្ធនឹងរដ្ឋបាល និងការគ្រប់គ្រងឃុំ-សង្កាត់
- ការគ្រប់គ្រងហិរញ្ញវត្ថុ និងប្រព័ន្ធធ្វើផែនការរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់
- របៀបពីការធានាឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍន៍




1.1

## ស្ថានភាពបច្ចុប្បន្ននៃវិមជ្ឈការក្នុងប្រទេសកម្ពុជា

វិមជ្ឈការ គឺជាគោលនយោបាយថ្មីមួយសំរាប់អភិបាលកិច្ចក្នុងប្រទេសកម្ពុជា។ ការដាក់វាចូលទៅក្នុងការអនុវត្ត វាជាកិច្ចការដ៏លំបាកមួយ !

**ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រថ្នាក់ជាតិ** ២០០៦-២០១០ គូសបញ្ជាក់នូវចំណុចសំខាន់ៗជាអាទិភាពនៃការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជា និងយុទ្ធសាស្ត្រចតុកោណ ដើម្បីកាត់បន្ថយភាពក្រីក្រ និងដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍។ អភិបាលកិច្ចល្អ គឺជាចំណុចស្នូលនៃយុទ្ធសាស្ត្រចតុកោណ និង វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានពិចារណាជាចំណុចគន្លឹះ ចំពោះការកែលំអអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ និងការអភិវឌ្ឍ។ ទាំងនេះ គេរំពឹងមកវិញថា នឹងលើកកំពស់នូវសុខមាលភាពដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសប្រជាពលរដ្ឋក្រីក្រ។

**ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រថ្នាក់ជាតិថ្លែងយ៉ាងច្បាស់ថា សកម្មភាពសំខាន់ៗជាក់លាក់ ៨យ៉ាងសំរាប់ វិមជ្ឈការ និងវិសហមជ្ឈការរួមមាន :**

១- ធ្វើពង្រាងច្បាប់អង្គការ ( Organic Law) ដើម្បីដឹកនាំដំណើរការផ្ទេរអំណាច។

២- ធ្វើប្រតិភូកម្មការទទួលខុសត្រូវតាមរយៈខ្សែបណ្តោយក្រសួង ការអភិវឌ្ឍ និងមូលនិធិប្រតិបត្តិដល់ ថ្នាក់ក្រោមជាតិ ដោយយោងទៅតាមច្បាប់ និងបទបញ្ញានានា។

៣- ការកំណត់ក្របខណ្ឌការងារសំរាប់វិសហមជ្ឈការនៃគំនិតផ្តួចផ្តើមដែលមានស្រាប់របស់ក្រសួងខ្សែ បណ្តោយទាំងឡាយ រួមមានការអប់រំ សុខភាព កសិកម្ម និងការអភិវឌ្ឍជនបទ និង ការគ្រប់គ្រងដីធ្លី និងការធ្វើផែនការអភិវឌ្ឍន៍ទីក្រុង និងសំណង់។

៤- ការបង្កើតយន្តការបែងចែកសំរាប់ផ្ទេរមូលនិធិដុល និងមូលនីធិតាមវិស័យដល់ថ្នាក់ក្រោមជាតិ។

៥- ការបង្កើន និងធ្វើឱ្យប្រសើរឡើងនូវមូលនិធិដែលបានគ្រោងទុកសំរាប់តំបន់ដាច់ស្រយាល និង តំបន់ផ្សេងទៀត ដែលមានកំរិតជីវភាពក្រីក្រខ្ពស់។

៦- ការស្វែងរកវិធីផ្សេងៗដែលនៅថ្នាក់ក្រោមជាតិអាចបង្កើតប្រភពចំណូលដោយខ្លួនឯង។។

៧- ការអនុវត្តខ្ជាប់ខ្ជួននូវប្រព័ន្ធគណនេយ្យវិមជ្ឈការឃុំ-សង្កាត់។

៨- ការកសាងសមត្ថភាពផ្នែកស្ថានប័ននៅថ្នាក់ក្រោមជាតិទាំងអស់។

រាជរដ្ឋាភិបាលកម្ពុជា បានទទួលយកក្របខណ្ឌការងារជាយុទ្ធសាស្ត្រសំរាប់ការងារវិមជ្ឈការ និង វិសហមជ្ឈការ (ឆ្នាំ២០០៥) និងក្របខណ្ឌយុទ្ធសាស្ត្រដំបូងសំរាប់ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ឆ្នាំ២០០៦) ហើយបានផ្តួចផ្តើមឡើងនូវដំណើរការពង្រាងច្បាប់អង្គការវិមជ្ឈការ និងវិសហមជ្ឈការ និងបង្កើតឱ្យមានគណៈកម្មាធិការជាតិដើម្បីការងារគ្រប់គ្រងវិមជ្ឈការ និងវិសហមជ្ឈការ (ឆ្នាំ២០០៦) និងចាប់ផ្តើមរៀបចំការងារសំរាប់កម្មវិធីកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការថ្នាក់ជាតិ ។

នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៥ ទីស្តីការគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានទទួលយកទស្សនៈវិស័យមួយ ដែលជាគោលគំនិតនិងគោលការណ៍ជាមូលដ្ឋាន និងយុទ្ធសាស្ត្ររួមសំរាប់កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីផ្តល់ក្របខណ្ឌការងារមួយដឹកនាំនូវរាល់កំណែទម្រង់ទាំងអស់ ដែលទាក់ទងទៅនឹងប្រព័ន្ធ គ្រប់គ្រងថ្នាក់ខេត្ត-ក្រុង ស្រុក-ខណ្ឌ និងថ្នាក់ឃុំ-សង្កាត់។ ទស្សនៈវិស័យ ដែលរដ្ឋាភិបាលបានបង្កើត ចំពោះវិមជ្ឈការ និង វិសហមជ្ឈការថែងថា " រាជរដ្ឋាភិបាលកម្ពុជានឹងបង្កើតប្រព័ន្ធគ្រប់គ្រងនៅថ្នាក់ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងឃុំ-សង្កាត់ ដោយផ្អែកលើគោលការណ៍ " ការចូលរួមតាមបែបលទ្ធិប្រជាធិបតេយ្យ "។ ប្រព័ន្ធនេះនឹងអនុវត្តដោយមាន តម្លាភាព និងគណនេយ្យភាព ដើម្បីលើកកំពស់ការអភិវឌ្ឍនៅមូលដ្ឋាន និងការផ្តល់សេវាកម្មសាធារណៈ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ហើយដើម្បីចូលរួមការកាត់បន្ថយភាពក្រីក្រនៅ តាមតំបន់ភូមិសាស្ត្ររៀងៗខ្លួន។

កម្មវិធីជាតិរយៈពេល ៥ឆ្នាំ កំពុងតែណែនាំឱ្យអនុវត្តន៍នូវកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីសំរេចបាននូវលទ្ធផលចំបងៗបី គឺ គោលនយោបាយនិងបទបញ្ញត្តិ ការចាត់ចែងនៅតាមស្ថាប័ន និងមុខងារតាមផ្នែក។ រាជរដ្ឋាភិបាលកម្ពុជាមានបំណងផ្ទេរការទទួលខុសត្រូវថែមទៀតទៅដល់ថ្នាក់មូលដ្ឋាន។ ការផ្ទេរអំណាចនិងធនធាន ត្រូវបានគេរំពឹងថា ធ្វើឡើងនៅក្នុងវិធីមួយដែលជួយលើកទឹកចិត្ត សំរាប់ក្រុមប្រឹក្សាដើម្បីកែលំអការផ្តល់សេវាកម្ម ការគ្រប់គ្រងធនធានធម្មជាតិ និងឱកាសបំរើការងារ ដើម្បីបង្កើនគណនេយ្យភាព និងបរិយាបន្នសង្គម ហើយលើកកំពស់ជីវភាពជនក្រីក្រ យេនឌ័រ និងបរិស្ថាន។

**ភាពរីកចំរើនសំខាន់ៗមួយចំនួនស្តីអំពីវិមជ្ឈការ និងវិសហមជ្ឈការចាប់តាំងពីបានអនុវត្តកន្លងមក :**

១- ក្របខណ្ឌជាយុទ្ធសាស្ត្រសំរាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវបានអនុម័ត នៅថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០០៥ ។ បញ្ហានេះ គឺកំណត់គោលដៅរបស់វិមជ្ឈការ និងវិសហមជ្ឈការ ជា " ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យ " និងកំណត់អំពីគោលបំណងសំខាន់ៗ អាទិភាព ការដកថយ និងការចាត់ចែង ដើម្បីសំរេចគោលដៅនេះ។

២- ពង្រាងច្បាប់អង្គការ សំរាប់រដ្ឋបាលថ្នាក់ក្រោមជាតិ បានចាប់ដំណើរការ។

៣- ក្របខណ្ឌអនុវត្តពង្រាងដំបូងមួយសំរាប់អភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានចេញផ្សាយកាលពីថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៦។

៤- ការប្តេជ្ញាចិត្តរួមគ្នារវាងរាជរដ្ឋាភិបាលនិងម្ចាស់ជំនួយ ចំពោះសុខដុមភាវូបនីយកម្ម និងការរួមបញ្ចូលគ្នា ត្រូវបានអះអាងដោយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា ចំពោះបញ្ហានេះ នៅខែធ្នូ ឆ្នាំ ២០០៤។ ក្របខណ្ឌរបស់រាជរដ្ឋាភិបាលកម្ពុជាសំរាប់ សុខដុមភាវូបនីយកម្ម និងការ រួមបញ្ចូលគ្នា និង ការគ្រប់គ្រងលទ្ធផល ផែនការសកម្មភាពសំរាប់ឆ្នាំ ២០០៦-២០១០ ការទទួលយកអនុសាសន៏ សំខាន់ៗ នៃការសិក្សាដោយឯករាជ្យដោយរាជរដ្ឋាភិបាលកម្ពុជា

ស្តីពីការគាំទ្ររបស់ម្ចាស់មូលនិធិ សំរាប់វិមជ្ឈការ និងវិសហមជ្ឈការនៅនៃថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៦។

៥- ព្រះរាជក្រិត្យបានបង្កើតគណៈកម្មាធិការជាតិដើម្បីគ្រប់គ្រងវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បី ទទួលខុសត្រូវចំពោះការអនុវត្តវិមជ្ឈការ និងវិសហមជ្ឈការរហូតដល់ទីភ្នាក់ងារដែលត្រូវស្នង ត្រូវបានបង្កើតឡើងដោយច្បាប់អង្គការ។ ឥឡូវនេះ គណៈកម្មាធិការជាតិដើម្បីគ្រប់គ្រងវិមជ្ឈការ និងវិសហមជ្ឈការ គឺទទួលខុសត្រូវចំពោះការធ្វើពង្រាងច្បាប់ និងបទបញ្ញាផ្សេងៗ ការរៀបចំ កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការថ្នាក់ជាតិ ភាពត្រូវគ្នារបស់ម្ចាស់មូលនិធិ និងការសម្រប សម្រួលគំរោងច្រើនប្រភេទដែលផ្តល់ជំនួយហិរញ្ញវត្ថុដោយម្ចាស់មូលនិធិ ដោយរួមបញ្ចូលទាំង សកម្មភាពទាំងឡាយដែលស្ថិតនៅក្រោមក្រុមការងាររបស់កម្មវិធីសិលា។

៦- ការងារដែលរៀបចំបានចាប់ផ្តើមសំរាប់កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីគាំទ្រ ការអភិវឌ្ឍច្បាប់អង្គការ និងបទបញ្ញាផ្សេងៗ ហើយដើម្បីបង្កើតធនធាននៃរចនាសម្ព័ន្ធរដ្ឋបាល និងនយោបាយថ្នាក់ក្រោមជាតិ ប្រព័ន្ធ និងនិតិវិធី។




1.2

## អត្ថន័យនៃពាក្យវិមជ្ឈការ

វិមជ្ឈការមានន័យថា គឺជាសិទ្ធិពិតប្រាកដ ការទទួលខុសត្រូវ និងធនធានដែលត្រូវ បានផ្ទេរពីថ្នាក់ជាតិនៃរដ្ឋាភិបាលដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ដែលបានបោះឆ្នោត ជ្រើសរើសតាមបែបប្រជាធិបតេយ្យ ។

### ១. វិមជ្ឈការនយោបាយ

វិមជ្ឈការនយោបាយ គឺជាញឹកញាប់សំដៅដល់ការផ្ទេរអំណាច និងមុខងារពីមជ្ឈឹមទៅដល់ការងារ គ្រប់គ្រងនៅមូលដ្ឋាន។ រដ្ឋាភិបាលមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា គឺផ្អែកទៅលើការតំណាង ផ្នែកនយោបាយ។ ក្រុមប្រឹក្សាឃុំត្រូវបានគេបោះឆ្នោតជ្រើសរើសនៅតាមមូលដ្ឋាននៅនឹងកន្លែង

ដោយផ្អែកទៅតាមសមាមាត្រ គឺមានន័យថា អាចលើសពីមួយគណបក្សនយោបាយឡើងទៅ ដែលធ្វើជាតំណាងដោយប្រជាជនមូលដ្ឋានដែលរស់នៅក្នុងតំបន់ភូមិសាស្ត្រស្របច្បាប់របស់ខ្លួន។
វិមជ្ឈការ នយោបាយ គឺសំដៅដល់ការផ្ទេរអំណាច (លោក Conyers ឆ្នាំ ១៩៨៣ និង លោក Stoop ឆ្នាំ ២០០២) បានចង្អុលបង្ហាញថា ការផ្ទេរអំណាច គឺជាកំរិតខ្ពស់នៃវិមជ្ឈការ ដែលអំណាចនៃការសំរេចចិត្តផ្នែកនយោបាយ និងសេចក្តីសំរេចចិត្តប្រកបដោយអំណាចត្រូវបាន ផ្ទេរទៅដល់ការគ្រប់គ្រងទៅតាមកំរិតទាបដាច់ដោយឡែកពីគ្នា។ ដូច្នេះ ការផ្ទេរអំណាច គឺផ្អែកទៅលើការសំរេចចិត្តពាក់កណ្តាលស្វ័យឯករាជ្យនៃអំណាចស្របច្បាប់របស់រដ្ឋាភិបាលចំពោះធនធានរបស់ខ្លួន និងជំហស្របច្បាប់នៃការកាត់ក្តីរបស់ខ្លួន។ ជាងនេះទៅទៀត នៅពេលថ្មីៗនេះ UNDP បានបញ្ជាក់ថា វិមជ្ឈការនយោបាយ គឺជា " វិមជ្ឈការប្រជាធិបតេយ្យ "។ នៅឆ្នាំ ១៩៩៩ លោក Erickson យល់ថា ការផ្ទេរអំណាច គឺជាទម្រង់ពិតប្រាកដនៃវិមជ្ឈការអំណាច ដែលគេអាចប្រើប្រាស់វា តាមរយៈតំណាងដែលត្រូវបានបោះឆ្នោតជ្រើសរើស ដើម្បីដោះស្រាយបញ្ហានៅក្នុងមូលដ្ឋាន។

ការផ្ទេរអំណាច អនុវត្តតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ គឺដើម្បីផ្លាស់ប្តូរការយកចិត្តទុកដាក់ចំពោះការអភិវឌ្ឍឆ្ពោះទៅរកប្រជាជន ដោយមានគំនិតប្រតិបត្តិនៃការកែសម្រួលរចនាសម្ព័ន្ធ ការពង្រឹងអភិបាលកិច្ចថ្នាក់មូលដ្ឋាន ការកាត់បន្ថយភាពក្រីក្រនិងវិសមភាព និងការលើកកំពស់ឱ្យមានសមធមិផ្នែកយេនឌ័រនៅគ្រប់កំរិតទាំងអស់។

នៅក្នុងប្រទេសកម្ពុជា មានច្បាប់ពីរសំខាន់ ដែលគ្រប់ដណ្តប់លើនយោបាយវិមជ្ឈការ។ ទីមួយ គឺច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ និងទីពីរ គឺច្បាប់ស្តីពីរដ្ឋបាលនិងការគ្រប់គ្រងឃុំ-សង្កាត់។ ច្បាប់ទាំងពីរនេះផ្តល់ឱ្យដល់ប្រជាពលរដ្ឋ និងជនទាំងឡាយណាដែលត្រូវបានគេបោះឆ្នោតជ្រើសតាំងជាតំណាងរបស់ប្រជាពលរដ្ឋ (ក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រធានភូមិ) នូវអំណាចកាន់តែច្រើន សំរាប់ការធ្វើសេចក្តីសំរេចចិត្តជាសាធារណៈ (ដោយលោក Rondinelli ឆ្នាំ ១៩៩៩ ទំព័រទី ២)។

ការកំណត់និយមន័យវិមជ្ឈការ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍន៍អន្តរជាតិ (USAID) បញ្ជាក់ថា វាគឺជាវិមជ្ឈការនយោបាយ។ លោក ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដែលបានថ្លែងនៅឯសិក្ខាសាលាស្តីពីទស្សនាទានវិមជ្ឈការនៅឆ្នាំ ២០០០ ក៏បានបញ្ជាក់ផងដែរថា វិមជ្ឈការក្នុងប្រទេសកម្ពុជា គឺជាវិមជ្ឈការនយោបាយ ដោយលោកបានចង្អុលបង្ហាញថា មានការ

យល់ដឹងជាច្រើនទូទាំងប្រទេសកម្ពុជា ដែលប្រជាជនត្រូវតែចូលរួមក្នុងការធ្វើសេចក្តីសំរេចចិត្ត លើអ្វីដែលប៉ះពាល់ដល់កិច្ចការរបស់គេ។ មានការយល់ដឹងច្រើនបន្ថែមទៀតដែរ ដែលរដ្ឋាភិបាល និងរដ្ឋបាលត្រូវតែយកចិត្តទុកដាក់ និងទទួលខុសត្រូវបន្ថែមទៀតចំពោះប្រជាពលរដ្ឋរបស់ខ្លួន (ដោយ ព្រំ សុខា ឆ្នាំ ២000 ទំព័រ ២)។

យោងតាមលោក David Ayres (ឆ្នាំ ២00១) វិមជ្ឈការនយោបាយ គឺជាការនិយមចូលចិត្ត ដោយក្រុមមនុស្ស ដែលអះអាងថា ដំណើរការសំរេចចិត្តដោយមានការចូលរួមនឹងផ្តល់ដំណឹងកាន់តែ ប្រសើរឡើង និងការគ្រប់គ្រងនៅតាមមូលដ្ឋាននឹងឆ្លើយតបបានច្រើនចំពោះសេចក្តីត្រូវការ និង ឱកាសនានានៅតាមមូលដ្ឋាន។

## ២. វិមជ្ឈការរដ្ឋបាល

ឆ្ពោះទៅរកនយោបាយសមហេតុផល កំណែទម្រង់វិមជ្ឈការក្នុងប្រទេសកម្ពុជា នៅតែមិនទាន់បាននាំ ផ្លូវទៅរកសេចក្តីថ្លែងអំពីទស្សនៈឱ្យបានច្បាស់លាស់ ដែលធ្វើឱ្យមានភាពជាក់ស្តែងចំពោះគោលបំណង ដ៏ធំធេងរបស់ខ្លួន និងអំពីរបៀបដែលរដ្ឋាភិបាលកម្ពុជា មានបំណងឈានទៅដល់ការផ្ទេរអំណាច នៃរដ្ឋបាល និងការទទួលខុសត្រូវចំពោះការផ្តល់សេវាកម្មផ្សេងៗ និងធនធានសារពើពន្ធដែលជាប់ ពាក់ព័ន្ធនោះនៅឡើយទេ។ យ៉ាងណាក៏ដោយ ផ្អែកលើទិសដៅរបស់រដ្ឋបាល សំណួរដ៏សំខាន់ចាំបាច់ មួយ ត្រូវបានសួរថា តើអ្វីខ្លះដែលជាតួនាទីពិតប្រាកដរបស់ឃុំ-សង្កាត់នៅមូលដ្ឋានក្នុងការផ្តល់ សេវាកម្មសាធារណៈ ជាពិសេសក្នុងផ្នែកធំៗមួយចំនួន ដែលសំខាន់សំរាប់យុទ្ធសាស្ត្រកាត់បន្ថយ ភាពក្រីក្រ។

*វិមជ្ឈការរដ្ឋបាលកើតឡើងដោយមានអំណាចស្របច្បាប់ ការទទួលខុសត្រូវ ធនធានហិរញ្ញវត្ថុសំរាប់ផ្តល់សេវាកម្មសាធារណៈ និងការបែងចែកការគ្រប់គ្រង ទៅតាមលំដាប់ថ្នាក់ខុសៗគ្នា (លោក Ayres 2001)។ វិមជ្ឈការរដ្ឋបាល គឺផ្អែក ទៅលើការផ្ទេរការទទួលខុសត្រូវ សំរាប់ការធ្វើផែនការ ការចាត់ចែងហិរញ្ញវត្ថុ និងការគ្រប់គ្រងមុខងារសាធារណៈពីរដ្ឋាភិបាលកណ្តាល និងទីភ្នាក់ងាររបស់ខ្លួន ទៅឱ្យផ្នែកដែលគ្រប់គ្រងដោយទីភ្នាក់ងារនោះ ផ្នែកនៅខាងក្រោមបង្គាប់ ឬ កំរិតនៃការគ្រប់គ្រង អាជ្ញាធរសាធារណៈពាក់កណ្តាលស្វ័យឯករាជ្យ ឬ សាជីវកម្ម តំបន់ ឬ ផ្នែក ឬអាជ្ញាធរតាមមុខងារ។*

*វិមជ្ឈការរដ្ឋបាល មានន័យថា គឺជាការធ្វើប្រតិភូកម្ម ការទទួលខុសត្រូវរបស់ រដ្ឋាភិបាល ទៅឱ្យផ្នែកខាងក្រោម ដែលស្ថិតនៅក្នុងប្រព័ន្ធគ្រប់គ្រងតែមួយ ឬរួមគ្នា ឬនៅក្នុង អត្តសញ្ញាណនៃភាពស្របច្បាប់ (លោក Stoop ឆ្នាំ ២00២)។*

នៅក្នុងប្រទេសកម្ពុជា ការបង្កើតផ្នែកសាធារណៈ គឺឆ្លុះបញ្ចាំងនៅថ្នាក់ស្រុក និងថ្នាក់ខេត្ត តាមខ្សែបណ្តោយការិយាល័យ ដូចជា នាយកដ្ឋានអប់រំ និងសុខភាព។ នៅពេលបច្ចុប្បន្ននេះ ខេត្ត និងស្រុកមិនមែនជាស្ថាប័នតំណាងនៅតាមមូលដ្ឋាននៅឡើយទេ នោះមានន័យថា ពួកគេមិនទាន់ត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាជនទេ ប៉ុន្តែពួកគេត្រូវបានឱ្យបំរើការដោយក្រសួងជំនាញរបស់ពួកគេ។ ការណ៏ដែលសំខាន់ វិសហមជ្ឈការអនុញ្ញាតឱ្យមន្ត្រីរដ្ឋាភិបាលដែលនៅតាមមូលដ្ឋានធ្វើសេចក្តីសំរេចចិត្តលើការបែងចែកនិងផលិតកម្មរបស់សេវាកម្ម និងទ្រព្យធនសាធារណៈ។ ពួកគេក៏អាចបង្កើតទំនាក់ទំនងរវាងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិបានដែរ។

## ៣_វិមជ្ឈការសារពើពន្ធ

វិមជ្ឈការសារពើពន្ធ ពាក់ព័ន្ធទៅនឹងការផ្ទេរមូលនិធិ និងអំណាចនៃការតំឡើងពន្ធអាករ ចាប់តាំងពីថ្នាក់ខ្ពស់រហូតដល់ថ្នាក់ទាបដែលស្ថិតក្រោមប្រព័ន្ធនយោបាយមួយ (សៀវភៅរបស់លោក រូស៊ីន នៅឆ្នាំ ២០០៤ ទំព័រ ២២)។ សៀវភៅរបស់លោក អៃរីស (Ayres) ឆ្នាំ២០០១ បានចាត់ទុកការទទួលខុសត្រូវផ្នែកសារពើពន្ធ ថាជាសមាសភាពសំខាន់មួយក្នុងចំណោមសមាសភាពសំខាន់ៗនានាក្នុងរបបវិមជ្ឈការ។ នេះពីព្រោះតែរដ្ឋាភិបាលមូលដ្ឋាននីមួយៗ ត្រូវតែមានប្រាក់ចំណូលគ្រប់គ្រាន់ដែលត្រូវបានប្រមូល ឬផ្ទេរជូនដោយស្របច្បាប់ពីរដ្ឋាភិបាលថ្នាក់កណ្តាល ដើម្បីឱ្យរដ្ឋបាលមូលដ្ឋានធ្វើការសម្រេចចិត្តក្នុងការចំណាយ។ បច្ចុប្បន្ននេះការផ្ទេរមូលនិធិទៅតាមឃុំ-សង្កាត់ពីរដ្ឋបាលថ្នាក់កណ្តាល គឺជាប្រភពចំណូលតែមួយគត់របស់រដ្ឋាភិបាលថ្នាក់មូលដ្ឋាន។ មូលនិធិនេះមានកំណត់ហើយ មិនត្រូវបានចែកឱ្យបានគ្រប់គ្រាន់នោះទេ។ ដើម្បីផ្តល់នូវការលើកទឹកចិត្ត ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ទាំងអស់ឱ្យចេះបង្កើតប្រាក់ចំណូលនិងគ្រប់គ្រងការចាយវាយផ្សេងៗ រដ្ឋាភិបាលត្រូវបង្កើតច្បាប់ស្តីអំពី ប្រភពចំណូលដែលជាធនធានផ្ទាល់របស់ឃុំ-សង្កាត់ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ យោងតាមរបាយការណ៏បានបញ្ជាក់ថា ប្រព័ន្ធសារពើពន្ធនិងការគ្រប់គ្រងហិរញ្ញវត្ថុដែលមានស្រាប់ នៅមាន លក្ខណៈទន់ខ្សោយនៅឡើយ។ ប្រព័ន្ធសារពើពន្ធរបស់រដ្ឋាភិបាលថ្នាក់មូលដ្ឋាន ត្រូវតែធ្វើការកែទម្រង់ឡើងវិញ ដើម្បីធ្វើឱ្យវាមានលក្ខណៈស្របគ្នាទៅនឹងគោលនយោបាយកំណែទម្រង់ទូទៅ តាម រយៈប្រព័ន្ធកែលំអ ការប្រមូល និងការគ្រប់គ្រងប្រាក់ចំណូល និងតាមរយៈការបង្កើតប្រព័ន្ធនៃការ គ្រប់គ្រងថវិកា ដែលមាននិរន្តរភាពរឹងមាំ មានប្រសិទ្ធិផល និងអាចសំរេចបាន។ វាក៏សំខាន់ផងដែរ ដែលត្រូវបង្កើតឱ្យមានយន្តការ សមរម្យមួយ ដើម្បីគាំទ្រដល់គណនេយ្យភាពក្នុងការធ្វើផែនការ និងការរៀបចំថវិកានៅតាមថ្នាក់ស្រុក-ខណ្ឌ និងខេត្ត-ក្រុង។ តាមការសិក្សាស្រាវជ្រាវមួយរបស់លោក អេម អេ មេនស៊ី (M. El Mensi) នៅឆ្នាំ ២០០៣

ស្តីពីប្រភពចំណូលផ្ទាល់ខ្លួនរបស់ឃុំ-សង្កាត់ថា វាផ្តល់នូវទិដ្ឋភាពរួម ការវិភាគ និងជំរើសគោលនយោបាយដ៏ល្អ ដើម្បីអភិវឌ្ឍបន្ថែមទៅលើប្រព័ន្ធប្រាក់ចំណូលក្នុងមូលដ្ឋាន។

ក្រុមប្រឹក្សាឃុំ-សង្កាត់ដែលត្រូវបានធ្វើវិមជ្ឈការ ត្រូវតែមានសមត្ថភាពដើម្បីអនុវត្តអំណាច និងការទទួលខុសត្រូវនានា ដែលត្រូវបានផ្តល់ជូនដល់ពួកគេ។ នៅក្នុងបរិបទអភិវឌ្ឍន៍ជនបទនៅក្នុងប្រទេសកម្ពុជា សមត្ថភាពមានន័យថា ជាលទ្ធភាពអាចធ្វើការងារ និងអាចធ្វើឱ្យប្រសើរដល់ការផ្តល់សេវាកម្ម។ ការខ្វះសមត្ថភាព ដោយយោងតាមរយៈលោក ប៉ាកគ័រ (Parker) អាចនឹងឆ្លុះបញ្ចាំងនៅក្នុងចំណុចណាមួយដូចខាងក្រោម :

- ការផ្តល់មូលនិធិមិនគ្រប់គ្រាន់ ដើម្បីបំពេញនូវស្តង់ដាអប្បបរមានៃសេវាកម្មនិងការផ្តល់សេវាកម្ម
- មិនមានជំនាញពេញលេញក្នុងកំណែនប្រភពហិរញ្ញវត្ថុដែលមានស្រាប់
- មិនអាចរកបានទំនិញ និងសេវាកម្មដែលមានតំលៃសមស្រប
- សេវាកម្មនានាដែលផ្តល់មិនត្រូវនឹងតម្រូវការរបស់ប្រជាពលរដ្ឋ (Parker, 1997, n.p.)

វិមជ្ឈការសារពើពន្ធអាចមានច្រើនសណ្ឋាន ដែលត្រូវបានគេសង្ខេបដូចខាងក្រោម :

- ស្វ័យតភាពលើការគ្រប់គ្រងហិរញ្ញវត្ថុ ឬការយកកំរៃពីអ្នកប្រើប្រាស់
- ការបង្កើនប្រាក់ចំណូលមូលដ្ឋាន តាមរយៈពន្ធអាករ និងការយកពន្ធដោយប្រយោល
- ការផ្ទេរផ្សេងៗពីរដ្ឋាភិបាលដ៏ទៃទៀត
- ការផ្តល់សិទ្ធិឱ្យមានឥណទាននៅតាមមូលដ្ឋាន (Rondinelli,1999, pp, 3)

ដោយយោងតាមយុទ្ធសាស្ត្រត្រីកោណរបស់រាជរដ្ឋាភិបាល សំរាប់កំណើនសេដ្ឋកិច្ច ភាពមានការងារធ្វើ សមភាព និងប្រសិទ្ធផល នៅឆ្នាំ២០០៣-២០០៨ (១) រដ្ឋាភិបាលព្យាយាមអស់ពីសមត្ថភាពរបស់ខ្លួន ដើម្បីពង្រឹងនូវការប្រមូលប្រាក់ចំណូល តាមរយៈការអនុវត្តយ៉ាងតឹងតែងទៅលើច្បាប់ ស្តីពីសារពើពន្ធនានា ដោយអនុវត្តវិធានការណ៍ប្រឆាំងនឹងការគេចពន្ធ និងការប្រឆាំងអំពើពុករលួយផ្សេងៗ តាមរយៈការធ្វើការលុបបំបាត់ការលើកលែងពន្ធមិនស្របច្បាប់ និងធ្វើការណែនាំអំពីការគ្រប់គ្រងទ្រព្យសម្បត្តរបស់រដ្ឋ ការគ្រប់គ្រងប្រកបដោយនិរន្តរភាព លើការយកផលប្រយោជន៍ពីធនធានធម្មជាតិ គោលការណ៍ ច្បាប់ជាផ្លូវការនឹងគ្របដណ្តប់រាល់ការអនុវត្តលើការប្រើប្រាស់ថវិកា។

ចំណុចនេះត្រូវមានការលើកលែងនៅក្នុងផ្នែកនៃសេវាកម្មសុខភាព ទំព័រ (១៩) ដែលបែបបទថ្លៃឈ្នួលលើអ្នកទទួលសេវាកម្មជាផ្លូវការ ត្រូវបានកំណត់ដោយមានការចូលរួមពីសហគមន៍។ ថ្មីៗនេះ ឃុំ-សង្កាត់ បានចាប់ផ្ដើមធ្វើការវាយតំលៃ និងប្រមូលប្រាក់កំរៃនិងពន្ធនានា ដែលទាក់ទងជាមួយនឹងសេវាកម្ម (ជាពិសេសផ្នែករដ្ឋបាល) ដែលក្រុមប្រឹក្សាឃុំធ្វើ។ ក៏ប៉ុន្តែការធ្វើបែបនេះ ត្រូវបានគេចាត់ទុកយ៉ាងធ្ងន់ធ្ងរថា ជាសកម្មភាពមិនស្របច្បាប់ ពីព្រោះពុំទាន់មានក្របខ័ណ្ឌច្បាប់ច្បាស់លាស់ដើម្បីចេញបទបញ្ញាលើសកម្មភាពនោះនៅឡើយទេ។ ជាមួយគ្នានោះដែរ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបានស្នើសុំឱ្យប្រមូលធនធានក្នុងមូលដ្ឋាននានា ក្នុងការបំពេញលើមូលនិធិបដិភាគ ដើម្បីឱ្យមានការផ្ទេរមូលនិធិឃុំ-សង្កាត់ (CSF)។ ការអនុវត្តបែបនេះ ក៏តម្រូវឱ្យមានការចេញជាបទបញ្ញាបន្ថែមទៀតផងដែរ។

ការប្រឈមមុខសំខាន់ៗមួយចំនួន ដែលត្រូវបានកំណត់ទំនាក់ទំនងជាមួយនឹងវិមជ្ឈការ និងវិសហមជ្ឈការសារពើពន្ធ រួមមាន :

- រចនាសម្ព័ន្ធទាំងមូលនៃអភិបាលកិច្ចថ្នាក់ក្រោមជាតិនៅមានឃុំដែលមិនទទួលបានថវិកាហិរញ្ញវត្ថុ ឃុំដែលទទួលបានថវិកាតិចតួច និងមិនស្មើភាពគ្នា
- ការបែងចែកការចំណាយមិនច្បាស់លាស់នៅគ្រប់កំរិត (តាមខ្សែទទឹងនិងខ្សែបណ្ដោយ) និងការខ្វះខាតបទដ្ឋានជាក់លាក់ ព្រមទាំងគោលការណ៍ណែនាំសំរាប់ការផ្ដល់សេវាកម្ម
- គ្មានទំនាក់ទំនងច្បាស់លាស់រវាងចំណូលនិងចំណាយ ដោយពាក់ព័ន្ធនឹងបញ្ហាពីរ ទាំងទំហំនិងប្រភេទនៃការរៀបចំសមាសភាពនៃប្រាក់ចំណូល
- ប្រព័ន្ធនៃការផ្ទេរសារពើពន្ធពីអន្តររដ្ឋាភិបាល ចាំបាច់ត្រូវកែទម្រង់ ដើម្បីឱ្យមានភាពច្បាស់លាស់ទៅលើមុខងារ និងរចនាសម្ព័ន្ធថ្មីៗរបស់រដ្ឋបាលគ្រប់ជាន់ថ្នាក់
- ការបែងចែកថវិកានៅថ្នាក់ខេត្តក្រុង នាពេលបច្ចុប្បនេះ វាមិនសូវមានជំរើសលើទិដ្ឋភាពជារួមទៅលើធនធានទាំងអស់ដែលត្រូវប្រើនៅតាមថ្នាក់ខេត្តក្រុង ហើយវាមានហានីភ័យលើការគណនាទ្វេរដង និងការខ្វះខាតនូវការសម្របសម្រួល និងការគិតតំលៃដែលគួរឱ្យទុកចិត្តពីសាធារណៈជន
- ការខ្វះខាតលើក្របខ័ណ្ឌច្បាប់ និងបទបញ្ញាសំរាប់កំណែនប្រភពចំណូល (ការយកកំលៃការប្រើប្រាស់ពន្ធបដិភាគសំរាប់មូលនិធិឃុំ-សង្កាត់ ហើយនិងមានលើសពីនេះទៅទៀត)
- ការរៀបចំមិនត្រឹមត្រូវទៅលើការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់ខេត្ត-ក្រុង ជាមួយអ្នកពាក់ពន្ធ័ជាច្រើន និងនីតិវិធីដ៏សាមញ្ញ ប៉ុន្តែការសម្របសម្រួល ការត្រួតពិនិត្យ និងគណនេយ្យភាពតាមខ្ទង់ថវិកានៅមានកំរិត
- ការខ្វះខាតការលើកទឹកចិត្តឱ្យកែលំអការអនុវត្តក្នុងការប្រមូលប្រាក់ចំណូលទូទៅនិងនីតិវិធីនៃការគ្រប់គ្រងហិរញ្ញវត្ថុ
- ការសម្របសម្រួលមិនគ្រប់គ្រាន់លើបញ្ហាកំណែទម្រង់សំខាន់ៗក្នុងបរិបទសារពើពន្ធវិមជ្ឈការ និងវិសហមជ្ឈការ។ ក្រុមប្រឹក្សាផ្ដល់មូលនិធិ **C/S** នៅតែមិនទាន់ប្រតិបត្តិបាននៅឡើយ ហើយវាមានអាណត្តិកំណត់។

ការបង្កើតប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការសារពើពន្ធ គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការកែច្នៃ និងការធ្វើឱ្យប្រសើរឡើងទៅលើរដ្ឋាភិបាលថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្ន និងអនាគត។ ចំណុចនេះ គឺពិតជាករណីពិសេសក្នុងការបែងចែកទំហំការងារ និងកិច្ចការចំណាយផ្សេងៗ ដែលមុខងារទាំងនោះត្រូវបានគេធ្វើវិមជ្ឈការតាមរយៈ (ការផ្ទេរអំណាចពីរដ្ឋាភិបាលកណ្តាល) ឬការធ្វើវិសហមជ្ឈការ (ដែលត្រូវបានធ្វើប្រតិភូកម្មស្ថិតក្នុងមុខងារជាភ្នាក់ងាររបស់រដ្ឋាភិបាលកណ្តាល) នៅខែមករា ឆ្នាំ ២០០៥ ដោយទីប្រឹក្សាផ្នែកវិមជ្ឈការ និងវិសហមជ្ឈការ។

គួរកត់សំគាល់ផងដែរថា ដោយផ្អែកលើបទពិសោធន៍លើគំរោងសាកល្បង និងសកម្មភាពដែលមានការផ្តួចផ្តើម យុទ្ធសាស្ត្រវិមជ្ឈការសារពើពន្ធមួយកំពុងត្រូវបានគេធ្វើផែនការដោយស្ថិតក្រោមកម្មវិធីឧបត្ថមផ្នែកវិមជ្ឈការសារពើពន្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ហើយវាត្រូវបានគេរំពឹងថា នឹងចប់សព្វគ្រប់នៅឆ្នាំ២០០៥-២០០៦។

## ៤. លក្ខណៈពិសេសនៃវិមជ្ឈការក្នុងប្រទេសកម្ពុជា

- ប្រជាពលរដ្ឋទាំងអស់ត្រូវបានផ្តល់សិទ្ធិឱ្យបោះឆ្នោតជ្រើសរើសមាជិកនៃក្រុមប្រឹក្សាឃុំ-សង្កាត់
- ប្រជាពលរដ្ឋទាំងអស់ ត្រូវបានផ្តល់សិទ្ធិ និងការទទួលខុសត្រូវឱ្យដើរតួនាទីសកម្មមួយក្នុងកិច្ចការឃុំ និងដំណើរការអភិវឌ្ឍន៍នៅតាមមូលដ្ឋាន។
- សរុបទាំងអស់មានឃុំ-សង្កាត់ចំនួន ១៦២១ នៅទូទាំងប្រទេសកម្ពុជា ជាឃុំដែលក្រុមប្រឹក្សាត្រូវគេបានជ្រើសរើសតាមរយៈការបោះឆ្នោត។ ក្រុមប្រឹក្សាទាំងអស់ជាតំណាងឱ្យប្រជាពលរដ្ឋ ដែលរស់នៅក្នុងឃុំ-សង្កាត់របស់ពួកគេ។
- ក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់នឹងមានអាណត្តិចំនួន៥ឆ្នាំ។ បន្ទាប់មកនឹងមានការបោះឆ្នោតសារជាថ្មី។
- ក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់ត្រូវបានផ្តល់ឱ្យនូវការទទួលខុសត្រូវ និងកាតព្វកិច្ចជាច្រើន។ ការទទួលខុសត្រូវទាំងអស់នោះខុសគ្នាទាំងស្រុងពីឃុំ-សង្កាត់ពីអតីត។ ភារកិច្ចសំខាន់ជាងគេ និងមុនគេបង្អស់របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ គឺត្រូវគាំទ្រការអភិវឌ្ឍឃុំ-សង្កាត់ និងសុខមាលភាពរបស់ប្រជាពលរដ្ឋ។
- នៅក្នុងការអនុវត្តកាតព្វកិច្ចទាំងអស់របស់ពួកគេ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់គេ។
- ក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់ត្រូវធានាថាសហគមន៍មូលដ្ឋានបានចូលរួមពេញលេញក្នុងដំណើរការនៃសេចក្តីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។ ការធ្វើរបៀបនេះ គឺសំខាន់ខ្លាំងណាស់

ពីព្រោះក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់ នឹងត្រូវធ្វើការសម្រេចចិត្តនានាដែលមានផលប៉ះពាល់ទៅដល់ការរស់នៅរបស់ប្រជាពលរដ្ឋ។ ឧទាហរណ៍ ក្រុមប្រឹក្សាឃុំនឹងធ្វើការសម្រេចចិត្តទៅលើវិធីណាមួយទាក់ទងទៅនឹងការចំណាយធនធាននានាដែលក្រុមប្រឹក្សាឃុំ-សង្កាត់អាចសំរេចបាន។

- ដើម្បីឱ្យមានលទ្ធភាពអាចអនុវត្តកាតព្វកិច្ចរបស់ពួកគេបាន ក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់នឹងមានប្រភពធនធានហិរញ្ញវត្ថុ និងបុគ្គលិកផ្ទាល់សំរាប់គាំទ្រពួកគេ និងមានស្មៀនម្នាក់ដែលត្រូវបានតែងតាំងដោយក្រសួងមហាផ្ទៃ។

For Your Review 1.3

## គោលបំណងរបស់វិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់

គោលបំណងនៃវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ គឺ ៖

- ដើម្បីផ្ដល់ឱកាសដល់ប្រជាពលរដ្ឋសាមញ្ញឱ្យរួមចូលចំណែកដ៏ទូលំទូលាយ ក្នុងការសម្រេចចិត្តនានាដែលមានឥទ្ធិពលដល់ការរស់នៅរបស់ពួកគេ និងដើម្បីសម្រេចលើអនាគតរបស់ពួកគេ
- ដើម្បីលើកកំពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពជីវភាព
- ដើម្បីធានាឱ្យមានការអភិវឌ្ឍដែលមាននិរន្តរភាព ដោយរួមទាំងការផ្ដល់សេវាកម្មជាមូលដ្ឋានមួយចំនួន។

### គោលបំណងចំបងៗនៃវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ៖

**▶▶ វិមជ្ឈការ គឺជាការផ្ដល់ឱកាសដល់ប្រជាពលរដ្ឋឱ្យចូលរួមចំណែកទូលំទូលាយក្នុងការសម្រេចចិត្តនានា ដែលមានឥទ្ធិពលដល់ការរស់នៅរបស់ពួកគេ ៖**

ស្ថិតក្រោមប្រព័ន្ធនៃអភិបាលកិច្ចថ្នាក់មូលដ្ឋាននៅកំរិតឃុំ-សង្កាត់ ប្រជាពលរដ្ឋទាំងអស់មានសិទ្ធិ និងការទទួលខុសត្រូវ ដើម្បីដើរតួនាទីសកម្មមួយក្នុងកិច្ចការរបស់ឃុំ និងរាល់ដំណើរការអភិវឌ្ឍន៍នៅមូលដ្ឋាន។ ប្រជាជនគ្រប់រូប ទាំងបុរស ស្ត្រី ក្មេង ចាស់ និងអ្នកក្រីក្រ ត្រូវការដឹងលឺ និងជាប់ពាក់ព័ន្ធ។ ប្រជាពលរដ្ឋទាំងអស់ត្រូវបានគេផ្ដល់សិទ្ធិ ដើម្បីបង្ហាញពីតម្រូវការ និងចំណាប់អារម្មណ៍របស់ខ្លួន និងចូលរួមក្នុងការបង្កើតនីតិវិធីនិងយន្តការនានា។

មានវិធី និងមធ្យោបាយផ្សេងៗ ដើម្បីឱ្យប្រជាពលរដ្ឋជាប់ពាក់ព័ន្ធ។ ប្រជាពលរដ្ឋអាចបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលពួកគេយល់ថាអាចធ្វើជាតំណាងនៃចំណាប់អារម្មណ៍របស់គេបានប្រសើរបំផុត។ ពួកគេអាចធ្វើការទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ចំពោះបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍឃុំ-សង្កាត់។ ប្រជាពលរដ្ឋ អាចបង្ហាញបញ្ហា និងចំណាប់អារម្មណ៍ទាំងឡាយ នៅពេលមានការអង្គប្រជុំ និងសិក្ខាសាលាតាមភូមិ។ ពួកគេអាចត្រួតពិនិត្យការអនុវត្តគម្រោងក្នុងមូលដ្ឋានរបស់គេ។ ប្រជាពលរដ្ឋមានសិទ្ធិក្នុងការទាមទារ និងទទួលបាននូវព័ត៌មានពីក្រុមប្រឹក្សាឃុំ-សង្កាត់។

ការជំរុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋ គឺជាកាតព្វកិច្ចសំខាន់មួយរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។ ការចូលរួមពីប្រជាពលរដ្ឋជួយឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ស្វែងយល់ពីតម្រូវការ និងចំណាប់អារម្មណ៍របស់ប្រជាពលរដ្ឋ ហើយដើម្បីរៀបចំកម្មវិធីអភិវឌ្ឍន៍ឱ្យឆ្លើយតបទៅនឹងតម្រូវការទាំងនោះ។ ប្រសិនបើប្រជាពលរដ្ឋមានជាប់ពាក់ព័ន្ធ ពួកគេនឹងមានភាពជាម្ចាស់និងការទទួលខុសត្រូវចំពោះការអភិវឌ្ឍមូលដ្ឋានរបស់គេ។

### ▶▶ វិមជ្ឈការ ត្រូវបានគេមើលឃើញថា ជាវិធីដ៏មានប្រសិទ្ធិភាពមួយ ដែលអាចជំរុញឱ្យមានអភិបាលកិច្ចល្អ:

មានគោលការណ៍សំខាន់ៗចំនួន ៤ ដែលត្រូវរៀបចំ ដើម្បីឱ្យមានអភិបាលកិច្ចល្អ :

១. ក្រុមប្រឹក្សាឃុំ-សង្កាត់ និងសមាជិករបស់គេទាំងអស់**ត្រូវតែអនុវត្តឱ្យស្របទៅនឹងច្បាប់**។ ច្បាប់ពន្យល់យ៉ាងច្បាស់នូវអំណាច តួនាទី និងមុខងារនានារបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។

២. ក្រុមប្រឹក្សាឃុំ-សង្កាត់នឹងត្រូវបានគេបោះឆ្នោតជ្រើសរើសឱ្យមានលក្ខណៈប្រជាធិបតេយ្យ និងមានអាណត្តិដោយប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។ ហេតុដូច្នេះហើយ **ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពទាំងស្រុងចំពោះប្រជាពលរដ្ឋរបស់ខ្លួន**។ មានន័យថាក្រុមប្រឹក្សាឃុំ-សង្កាត់ ចាំបាច់ត្រូវធ្វើផែនការក្នុងរបៀបណាមួយ ដែលត្រូវទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ-សង្កាត់នឹងត្រូវផ្តល់ព័ត៌មានអំពីរបៀប ដែលធនធាននានាត្រូវបានចំណាយ ហើយថាតើការចំណាយនេះ ពិតជាបានផលប្រយោជន៍ដល់ប្រជាជនឬក៏អត់។

៣. **ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវមានតម្លាភាព** នូវរាល់អ្វីៗដែលក្រុមប្រឹក្សាឃុំ-សង្កាត់ធ្វើ មានន័យថាក្រុមប្រឹក្សាឃុំ-សង្កាត់មិនត្រូវលាក់កំបាំងជាមួយសាធារណៈជនឡើយ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវជូនដំណឹងដល់សាធារណៈជនអំពីបញ្ហា ឬប្រធានបទដែលក្រុមប្រឹក្សាឃុំ-សង្កាត់ បានពិភាក្សា

ឬការសម្រេចចិត្តនានាដែលបានធ្វើឡើង។ ឧទាហរណ៍ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវផ្តល់ដំណឹង ដល់សាធារណៈជន ហើយសួរផងដែរនូវយោបល់ ផែនការអភិវឌ្ឍន៍ និងការប្រើប្រាស់ថវិកា។ កំណត់ហេតុទាំងអស់ដែលទទួលបានពីអង្គប្រជុំ សេចក្តីសំរេចនានាដែលបានអនុម័តដោយក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវតែយកទៅបិទនៅលើក្តារខៀនប្រកាសព័ត៌មាន។

៤. **ការចូលរួម**ដូចដែលបានពន្យល់ខាងលើ វាជាគោលការណ៍គ្រឹះមួយផ្សេងទៀតនៃអភិបាលកិច្ចល្អ។

**▶▶ ការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ គឺជាការគាំទ្រការអភិវឌ្ឍប្រកបដោយនិរន្តភាព ដែលក្នុងនោះរួមមានការផ្តល់សេវាកម្មផ្សេងៗ។ តើការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់នោះ អាចធ្វើទៅបានដោយរបៀបណា?**

ក្រុមប្រឹក្សាឃុំ-សង្កាត់ ជាអ្នកស្ថិតនៅជិតប្រជាពលរដ្ឋដែលរស់នៅតាមមូលដ្ឋាន ដូច្នេះហើយពួកគេស្ថិតក្នុងទីតាំងល្អមួយ ដើម្បីទទួលដឹងនូវអ្វីដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាទាំងនេះអាចបង្កើតកម្មវិធីជាច្រើនទៀត ដើម្បីធ្វើឱ្យស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់ប្រសើរឡើង។ ធ្វើដូច្នេះ គឺដើម្បីឱ្យធនធានទាំងអស់អាចចំណាយមានប្រសិទ្ធិភាពច្រើន។ ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន អាចសង្កេតមើលពីរបៀបដែលធនធានទាំងអស់ត្រូវបានគេចំណាយ ហើយសង្កេតមើលថាតើធនធានទាំងអស់នោះ ពិតជាត្រូវបានចំណាយដើម្បីជាប្រយោជន៍របស់ប្រជាពលរដ្ឋមែនដែរឬ។ ប្រសិនបើ ប្រជាពលរដ្ឋបានចូលរួមនិងធ្វើផែនការគម្រោងនានានៅក្នុងមូលដ្ឋាន នោះពួកគេនឹងមានការទទួលខុសត្រូវកាន់តែច្រើន។




1.4

## អំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់

ក្រុមប្រឹក្សាឃុំ-សង្កាត់ គឺជាតំណាងរបស់ប្រជាពលរដ្ឋដែលត្រូវបានបោះឆ្នោតជ្រើសរើស តាមបែបប្រជាធិបតេយ្យ ដោយប្រជាពលរដ្ឋនៅតាមឃុំនិមួយៗដែលខ្លួនតាំងនៅ។ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់លើកទី២ ត្រូវបានធ្វើឡើងនៅថ្ងៃទី ១ ខែ មេសា ឆ្នាំ២០០៧។ ក្រុមប្រឹក្សាឃុំ-សង្កាត់ឈរឈ្មោះចំនួន ១១,៣៥៣ នាក់ ហើយត្រូវបានបោះឆ្នោតជ្រើសរើសឱ្យធ្វើជាក្រុមប្រឹក្សាឃុំ-សង្កាត់ចំនួន ១៦២១ នាក់។ ក្រុមប្រឹក្សាទាំងអស់នោះ ត្រូវបានផ្តល់អំណាច តួនាទី និងមុខងារមួយចំនួន។

**ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ មាត្រា ៤១ ចែងថា :** "រដ្ឋបាលក្រុមប្រឹក្សាឃុំ-សង្កាត់ មានតួនាទីប្រតិបត្តិ និងគាំទ្រអភិបាលកិច្ចល្អតាមរយៈការប្រើប្រាស់ធនធានទាំងអស់ដែលមាន ដើម្បីលើកឡើងពីតម្រូវការជាមូលដ្ឋាននៅក្នុងឃុំ-សង្កាត់របស់ខ្លួន ក្នុងគោលបំណងបំរើផល ប្រយោជន៍ប្រជាពលរដ្ឋ និងទទួលស្គាល់ផលប្រយោជន៍ជាតិ ដោយអនុលោមទៅតាមគោល នយោបាយទូទៅរបស់រដ្ឋ។

## ▶▶ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបានផ្តល់អំណាច ដូចជា :

ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបានផ្តល់អំណាច ដើម្បីគ្រប់គ្រង និងចាត់ចែងឃុំ-សង្កាត់។ ពួកគេត្រូវតែ បំរើផលប្រយោជន៍ទូទៅរបស់ឃុំ-សង្កាត់។

ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបានផ្តល់**អំណាចបញ្ញត្តិ**។ ពួកគេអាចបង្កើត និងចេញដីកា (សេចក្តីសំរេច) ដោយយោងទៅលើក្របខ័ណ្ឌច្បាប់ ស្តីពីតួនាទី និងការទទួលខុសត្រូវដែលត្រូវបានផ្តល់ជូនក្រុមប្រឹក្សា ឃុំ-សង្កាត់។ សេចក្តីសម្រេចទាំងនោះមានប្រសិទ្ធិបានតែនៅក្នុងរង្វង់ដែនដីនៃឃុំ-សង្កាត់និមួយៗរបស់ ខ្លួនគេតែប៉ុណ្ណោះ។ សេចក្តីសម្រេចទាំងនោះត្រូវមិនឱ្យផ្ទុយពីរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ និង សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិឡើយ។ បើពុំដូច្នោះទេ សេចក្តីសំរេចទាំងនោះនឹងត្រូវចាត់ទុក ជាមោឃៈ។

ក្រុមប្រឹក្សឃុំ-សង្កាត់ត្រូវបានផ្តល់**អំណាចប្រតិបត្តិ**។ ពួកគេត្រូវបានផ្តល់សិទ្ធិអំណាច ដើម្បីអនុវត្ត សេចក្តីសម្រេចផ្សេងៗរបស់ខ្លួនដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃតួនាទី និងការទទួលខុសត្រូវដែលត្រូវបាន ផ្តល់ជូន។

## ▶▶ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបានផ្តល់តួនាទី និងមុខងារ :

តួនាទី និងការទទួលខុសត្រូវដែលសំខាន់ជាងគេបំផុតរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ គឺត្រូវលើកកំពស់ យ៉ាងសកម្មលើការអភិវឌ្ឍឃុំ-សង្កាត់ និងសុខមាលភាពរបស់ប្រជាពលរដ្ឋរបស់គេ។ ក្រុមប្រឹក្សាឃុំ- សង្កាត់ត្រូវតែប្រើប្រាស់ឱ្យបានសមរម្យនូវធនធាន ដែលក្រុមប្រឹក្សាឃុំ-សង្កាត់អាចធ្វើបាន ដើម្បីបំរើ សេចក្តីត្រូវការរបស់ឃុំ និងប្រជាពលរដ្ឋរបស់គេ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់មានកាតព្វកិច្ច បំរើកិច្ចការនានាក្នុងមូលដ្ឋាន។ កិច្ចការទាំងនោះ រួមមាន :

១. គ្រប់គ្រងសេវាកម្មសាធារណៈសំខាន់ៗ និងធ្វើឱ្យប្រាកដថា សេវាកម្មទាំងនោះដំណើរការទៅបានល្អ ឧទាហរណ៍ ការប្រមូលសំរាមនិងកាកសំណល់។

២. រក្សាការពារបរិស្ថាន និងធនធានធម្មជាតិ មានន័យថា គាំទ្រប្រជាពលរដ្ឋដើម្បីថែរក្សាទន្លេ និងបរិស្ថានភូមិរបស់ពួកគេ ឬទីប្រជុំជនឱ្យមានសុវត្ថិភាព និងមិនមានការបំផ្លាញ។

៣. លើកកំពស់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច មានន័យថា ក្រុមប្រឹក្សាឃុំ-សង្កាត់អាចសម្របសម្រួលកិច្ចសហប្រតិបត្តិការណ៍ល្អជាមួយសង្គមស៊ីវិលផ្សេងៗ គេអាចលើកទឹកចិត្តអាជីវករ ដើម្បីធ្វើអាជីវកម្ម និងជំនួញនៅមូលដ្ឋានរបស់ខ្លួន។

៤. កែលំអស្ថានភាពជីវភាពរស់នៅរបស់ប្រជាជន មានន័យថា ក្រុមប្រឹក្សាឃុំ-សង្កាត់ចាំបាច់ត្រូវធ្វើផែនការដើម្បីអនុវត្តនូវអ្វីដែលប្រជាជនយល់ថាជាតម្រូវការអាទិភាពរបស់គេ ជាអាទិ៍ដូចជាទឹកផឹកសុវត្ថិភាព សេវាកម្មអប់រំនិងសុខភាព។ល។

៥. លើកកំពស់ភាពអត់ធ្មត់ និងការស្វែងយល់ដ៏ល្អក្នុងចំណោមប្រជាពលរដ្ឋ នេះមានន័យថា ក្រុមប្រឹក្សាឃុំ-សង្កាត់ គួរជួយក្នុងការដោះស្រាយជំលោះក្នុងចំណោមប្រជាពលរដ្ឋ។

៦. រក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម។ ការងារនេះគេអាចធ្វើទៅបាននៅក្នុងលក្ខណៈអហឹង្សា។ ក្រុមប្រឹក្សាឃុំ-សង្កាត់ មិនអាចបង្កើតកងកម្លាំងយោធា ឬនគរបាលបានទេ។

លើសពីនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ មានតួនាទី ដែលគេអនុវត្តតាងមានជំនួសឱ្យរដ្ឋាភិបាលថ្នាក់ជាតិ។ តួនាទីទាំងនេះ គេហៅថា " **មុងងារជាភ្នាក់ងារ** " ដោយរួមមានទាំង ការចុះបញ្ជីរប្រជាពលរដ្ឋនៅក្នុងឃុំ-សង្កាត់។ ក្នុងករណីក្រុមប្រឹក្សាឃុំ-សង្កាត់ធ្វើអ្វីមួយតាងនាមជំនួសឱ្យរដ្ឋ ពួកគេគួរតែត្រូវបានគាំទ្រដោយរដ្ឋ។ ឧទាហរណ៍ ពួកគេត្រូវបានបណ្តុះបណ្តាល ផ្តល់សម្ភារៈ ឬហិរញ្ញវត្ថុដើម្បីអនុវត្តការងារ។

## ▶▶ ដែនកំណត់របស់អំណាច :

ក្រុមប្រឹក្សាឃុំ-សង្កាត់អាចដើរតួនាទីតែនៅក្នុងក្របខណ្ឌនៃអំណាច តួនាទី និងមុខងារ ដែលគេបានផ្តល់ទៅឱ្យពួកគេ។ នេះមានន័យថា ពួកគេមិនអាចដើរតួនាទីខុសពីគោលការណ៍ និងបទបញ្ជានេះដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ដទៃទៀត ឬអនុក្រិត្យ នេះបានទេ។ សំរាប់បញ្ហាខ្លះដែលជាការចាប់អារម្មណ៍ ក្រុមប្រឹក្សាឃុំ-សង្កាត់មិនមានអំណាចដើរតួរនាទីនៅថ្នាក់ជាតិបានទេ។ បញ្ហាទាំងនោះ វាចិតនៅក្រៅការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។ សមាជិកក្រុមប្រឹក្សាឃុំម្នាក់មិនមានអំណាចនៅក្នុងវិស័យដូចតទៅ : រុក្ខវប្បកម្ម សេវាកម្មទូរគមនាគមន៍និងប្រៃសណីយ៍ ការការពារជាតិ សន្តិសុខជាតិ កិច្ចការរូបិយវត្ថុ និងគោលនយោបាយសារពើពន្ធ។

# 1.5

## រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់

ដូចមានចែងនៅក្នុងច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ក្រុមប្រឹក្សាឃុំ-សង្កាត់និមួយៗ គួរមានរចនាសម្ព័ន្ធច្បាស់លាស់ :




- ផ្អែកទៅតាមទំហំនៃតំបន់ និងចំនួនប្រជាពលរដ្ឋរស់នៅ ក្រុមប្រឹក្សាមានប្រាំនាក់ ប្រាំពីរនាក់ ប្រាំបួននាក់ ឬដប់មួយនាក់។ ចំនួនពិនិត្យប្រាកដរបស់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់សំរាប់ឃុំ-សង្កាត់និមួយៗ ត្រូវបានកំណត់ដោយអនុក្រិត្យ។
- ឃុំ-សង្កាត់និមួយៗ មាន**មេឃុំម្នាក់**។ មេឃុំត្រូវបំពេញភារកិច្ចបន្ថែមដែលបង្ហាញនៅខាងក្រោម។
- ក្រុមប្រឹក្សាឃុំ-សង្កាត់និមួយៗ មាន**ប្រធាន**ម្នាក់ ដែលគេហៅថា **ប្រធានក្រុមប្រឹក្សា**។ មេឃុំ ឬចៅសង្កាត់ដើរតួនាទីជាប្រធានក្រុមប្រឹក្សា។
- មេឃុំមានជំទប់ពីរនាក់ គឺ**ជំទប់ទីមួយ** និង**ជំទប់ទីពីរ**។
- ក្រុមប្រឹក្សាឃុំ-សង្កាត់ ជ្រើសរើសមេភូមិម្នាក់នៅក្នុងភូមិនិមួយៗនៅក្នុងព្រំដែនឃុំរបស់ខ្លួន។ ស្ត្រីឬបុរសទាំងឡាយដែលក្លាយជាមេភូមិ។ មេភូមិគឺជាអ្នកទំនាក់ទំនងផ្លូវការរវាងភូមិនិងក្រុមប្រឹក្សាឃុំ-សង្កាត់។

- មេឃុំ ឬចៅសង្កាត់ ក៏អាចចាត់តាំង**គណៈកម្មាធិការផ្តល់ប្រឹក្សា**បានដែរ។ គណៈកម្មាធិការមួយ គឺជាក្រុមមួយដែលមានមនុស្សយ៉ាងហោចណាស់បីនាក់ ដែលផ្តល់ប្រឹក្សា និងជំនួយការទៅដល់ក្រុមប្រឹក្សាឃុំ-សង្កាត់លើបញ្ហា ឬប្រធានបទជាក់លាក់។ សមាជិករបស់គណៈកម្មាធិការអាចជាសមាជិកក្រុមប្រឹក្សា ប៉ុន្តែក៏អាចជាអ្នកផ្សេងទៀត ដែលគេអនុញ្ញាតិដើម្បីបោះឆ្នោតដើម្បីចាត់តាំងជាសមាជិក។ សមាជិកអាចជាបុរស ឬស្ត្រី។ នៅពេលដែលបុគ្គលក្រុមប្រឹក្សាឃុំ-សង្កាត់ ដើរតួរជាសមាជិកគណៈកម្មាធិការ មេឃុំ ឬចៅសង្កាត់ត្រូវធ្វើឱ្យប្រាកដថា សមាសភាពឆ្លុះបញ្ចាំងសមាសភាពនយោបាយនៃក្រុមប្រឹក្សាឃុំ-សង្កាត់។
- ឃុំ-សង្កាត់និមួយៗ មានស្មៀនម្នាក់ ដែលត្រូវបានចាត់តាំង និងធ្វើការថិតនៅក្រោមក្របខណ្ឌរដ្ឋបាលរបស់ក្រសួងមហាផ្ទៃ។ ស្មៀនឃុំ-សង្កាត់អាចឆ្លើយតប និងទទួលខុសត្រូវផ្ទាល់ចំពោះក្រុមប្រឹក្សាឃុំ-សង្កាត់។ ក្នុងពេលដំណើរការមុខងាររបស់ខ្លួន ស្មៀនឃុំ-សង្កាត់ ត្រូវតែមានភាពអព្យាក្រិត្យ និងមិនលំអៀងដាច់ខាត ហើយតួនាទីស្មើភាពចំពោះប្រជាពលរដ្ឋគ្រប់រូបដែលក្នុងឃុំ-សង្កាត់ ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្រុមនយោបាយនៃក្រុមប្រឹក្សាឃុំ-សង្កាត់ និងគណៈកម្មាធិការ។ ទាំងនេះក៏មានន័យថា ស្មៀនត្រូវតែចាត់ទុករាល់ក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់ស្មើៗគ្នា ដោយមិនអើពើពីគណៈបក្សនយោបាយដែលគេជាសមាជិកនោះទេ។
- ក្រុមប្រឹក្សាមួយ អាចជួល**បុគ្គលិកផ្សេងទៀត** ដែលមិននៅក្នុងក្របខ័ណ្ឌរដ្ឋ។ បញ្ហានេះ គឺធ្វើឡើងដើម្បីជួយកិច្ចការដល់ក្រុមប្រឹក្សា ដោយយោងទៅតាមតម្រូវការចាំបាច់ជាក់លាក់ និងការសំរេចចិត្តរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់នោះ។ ការបំរើការងាររបស់គេ អាចបន្តដោយអនុលោមទៅតាមការសំរេចចិត្តរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់សំរាប់អាណត្តិបន្ទាប់។
- ស្ត្រី និងបុរសអាចទទួលយកតំណែងទាំងនេះដែលបានរៀបរាប់ដូចខាងលើ។




**1.6**

## តួនាទី និងការទទួលខុសត្រូវរបស់បុគ្គលសំខាន់ៗនៅក្នុងការអភិវឌ្ឍឃុំ

**សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់**

- ត្រូវប្រាកដថា ក្រុមប្រឹក្សាឃុំ-សង្កាត់ដំណើរការដោយមានអំណាច តួនាទី និងមុខងារ
- ត្រូវចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់
- ត្រូវទំនាក់ទំនងជាមួយអ្នកបោះឆ្នោត

**មេឃុំ ឬចៅសង្កាត់**

- ធ្វើឱ្យប្រាកដថា ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបានយកទៅអនុវត្ត
- រាយការណ៍ប្រចាំខែពីការងារដែលបានអនុវត្តទៅដល់ក្រុមប្រឹក្សាឃុំ-សង្កាត់
- ផ្តល់ប្រឹក្សា និងជួយដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងការធ្វើផែនការ ថវិការ និងហ្វឹកហាត់ការងារនិងផ្តល់អំណាចដល់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ។
- បំពេញការងារដទៃទៀត សំណើដោយក្រុមប្រឹក្សាឃុំ-សង្កាត់ ។

**ប្រធានក្រុមប្រឹក្សា**

- ធ្វើជាអធិបតេយ្យនៅក្នុងការប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់
- ធ្វើឱ្យប្រាកដថា ក្រុមប្រឹក្សាឃុំ-សង្កាត់ជួបជុំគ្នាយ៉ាងហោចណាស់មួយខែម្តង ។
- ធ្វើឱ្យប្រាកដថា ការប្រជុំដំណើរការអនុលោមទៅតាម វិន័យ និងបទបញ្ជាផ្ទៃក្នុង ។

**ជំទប់ឃុំទីមួយ**

- ដើរតួនាទីជាមេឃុំ ឬចៅសង្កាត់ ក្នុងករណីអវត្តមានរបស់មេឃុំ ឬចៅសង្កាត់
- ជួយដល់មេឃុំ ឬចៅសង្កាត់ ក្នុងបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងការងារហិរញ្ញវត្ថុ និងសេដ្ឋកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។
- បំពេញការងារដទៃទៀតទៅតាមការចាត់តាំងរបស់មេឃុំ ឬចៅសង្កាត់ ។

**ជំទប់ឃុំទីពីរ**

- ដើរតួនាទីជាមេឃុំ ឬចៅសង្កាត់ ក្នុងករណីអវត្តមានមេឃុំ ឬចៅសង្កាត់ និងជំទប់ទីមួយ ។
- ជួយដល់មេឃុំ ឬចៅសង្កាត់ ក្នុងការងាររដ្ឋបាល ការងារសង្គម សេវាកម្មសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ ។
- បំពេញការងារដទៃទៀតទៅតាមការចាត់តាំងរបស់មេឃុំ ឬចៅសង្កាត់ ។

**គណៈកម្មាធិការក្រុមប្រឹក្សា**

- ផ្តល់ប្រឹក្សា និងជួយដល់ការងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ នៅក្នុងវិស័យនៃប្រធានបទមួយជាក់លាក់ ដូចជា ការធ្វើផែនការ និងការធ្វើផែនការថវិកា ។
- រាយការណ៍ប្រចាំខែពីការរីកចំរើន ។

- ផ្តល់អនុសាសន៍សកម្មភាព ដែលត្រូវធ្វើដែលជាប់ទាក់ទងទៅនឹងបញ្ហាលើប្រធានបទរបស់ខ្លួនរៀងៗខ្លួន ។

**មេភូមិ**

- ដាក់សំណើ ឬធ្វើជាតំណាងរបស់អ្នកភូមិ ជូនចំពោះក្រុមប្រឹក្សាឃុំ-សង្កាត់ ។
- ដំណើរការការងារដែលបានប្រគល់ជូនដោយក្រុមប្រឹក្សាឃុំ-សង្កាត់ ។
- ធ្វើឱ្យប្រាកដថា មានការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅក្នុងភូមិ ។
- ធ្វើឱ្យប្រាកដថា មានសណ្តាប់ធ្នាប់សាធារណៈ ។

**ស្មៀនឃុំ-សង្កាត់**

ស្មៀនឃុំ-សង្កាត់ គឺជាសមាជិកបុគ្គលិកម្នាក់នៅក្នុងក្របខ័ណ្ឌរដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ប៉ុន្តែក្នុងការបំពេញការងាររបស់ខ្លួន ត្រូវថិតនៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

- ជួយដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងជាតំណាងនៅក្នុងការហ្វឹកហាត់អំណាច តួនាទី និងមុខងារដោយផ្អែកទៅតាមច្បាប់ ។
- ធ្វើការងាររដ្ឋបាល ។
- ធ្វើឱ្យប្រាកដថា ការសំរេចចិត្ត និងការអនុវត្តរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ស្របទៅតាមច្បាប់ ។
- ជួយដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការរៀបចំនិងអនុវត្តរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងការប្រជុំរបស់គណៈកម្មាធិការ ។
- ចូលរួមរាល់ការប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ឬគណៈកម្មាធិការ យ៉ាងហោចណាស់ត្រូវមានការអនុញ្ញាតិជាមុនពីក្រុមប្រឹក្សាឃុំ-សង្កាត់ ឬនៅពេលមេឃុំ ឬចៅសង្កាត់អវត្តមាន ។
- ផ្តល់យោបល់ដល់មេឃុំ ឬចៅសង្កាត់ចំពោះការចាំបាច់ និងនិតិវិធីចំពោះការបោះឆ្នោតជ្រើសរើសមេភូមិ ។
- ជួយក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីបង្កើតក្តារព័ត៌មានមួយ ឬពីរ ដែលសាធារណៈជនអាចមកមើលបាន យ៉ាងហោចណាស់ក្នុងពេលម៉ោងធ្វើការងារ ។
- ដាក់បង្ហាញរាល់កំណត់ត្រាទាំងឡាយ ដែលក្រុមប្រឹក្សឃុំ-សង្កាត់តម្រូវ ឬចង់ឱ្យដាក់បង្ហាញ ដូចជា ការសំរេចចិត្តរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។
- ជំរាបជូនដល់អភិបាលក្រុង ឬខេត្តភ្លាមៗក្នុងករណីក្រុមប្រឹក្សាឃុំ-សង្កាត់សំរេចចិត្តធ្វើសកម្មភាពពិន័យប្រឆាំងនឹងក្រុមប្រឹក្សាឃុំ-សង្កាត់ ឬបញ្ឈប់

នរណាម្នាក់ ។

- ❑ ជំរាបជូនដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ភ្លាមៗ អំពីឈ្មោះ និងកាលបរិច្ឆេទបោះឆ្នោតសំរាប់ក្រុមប្រឹក្សាថ្មីណាម្នាក់ ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានជ្រើសរើសជំនួសក្រុមប្រឹក្សា ។

**សាធារណៈជនទូទៅ**

- ❑ ជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់
- ❑ ចូលរួមក្នុងកិច្ចការភូមិ និងឃុំ-សង្កាត់ តាមរយៈនិតិវិធីដែលបានបង្កើតឡើង ដូចជាដំណើរការនៃការធ្វើផែនការអភិវឌ្ឍន៍ ។
- ❑ ទាមទារព័ត៌មាន ភាពទទួលខុសត្រូវ និងគណនេយ្យភាពពីក្រុមប្រឹក្សាឃុំ-សង្កាត់ ។
- ❑ បង់ពន្ធ ពន្ធគយ និងថ្លៃឈ្នួល ដែលបានចែងនៅក្នុងច្បាប់ ។
- ❑ ចូលរួមនៅក្នុងការត្រួតពិនិត្យការអនុវត្តគំរោងអភិវឌ្ឍន៍ ។

**អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងក្រុមជួយខ្លួនឯង**

- ❑ ធ្វើកំណែនសហគមន៍មូលដ្ឋាន ។
- ❑ លើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមរបស់សហគមន៍មូលដ្ឋាន ។
- ❑ តស៊ូមតិដើម្បីការចាប់អារម្មណ៏របស់ប្រជាជនដែលគេតំណាងឱ្យ ។
- ❑ ទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ចំពោះបញ្ហាសំខាន់ៗ ដែលទាក់ទងទៅនឹងការអភិវឌ្ឍភូមិ និងឃុំ-សង្កាត់ ។
- ❑ បង្កើតការយល់ដឹងដល់សាធារណៈជន ស្តីអំពីវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ។

**ផ្នែកឯកជន សហគ្រាសក្នុងស្រុក ។ល ។**

- ❑ ទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ចំពោះបញ្ហាដែលទាក់ទងទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ឃុំ-សង្កាត់ ។
- ❑ លើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចរបស់ឃុំ-សង្កាត់ ។
- ❑ ផ្តល់ឱកាសបំរើការងារចំពោះប្រជាពលរដ្ឋ ។

**1.7**

## បណ្តាញគាំទ្រឃុំ-សង្កាត់

រដ្ឋបាលនិងការគ្រប់គ្រងឃុំ-សង្កាត់ គឺជាការងារប្រឈមមុខមួយ។ ទោះជាយ៉ាងនេះក្តី មានស្ថាប័ន និងអង្គការជាច្រើន គាំទ្រដល់ក្រុមប្រឹក្សាឃុំសង្កាត់ ដែលធ្វើឱ្យវិមជ្ឈការទទួលបានជោគជ័យ។

### ថ្នាក់ជាតិ

- **ក្រុមប្រឹក្សាជាតិដើម្បីការងារគ្រប់គ្រងវិមជ្ឈការនិងវិសហមជ្ឈការ** (**NCDD**) ត្រូវបានបង្កើតឡើង។ សមាសភាព អំណាច និងមុខងាររបស់ក្រុមប្រឹក្សានេះត្រូវបានកំណត់ដោយព្រះរាជក្រិត្យ។ ក្រុមប្រឹក្សាជាតិដើម្បីការងារគ្រប់គ្រងវិមជ្ឈការនិងវិសហមជ្ឈការ ទទួលខុសត្រូវដើម្បីតម្រង់ទិសលើគោលនយោបាយ និងការត្រួតត្រាលើការកែទម្រង់វិជម្ឈការនិងវិសហមជ្ឈការ ដែលរួមមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន និងរដ្ឋមន្ត្រីផ្សេងទៀតនៃគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងផែនការ និងកិច្ចការនារី ព្រមទាំងរដ្ឋលេខានៃរដ្ឋលេខាធិការការងារសាធារណៈ និងរដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ។ បេសសកម្មរបស់ ក្រុមប្រឹក្សាជាតិដើម្បីការងារគ្រប់គ្រងវិមជ្ឈការនិងវិសហមជ្ឈការ (មាត្រាទី ៣) ជាសង្ខេបរួមមាន :

- ការសន្មត់មុខងាររបស់គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់ និងគណៈកម្មាធិការអន្តរក្រសួង ដើម្បីពង្រាងច្បាប់អង្គការ។
- ការរៀបចំនិងការអនុវត្តយុទ្ធសាស្ត្រសំរាប់អន្តរភាព សមាហរណកម្ម និងការដកចេញពីកម្មវិធីសិលានៅចុងឆ្នាំ ២០០៦។
- ការបង្កើត និងការអនុវត្តកម្មវិធីថ្នាក់ជាតិជំហានតំបូងសំរាប់ការអភិវឌ្ឍលទ្ធិប្រជាធិប្បតេយ្យនៅថ្នាក់ក្រោមជាតិ។
- ការបង្កើតនិងការអនុវត្តក្របខ័ណ្ឌជំហានដំបូង ផ្នែកពេលវេលាគ្រោង និងសកម្មភាពបណ្តោះអាសន្ននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រហូតដល់ច្បាប់អង្គការ ត្រូវបានប្រកាសឱ្យប្រើ។

- ការគ្រោងនិងបង្កើតជាអនុសាសន៍សំរាប់ការបង្កើតមូលនិធិ ដើម្បីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការធ្វើកំណែទនិងការលៃលកជំនួយការរបស់អ្នកផ្តល់ជំនួយ ។
- ការរៀបចំកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយទៅលើការគាំទ្រកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដើម្បីលើកតំកើងការចុះសម្រុងគ្នា និងភាពស្របគ្នាតាមលំដាប់លំដោយនៃការគាំទ្ររបស់អ្នកផ្តល់ជំនួយ ។
- ការធ្វើឱ្យកាន់តែជាក់លាក់នៃការសម្របសម្រួល ក្នុងចំណោមក្រុមប្រឹក្សាជាតិដើម្បីការងារគ្រប់គ្រងវិមជ្ឈការ និងវិសហមជ្ឈការ និងក្រសួង-ស្ថាប័នមជ្ឈិមនៅក្នុងការផ្ទេរភារៈកិច្ចមុខងារ អំណាច និងធនធាន ឱ្យទៅដល់អង្គភាពថ្នាក់ក្រោមជាតិ ។
- ការចាត់ចែងវេទិកាសមស្រប សំរាប់រាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ដើម្បីសម្របសម្រួលការងារសហការណ៍ និងការធ្វើកំណែទធនធានក្នុងការគាំទ្រទៅដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

- យោងតាមអាណត្តិរបស់នាយកដ្ឋានពីរ គឺនាយកដ្ឋានរដ្ឋបាលទូទៅ និងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ត្រូវបានដាក់បញ្ចូលគ្នា ដើម្បីបង្កើតជា**អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន** ។ នាយកដ្ឋាននេះត្រូវបានតំឡើងឱ្យទៅជារដ្ឋលេខាធិការនៃក្រុមប្រឹក្សាជាតិដើម្បីគ្រប់គ្រងវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីដំណើរការជាមួយនឹងសមត្ថកិច្ចពេញលេញ ។

- **នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន(DoLA)** គឺជាចំណុលបង្គោលសំរាប់បញ្ហាទាំងអស់ ដែលពាក់ពន្ធ័ទៅនឹងវិមជ្ឈការ និងការងារគ្រប់គ្រងនិងរដ្ឋបាលឃុំ-សង្កាត់ នៅក្នុង ក្រសួងមហាផ្ទៃ ។ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ទទួលខុសត្រូវក្នុងការត្រួតពិនិត្យ វាយតំលៃនិងរាយការណ៍ទៅលើសមត្ថភាពនិងធនធានរបស់ក្រុមប្រឹក្សាឃុំ និងមន្ត្រីដែលបានចាត់តាំង ដូចជា ស្មៀនជាដើម ។ នាយកដ្ឋាន រដ្ឋបាលមូលដ្ឋាន ត្រូវតែធ្វើឱ្យប្រាកដប្រជាថា ការវាស់វែងសមស្របសំរាប់វគ្គបណ្តុះបណ្តាល និងការកសាងសមត្ថភាព ដោយរាប់បញ្ចូលទាំងការអប់រំសាធារណៈដែលត្រូវបានគេអនុវត្ត ។

- **ក្រសួងថ្នាក់ជាតិផ្សេងៗ** ជួយក្នុងការបង្កើតគោលនយោបាយសំរាប់វិមជ្ឈការ និងការងារគ្រប់គ្រងនិងរដ្ឋបាលឃុំ-សង្កាត់ ។

- មានការប្តេជ្ញាចិត្តផ្នែកលើមូលដ្ឋានទូលំទូលាយ ក្នុងចំណោម**អង្គការ**ផ្តល់ជំនួយ **អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ** ដែលទាក់ទងទៅនឹងការគាំទ្រដំណើរការវិមជ្ឈការ និងការងារគ្រប់គ្រងនិងរដ្ឋបាលឃុំ-សង្កាត់។ អ្នកទាំងអស់នោះ ជួយនៅក្នុងមធ្យោបាយជាច្រើន ដូចជាវគ្គបណ្តុះបណ្តាល និងការកសាងសមត្ថភាព។

## ថ្នាក់ខេត្តនិងថ្នាក់ស្រុក

- **មន្ទីររដ្ឋបាលនិងបច្ចេកទេសខេត្ត :** ក្រសួងមហាផ្ទៃបានផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវទៅឱ្យអភិបាលខេត្ត ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាឃុំ និងដើម្បីគ្រប់គ្រងផ្ទាល់លើស្នាដៃការងាររបស់ពួកគេ។ បុគ្គលក្រុមប្រឹក្សាឃុំត្រូវតែប្រាកដប្រជាថា មន្ទីរបច្ចេកទេសផ្តល់ការគាំទ្រ និងការណែនាំដល់ក្រុមប្រឹក្សាឃុំ។
- ក្រសួងមហាផ្ទៃ នឹងបង្កើត**ការិយាល័យរដ្ឋបាលមូលដ្ឋានថ្នាក់ខេត្ត និងថ្នាក់ស្រុក** ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាឃុំ។
- **កម្មវិធីអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលជាច្រើន** មានសាខារបស់ខ្លួននៅថ្នាក់ខេត្ត និងនៅថ្នាក់ស្រុក។ សាខាទាំងនោះ ត្រូវបានគេរំពឹងទុកថា នឹងផ្តល់ការគាំទ្រតាមរយៈវគ្គបណ្តុះបណ្តាល និងការអប់រំសាធារណៈចំពោះបញ្ហាទាំងឡាយណាដែលពាក់ពន្ធ័នឹងក្រុមប្រឹក្សាឃុំ។

## ថ្នាក់ឃុំ-សង្កាត់

- **ស្មៀនឃុំ-សង្កាត់** ត្រូវបានចាត់តាំងដោយក្រសួងមហាផ្ទៃ ដើម្បីជួយកិច្ចការរបស់ឃុំ-សង្កាត់ និងធ្វើឱ្យប្រាកដប្រជាពីនិរន្តរភាពនៃកិច្ចការរដ្ឋបាល។
- អង្គការមូលដ្ឋាន (**កម្មវិធីអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ក្រុមជួយខ្លួនឯង**) អាចគាំទ្រដល់ក្រុមប្រឹក្សាឃុំ នៅក្នុងកំណែទនៃសហគមន៍មូលដ្ឋាន។

For Your Review 1.8

# ភារកិច្ចសំខាន់ៗរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់

## ដំណើរការប្រជុំ

ការប្រជុំផ្តល់ឱកាស :

- ❑ ដើម្បីទទួលយកគំនិតម្នាក់ៗស្តីពីប្រធានបទមួយ
- ❑ ដើម្បីទទួលការគាំទ្រសំរាប់គំនិតមួយ
- ❑ ដើម្បីសង្ខេបលើសាច់រឿង ដែលនឹងកើតមានឡើង ឬបានកើតឡើង
- ❑ ដើម្បីពិភាក្សា និងផ្លុះបញ្ចាំងទៅលើបញ្ហាសំខាន់ៗ
- ❑ ដើម្បីទទួលយកការផ្តល់ប្រឹក្សាពីប្រជាជន ដែលមានចំណេះដឹង
- ❑ ដើម្បីធ្វើសេចក្តីសំរេចចិត្ត

ការប្រជុំមួយដែលរៀបចំបានល្អ អាចឈានទៅរកការសំរេចចិត្តដែលគិតបានល្អិតល្អន់ និងការប្រាស្រ័យទាក់ទងល្អក្នុងចំណោមបុគ្គលក្រុមប្រឹក្សា បុគ្គលិកនិងអ្នកដទៃផ្សេងទៀតដែលត្រូវបានអញ្ជើញឱ្យចូលរួម។ ការប្រជុំមួយ ដែលមានការចូលរួមយ៉ាងសកម្ម និងឱ្យតំលៃទៅលើការចូលរួមចំណែកនៃវត្តមានរបស់បុគ្គលម្នាក់ៗ លើកទឹកចិត្តភាពត្រឹមត្រូវមួយនៃភាពជាម្ចាស់សំរាប់ផលសំរេចនៃការប្រជុំ។

### តើប្រភេទនៃការប្រជុំអ្វីខ្លះ ដែលក្រុមប្រឹក្សាឃុំមាន?

វិន័យនិងបទបញ្ជាផ្ទៃក្នុងចែងថា ក្រុមប្រឹក្សាឃុំអាចមានការប្រជុំពីរប្រភេទ : **ការប្រជុំទៀងទាត់** ដែលត្រូវប្រព្រឹត្តិទៅយ៉ាងហោចណាស់ម្តងក្នុងមួយខែ និង**ការប្រជុំពិសេស** ដែលធ្វើឡើងដើម្បីពិភាក្សាគ្នាពីបញ្ហាពិសេសដែលទាមទារការយកចិត្តទុកដាក់ជាពិសេស ឬបន្ទាន់ដោយក្រុមប្រឹក្សាឃុំ។

**ចូរចងចាំថា!** រាល់ការលំអិតដែលសំខាន់សំរាប់ការរៀបចំនិងការប្រជុំរបស់ក្រុមប្រឹក្សាឃុំ ត្រូវតែរៀបរាប់នៅក្នុង " បទវិន័យនិងបទបញ្ជាផ្ទៃក្នុងសំរាប់ការប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និង គណៈកម្មាធិការរបស់ខ្លួន "។

- ស្មៀនឃុំ-សង្កាត់ និងមន្ត្រីក្រុមប្រឹក្សាឃុំផ្សេងទៀត ត្រូវតែមានសិទ្ធិចូលរួមនៅក្នុងការប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។ ដើម្បីពិភាក្សាពីបញ្ហាជាក់លាក់ទាំងឡាយ គេអាចតម្រូវឱ្យមានការអញ្ជើញចូលរួមរបស់ប្រជាជនដែលមានចំណេះដឹង ជំនាញនិងបទពិសោធន៍ ពិសេសដូចជាចំណេះដឹងខាងបច្ចេកទេស សំរាប់គ្រោងនូវគំរោងមួយដែលក្រុមប្រឹក្សាទទួលធ្វើការងារនោះ។ ស្មៀននិងប្រជាពលរដ្ឋធម្មតា ដែលមិនមែនជាសមាជិករបស់ក្រុមប្រឹក្សា មិនត្រូវអនុញ្ញាតិឱ្យចូលរួមនៅក្នុងដំណើរការសំរេចចិត្ត និងបោះឆ្នោតនោះទេ។
- ការងារផ្សេងទៀតក្នុងអំឡុងពេលប្រជុំ។ មានទម្រង់ការស្រាប់ និងហេតុបច្ច័យដែលមានក្រុមប្រឹក្សាឃុំ ត្រូវតែលើកឡើងនៅក្នុងការប្រជុំរបស់គេ :

1. ត្រូវអះអាងពីភាពស្របច្បាប់នៃការប្រជុំរបស់ក្រុមប្រឹក្សាឃុំ
2. ត្រូវពិភាក្សានិងដាក់ចូលទៅក្នុងរបៀបវារៈនៃការប្រជុំ
3. ត្រូវពិនិត្យឡើងវិញនិងយល់ព្រមលើកំណត់ហេតុនៃការប្រជុំពីលើកមុន ការចុះហត្ថលេខាទៅលើកំណត់ហេតុដោយក្រុមប្រឹក្សាដែលធ្វើជាអធិបតីនៃអង្គប្រជុំ
4. ត្រូវបង្កើតឯកសារនិងឆ្លើយឆ្លងគ្នាដែលបានដាក់សំណើសំរាប់ការពិចារណា និងការសំរេចចិត្ត
5. បញ្ហាផ្សេងៗ

## ការធ្វើសេចក្តីសំរេចចិត្ត

គ្រប់ក្រុមប្រឹក្សាឃុំ ត្រូវបានអនុញ្ញាតិដើម្បីឱ្យបោះឆ្នោតនៅក្នុងរាល់ការប្រជុំរបស់ក្រុមប្រឹក្សាឃុំ។ ការបោះឆ្នោតធ្វើឡើងដោយការលើកដៃ។ ចំនួនសំលេងឆ្នោតដែលពេញចិត្ត និងចំនួនដែលប្រឆាំងទៅនឹងសំណើដែលលើកឡើង ត្រូវតែប្រកាសភ្លាមៗ និងកត់ត្រានៅក្នុងកំណត់ហេតុនៃការប្រជុំ។

## ការរក្សាទុក និងការរៀបចំទៅតាមលំដាប់នៃកំណត់ត្រា

## តើអ្វីទៅជាការរក្សាទុកកំណត់ត្រា?

ការរក្សាទុកកំណត់ត្រា មានន័យថា ការរក្សាទុកប្រកបដោយសុវត្ថិភាពនូវរាល់ព័ត៌មានសំរាប់ការប្រើប្រាស់នាពេលខាងមុខ និងជាឯកសារយោង ស្ទើរតែគ្រប់ឯកសារទាំងអស់នឹងសុទ្ធជាការសរសេរ ប៉ុន្តែវាក៏អាចជាកាសែតខ្សែអាត់ ឬកាសែតវីដេអូ ។ ការរក្សាទុកកំណត់ត្រា គឺជាផ្នែកដ៏សំខាន់របស់រដ្ឋបាលក្រុមប្រឹក្សាឃុំ

## តើមានផលប្រយោជន៍អ្វីខ្លះនៃរក្សាទុកកំណត់ត្រា?

- ងាយស្រួលក្នុងការយកព័ត៌មាន ដើម្បីណែនាំក្រុមប្រឹក្សាឃុំនៅក្នុងការពិភាក្សាសំរេច
- ការបន្ត គឺថាព័ត៌មាននៅតែមាន ទោះបីជាមន្ត្រីខ្លះបានចេញ ហើយមន្ត្រីថ្មីបានចូលមកជំនួសវិញក៏ដោយ ។
- ជាកំណត់ត្រាមួយនៃរឿងរ៉ាវ
- តម្លាភាពនៃប្រតិបត្តិការណ៍របស់ក្រុមប្រឹក្សាឃុំត្រូវបានកែលំអ

## តើអ្វីទៅជាឧទាហរណ៍នៃប្រភេទកំណត់ត្រាដែលត្រូវរក្សាទុក?

- កំណត់ហេតុនៃការប្រជុំ
- ការឆ្លើយឆ្លងគ្នាទៅវិញទៅមក
- ផែនការអភិវឌ្ឍន៍និងថវិការបស់ក្រុមប្រឹក្សាឃុំ-សង្កាត់
- កំណត់ត្រាហិរញ្ញវត្ថុ
- សន្និធិទ្រព្យសម្បត្តិរបស់ក្រុមប្រឹក្សាឃុំ
- សៀវភៅអាសយដ្ឋាន ដែលរួមមានឈ្មោះ អាសយដ្ឋាន លេខទូរសព្ទ័និងទូរសារ ទីកន្លែង អ៊ីមែលរបស់អ្នកសហការណ៍ និងដៃគូ ដូចជា អង្គការក្រៅរដ្ឋាភិបាល ទីភ្នាក់ងារផ្តល់ជំនួយនាយកដ្ឋានតាមវិស័យជាដើម ។
- សំណើកិច្ចសន្យា ឬសកម្មភាពរៃអង្គាសមូលនិធិ ។
- ការងារកំពុងដំណើរការដែលភ្ជាប់ទាក់ទងទៅនឹងស្រុក ឬតំបន់ ជាដើម ។ល ។
- សៀវភៅទិន្នន័យភូមិ
- ដីការឃុំ

ការរក្សាទុកកំណត់ត្រា ត្រូវតែធ្វើឡើងតាមមធ្យោបាយមួយថ្មី និងបើកចំហរ ដែលអាចឱ្យសាធារណៈងាយទទួលយក និងយល់ដឹងអំពីព័ត៌មាន និងកំណត់ត្រា ដែលជាអាទិភាពខ្ពស់ ដែលផ្តុយទៅនឹងការលាក់កំបាំង។ បើសិនណា ក្រុមប្រឹក្សាឃុំកំពុងតែប្រឹងប្រែងដើម្បីបង្កើន**តម្លាភាព** និង**គណនេយ្យភាព** ពួកគេអាចធ្វើរឿងជាច្រើន ដែលធ្វើឱ្យប្រាកដថា សាធារណៈជនត្រូវបានគេផ្តល់ឱ្យដឹងពីការសំរេចចិត្តសំខាន់ៗ និងផ្នែកផ្សេងៗទៀតនៃព័ត៌មានដែលជះឥទ្ធិពលដល់ពួកគេ។

- ពួកគេអាចរៀបចំឈុតឆាកនៅក្នុងការិយាល័យរបស់ក្រុមប្រឹក្សា ជាទីដែលប្រជាជនអាចទៅ ហើយស្វែងរកអ្វីក៏ដោយដែលពួកគេចង់ដឹង។
- ពួកគេអាចផ្តល់ដំណឹងដល់ប្រជាជន ពីកំណត់ត្រានិងព័ត៌មាននៅក្នុងការិយាល័យរបស់ពួកគេ ដែលបើកចំហសំរាប់សាធារណៈជន។
- ក្រុមប្រឹក្សាអាចធ្វើការងារនៅក្នុងមធ្យោបាយបើកចំហមួយ ដែលផ្តល់ព័ត៌មាន និងឆ្លើយតបភ្លាមៗ និងជាវិជ្ជមានទៅនឹងសំណូមពរទាំងឡាយចំពោះព័ត៌មាន។ ព័ត៌មាន គឺជាឧបករណ៍គន្លឹះមួយសំរាប់លទ្ធិប្រជាធិប្បតេយ្យ និងអភិវឌ្ឍន៍។
- ត្រូវបោះពុម្ពឯកសារ ដែលអាចរៀបចំឡើងទៅតាមលំដាប់ ធ្វើដូចនេះប្រជាជនងាយស្រួលក្នុងការទទួលយកព័ត៌មាន។
- កំណត់ត្រាទាំងឡាយ ត្រូវតែរក្សាទុកនៅក្នុងការិយាល័យឱ្យបានយូរដូចដែលបានចែងនៅក្នុងបទបញ្ជាទៅតាមលំដាប់រៀង។

## ការផ្ទេរភារៈកិច្ច និងបែងចែកការងារ និងការទទួលខុសត្រូវ

ក្រុមប្រឹក្សាឃុំ មានការងារជាច្រើនដែលត្រូវធ្វើ។ បើពួកគេផ្ទេរការងារ និងការទទួលខុសត្រូវទៅដល់អ្នកផ្សេង នោះធ្វើឱ្យអ្នកជាច្រើនចូលរួមនៅក្នុងសកម្មភាពអភិវឌ្ឍន៍។ នេះជាការប្រសើរសំរាប់ហេតុផលពីរយ៉ាងគឺ :

- អាចធ្វើការងារកាន់តែបានច្រើន មានន័យថា អភិវឌ្ឍន៍កាន់តែវិជ្ជមាននៅក្នុងឃុំ-សង្កាត់។
- ប្រជាជនកាន់តែច្រើន ត្រូវបានចូលរួម និងកំពុងចូលរួម មានន័យថា ពួកគេនឹងមានអារម្មណ៍ត្រឹមត្រូវក្នុងភាពជាម្ចាស់។

ការផ្ទេរភារៈកិច្ចនៃការងារ គឺមិនមែនជារឿងងាយនោះទេ។ វាមិនមែនគ្រាន់តែជារឿងរុញការងារឱ្យធ្វើនោះទេ។ នេះគឺជាបណ្តុំនៃជំនាញទាំងឡាយ ដែលប្រជាជនភាគច្រើនបានរៀនសូត្រដើម្បីធ្វើវាឱ្យកាន់តែល្អ។

## តើការចាំបាច់អ្វីខ្លះដែលត្រូវពិចារណាដើម្បីឱ្យប្រាកដថា ការផ្ទេរភារកិច្ចដំណើរការទៅបានល្អ?

| | |
|---|---|
| ❑ **ត្រូវកំណត់ការងារឱ្យបានច្បាស់លាស់** | • តើការងារអ្វីឱ្យពិតប្រាកដ ដែលបុគ្គលម្នាក់ត្រូវធ្វើ?<br>• តើបទដ្ឋានបែបណាតម្រូវឱ្យមាន?<br>• តើអ្នកបានផ្តល់ដល់បុគ្គលម្នាក់នោះ នូវរាល់ព័ត៌មាននិងសម្ភារៈដែលចាំបាច់នៅក្នុងការបំពេញការងារនោះដែរឬទេ?<br>• ត្រូវកំណត់ពេលវេលា នៅពេលណាដើម្បីបញ្ចប់ការងារ ។ |
| ❑ **ត្រូវកំណត់ឱ្យពិតប្រាកដថា អ្នកណាគួរធ្វើការងារនេះ** | • តើមនុស្សប៉ុន្មានអ្នកដែលតម្រូវឱ្យធ្វើកិច្ចការនោះ?<br>• តើកំរិតចំណេះដឹង ជំនាញនិងបទពិសោធន៍ត្រឹមណាតម្រូវឱ្យមាន?<br>• តើមានមនុស្សគ្រប់គ្រាន់ដែលមានកំរិតចំណេះដឹង បទពិសោធន៍ ឬជំនាញត្រឹមត្រូវដែរឬទេ? |
| ❑ **ការគ្រប់គ្រងផ្ទាល់** | • តើអ្វី និងនៅពេលណា ដែលអ្នកទាំងនោះត្រូវរាយការណ៍ជូនដល់អ្នក?<br>• តើអ្នកនឹងផ្តល់សេរីភាពប៉ុណ្ណាដល់ពួកគេដើម្បីធ្វើការងារតាមមធ្យោបាយរបស់គេ? ឬតើការងារនោះត្រូវសំរេចទៅតាមមធ្យោបាយមួយណា? |
| ❑ **ត្រូវពិនិត្យមើលពីការយល់ដឹង** | • ត្រូវធ្វើឱ្យប្រាកដថា បុគ្គលនោះដឹងច្បាស់ពីអ្វីដែលត្រូវធ្វើ ។<br>• ត្រូវអនុញ្ញាតិឱ្យគេសួរសំណួរ |

## សម្របសម្រួលប្រព័ន្ធធ្វើផែនការឃុំ-សង្កាត់

> មាត្រា ទី៦០ នៃច្បាប់រដ្ឋបាលនិងគ្រប់គ្រងឃុំ-សង្កាត់ : " ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវតែរៀបចំ យល់ព្រម និងអនុវត្តផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ នៅក្នុងគោលបំណងនៃការកំណត់គោលទស្សនៈ កម្មវិធី និង ការអភិវឌ្ឍ ឃុំ-សង្កាត់ ។ "

ក្រុមប្រឹក្សាឃុំម្នាក់ៗ ត្រូវតែបង្កើតផែនការអភិវឌ្ឍន៍ឃុំ នៅក្នុងឆ្នាំទីមួយនៃអាណត្តិរបស់ខ្លួន និងជារៀងរាល់ឆ្នាំ ត្រូវរៀបចំកម្មវិធីវិនិយោគវិលបីឆ្នាំម្តងរបស់ឃុំ ។ បញ្ហានេះវាអាស្រ័យទៅនឹងក្រុមប្រឹក្សាឃុំ សហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋ ដើម្បីសំរេច និងអនុវត្តអ្វីដែលនឹងកើតមានឡើងនៅក្នុងផ្នែកនិមួយៗ ។ ការចូលរួមរបស់ប្រជាពលរដ្ឋនិងសហគមន៍មូលដ្ឋាន គឺជាលក្ខណៈពិសេសនៃការធ្វើផែនការអភិវឌ្ឍន៍ឃុំ-

សង្កាត់។ នេះមានន័យថា ការឈានផ្ទាល់ទៅដល់បុរសនិងស្ត្រី អ្នកមាននិងអ្នកក្រ មនុស្សចាស់និងក្មេង ដែលមានការងារធ្វើ និងគ្មានការងារធ្វើ។

នៅពេលដែលអនុវត្តគំរោង និងកម្មវិធី ក្រុមប្រឹក្សាឃុំ ត្រូវធ្វើឱ្យប្រាកដថា អ្នកទទួលផលត្រូវបានជាប់ពាក់ពន្ធ័គ្រប់គ្រាន់នៅក្នុងការគ្រោងលំអិតនៃគំរោង និងការគ្រប់គ្រងផ្ទាល់គ្រប់គំរោងទាំងអស់នៃផែនការអភិវឌ្ឍន៍។

ប្រាំមួយខែមុនបញ្ចប់អាណត្តិរបស់ក្រុមប្រឹក្សាឃុំ លទ្ធផលនិងផលប៉ះពាល់នៃផែនការអភិវឌ្ឍន៍ ត្រូវតែវាយតំលៃ។

## ដំណើរការធ្វើផែនការផ្លាស់ប្តូររបស់ឃុំ

### ដំណើរការនៃការធ្វើផែនការអភិវឌ្ឍន៍ឃុំ

*ដំណាក់កាលទី ១ : ការវិភាគទិន្នន័យ និងការប៉ាន់ស្មានតម្រូវការ*

ជំហានទី ១ : ការវិភាគទិន្នន័យ និងការប៉ាន់ស្មានតម្រូវការក៏រិត ឃុំ-សង្កាត់

ជំហានទី ២ : ការប៉ាន់ស្មានតម្រូវការដោយមានការចូលរួម

ជំហានទី ៣ : ការឱ្យអាទិភាពនៃបញ្ហាដែលត្រូវអភិវឌ្ឍន៍

*ដំណាក់កាលទី ២ : ការកំណត់យុទ្ធសាស្ត្រ*

ជំហានទី ៤ : ការកំណត់យុទ្ធសាស្ត្រ និងគំរោង

*ដំណាក់កាលទី ៣ : ការបង្កើតគំរោង*

ជំហានទី ៥ : ការបង្កើត និងការកំណត់តម្លៃរបស់គំរោង

ជំហានទី ៦ : ការព្យាករណ៍ចំណូលមធ្យម

ជំហានទី ៧ : ការជ្រើសរើសគំរោង

ជំហានទី ៨ : សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក

*ដំណាក់កាលទី ៤ : ការបង្កើតគំរោង*

ជំហានទី ៩ : ការបង្កើតកម្មវិធីសមាហរណកម្ម

ជំហានទី ១០ : ការពង្រាងផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធី វិនិយោគឃុំ

*ដំណាក់កាលទី ៥ : បង្កើតឱ្យមានការយល់ព្រម*

ជំហានទី ១១ : ការយល់ព្រមលើផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីវិនិយោគឃុំ

### វដ្តរបស់ផែនការយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍ឃុំ

ជំហានទី ១ : ពង្រាងគ្រោងការអភិវឌ្ឍន៍ និងថវិការ

ជំហានទី ២ : ការប្រជុំពិគ្រោះលើការអភិវឌ្ឍឃុំ

ជំហានទី ៣ : ពង្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឃុំ

ជំហានទី ៤ : ឯកភាពលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឃុំ

ជំហានទី ៥ : វាយតំលៃការអនុវត្តផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ឃុំ

### វដ្តរបស់កម្មវិធីវិនិយោគឃុំ

ជំហានទី ១ : ការបង្កើតគំរោងឃុំ និងការគ្រោងថវិការ

ជំហានទី ២ : សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក

ជំហានទី ៣ : ការផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាមួយ ប្រជាជនក្នុងឃុំ

ជំហានទី ៤ : យល់ព្រមលើកម្មវិធីវិនិយោគឃុំ

ជំហានទី ៥ : ការត្រួតពិនិត្យ និងវាយតំលៃកម្មវិធី វិនិយោគឃុំ

# ការធ្វើឱ្យប្រាកដប្រជានូវការចូលរួមជាសាធារណៈ នៅក្នុងដំណើរការធ្វើផែនការ

មាត្រាទី ៦៤ នៃច្បាប់រដ្ឋបាលនិងគ្រប់គ្រងឃុំ-សង្កាត់ : "ផែនការ អភិវឌ្ឍន៍ ឃុំ-សង្កាត់ ត្រូវតែកំណត់ពីវិធីសាស្ត្រ និងមធ្យោបាយដើម្បីផ្តល់ឱកាសសំរាប់ការចូលរួមរបស់ប្រជាពលរដ នៃឃំ-សងាត់នៅកងដំណើរការទាំងមល ។"

## តើផលប្រយោជន៍នៃការចូលរួមមានអ្វីខ្លះ?

- ការចូលរួម គឺធ្វើឱ្យប្រាកដថា គំរោងពិតជាបានបង្ហាញពីការចាប់អារម្មណ៍ និងតម្រូវការរបស់ប្រជាជនពិតប្រាកដមែន ដូចនេះពួកគេកាន់តែទទួលបានជោគជ័យ ។
- ប្រជាពលរដ្ឋ នឹងមានអារម្មណ៍កាន់តែទទួលខុសត្រូវចំពោះគំរោងនៅក្នុងមូលដ្ឋានរបស់ពួកគេ នៅពេលពួកគេត្រូវបានឱ្យចូលរួមនៅក្នុងការធ្វើសេចក្តីសំរេចចិត្ត ការអនុវត្ត និងការវាយតំលៃពីសកម្មភាពអភិវឌ្ឍន៍ ។
- ការចូលរួមធ្វើឱ្យប្រជាជនកាន់តែឯករាជ្យពីជំនួយពីខាងក្រៅ ពីព្រោះពួកគេចាប់ផ្តើមគិតពីការធ្វើការងារដោយខ្លួនគេ ស្វែងរកដំណោះស្រាយចំពោះបញ្ហារបស់ពួកគេ និងការផ្តួចផ្តើមធ្វើសកម្មភាព ។
- ការចូលរួមគាំទ្រដល់ការខំប្រឹងប្រែងនៃការកាត់បន្ថយភាពក្រីក្រ ពីព្រោះប្រជាជនក៏បានចូលរួមដែរ ។
- ដូចនេះ ការចូលរួមក៏ជួយដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីប្រើប្រាស់ធនធានរបស់គេកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល ។

## តើការលំបាកនៅក្នុងការចូលរួមរបស់សាធារណៈជនអាចមានអ្វីខ្លះ?

- គោលគំនិតនៃការចូលរួម គឺថ្មីសំរាប់យើងម្នាក់ៗ ដូចជាបុគ្គលក្រុមប្រឹក្សាម្នាក់ៗត្រូវតែរៀនពីរបៀបសម្របសម្រួលការចូរលរួម ហើយប្រជាជនត្រូវរៀនពីដំណើរការដើម្បីចូលរួម ។
- ប្រជាជនដែលគេឱ្យចូលរួមផ្ទាល់នៅក្នុងការធ្វើសេចក្តីសំរេចចិត្ត អាចគ្របដណ្តប់លើអ្នកផ្សេង ។

- អាចមានប្រជាជនខ្លះ ដូចជាស្ត្រី អ្នកក្រីក្រ ជនពិការ ជាដើម ដែលមិនហ៊ានបញ្ចេញមតិពីតម្រូវការរបស់ពួកគេ ហើយអ្នកដែលមិនខ្លាច ដោយសារតែភាពប្រសើរលើសលុបនៅក្នុងសង្គម អាចតតាំងដើម្បីការពារការចាប់អារម្មណ៍របស់ពួកគេ ។

## តើអាចមានមធ្យោបាយសមស្របអ្វីខ្លះ ដើម្បីលើកស្ទួយការចូលរួមរបស់សាធារណៈជន?

- នៅក្នុងការប្រជុំថ្នាក់ភូមិ ប្រជាពលរដ្ឋទាំងអស់ គេត្រូវអនុញ្ញាតិឱ្យគាត់មានឱកាសដើម្បីពិភាក្សាពីតម្រូវការ និងការចាប់អារម្មណ៍របស់ពួកគាត់ ។ ត្រូវធ្វើឱ្យប្រាកដថា គ្រប់វ័យរបស់ប្រជាពលរដ្ឋ ទាំងស្ត្រីនិងបុរស ទាំងចាស់និងក្មេង ទាំងអ្នកមាននិងអ្នកក្រ ជាដើម ត្រូវបានផ្តល់ឱកាសដល់ពួកគេ ដើម្បីសំដែងចេញពីតម្រូវការ និងកង្វល់របស់ពពួកគេ ។
- អង្គការសង្គមស៊ីវិល អាចចូលរួមនៅក្នុងការរៀបចំផែនការអភិវឌ្ឍឃុំ-សង្កាត់ និងកម្មវិធីវិនិយោគឃុំ-សង្កាត់ ដោយធ្វើជាតំណាងឱ្យការចាប់អារម្មណ៍របស់សហគមន៍មូលដ្ឋាន និងក្រុមជាក់លាក់ទាំងឡាយណាមួយ ដូចជា ប្រជាជនក្រីក្រ ស្ត្រី សហគមន៍អន្តោប្រាម ជាដើម ។
- អង្គការសង្គមស៊ីវិល អាចចែករំលែកចំណេះដឹង និងគំនិតនៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ។
- ប្រជាជនគួរតែគេផ្តល់ឱកាសដល់គាត់ដើម្បីផ្តល់ជាយោបល់ចំពោះផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ។
- ប្រជាពលរដ្ឋ គួរតែគេឱ្យចូលរួមនៅក្នុងការត្រួតពិនិត្យការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ។

## ការគ្រប់គ្រងហិរញ្ញវត្ថុឃុំ-សង្កាត់

> មាត្រាទី ៧៣ នៃច្បាប់រដ្ឋបាលនិងគ្រប់គ្រងឃុំ-សង្កាត់ : " ឃុំ-សង្កាត់ ត្រូវតែមានប្រភពធនធានហិរញ្ញវត្ថុ ថវិការ និងទ្រព្យសម្បត្តិរបស់ខ្លួន " ។
>
> មាត្រាទី ៨២ នៃច្បាប់រដ្ឋបាលនិងគ្រប់គ្រងឃុំ-សង្កាត់ : " ឃុំ-សង្កាត់ គួរតែបង្កើតប្រពន្ធ័មួយ សំរាប់គ្រប់គ្រង ត្រួតពិនិត្យ និងតាមដាន ហិរញ្ញវត្ថុរបស់ខ្លួន " ។

ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបានគេផ្តល់អំណាចដើម្បីគ្រប់គ្រងប្រភពធនធានហិរញ្ញវត្ថុរបស់គេ ។ ពួកគេត្រូវបានគេផ្តល់ការទទួលខុសត្រូវ ដើម្បីគ្រប់គ្រងធនធានទាំងនេះប្រកបដោយការជឿជាក់ និងការទទួលខុស

ត្រូវខ្ពស់ ដូចនេះសាធារណៈជនអាចទុកចិត្តលើពួកគេបាន។ មិនអាចមានអ្វីកើតមានឡើងចំពោះភាពមិនជឿជាក់របស់សាធារណៈជនទេ ដូចជាការសួរអំពីលុយដែលបានចំណាយ។

## តើប្រភពចំណូលសំខាន់ៗរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់មានអ្វីខ្លះ?

ក្រុមប្រឹក្សាឃុំ-សង្កាត់មានប្រភពចំណូលបីសំខាន់ៗ :

- ពួកគេបានផ្តល់អំណាចដើម្បីប្រមូល**ចំណូលផ្ទាល់** ដូចជា កំណត់ពន្ធលើដីធ្លី ឬអាគារ។ ពួកគេត្រូវបានអនុញ្ញាតិឱ្យយកថ្លៃឈ្នួល នៅពេលពួកគេផ្តល់សេវាកម្ម។ ច្បាប់ក៏បានចែងដែរថា ការលំអិតទាំងឡាយនឹងមានចែងនៅក្នុងច្បាប់ដាច់ដោយឡែកមួយ។
- ពួកគេក៏នឹងទទួលផងដែរនូវចំណែកមួយនៃ**មូលនិធិឃុំ-សង្កាត់**។ មូលនិធិនេះ នឹងត្រូវបង្កើតឡើងដើម្បីផ្ទេរធនធានពីថ្នាក់ជាតិទៅឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់។ មូលនិធិនឹងមានចំណែកមួយសំរាប់ការចំណាយរដ្ឋបាល និងចំណែកមួយសំរាប់ការចំណាយសំរាប់ការអភិវឌ្ឍរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។ ចំណែកនៃមូលនិធិរបស់ឃុំ-សង្កាត់ ដែលនឹងត្រូវទទួលដោយក្រុមប្រឹក្សាឃុំ-សង្កាត់ម្នាក់ៗ នឹងត្រូវគេកំណត់ដោយវិធីមួយ តាមរូបមន្តប្រកបដោយតម្លាភាព។
- ពួកគេត្រូវបានអនុញ្ញាតិ ដើម្បីទទួលយក**ថ្លៃឈ្នួល** នៅពេលដែលពួកគេបំពេញតួនាទីរបស់ខ្លួនក្នុងមានរដ្ឋាភិបាលថ្នាក់ជាតិ។ នេះគឺត្រូវបានកំណត់ជា" មុខងាររបស់ទីភ្នាក់ងារ " ។

ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវតែអនុវត្តតាមប្រភេទជាច្រើននៃនិតិវិធី ដើម្បីធ្វើឱ្យប្រាកដថា ធនធានត្រូវបានចំណាយក្នុងរបៀបមួយប្រកបដោយតម្លាភាព និងគណនេយ្យភាព។

1. ថវិកាឃុំ-សង្កាត់
2. ប្រពន្ធ័គណនេយ្យភាពរបស់ឃុំ-សង្កាត់
3. របាយការណ៍ហិរញ្ញវត្ថុ
4. វដ្ត ឬខួបនៃការចំណាយ
5. បទវិន័យនៃលតកម្ម
6. ទ្រព្យសម្បត្តិយូរអង្វែងរបស់ឃុំ-សង្កាត់
7. សវនកម្មគណនីឃុំ-សង្កាត់ និងប្រតិបត្តិការណ៍គណនី

## ការបង្កើតផែនការសកម្មភាព

ផែនការសកម្មភាពមួយ គឺជាឯកសារ ដែលបង្ហាញពីមធ្យោបាយលំអិត ថាតើប្រជាជន ចង់បានអ្វីឱ្យកើតមានឡើងយ៉ាងដូចម្តេច ។ វាគឺជាបញ្ជីសកម្មភាពទាំងឡាយ ដែលគេ មានបំណងចង់ធ្វើក្នុងអំឡុងពេលមួយ ។ វាបង្ហាញពី *អ្វី*ដែលគេចង់ធ្វើ *ពេលណា*ដែលគេ ចង់ធ្វើវា និង*នរណា*ជាអ្នកធ្វើវា ។

ក្រុមប្រឹក្សាឃុំ-សង្កាត់មានការងារជាច្រើនដើម្បីធ្វើឱ្យសំរេច ។ ទាំងនេះ គឺទាមទារដាក់វាទៅតាមលំដាប់ លំដោយ ធ្វើដូចនេះម្នាក់ៗអាចដឹងថានឹងមានអ្វីកើតឡើងនៅពេលខាងមុខ ។ វាមានសារៈសំខាន់ណាស់ ដើម្បីដឹងថាអ្នកទទួលខុសត្រូវការងារផ្សេងៗ និងអ្នកដែលត្រូវធ្វើអ្វី និងនៅពេលណា ។
ផែនការសកម្មភាពសំរាប់ :

- ណែនាំសកម្មភាពនាពេលខាងមុខ
- រំលឹកដល់ប្រជាជនអំពីសកម្មភាពទាំងឡាយ ដើម្បីអាចឱ្យគេត្រៀមលក្ខណៈជាមុន ។
- ជួយដល់បុគ្គលិកថ្មី និងអ្នកខាងក្រៅឱ្យដឹងនូវអ្វីដែលម្នាក់ៗនឹងត្រូវធ្វើ ។

## ការត្រួតពិនិត្យ និងវាយតំលៃ

ការត្រួតពិនិត្យ គឺជាដំណើរការមួយក្នុងការប្រមូលព័ត៌មាន ស្តីអំពីការរីកចំរើនរបស់ការងារ និងការប្រើប្រាស់ព័ត៌មានទាំងនេះ ដើម្បីធ្វើការសំរេចចិត្ត និងធ្វើផែនការបានល្អប្រសើរ នាពេលខាងមុខ ។ ការត្រួតពិនិត្យ ជួយឱ្យមើលឃើញនូវអ្វីខ្លះដែលកំពុងដំណើរការល្អ និងអ្វីខ្លះ ដែលចាំបាច់ត្រូវផ្លាស់ប្តូរ ឬកែលំអ ។

ក្រុមប្រឹក្សាឃុំ-សង្កាត់ ជាពិសេសត្រូវបានគេស្នើឱ្យត្រួតពិនិត្យ ដូចតទៅនេះ :

- ការអនុវត្តផែនការ កម្មវិធី គំរោង និងសេវាកម្មផ្សេងៗ ដែលបានផ្តល់សំរាប់សុខមាលភាពរបស់ ប្រជាពលរដ្ឋ ។

- ហិរញ្ញវត្ថុ ឧទាហរណ៍ ដូចជាការអនុវត្តគណនេយ្យ ការគ្រប់គ្រងទ្រព្យសម្បត្តិ ការគ្រប់គ្រងសវនកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុ ។

ការត្រួតពិនិត្យជួយ ៖

- ក្នុងការពិនិត្យសង្កេតពីរបៀបដែលរឿងរ៉ាវកំពុងដំណើរការ ឬរីកចំរើន ។
- ក្នុងការកំណត់បញ្ហា និងរឿងរ៉ាវដែលកំពុងកើតឡើង ឬដំណើរការមិនត្រឹមត្រូវ ។
- ក្នុងការសំរេចចិត្តសំរាប់ការផ្លាស់ប្តូរសមស្រប ដើម្បីធ្វើឱ្យរឿងរ៉ាវទាំងឡាយត្រឡប់មកត្រឹមត្រូវវិញ
- ក្នុងការប្រើប្រាស់ធនធានកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល ។
- ក្នុងការថែរក្សាគុណភាពឱ្យល្អ ។

# ឯកសារយោង


1. Caroline Rusten et al. 2004: the challenges of the decentralization design in Cambodia
2. David Ayres 2001: literature review on decentralization, CCSP
3. Diana Conyers 1983, IDS: decentralization: the last fashion in development administration?
4. El Mensi: a study on communes' own source revenue in Cambodia
5. NCDD is established by a Royal decree No. 0806/355 Kingdom of Cambodia
6. Patrick Stoop 2002:  assessment of the recent decentralization policies of the Lao PDR government
7. Parker 1997: Promoting Good Local Governance through Social Funds and Decentralization
8. Paul Erickson et al.1999: devolution and electoral politics
9. Prum Sokha: Secretary of State of Ministry of Interior, Cambodia
10. Rondinelli 1999 (a): democratic decentralization and local participation: a review of recent research
11. Rondinelli 1999 (b): concept of fiscal decentralization a worldwide overview



# ម៉ូឌុលទី ២

# ក្របខ័ណ្ឌច្បាប់សំរាប់សេវាកម្មសាធារណៈនៅប្រទេសកម្ពុជា

## គោលបំណងរបស់ម៉ូឌុល

ដើម្បីផ្តល់ចំណេះដឹង និងការស្វែងយល់ពីច្បាប់ ចំពោះអត្ថន័យទូទៅនៃការផ្តល់សេវាកម្មសាធាណេះ ដែលទទួលដឹងដោយរដ្ឋាភិបាល និងគោលទស្សនៈនិងគោលនយោបាយរបស់រដ្ឋាភិបាល ចំពោះការផ្តល់សេវាកម្មសាធារណៈ ។

## ការរំពឹងទុករបស់ម៉ូឌុល

គេរំពឹងថា នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងមានការយល់ដឹងជាមូលដ្ឋានអំពី :

- គោលទស្សនៈ គោលបំណង និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះការផ្តល់សេវាកម្មសាធារណៈ ។
- អត្ថន័យនៃពាក្យសេវាកម្មសាធារណៈ និងវិធីសាស្ត្រនិងយន្តការផ្សេងៗ សំរាប់ការផ្តល់សេវាកម្មសាធារណៈ ។
- ក្របខ័ណ្ឌច្បាប់ និងកិច្ចសហប្រតិបត្តិការណ៍ ដើម្បីការផ្តល់សេវាកម្មសាធារណៈប្រកបដោយប្រសិទ្ធិភាព ។
- ការប្រឈមមុខទាំងឡាយនៅក្នុងការផ្តល់សេវាកម្មសាធារណៈនៅថ្នាក់មូលដ្ឋាន ។

**កំណត់សំគាល់ :** ម៉ូឌុលនេះ ត្រូវបានកែសម្រួលចេញពីគោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជាចំពោះការផ្តល់សេវាកម្មសាធារណៈ (បំរើប្រជាជនកាន់តែប្រសើរ) ដោយដកស្រង់ទាំងស្រុងរបស់គណៈរដ្ឋមន្ត្រី ប្រទេសកម្ពុជា នៅខែឧសភា ឆ្នាំ ២០០៦ ។

2.1

## គោលទស្សនៈរដ្ឋាភិបាលចំពោះការផ្តល់សេវាកម្មសាធារណៈ

យុទ្ធសាស្ត្រ និងកម្មវិធីទាំងឡាយ ដែលដកស្រង់ចេញពីពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការសកម្មភាពអភិបាលកិច្ចលើកទីពីរ បានបង្ហាញគោលបំណងមួយយ៉ាងច្បាស់ និងបានដើរតួរជាត្រីវិស័យមួយ ឆ្ពោះទៅរកការអនុវត្តវិស័យកំណែទម្រង់ជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ។

ប្រទេសកម្ពុជា មិនមានជំរើសឱ្យប្រសើរជាជាងកំណែទម្រង់ នៅពេលខ្លួនឋិតក្នុងបរិបទមួយនៃការកើនឡើងអត្ថប្រយោជន៍ពីសន្តិភាព និងស្ថេរភាពនោះទេ។ រដ្ឋបាលសាធារណៈបច្ចុប្បន្ន ត្រូវបានលើកទឹកចិត្តឆ្ពោះទៅរកកំណែទម្រង់ឱ្យកាន់តែងាយយល់ និងស៊ីជម្រៅ ធ្វើដូចនេះដើម្បីក្លាយទៅជាអ្នកផ្តល់សេវាកម្មមួយប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ហើយជាដៃគូអភិវឌ្ឍន៍មួយគួរឱ្យជឿជាក់ ដើម្បីបំពេញនូវបេសកកម្ម " នៃការផ្តល់សេវាកម្មកាន់តែប្រសើរដល់ប្រជាជន " ដែលជាការមានប្រសាសន៍របស់ **សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន**។ នៅក្នុងឱកាសនោះដែរ គ្រប់ក្រសួងនិងស្ថាប័នទាំងអស់ និងអ្នកពាក់ព័ន្ធរដ្ឋបាលសាធារណៈទាំងអស់ ត្រូវតែគោរពការងារ សំដៅសំរេចការផ្លាស់ប្តូរប្រកបដោយនិរន្តរភាព និងពង្រឹងភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់របស់ប្រទេសកម្ពុជា។

**សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានមានប្រសាសន៍កាលពីថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០០៦ ថា រដ្ឋបាលសាធារណៈគួរតែមានលក្ខណៈសំខាន់បួនយ៉ាងដូចខាងក្រោម ៖

- **ការលើកទឹកចិត្ត និងការជំរុញខ្លាំងខ្លាដើម្បីអនុវត្តការងារ** ៖ រដ្ឋបាលសាធារណៈត្រូវតែមានភក្តីភាពចំពោះការងារ និងលើកកំពស់ការងាររបស់មន្ត្រីរាជការស៊ីវិល។
- **ភាពស្មោះត្រង់** ៖ រដ្ឋបាលសាធារណៈដែលជាជំនួយការរបស់រាជរដ្ឋាភិបាលកម្ពុជា និងជាស្ថាប័នរដ្ឋត្រូវតែស្មោះត្រង់ចំពោះរដ្ឋ និងប្រជាពលរដ្ឋ។
- **ការផ្តោតលើសេវាកម្ម** ៖ រដ្ឋបាលសាធារណៈត្រូវបំលែងពីអ្នកចាត់ការរដ្ឋបាល ទៅជាអ្នកផ្តល់សេវាកម្ម ហើយត្រូវតែយុត្តិធម៌ក្នុងការប្រតិបត្តិ និងឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ប្រជាជន។
- **វិជ្ជាជីវៈនិយម** ៖ រដ្ឋបាលសាធារណៈត្រូវតែអនុវត្តការងាររបស់ខ្លួនប្រកបដោយតម្លាភាព សមត្ថភាព និងប្រសិទ្ធិភាព។

ចរិកលក្ខណៈរបស់រដ្ឋបាលសាធារណៈដែលបានបង្ហាញដូចខាងលើ មិនអាចសម្រេចបានទេ លុះត្រាតែទំលាប់ការងារ និងឥរិយាបទរបស់មន្ត្រីរាជការស៊ីវិលត្រូវបានផ្លាស់ប្ដូរ។ ការជោគជ័យនៃកំណែទម្រង់វាអាស្រ័យទៅនឹងល្បឿននៃការផ្លាស់ប្ដូរនេះ មានន័យថា មធ្យោបាយនៃការពិចារណា និងឥរិយាបទរបស់មន្ត្រីរាជការពីអ្នកចាត់ការរដ្ឋបាលទៅជាអ្នកផ្ដល់សេវាកម្ម ក្នុងលំនាំកាន់តែមានប្រសិទ្ធិភាព ហើយជាពិសេស គឺផ្ដោតទៅលើចំណុចដូចខាងក្រោម :

- ❑ ភាពអាចរក និងទទួលសេវាកម្មរបស់អ្នកប្រើប្រាស់
- ❑ ភាពរាក់ទាក់ ស្លូតបូត និងការយកចិត្តទុកដាក់ចំពោះតម្រូវការរបស់អ្នកប្រើប្រាស់
- ❑ ការផ្ដល់សេវាកម្មទាន់ពេល មានប្រសិទ្ធិភាព និងស្លូតបូតចំពោះអ្នកប្រើប្រាស់
- ❑ ការពន្យល់ និងការឆ្លើយតបទៅនឹងចម្ងល់ទាំងឡាយអំពីសេវាកម្ម និងការត្អូញត្អែ។

សេចក្ដីបន្ថែមទៅលើអត្ថបទនៃផែនការសកម្មភាពអភិបាលកិច្ចទី ២ ដែលគណៈរដ្ឋមន្ត្រីបានអនុម័តនៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៦ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលបានកំពុងបង្កើតគោលនយោបាយជាច្រើន ដើម្បីពង្រីក និងធ្វើឱ្យកាន់តែស៊ីជម្រៅទៅលើវិស័យកំណែទម្រង់ ហើយធ្វើឱ្យប្រាកដប្រជានូវភាពជោគជ័យនៃយុទ្ធសាស្ត្រចតុកោណ។ ទាំងនេះ គឺជាគោលនយោបាយស្ដីអំពីការផ្ដល់សេវាកម្មសាធារណៈ គោលការណ៍រួមនៃការផ្ដល់សេវាកម្មសាធារណៈតាមរយៈយន្តការនៃការិយាល័យបង្អួចតែមួយ គោលនយោបាយស្ដីអំពីការគ្រប់គ្រងធនធានមនុស្ស គោលនយោបាយស្ដីអំពីការអភិវឌ្ឍធនធានមនុស្ស គោលនយោបាយស្ដីអំពីការផ្ដល់ផលប្រយោជន៍នៅក្នុងការងា គោលនយោបាយស្ដីអំពីការគ្រប់គ្រងនិយោជិត ក្របខ័ណ្ឌគ្រប់គ្រងសំរាប់អភិវឌ្ឍន៍សមត្ថភាព និងបច្ចេកវិជ្ជាព័ត៌មាន និងប្រាស្រ័យទាក់ទង។ នយោបាយទាំងនេះ នឹងជួយកែលំអដល់ការផ្ដល់សេវាកម្មសាធារណៈ។

រាជរដ្ឋាភិបាលកម្ពុជា បានអភិវឌ្ឍនិងបើកយុទ្ធនាការលើកម្មវិធីជាតិរយៈពេល៥ឆ្នាំ (២០០៤-២០០៨) សំរាប់កំណែទម្រង់រដ្ឋបាល ដែលបានកំណត់យ៉ាងច្បាស់នូវគោលបំណងដ៏សំខាន់ គឺ "ការបំរើប្រជាពលរដ្ឋឱ្យកាន់តែល្អ ប្រសើរឡើង" យុទ្ធសាស្ត្រនៃកម្មវិធីនេះ គឺផ្អែកលើ គោលការណ៍សំខាន់៧បួន (១) ការកែលំអការផ្ដល់សេវាកម្ម (២) បង្កើនប្រាក់បៀវត្សនិងការងារធ្វើ (៣) អភិវឌ្ឍន៍សមត្ថភាព (៤) លើកកំពស់បច្ចេកវិជ្ជាព័ត៌មាននិងការប្រាស្រ័យទាក់ទង។ ក្រុមបេសកកម្មអាទិភាព (PMG) ជាចំណុចស្នូលនៃយុទ្ធសាស្ត្រនេះ។

គោលនយោបាយស្ដីអំពីការផ្ដល់សេវាកម្មសាធារណៈ ជាលទ្ធផលនៃការពិភាក្សារួម និងការផ្លាស់ប្ដូរគំនិតគ្នារវាងក្រសួង ស្ថាប័ន នៅក្នុងកិច្ចប្រជុំអន្តរក្រសួង ឆ្ពោះទៅរកការអនុម័តដោយគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គនៅថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០០៦។ នយោបាយដាក់ចេញនូវនិយមន័យប្រភេទសេវាកម្មសាធារណៈរបស់រដ្ឋ ទិសដៅ និងយុទ្ធសាស្ត្រ យន្តការនៃការអនុវត្ត ការកែលំអនៅក្នុងគំរោងច្បាប់ និងការសំរបសំរួលនៃការប្រតិបត្តិ។ វាមិនគ្រាន់តែសំរាប់បង្ហាញផ្លូវចំពោះថ្នាក់ដឹកនាំជាន់ខ្ពស់ និងមន្ត្រី

បំរើការស៊ីវិលនោះទេ ប៉ុន្តែថែមទាំងបង្ហាញនូវសកម្មភាពជាអាទិភាពដ៏ច្រើន ដែលរដ្ឋាភិបាលធ្វើការកែទម្រង់រដ្ឋបាល ដើម្បីធ្វើឱ្យរដ្ឋបាលសាធារណៈមានសមត្ថភាព ដើម្បីបំរើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ ។

2.2

## គោលនយោបាយរដ្ឋាភិបាលចំពោះការផ្តល់សេវាសាធារណៈ

### និយមន័យ និងប្រភេទនៃការផ្តល់សេវាសាធារណៈ

គោលនយោបាយចំពោះការផ្តល់សេវាកម្មសាធារណៈដាក់ចេញជានិយមន័យ និងប្រភេទផ្សេងៗនៃសេវាកម្មសាធារណៈរបស់រដ្ឋ គោលបំណងនិងយុទ្ធសាស្ត្រ យន្តការប្រតិបត្តិការណ៍ ការកែលំអប្រពន្ធ័ច្បាប់ ការសម្របសម្រួលនៃការអនុវត្តច្បាប់ ។ លើសពីនេះ គោលនយោបាយនេះ គឺជាឯកសារគោលសំរាប់ការអនុវត្តកំណែទម្រង់ផ្សេងៗ ដើម្បីកែលំអការផ្តល់សេវាកម្មដោយផ្អែកទៅលើបទពិសោធល្អៗពីមុន និងបច្ចុប្បន្ន ។

**និយមន័យ**

**ទីភ្នាក់ងារមានសមត្ថកិច្ច :**
គឺសំដៅទៅស្ថាប័នរដ្ឋ ឬទីភ្នាក់ងាររដ្ឋ ឬអាជ្ញាធររដ្ឋគ្រប់លំដាប់ថ្នាក់ ដែលធ្វើការក្នុងតំបន់របស់ពួកគេ ដែលមានសមត្ថកិច្ចក្នុងយុត្តាធិការ ។

**សេវាកម្មសាធារណៈ**
ត្រូវបានឱ្យនិយមន័យដូចខាងក្រោម : សកម្មភាពទាំងអស់ដែលបានអនុវត្តដោយទីភ្នាក់ងារមានសមត្ថកិច្ចនិងផ្ទេរសិទ្ធិឱ្យក្នុងបំណងដើម្បីបំរើផលប្រយោជន៍សាធារណៈ គឺជាសេវាកម្មសាធារណៈ ។

**ទីភ្នាក់ងារទទួលភារៈកិច្ច :**
គឺសំដៅទៅលើអង្គភាពនៅក្នុងផ្នែកឯកជន ឬសង្គមស៊ីវិលដែលបានផ្ទេរការងារ និងការទទួលខុសត្រូវ ពិសេសពីរដ្ឋប៉ុន្តែស្ថិតនៅក្រោមត្រួតពិនិត្យរបស់រដ្ឋនិងទីភ្នាក់ងាររដ្ឋ។ ការត្រួតពិនិត្យដោយរដ្ឋ និងទីភ្នាក់ងាររដ្ឋនៃផ្នែកឯកជន ឬអង្គការសង្គមស៊ីវិលដោយផ្អែកទៅលើកិច្ចព្រមព្រៀង ឬកិច្ចសន្យាច្បាស់លាស់រួមទាំងសកម្មភាពការងារ លទ្ធផលដែលអាចសំរេចបាន ទិសដៅ និងផលប៉ះពាល់សង្គមដ៏ទៃទៀត ។

## ប្រភេទនៃសេវាកម្មសាធារណៈ

សេវាកម្មសាធារណៈ ត្រូវបានគេចែងដូចនៅខាងលើដែលចិតនៅក្នុងច្បាប់នេះ ត្រូវបានគេចែកជាប្រាំពីរប្រភេទ ដោយផ្អែកលើផ្នែក និងការទទួលខុសត្រូវរបស់ក្រសួង ឬស្ថាប័នដូចខាងក្រោម :

- សេវាកម្មដែលទាក់ទងទៅនឹងអធិបតេយ្យរបស់រដ្ឋ
- សេវាកម្មដែលទាក់ទងទៅនឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម
- សេវាកម្មដែលទាក់ទងទៅនឹងយុត្តិធម៌ និងការវិនិច្ឆ័យតាមផ្លូវច្បាប់
- សេវាកម្មដែលទាក់ទងទៅនឹងការបង្កើនការងារពាណិជ្ជកម្ម សហគ្រាសធុនតូច និងមធ្យម បរិយាកាសវិនិយោគទុន និងការចូលរួមរបស់វិស័យឯកជនក្នុងការកសាង និងជួលជុលហេដ្ឋារចនាសម្ព័ន្ធ
- សេវាកម្មសង្គម វប្បធម៌ និងកិច្ចការស្ត្រី
- សេវាកម្មដែលទាក់ទងទៅនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- សេវាកម្មដែលទាក់ទងទៅនឹងការប្រមូលប្រាក់ចំណូល ភាពសមហេតុផលនៃការចំណាយ និងការចំណាយ ។

**សេវាកម្មដែលទាក់ទងទៅនឹងអធិបតេយ្យរបស់រដ្ឋ**

សេវាកម្មដែលទាក់ទងនឹងអធិបតេយ្យភាពរបស់រដ្ឋ ដោយមិនរាប់បញ្ចូលការទទួលខុសត្រូវរបស់រដ្ឋ ហើយត្រូវបានផ្តល់ដោយទីភ្នាក់ងាររបស់រដ្ឋ ឬអង្គភាពរដ្ឋដែលចិតនៅក្រោមច្បាប់សាធារណៈ រដ្ឋបានផ្ទេរសិទ្ធិអំណាចដើម្បីអនុវត្តសេវាកម្មនោះ។ សេវាកម្មនេះរួមមាន : លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអាពាហ៍ពិពាហ៍ សំបុត្រកំណើត បណ្ណបើកបរយានយន្ត លិខិតបញ្ជាក់មុខងារ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ និត្យានុកូលកម្ម ។ល។ ចំពោះសេវាកម្មទាំងនេះ ការចាត់ចែងនិងការប្រតិបត្តិ គឺជាការទទួលខុសត្រូវរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ ។

**សេវាកម្មដែលទាក់ទងទៅនឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម**

សេវាកម្មទាំងនេះមានទំនាក់ទំនងទៅនឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការស្នាក់នៅ ការធ្វើដំណើរ ការប្រាស្រ័យទាក់ទង និងសុវត្ថិភាពសង្គម ។ ទាំងអស់នេះ គឺចិតនៅក្នុងសមត្ថកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ច នគរបាល កងសន្តិសុខ និងកងកំលាំងប្រដាប់អាវុធ ។ សេវាកម្មទាំងនេះមានសារៈសំខាន់ណាស់ ដើម្បីការពារបរិយាកាសអភិវឌ្ឍន៍ប្រទេស ការកាត់បន្ថយភាពក្រីក្រ និងសុភមង្គលរបស់

ប្រជាជននិងភាពសុខសាន្ត ស្ថេរភាពនិងភាពប្រាដកប្រជាសំរាប់អ្នកវិនិយោគនិងអាជីវករនៅក្នុងមុខជំនួញ។ ចំពោះសេវាកម្មទាំងនេះ ការចាត់ចែង និងការប្រតិបតិការណ៍របស់ពួកគេ គឺជាការទទួលខុសត្រូវរបស់រដ្ឋ និងភ្នាក់ងាររបស់រដ្ឋ។

**សេវាកម្មដែលទាក់ទងទៅនឹងយុត្តិធម៌ និងការវិនិច្ឆ័យតាមផ្លូវច្បាប់**

សេវាកម្មទាំងនេះទាក់ទងទៅនឹងយុត្តិធមិនិងការវិនិច្ឆ័យតាមផ្លូវច្បាប់ រវាងពលរដ្ឋនិងពលរដ្ឋ ឬពលរដ្ឋនិងសេវាកម្មស៊ីវិល ឬពលរដ្ឋនិងផ្នែកឯកជន ឬសេវាកម្មស៊ីវិលនិងផ្នែកឯកជន។ល។ សេវាកម្មទាំងនេះ ត្រូវបានបែងចែកជាពីរស្ថាប័ន :

(១) ក្រុមប្រឹក្សាអាជ្ញាកណ្តាល ជាអ្នកសំរបសំរួលដើម្បីដោះស្រាយនូវវិវាទបន្ទាប់បន្សំរវាងភាគីទាំងពីរក្រៅប្រព័ន្ធតុលាការ និងកាត់បន្ថយបន្ទុកនៃវិវាទដែលមាននៅក្នុងតុលាការ។
(២) ក្នុងតុលាការ : នៅក្នុងករណីអ្នកមានវិវាទមិនព្រមទទួលយកដំណោះស្រាយដែលធ្វើឡើងដោយអាជ្ញាកណ្តាល ពួកគេនឹងរកផ្លូវដោះស្រាយតាមរយៈតុលាការ។

ទំនុកចិត្តនៃអ្នកប្រើប្រាស់សេវាកម្ម និងអ្នកពាក់ពន្ធ័ដ៏ទៃទៀត គឺឯករាជ្យ ដោយឈរលើការប្រតិបត្តិច្បាប់ប្រកបដោយប្រសិទ្ធិភាព គុណភាព ធម្មចរិយា យុត្តិធមិ និងតម្លាភាព ក្នុងបរិបទដែលរក្សានូវវិធានច្បាប់ ដូច្នេះសកម្មភាពទាំងអស់សំរាប់ការកែលំអការងារ គួតែត្រូវបានរៀបចំបន្តិចម្តងៗដោយប្រុងប្រយ័ត្ន ដើម្បីបង្កើនគុណភាព និងប្រសិទ្ធិភាពនៃសេវាកម្មតុលាការ។

**សេវាកម្មដែលទាក់ទងទៅនឹងការបង្កើនការងារពាណិជ្ជកម្ម សហគ្រាសធុនតូចនិងមធ្យម បរិយាកាស វិនិយោគទុន និងការចូលរួមរបស់វិស័យឯកជនក្នុងការកសាង**

**ការបង្កើនកិច្ចការពាណិជ្ជកម្ម :**

រាជរដ្ឋាភិបាល គឺជាអ្នកយុទ្ធសាស្ត្រ និងជាអ្នកដឹកនាំនៃដំណើរការអភិវឌ្ឍន៍ ដែលទទួលខុសត្រូវក្នុងការបង្កើតបរិយាកាសមួយដើម្បីបង្កើនសហគ្រាសឯកជន ដោយគិតថាផ្នែកឯកជនគឺជាក្បាលម៉ាស៊ីនសំរាប់ការរីកចំរើន។ អាទិភាពពិសេស ត្រូវបានផ្តល់ឱ្យក្នុងការរៀបចំវាស់វែងដែលបង្កើតនូវបរិយាកាសទូទៅ ដែលធ្វើឱ្យមានការអភិវឌ្ឍ

**និងផ្លូលផុលហេដ្ឋារចនាសម្ព័ន្ធ**

ផ្នែកឯកជន ត្រូវឆ្លងកាត់តំណាក់កាលច្បាស់លាស់ :

- ការពង្រឹងទាំងអភិបាលកិច្ចសាជីវកម្ម និងសាធារណៈ
- ការកាត់បន្ថយការិយាល័យធិបតេយ្យ និងកិច្ចការរដ្ឋការនៅក្នុងក្រសួង ឬស្ថាប័ន ដោយគិតគូពីការនាំចេញនាំចូល
- ការបំបាត់ចោលនូវការងារត្រួតស៊ីគ្នារបស់ក្រសួង ឬស្ថាប័ន ដោយជំរុញដំណើរការត្រួតពិនិត្យតែម្តងចប់
- ការកែលំអការអនុវត្តយន្តការការិយាល័យបង្អួចមួយនៅច្រកព្រំដែនអន្តរជាតិ

## សហគ្រាសធុនតូច និងមធ្យម

រាជរដ្ឋាភិបាលបន្តកែលំអអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ដោយឆ្លងកាត់គោលនយោបាយដូចខាងក្រោម :

- ត្រូវលើកទឹកចិត្តការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមជាពិសេស តាមរយៈការផ្តល់ហិរញ្ញវត្ថុ រយៈពេលវែង និងរយៈពេលមធ្យម
- ត្រូវទប់ស្កាត់ការរត់ពន្ធគ្រប់ប្រភេទ
- ត្រូវកាត់បន្ថយបែបបទចុះបញ្ជី និងការចាប់ផ្តើមតំបូងរបស់ក្រុមហ៊ុន
- ត្រូវសម្រួលដល់សកម្មភាពនាំចេញនាំចូល ដោយធ្វើទំរង់ការឱ្យសាមញ្ញ ដូចជាការចេញអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតដទៃទៀត
- ត្រូវកាត់បន្ថយការស៊ីពេល និងការគិតថ្លៃសេវាកម្មចំពោះការអនុញ្ញាតិ សំរាប់ប្រតិបត្តិការណ៍ផលិតកម្មសហគ្រាសធុនតូច និងមធ្យមដោយឆ្លងកាត់តាមយន្តការការិយាល័យច្រកចេញចូលតែមួយ (One Window Office)
- ត្រូវផ្តល់ការគាំទ្រក្នុងការការពារដើម្បីជ្រើសរើសសហគ្រាសក្នុងអំឡុងពេលសមស្រប
- ត្រូវជំរុញការចងសម្ព័ន្ធភាព រវាងសហគ្រាសធុនតូច និងមធ្យម និងសហគ្រាសធំៗ។ល។

ដើម្បីសំរេចបាននូវគោលបំណងខាងលើ រដ្ឋាភិបាលត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើ :

- ការលើកទឹកចិត្តផលិតផលក្នុងស្រុក ដើម្បីជំនួសការនាំចូល និងដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្រ្តសំរាប់ការបង្កើតឱ្យមានផលិតផលក្នុងស្រុក ដោយអនុលោមទៅតាមបរិយាកាសទូទៅនៃតំបន់ និងសកលភាវូបនីយកម្ម
- ការបង្កើតយុទ្ធសាស្រ្តមួយ ដើម្បីធ្វើឱ្យសមត្ថភាពប្រកួតប្រជែងរបស់សហគ្រាសធុនតូច និងមធ្យមកាន់តែប្រសើរឡើង
- ការបង្កើតផែនការសកម្មភាព និងបទបញ្ញាផ្សេងៗ ដើម្បីជួយគាំទ្រ និងត្រួតពិនិត្យការងាររបស់សហគ្រាសធុនតូច និងមធ្យម ។

### បរិយាកាសវិនិយោគ និងការចូលរួមរបស់វិស័យឯកជន ក្នុងការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធ

ចំពោះកិច្ចការនេះ រាជរដ្ឋាភិបាលកម្ពុជានឹងត្រូវអនុវត្តការវាស់វែងចាំបាច់ ដើម្បីកែលំអបរិយាកាសវិនិយោគ និងជំនួញ ។ ការវាស់វែងរួមមាន គោលនយោបាយលើកទឹកចិត្ត បទបញ្ញាផ្លូវការ និងជំរុញការចូលរួមផ្នែកឯកជនក្នុងការសាងសង់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធ ។

រចនាសម្ព័ន្ធនៃសេវាកម្មទាំងឡាយដាក់ជាក្រុម ដែលមិនទាន់ឆ្លើយតបគ្រប់គ្រាន់ចំពោះតម្រូវការចាំបាច់សំខាន់ៗនៅឡើយ ក្នុងការសម្របសម្រួលប្រតិបត្តិការណ៍អាជីវកម្ម ការវិនិយោគ និងការអភិវឌ្ឍវិស័យឯកជន ត្រូវតែផ្លាស់ប្តូរឱ្យបានសមស្រប និងបន្ទាន់ ដើម្បីឱ្យស្របទៅតាមស្ថានភាពជាក់ស្តែង និងធនធានដែលមាន ។

### សេវាកម្មកិច្ចការសង្គម វប្បធម៌ និងកិច្ចការស្ត្រី

សេវាកម្មទាំងនោះរួមមាន : សេវាកម្មអប់រំ (លើកកំពស់គុណភាពអប់រំទាំងអស់ សម្ភារៈសិក្សា និងសិទ្ធិទទួលយកការអប់រំជាមូលដ្ឋាន) សេវាកម្មសុខភាពនិងអនាម័យ (ភាពអាចទទួលបាន គុណភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាកម្មសុខភាពដែលមានសមធម៌ និងសេវាកម្មសុខភាពបឋម ជាពិសេសសំរាប់អ្នកក្រីក្រ និងជនងាយ

រងគ្រោះបំផុត) សេវាកំសាន្ត សេវាកម្មសង្គម សេវាកម្មដែលផ្តល់ការការពារដល់ក្មេងកំព្រា ក្មេងងាយរងគ្រោះ ជនពិការ សេវាកម្មដែលបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសេវាកម្មដទៃទៀតដែលជួយកាត់បន្ថយភាពក្រីក្រ។

**សេវាកម្មដែលទាក់ទងទៅនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត**

សេវាកម្មដែលទាក់ទងនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាក់ស្តែងគឺជាអាទិភាពចំបងរបស់រាជរដ្ឋាភិបាលក្នុងការជំរុញ និងការពន្លឿនការលូតលាស់ផ្នែកសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាក់ស្តែងត្រូវតែផ្តោតលើការកសាងច្រើនទៀតនៃប្រពន្ធ័ដឹកជញ្ជូនដូចជា : ផ្លូវថ្នល់ ស្ពាន ផ្លូវរថភ្លើង ផ្លូវទឹក កំពង់ផែ អាកាសយានដ្ឋាន និង មន្ទីរពេទ្យ សាលារៀន អណ្តូងទឹក ប្រព័ន្ធទឹកស្អាត ប្រព័ន្ធធារាសាស្ត្រ អគ្គិសនី ថាមពល ព័តិមានវិទ្យា ប្រៃសនីយ៏និងទូរគមនាគមន៏។ល។ ចំពោះសេវាកម្មទាំងនេះ រាជរដ្ឋាភិបាលជំរុញគោលនយោបាយលើកទឹកចិត្តដើម្បីលើកទឹកចិត្តការចូលរួមពីអ្នកពាក់ពន្ធ័ទាំងអស់ជាពិសេសផ្នែកឯកជន។

**សេវាកម្មដែលទាក់ទងទៅនឹងការប្រមូលប្រាក់ចំណូលភាពសមហេតុផលនៃការចំណាយ និងការចំណាយ**

សេវាកម្មទាំងនេះមានទំនាក់ទំនងទៅនឹងការកែលំអ ការគ្រប់គ្រងប្រាក់ចំណូល ប្រព័ន្ធបង់ប្រាក់ និងការចំណាយកាន់តែមានតម្លាភាព និងប្រសិទ្ធភាពថែមទៀត និងទំរង់ការផ្សេងៗ ដើម្បីកាត់បន្ថយការលំបាករបស់អ្នកប្រើប្រាស់សេវាកម្ម។ នៅក្នុងការសម្របសម្រួលដល់ការអនុវត្ត ក្រសួង ឬស្ថាប័នដែលទទួលខុសត្រូវនៃប្រភេទសេវាកម្មទាំងប្រាំពីរខាងលើ ត្រូវតែរៀបចំនិងចងក្រងបញ្ជីរសេវាកម្មទាំងនេះឱ្យបានល្អ។ ក្នុងករណីមានការរីកចំរើនខ្លះក្នុងសេដ្ឋកិច្ចទីផ្សា បច្ចេកវិជ្ជាទំនើប និងតម្រូវការជាក់ស្តែង ជាលទ្ធផលនៃចលនាវិវត្តន៏របស់សង្គម សេវាកម្មសាធារណៈទាំងនេះ នឹងត្រូវកំណត់ឡើងវិញដែលបណ្តាលមកពីការវិវត្តន៏នោះ។ ការផ្តល់គ្រប់ប្រភេទនូវសេវាកម្មសាធារណៈដោយមិនគិតពីយន្តការ ទីកន្លែង និងកាលៈទេសៈត្រូវតែប្រុងប្រយត្ន័ ចំពោះវិធីដែលគាំទ្រការអាចទទួលយករបស់អ្នកក្រីក្រ ជនពិការ ចាស់ជរា និងក្មេងៗទាំងនៅទីក្រុង និងជនបទ។

## គោលបំណង និង វិធីសាស្ត្រ

### គោលបំណង ៖

គោលបំណងជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការផ្តល់សេវាកម្មសាធារណៈ គឺ "ដើម្បីបំរើប្រជាជនឱ្យកាន់តែល្អប្រសើរ" ។ នេះមានន័យថា រដ្ឋបាលសាធារណៈត្រូវតែ ៖

### 1. ការអាចទទួលយកបានចំពោះសេវាកម្ម

ផ្តល់នូវព័ត៌មានគ្រប់គ្រាន់ ច្បាស់លាស់ និងអាចយល់បាន។ កាត់បន្ថយការិយាល័យធិប្បតេយ្យ និងរដ្ឋាករ ក្នុងបំណងកាត់បន្ថយការលំបាកដល់អ្នកប្រើប្រាស់សេវាកម្មក្នុងការស្វែងរកសេវាកម្មដោយខ្លួនគេ និងការកាត់បន្ថយការបង់ប្រាក់បន្ថែមសំរាប់ដំណើរប្រតិបត្តិក្រៅផ្លូវការ។

### 2. ការផ្តោតលើតម្រូវការជាក់ស្តែងនៃអ្នកប្រើប្រាស់សេវាកម្ម

នៅក្នុងអតីតកាល មន្ត្រីរាជការស៊ីវិល ដូចជាអ្នករដ្ឋបាល ត្រូវបានកំណត់ជាមុននូវប្រភេទសេវាកម្មដែលបានផ្តល់ទៅឱ្យអ្នកប្រើប្រាស់ ទោះយ៉ាងនេះក្តី សេវាកម្មខ្លះមិនបានបំពេញទៅតាមតម្រូវការរបស់ពួកគេទាំងអស់នោះទេ។ ឥឡូវនេះ ក្នុងនាមជាអ្នកផ្តល់សេវាកម្ម មន្ត្រីរាជការស៊ីវិលត្រូវតែផ្លាស់ប្តូរឥរិយាបទការងារ និងកំណត់ប្រភេទសេវាកម្មដោយផ្អែកលើតម្រូវការរបស់អ្នកប្រើប្រាស់ និងទីផ្សារ។

### 3. សេវាកម្មទូលំទូលាយដល់ទីកន្លែងដែលចាំបាច់

រដ្ឋបាលសាធារណៈ ត្រូវតែផ្តល់សេវាកម្មទៅទីកន្លែងណាដែលពួកគេត្រូវការ លើកលែងតែក្នុងករណីដែលពួកគេមិនអាចធ្វើទៅបាន។ ឧទាហរណ៍ សេវាកម្មឯកទេសដែលមានតំលៃខ្ពស់ផ្តល់នូវការវះកាត់បេះដូង ដែលអាចធ្វើទៅបានតែនៅពីរបីកន្លែង អាចនិយាយបានថាមានតែនៅទីក្រុងភ្នំពេញ។ ចំពោះបញ្ហាទូទៅ រដ្ឋបាលសាធារណៈគួរតែយកប្រជាពលរដ្ឋជាមូលដ្ឋានសំរាប់ការផ្តល់សេវាកម្ម។ ឧទាហរណ៍ប្រជាពលរដ្ឋត្រូវការប្រភេទសេវាកម្មមួយណា នៅទីកន្លែងខ្លះ នោះរដ្ឋបាលគួរតែកំណត់ប្រភេទសេវាកម្មទាំងនោះ ដើម្បីផ្តល់ឱ្យដល់ទីកន្លែងនោះ។ នោះគឺអាចជៀសវាងការដើរស្វែងរកនូវសេវាកម្មដែលនៅឆ្ងាយពីសហគមន៍របស់ពួកគេ។

### 4. ការផ្តល់សេវាកម្មដែលមានតម្លាភាព និងការទទួលខុសត្រូវ

អ្នកផ្តល់សេវាកម្មត្រូវតែផ្តល់រាល់ព័ត៌មានដោយចំហនិងគ្រប់ជ្រុងជ្រោយ ដោយមិនរើសអើងពូជសាសន៍ និងផ្តោតទៅលើគុណភាពនៃការផ្តល់ឱ្យទាន់ពេលវេលាជាមួយនឹងការទទួលខុសត្រូវខ្ពស់។ អ្នកផ្តល់សេវាកម្ម ត្រូវតែផ្តល់ព័ត៌មាននិងឱកាស ដើម្បីត្រួតពិនិត្យ និងយល់ដឹងពីនិតិវិធី រិះគន់ និងត្អូញត្អែរ ឬស្វែងរកការកែលំអចំពោះការផ្តល់សេវាកម្ម ដើម្បីឆ្លើយតបនូវតម្រូវការរបស់ពួកគេ និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធផល ប្រសិទ្ធិភាព និងតម្លាភាព ដូច្នេះគឺប្រកាន់ខ្ជាប់នូវគោលការណ៍អភិបាលកិច្ចល្អ។

## 5. គុណភាព ប្រសិទ្ធិផល និងប្រសិទ្ធិភាពនៃសេវាកម្ម

អ្នកផ្តល់សេវាកម្មត្រូវតែឆ្លើយតបទៅនឹងបទដ្ឋានសេវាកម្មដែលបានកំណត់។ នេះមានន័យថា អ្វីដែលបានផ្តល់ដល់អ្នកប្រើប្រាស់ត្រូវអនុលោមទៅតាមបទដ្ឋានតំលៃ ពេលវេលា និងគុណភាព។ គុណភាពសេវាកម្មត្រូវបានកំណត់ដោយផ្អែកទៅលើការពេញចិត្តរបស់អ្នកប្រើប្រាស់ ទីកន្លែងដែលសេវាកម្មឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍សាធារណៈរបស់អ្នកប្រើប្រាស់។ បើសិនរដ្ឋបាលសាធារណៈមិនអាចផ្តល់ ឬលៃលកបង្កើតនូវសេវាកម្មនេះទេ រដ្ឋអាចស្វែងរកដៃគូរអភិវឌ្ឍន៍ ដែលអាចជួយផ្តល់ដល់តម្រូវការរបស់អ្នកប្រើប្រាស់។

### វិធីសាស្ត្រ

ដើម្បីសំរេចគោលបំណងដែលបានលើកឡើងខាងលើ មានយុទ្ធសាស្ត្រធំពីរ សំរាប់ដំណើរការប្រតិបត្តិ :

**ទីមួយ** គឺផ្លាស់ប្តូរអាកប្បកិរិយា និងឥរិយាបទការងាររបស់សេវាកម្មស៊ីវិលពីរដ្ឋបាលទៅជាអ្នកផ្តល់សេវា។ នេះគឺជាចំណុចសំខាន់ ពីព្រោះដោយហេតុថាមានគំរូល្អ និងទម្រង់ការល្អ សំរាប់អនុវត្ត បើសិនជាមន្ត្រីរាជការស៊ីវិលមិនចង់ផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគេ នោះគុណភាពនៃការផ្តល់សេវាកម្មមិនអាចនាំមកនូវផលល្អ និងប្រសិទ្ធិភាពបានទេ។ អ្នកផ្តល់សេវាកម្មត្រូវមានឥរិយាបទល្អ ដើម្បីបំរើអ្នកប្រើប្រាស់ដោយរួមបញ្ចូលទាំងការប្រើប្រាស់ពាក្យសំដី និងអាកប្បកិរិយាទំនាក់ទំនងការងារទូទៅ។ ដើម្បីផ្តល់សេវាកម្មប្រកបដោយគុណភាព ប្រសិទ្ធិផល និងប្រសិទ្ធិភាព ជាតំបូងទាមទារឱ្យមន្ត្រីរាជការស៊ីវិលមានការយល់ដឹងច្បាស់លាស់ អំពីគោលទស្សនៈរបស់ "អ្នកផ្តល់សេវាកម្ម" និង "អ្នកប្រើប្រាស់សេវាកម្ម" ដូចនេះគឺអាចផ្លាស់ប្តូរវិធីសាស្ត្រនៃការគិតគូរដែលមានគោលបំណងកាត់បន្ថយការិយាល័យធិប្បតេយ្យ និងរដ្ឋការក្នុងការផ្តល់សេវាកម្ម។ ការផ្លាស់ប្តូរវិធីគិតគូរនិងអាកប្បកិរិយារបស់មន្ត្រីរាជការស៊ីវិល ឱ្យចេញឆ្ងាយពីបញ្ហាទាំងនេះដែលបានចាក់ឫសយ៉ាងជ្រៅទៅក្នុងគោលគំនិតជា**អ្នករដ្ឋបាល** គឺទាមទាររយៈពេលវេលាយូរសមល្មមមួយ។

**ទីពីរ** គឺការផ្លាស់ប្តូរដំណើរការការងារពី "ទម្រង់ការមុខងារ" ទៅជា "ទម្រង់ការប្រតិបត្តិ"។ វិធីនេះគឺផ្តោតទៅលើការកែលំអឥរិយាបទការងារនៅក្នុងរដ្ឋបាលសាធារណៈឆ្ពោះទៅរកលទ្ធផលល្អ។ បច្ចុប្បន្នឥរិយាបទការងារនៅក្នុងទម្រង់ការមុខងារអនុលោមទៅតាមនិតិវិធី និងបទបញ្ជាដែលបានកំណត់ដោយគ្មានការគិតគូរពីលទ្ធផល ប្រសិទ្ធផល និងប្រសិទ្ធភាព និងការពេញចិត្តរបស់អ្នកប្រើប្រាស់សេវាកម្ម។ រចនាសម្ពន្ធ័ប្រតិបត្តិការណ៍ត្រូវបានគេអនុវត្តទៅតាមគោលទស្សនៈពីរ គឺ "ការិយាល័យជួរមុខ" និង "ការិយាល័យជួរក្រោយ"។

## ***ការិយាល័យជួរមុខ***

ការិយាល័យជួរមុខទាក់ទងផ្ទាល់ជាមួយអ្នកប្រើប្រាស់។ ដើម្បីធ្វើឱ្យការិយាល័យជួរមុខមានសមត្ថភាពក្នុងការផ្តល់សេវាកម្មដល់ប្រជាជន និងអតិថិជន មន្ត្រីរាជការស៊ីវិល ឬភ្នាក់ងារដែលជួលឱ្យធ្វើការក្នុងផ្នែកនេះ ត្រូវតែមានសមត្ថភាព និងការយល់ដឹងល្អទាក់ទងទៅនឹងសេវាកម្មសាធារណៈ មានអាកប្បកិរិយាល្អ ផ្តោតអារម្មណ៍ទៅលើតម្រូវការរបស់អតិថិជន ហើយពន្យល់នូវចំណុចសំខាន់ៗនៃសេវាកម្មរបស់ពួកគេ ហើយអាចដោះស្រាយបញ្ហារបស់អ្នកប្រើប្រាស់។ ការិយាល័យជួរមុខ មានតួនាទីផ្តល់ព័ត៌មាន ពន្យល់រាល់ទម្រង់ការសំរាប់ការធ្វើលតកម្មនិងការផ្តល់សេវាកម្ម ការបញ្ជូនឯកសារឯកទេសសំខាន់ៗ ការទទួលប្រាក់ឈ្នួលសេវាកម្ម ហើយផ្តល់លទ្ធផលនិងសេចក្តីសំរេចចិត្ត ដែលទាក់ទងទៅនឹងសំណើរដែលបានចុះឈ្មោះដោយអ្នកប្រើប្រាស់។ កន្លែងដែលចាំបាច់ ការណែនាំនិងជំនួយបន្ថែម គួរតែបានផ្តល់ឱ្យនិងជួយបំពេញពាក្យស្នើសុំដល់អ្នកប្រើប្រាស់ ដែលមិនយល់ដឹងក្នុងការបំពេញបែបបទ ឬមិនអាចអាននិងសរសេរបាន។

## ***ការិយាល័យជួរក្រោយ***

ការិយាល័យជួរក្រោយជាកន្លែងសំខាន់ជួយគាំទ្រការជោគជ័យដល់ការិយាល័យជួរមុខ។ ការិយាល័យជួរក្រោយ មានតួនាទីពិនិត្យពាក្យស្នើសុំ និងឯកសារដទៃទៀត ការដាក់សំណើនិងបញ្ជូនឯកសារទាំងនោះទៅអ្នកដែលអាចសំរេច បន្ទាប់មកធ្វើត្រឡប់មកការិយាល័យជួរមុខវិញ។

អង្គភាពរបស់ការិយាល័យជួរមុខគួរតែផ្អែកលើកត្តាសំខាន់ប្រាំ :

- **ធនធានមនុស្ស**

  មន្ត្រីរាជការស៊ីវិលត្រូវតែយល់ដឹងអំពីគោលទស្សនថ្មី នៃការផ្តល់សេវាកម្មសាធារណៈឱ្យត្រូវទៅនឹងបទដ្ឋានគុណភាព ប្រសិទ្ធផល និងប្រសិទ្ធភាព ដោយការផ្លាស់ប្តូរឥរិយាបទ និងអាកប្បកិរិយាការងារ ពី "រដ្ឋបាល" ទៅជា "អ្នកផ្តល់សេវាកម្ម" ហើយពួកគេគួរតែទទួលការហ្វឹកហ្វឺនដើម្បីបង្កើនសមត្ថភាព ពង្រឹងវិជ្ជាជីវៈកម្ម និងបង្កើនចំណេះដឹង និងចំណេះធ្វើ។ ពួកគេគួរតែទទួលខុសត្រូវក្នុងការផ្តល់សេវាកម្មដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សា។ ក្នុងបរិបទនៃការគ្រប់

គ្រប់គ្រងធនធានមនុស្ស អាទិភាពគួរតែផ្តល់ឱ្យមន្ត្រីរាជការស៊ីវិលណាដែលសំរេចបាននូវស្នាដៃល្អ ក្នុងការតំឡើងឋានៈ ការផ្តល់មេដាយ និងគ្រឿងលើកទឹកចិត្តដទៃទៀត ។

- ❑ **ធនធានហិរញ្ញវត្ថុ**

ធនធានហិរញ្ញវត្ថុគួរតែអនុលោមទៅតាមផែនការការងារ និងសកម្មភាពប្រចាំឆ្នាំនៃវិស័យនិមួយៗ លើសពីនេះ ប្រតិបត្តិការណ៍សាច់ប្រាក់គួរតែប្រព្រឹត្តិទៅតាមពេលវេលាដែលបានកំណត់ ។

- ❑ **ផែនការ**

ការិយាល័យជួរក្រោយគួរបង្កើតផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិការណ៍ សំរាប់ការផ្តល់សេវាកម្ម ប្រកបដោយប្រសិទ្ធផល ប្រសិទ្ធភាព គុណភាព និងទាន់ពេលវេលា។ ផែនការរួមមាន : ផែនការការងារ ផែនការសកម្មភាព ផែនការថវិការ ផែនការហិរញ្ញវត្ថុ លទ្ធផលរំពឹងទុក និងការប៉ាន់ប្រមាណពីហានិភ័យ ។

- ❑ **សវនកម្ម និង ការវាយតំលៃ**

ការអនុវត្តផែនការសកម្មភាពដើម្បីការផ្តល់សេវាកម្មសាធារណៈ ត្រូវបានរៀបចំ ត្រួតពិនិត្យ វាយតំលៃ និងធ្វើសវនកម្ម ដើម្បីប្រៀបធៀបជាមួយនឹងលទ្ធផលរំពឹងទុក ដែលបានកំណត់នៅក្នុងផែនការសកម្មភាព ។

- ❑ **បច្ចេកវិជ្ជាទំនាក់ទំនងព័ត៌មាន ICT**

ការប្រើប្រាស់បច្ចេកវិជ្ជាទំនាក់ទំនងព័ត៌មាន គឺជាវិធីសាស្ត្រទំនើប សំរាប់ការផ្លាស់ប្តូរសំខាន់ៗ ក្នុងតំរិយាបទប្រាស្រ័យទាក់ទងរវាងប្រពន្ធ័រដ្ឋបាលសាធារណៈ និងអ្នកប្រើប្រាស់សេវាកម្ម។ បច្ចេកវិជ្ជាព័ត៌មាននិងប្រាស្រ័យទាក់ទង ត្រូវបានគេប្រើប្រាស់ ដើម្បីកាត់បន្ថយការិយាល័យធិប្បតេយ្យ និងការចំណាយពេល បង្កើនតម្លាភាព ប្រសិទ្ធភាព និងប្រសិទ្ធផល ហើយដើម្បីធ្វើឱ្យប្រាកដថា ងាយទទួលយកព័ត៌មាន និងទីតាំ ពេលវេលានៃសេវាកម្មដែលត្រូវការ ។

ដោយសង្ខេប គួរតែមានអន្តរអំពើដ៏រលូនរវាងប្រតិបត្តិការណ៍ការិយាល័យជួរមុខនិងការិយាល័យជួរក្រោយ ដែលត្រូវបានសម្របសម្រួលនៅគ្រប់តំណាក់កាល ដើម្បីសំរេចបាននូវគោលបំណងពិតប្រាកដ : "ការបំរើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង" ។

## យន្តការនៃប្រតិបត្តិការណ៍

យន្តការប្រតិបត្តិការណ៍បានគូសបញ្ជាក់គោលបំណងសំខាន់ៗ ដូចខាងខាងក្រោម ក្នុងការសម្របសម្រួលការងាររបស់ក្រសួង ឬស្ថាប័នដើម្បីកែលំអនិងបង្កើតនូវបទដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តនៃយន្តការ គឺអាស្រ័យទៅតាមកាលៈទេសៈ និងស្ថានភាពជាក់ស្តែង នៅក្នុងប្រព័ន្ធរដ្ឋបាលសាធារណៈរបស់

ប្រទេសកម្ពុជា។ ជោគជ័យនៃការផ្តល់សេវាកម្មសាធារណៈ គឺផ្អែកទៅលើដំណើរការនិងយន្តការ ការកំណត់ពេលវេលានៃការអនុវត្ត និងតំលៃសំរាប់សេវាកម្មដែលផ្តល់ដល់ប្រជាពលរដ្ឋ។ យន្តការទាំងឡាយខាងក្រោម អាចធ្វើទៅបានដើម្បីការផ្តល់សេវាកម្មសាធារណៈ។

## ការកែលំអដំណើរការនៃការផ្តល់សេវាកម្មសាធារណៈ

ដំណើរការកែលំអនៃការផ្តល់សេវាកម្ម គឺជាយន្តការសំខាន់មួយដើម្បីកែលំអការផ្តល់សេវាកម្មសាធារណៈ។ ការងារនេះត្រូវបានធ្វើក្នុងក្រសួង ឬស្ថាប័ន និងទីភ្នាក់ងាររដ្ឋ ដោយលប់បំបាត់ចោលនូវការងារត្រួតស៊ីគ្នា ឬជម្រះចោលនូវភាពមិនច្បាស់លាស់នៃការងារនិងទម្រង់ការ។ ការផ្តោតយកចិត្តទុកដាក់ គួរតែធ្វើការទៅលើទម្រង់ការ និងដំណើរការការងារ ពេលវេលាដែលប្រើប្រាស់ ថ្លៃសេវាកម្ម ប្រសិទ្ធផលនិងប្រសិទ្ធភាពព្រមទាំងគុណភាពនៃសេវាកម្មសាធារណៈ និងការជឿជាក់។

## ការិយាល័យច្រកចេញចូលតែមួយ (One Window Office)

ការិយាល័យបង្អួចមួយ គឺជាយន្តការសំរាប់ការផ្តល់សេវាកម្មសាធារណៈដែលសម្របសម្រួលការទទួលយករបស់ប្រជាពលរដ្ឋចំពោះសេវាកម្មឆ្លងកាត់តាមទម្រង់ការសាមញ្ញ តម្លាភាព ប្រសិទ្ធផល ប្រសិទ្ធិភាព និងការទទួលយកគោលទស្សនៈនិងតម្រូវការរបស់អ្នកប្រើប្រាស់។ យន្តការនេះប្រមូលផ្តុំសេវាកម្មសាធារណៈ និងផ្តល់ច្រកចូលនៅមួយកន្លែងសំរាប់ការដាក់ស្នើសុំ និងទទួលសេវាកម្ម ដោយកំណត់បទដ្ឋានពេលវេលាសំរាប់ការប្រើប្រាស់ ការផ្តល់សេវាកម្ម និងការកំណត់ថ្លៃជាក់លាក់សំរាប់សេវាកម្ម។ ការអនុវត្តល្អគឺបានរៀនសូតពីការប្រតិបត្តិពីពេលមុន ដែលត្រូវបានប្រើជាគំរូមួយសំរាប់ការធ្វើជាថ្មីទូទាំងប្រទេស។ ការិយាល័យបង្អួចមួយ គួរតែរៀបចំការបែងចែកតួនាទីឱ្យបានច្បាស់លាស់ មុខងារ និងសមត្ថភាពប្រកួតប្រជែង។ ការចាត់ចែង មុខងារ គ្រោងការ គោលការណ៍ ទម្រង់ការ និងរចនាសម្ព័ន្ធការិយាល័យបង្អួចមួយ ដោយផ្អែកទៅលើការសំរេចចិត្តរបស់រដ្ឋាភិបាល។

## វិសហមជ្ឈការសេវាកម្មសាធារណៈ

ការចាត់ចែងប្រព័ន្ធរដ្ឋបាលសាធារណៈ គឺជាកិច្ចការជាយុទ្ធសាស្ត្រនិងជាអាទិភាព ដែលបានចែងនៅក្នុងគ្រោងការយុទ្ធសាស្ត្រស្តីអំពីវិមជ្ឈការនិងវិសហមជ្ឈការ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល នាសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី ១៧ មិថុនា ឆ្នាំ ២០០៥។ ទោះជាយ៉ាងណាក៏ដោយ " វិសហមជ្ឈការ " នៅក្នុងគោលនយោបាយនេះ បានកំណត់សេវាកម្មសាធារណៈ និងការផ្តល់សេវាកម្មសាធារណៈលំដាប់ថ្នាក់ក្រោមជាតិ ឆ្លងកាត់ប្រព័ន្ធរដ្ឋបាលរួមគ្នា។ ប្រព័ន្ធរដ្ឋបាលរួមនៃសាលាខេត្ត-ក្រុង និងស្រុក-

ខ័ណ្ឌ និងជួយសម្របសម្រួលសកម្មភាពរដ្ឋបាលសាធារណៈទាំងអស់ ក្នុងដែនដីរៀងៗខ្លួន ជាមួយទស្សនៈ ដើម្បីលើកទឹកចិត្តការអភិវឌ្ឍ និងការផ្តល់សេវាកម្មក្នុងការឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋ។

## វិមជ្ឈការសេវាកម្មសាធារណៈ

ដូចបានចែងនៅក្នុងច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ប្រកាសឱ្យប្រើដោយព្រះរាជក្រម RK/0301/05 ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០១ រដ្ឋបាលឃុំ-សង្កាត់មានតួនាទីពីរ ដែលត្រូវបំពេញ :

១. គ្រប់គ្រងកិច្ចការនៅមូលដ្ឋាន ដើម្បីបំរើផលប្រយោជន៍របស់ឃុំ-សង្កាត់ និងប្រជាពលរដ្ឋរបស់ឃុំ-សង្កាត់នោះ។

២. ដំណើរការជាភ្នាក់ងាររដ្ឋក្រោមការចាត់តាំង ឬផ្ទេរសិទ្ធិអំណាចរបស់អាជ្ញាធរថ្នាក់រដ្ឋ។

មាត្រា ៤៣ និង៤៤ នៃច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ចែងថា ភារកិច្ចរបស់ឃុំ-សង្កាត់ក្នុងការបំពេញតួនាទីទាំងពីរខាងលើ។ ឃុំ-សង្កាត់ត្រូវតែចាត់ចែងការផ្តល់សេវាកម្មសាធារណៈបន្តិចម្តងៗ។ ការងារនេះគួរតែផ្អែកទៅលើស្ថានភាពជាក់ស្តែងនៃការអភិវឌ្ឍសេដ្ឋកិច្ច និងតម្រូវការរបស់អ្នកប្រើប្រាស់។

## គ្រឹះស្ថានសាធារណៈដែលមានចរិតលក្ខណៈរដ្ឋបាល

គ្រឹះស្ថានសាធារណៈដែលមានចរិតលក្ខណៈរដ្ឋបាល គឺជាទម្រង់មួយផ្សេងទៀតនៃយន្តការសំរាប់ការផ្តល់សេវាកម្មសាធារណៈ។ ទាំងនេះ គឺជាស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុដែលបានឯកភាព និងជានីតិបុគ្គលក្រោមច្បាប់នេះ ដែលទទួលខុសត្រូវចំបង ចំពោះការផ្តល់សេវាកម្មរដ្ឋបាល សង្គម សុខភាព វប្បធម៌ វិទ្យាសាស្ត្រ ឬសេវាបច្ចេកទេស។

ដូច្នេះ ស្ថាប័នសាធារណៈបែបនេះ ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម :

១. នាមរបស់ស្ថាប័ន និងការិយាល័យ

២. គោលបំណងនៃសកម្មភាព (សេចក្តីថ្លែងនៃបេសកកម្ម)

៣. ក្រុមប្រឹក្សាភិបាលដែលដឹកនាំ និងគ្រប់គ្រងប្រតិបត្តិការណ៍ដោយប្រើរបៀបនៃការគ្រប់គ្រងរបស់ខ្លួន

៤. ថវិកាខ្លួនឯង

៥. ធនធានសំរាប់អនុវត្តសកម្មភាពដែលបានគ្រោងទុកក្នុងសេចក្តីថ្លែងនៃបេសកកម្ម
៦. សមត្ថភាពដើម្បីចុះហត្ថលេខា និងអាចពាំនាំវិវាទ ឬការការពារក្តីនៅក្នុងតុលាការ
៧. ទទួលខុសត្រូវក្រោមច្បាប់រដ្ឋប្បវេណី និងច្បាប់ព្រហ្មទ័ណ្ឌដើម្បីសកម្មភាពរបស់តំណាងស្របច្បាប់ ឬនិយោជិតរបស់ពួកគេដែលកំពុងធ្វើការសំរាប់ស្ថាប័ននោះ។

គ្រឹះស្ថានសាធារណៈដែលមានចរិតលក្ខណៈរដ្ឋបាលត្រូវបានបង្កើតដោយអនុក្រិត ដោយអនុលោមទៅតាមសំណើរួមរបស់ក្រសួង ឬអាជ្ញាធរអភិរក្សបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ គ្រឹះស្ថានសាធារណៈ ត្រូវតែកំណត់ជាពិសេសនូវបេសកកម្ម អភ័យឯកសិទ្ធិ កាតព្វកិច្ច សមាសភាពនៃក្រុមប្រឹក្សាភិបាលនាយក និងបទវិន័យពិសេសសំរាប់ការប្រតិបត្តិការងារគ្រប់គ្រង និងត្រួតពិនិត្យគ្រឹះស្ថាន ហើយត្រូវតែកំណត់ក្រសួងអភិរក្សនោះ ឬអាជ្ញាធរនោះ។ លក្ខខណ្ឌ និងគោលការណ៍ក្នុងការបង្កើតគ្រឹះស្ថានសាធារណៈមានចរិតលក្ខណៈរដ្ឋបាល ត្រូវអនុលោមទៅតាមព្រះរាជក្រឹត្យ ន ស រ ក ត ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីអំពីលក្ខន្តិកៈនៃការបង្កើតគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈរដ្ឋបាល។

## សហគ្រាសសាធារណៈ

សហគ្រាសសាធារណៈ គឺជាផ្នែកមួយនៃយន្តការក្នុងការផ្តល់សេវាកម្មដែលអនុវត្តដោយរដ្ឋ ហើយត្រូវបានបង្កើតឡើងក្រោមច្បាប់ស្តីពីនីតិឯកជននិងនីតិសាធារណៈ។ វាជាអង្គភាពឯករាជ្យផ្នែកហិរញ្ញវត្ថុស្របច្បាប់មួយ ហើយមូលធនភាគច្រើន ឬទាំងអស់ជារបស់រដ្ឋ។ បេសកកម្មរបស់សហគ្រាសសាធារណៈ គឺដើម្បីលើកកំពស់សេដ្ឋកិច្ចរបស់ប្រទេស និងការអភិវឌ្ឍសង្គម ពោលគឺតាមរយៈការបង្កើនតំលៃធនធានធម្មជាតិ និងការបង្កើតការងារ។

សហគ្រាសសាធារណៈមានទម្រង់ដូចខាងក្រោម :

១. គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច
២. ក្រុមហ៊ុនរបស់រដ្ឋ
៣. ការចូលហ៊ុនគ្នាដែលនៅក្នុងនោះរដ្ឋត្រូវមានដើមទុនដោយផ្ទាល់ ឬដោយប្រយោល ឬមានសិទ្ធិបោះឆ្នោត លើសពី៥១%

សហគ្រាសសាធារណៈត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវផ្នែកបច្ចេកទេសរបស់ក្រសួង ឬអាជ្ញាធរសាធារណៈ ដោយយោងទៅតាមប្រភេទនៃសកម្មភាពរបស់សហគ្រាស។

### ១. គ្រឹះស្ថានសាធារណៈដែលមានចរិតសេដ្ឋកិច្ច

គ្រឹះស្ថានសាធារណៈដែលមានចរិតសេដ្ឋកិច្ច គឺជាអង្គភាពស្របច្បាប់ដែលស្ថិតនៅក្រោមនីតិសាធារណៈ ហើយមានឯករាជ្យភាពហិរញ្ញវត្ថុ។ ស្ថាប័នទាំងនេះផលិតទំនិញ ឬលក់សេវាកម្មនៅលើទីផ្សារ។ គ្រឹះស្ថានសាធារណៈដែលមានចរិតសេដ្ឋកិច្ចត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ ហើយមានសំណើរួមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាជ្ញាធរ ឬស្រួងដែលមានភារៈទទួលខុសត្រូវ។ អនុក្រឹត្យបានកំណត់ការទទួលខុសត្រូវ មូលធន អាជ្ញាធរ ឬក្រសួងដែលមានភារៈទទួលខុសត្រូវ សមាសភាពក្រុមប្រឹក្សានាយកការគ្រប់គ្រងរដ្ឋបាលនិងហិរញ្ញវត្ថុ និងវិធានប្រតិបត្តិរបស់គ្រឹះស្ថាន។

## ២. ក្រុមហ៊ុនរបស់រដ្ឋ

ក្រុមហ៊ុនរបស់រដ្ឋ គឺជាក្រុមហ៊ុនមួយដែលមូលធនទាំងអស់ជារបស់រដ្ឋ។ ក្រុមហ៊ុនរបស់រដ្ឋ គឺជាយន្តការមួយសំរាប់ផ្តល់សេវាសាធារណៈ។ ក្រុមហ៊ុននេះត្រូវប្រកួតប្រជែងនៅលើទីផ្សារ និងត្រូវប្រតិបត្តិដោយឯករាជ្យ។ ក្រុមហ៊ុនរបស់រដ្ឋត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ ហើយមានសំណើរួមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាជ្ញាធរ ឬស្រួងដែលមានភារៈទទួលខុសត្រូវ។ នៅក្នុងអនុក្រឹត្យនោះ បានបញ្ជាក់យ៉ាងច្បាស់ពីគោលបំណង និងជាអង្គភាពស្របច្បាប់ ជាអាជ្ញាធរ ឬក្រសួងដែលមានភារៈទទួលខុសត្រូវជាស្ថាប័នអនុវត្តនូវប្រព័ន្ធត្រួតពិនិត្យ និងមានសមាសភាពក្រុមប្រឹក្សានាយក។

អាជ្ញាធរ ឬក្រសួងដែលមានភារៈទទួលខុសត្រូវផ្នែកបច្ចេកទេស ត្រូវអនុវត្តនីតិវិធីរបស់គ្រឹះស្ថានឬក្រុមហ៊ុនដូចមានចែងខាងក្រោមនេះដើម្បីឱ្យបានជោគជ័យ :

- ❖ រៀបចំលក្ខន្តិកៈក្រុមហ៊ុនដោយមានកិច្ចព្រមព្រៀងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ❖ រៀបចំចុះបញ្ជីពាណិជ្ជកម្ម
- ❖ បំពេញគ្រប់ទម្រង់ទាំងអស់ដោយផ្អែកទៅតាមគោលការណ៍ និងនីតិវិធីទាំងឡាយដែលស្ថិតនៅក្រោមច្បាប់ស្តីពីក្រុមហ៊ុនពាណិជ្ជកម្ម

## ៣. ក្រុមហ៊ុនភាគហ៊ុនរួម (ការរកស៊ីរួមគ្នា)

ការចូលហ៊ុនរកស៊ីរួមគ្នា ត្រូវបានបង្កើតឡើងក្រោមគោលការណ៍ និងនីតិវិធីដែលបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងច្បាប់ទាក់ទងនឹងក្រុមហ៊ុនពាណិជ្ជកម្ម ដែលមូលធនសរុបជាកម្មសិទ្ធិរួមរបស់អង្គភាព ឬបុគ្គលស្របច្បាប់ និងអង្គភាពស្របច្បាប់របស់រដ្ឋ។ ប្រសិនបើមូលធន ឬសិទ្ធិបោះឆ្នោតលើសពី ៥១% ដែលបានមកពីផ្នែកសាធារណៈ ស្ថាប័នដែលបានចូលហ៊ុនគ្នានោះត្រូវបានចាត់ទុកថាជាសហគ្រាសសាធារណៈ ឬសហគ្រាសរបស់រដ្ឋ។

អ្នកតំណាងគ្រឹះស្ថានសាធារណៈ ឬគ្រឹះស្ថានរបស់រដ្ឋ ត្រូវបានតែងតាំងដោយរដ្ឋាភិបាលទៅតាមសំណើដែលធ្វើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការទទួលខុសត្រូវលើបំណុល របស់អ្នកតំណាងនៅក្នុងការបំពេញភារកិច្ចរបស់គេត្រូវធ្លាក់មកលើរដ្ឋ គ្រឹះស្ថានសាធារណៈ និងក្រុមហ៊ុនរបស់រដ្ឋ ប៉ុន្តែពួកគេត្រូវទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌដោយខ្លួនឯង។

លក្ខខណ្ឌ និងគោលការណ៍ក្នុងការបង្កើតសហគ្រាសសាធារណៈ ដែលមានទម្រង់ជាគ្រឹះស្ថានសាធារណៈដែលមានចរិតសេដ្ឋកិច្ច ក្រុមហ៊ុនរបស់រដ្ឋ ឬជាការចូលហ៊ុនគ្នាដែលរដ្ឋមានមូលធន ឬសិទ្ធិក្នុងការបោះឆ្នោតលើសពី ៥១% នោះត្រូវ អនុលោមទៅតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅរបស់សហគ្រាសសាធារណៈដែលត្រូវបានប្រកាសឱ្យប្រើដោយ ក្រម CS/RKM លេខ ០៦០៩ /០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ និងអនុក្រឹត្យ លេខ ៤១ ANKR.BK ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ១៩៩៧ លើការអនុវត្តក្រមស្តីពីលក្ខន្តិកៈទូទៅរបស់សហគ្រាស សាធារណៈ។

## ការចុះកិច្ចសន្យា

ការចុះកិច្ចសន្យា គឺជាយន្តការមួយសំរាប់ផ្តល់សេវាសាធារណៈ ដែលក្នុងនោះរដ្ឋមិនមានលទ្ធភាពចំណាយលើសេវាកម្មសាធារណៈ។ យន្តការក្នុងការចុះកិច្ចសន្យាគួរតែបង្ហាញលក្ខខណ្ឌការងារឱ្យបានច្បាស់ ដោយផ្អែកលើលទ្ធផលដែលរំពឹងទុក លក្ខខណ្ឌនៃការអនុវត្ត និងធនធានចាំបាច់ ដើម្បីជួយឱ្យដំណើការទាំងនេះកើតឡើង ការត្រួតពិនិត្យ និងវាយតំលៃ។ ភាគីក្នុងកិច្ចសន្យាត្រូវជួលមន្ត្រីរាជការនៅកន្លែងធ្វើការរបស់ខ្លួន ហើយផ្តល់ប្រាក់ឧបត្ថម្ភអាស្រ័យទៅតាមសមត្ថភាព ការទទួលខុសត្រូវ និងលទ្ធផលដែលសំរេចបាន។ ក្នុងករណីចាំបាច់ ភាគីក្នុងកិច្ចសន្យាអាចជួលបុគ្គលិកបន្ថែមទៀតក្រៅពីមន្ត្រីរាជការ ដើម្បីបំពេញតាមតម្រូវការដែលត្រូវការកម្លាំងបន្ថែម។ សេចក្តីសំរេចដើម្បីផ្តល់សេវាសាធារណៈតាមរយៈយន្តការនៃការចុះកិច្ចសន្យានេះ ត្រូវបានធ្វើឡើងដោយមានគំនិតផ្តួចផ្តើមពីស្ថាប័ន ឬក្រសួងពាក់ព័ន្ធ ហើយត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល។

## ទីភ្នាក់ងារប្រតិបត្តិការពិសេស

ផ្នែកគ្រប់គ្រង និងផ្នែកផ្តល់សេវាកម្មសាធារណៈតាមរយៈយន្តការរបស់ទីភ្នាក់ងារប្រតិបត្តិការពិសេស គឺជាគោលទស្សនៈថ្មីមួយ ដែលត្រូវការឱ្យមានការអភិវឌ្ឍន៍បន្ថែមទៀត។ ទីភ្នាក់ងារប្រតិបត្តិការពិសេសគឺជាអង្គភាពមួយរបស់ក្រសួង ឬស្ថាប័នដែលត្រូវបានតែងតាំង ដើម្បីធ្វើយ៉ាងណាសំរេចឱ្យបាននូវគោលបំណងសំខាន់របស់រាជរដ្ឋាភិបាល។ ទីភ្នាក់ងារនេះត្រូវបានបង្កើតឡើងក្រោមលក្ខខណ្ឌផ្សេងៗ ដើម្បីបំពេញបេសកកម្មរបស់ខ្លួនប្រកបដោយការអនុគ្រោះ និងមានការបត់បែនបំផុតនៅក្នុងអង្គភាព និង

ការបំពេញមុខងារ រួមបញ្ចូលទាំងការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ។ វាមានលក្ខណៈខុសប្លែកពីអង្គភាពដទៃទៀត សូម្បីតែនៅក្នុងស្ថាប័ន ឬក្រសួងក៏ដោយ។

គោលបំណងនៃការបង្កើតទីភ្នាក់ងារប្រតិបត្តិការពិសេសនេះ គឺដើម្បីលើកកំពស់ប្រសិទ្ធភាព និងប្រសិទ្ធផលការងារ ពង្រឹងការទទួលខុសត្រូវនិងជំរុញឱ្យមានគំនិតផ្តួចផ្តើម និងរិះរកអ្វីដែលថ្មី ដើម្បីកែលំអវប្បធម៌ឱ្យចេះផ្តោតការយកចិត្តទុកដាក់ចំពោះសេវាកម្មអតិថិជន។

លក្ខខណ្ឌរបស់បេសកកម្មដែលទីភ្នាក់ងារប្រតិបត្តិការពិសេសត្រូវអនុវត្តផ្អែកលើមូលដ្ឋាន ៤ យ៉ាងដូចខាងក្រោម :

១. ***ផ្តោតការយកចិត្តទុកដាក់ខ្លាំងទៅលើតម្រូវការនៃសេវាកម្មអតិថិជនតាមរយៈការកំណត់ប្រភេទគុណភាព និងតំលៃក្នុងការផ្តល់សេវាកម្មឱ្យបានច្បាស់***

២. ***ត្រូវកំណត់ឱ្យបានច្បាស់នូវលទ្ធផលដែលរំពឹងទុក និងធនធានចាំបាច់ទាំងអស់***

៣. ***ត្រូវកំណត់ឱ្យបានច្បាស់នូវអង្គភាព និងមុខងាររបស់ភ្នាក់ងារនេះ***

៤. ***ត្រូវកំណត់ឱ្យបានច្បាស់នូវយន្តការគ្រប់គ្រង ត្រួតពិនិត្យ និងវាយតំលៃ***

## ឯកជនភាវូបនីយកម្ម

ក្នុងករណីចាំបាច់ ឯកជនភាវូបនីយកម្មអាចត្រូវបានជ្រើសរើសជាយន្តការមួយសំរាប់សម្របសម្រួលជាមួយអតិថិជន និងការផ្តល់សេវាកម្ម។ ឯកជនភាវូបនីយកម្ម គួរអនុលោមទៅតាមបទបញ្ញត្តិដែលដាក់ចេញឱ្យប្រើប្រាស់និងផ្សព្វផ្សាយជាសាធារណៈ ទាក់ទងនឹងដំណើរការ និងការប្រតិបត្តិ។ ឯកជនភាវូបនីយកម្មត្រូវអនុវត្តទៅតាមសេចក្តីសំរេចរបស់រដ្ឋាភិបាល រួមជាមួយនឹងសំណើរបស់ស្ថាប័ន និងក្រសួងពាក់ព័ន្ធផ្សេងៗ។

## ការកែលំអក្របខ័ណ្ឌច្បាប់ និងការសម្របសម្រួលការប្រតិបត្តិ

### ការកែលំអក្របខ័ណ្ឌច្បាប់

ដើម្បីកែលំអសេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធិភាព និងជោគជ័យថែមទៀតនៅក្នុងការប្រតិបត្តិនោះ គួរតែកែលំអទម្រង់ការងារច្បាប់ដែលមានស្រាប់ ឬបង្កើតទម្រង់ការងារច្បាប់ថ្មី ដែលបង្ហាញពីតម្រូវការចាំបាច់ ។

ខាងក្រោមនេះ គឺជាភារកិច្ចដែលត្រូវបំពេញ :

- ត្រូវពិនិត្យមុខងារទាំងឡាយណាដែលត្រួតស៊ីគ្នា និងបដិវាទកម្មដែលរារាំង ឬនាំឱ្យមានភាពមិនច្បាស់លាស់ក្នុងការផ្តល់សេវាកម្មសាធារណៈ ហើយធ្វើយ៉ាងណាឱ្យនីតិវិធីនោះត្រូវគ្នា ដើម្បីឱ្យដំណើរការផ្តល់សេវានេះប្រព្រឹត្តទៅកាន់តែរលូនថែមទៀត ។
- ត្រូវសម្រួលនីតិវិធី និងបែបបទទាំងឡាយដែលស្មុគស្មាញឱ្យមានលក្ខណៈសាមញ្ញ
- ត្រូវកែសំរួលបទបញ្ញត្តិដែលមានស្រាប់ដើម្បីសម្របទៅតាមតម្រូវការជាក់ស្តែង
- ត្រូវបង្កើតបទបញ្ញត្តិថ្មីអនុលោមទៅតាមប្រភេទសេវាកម្មសាធារណៈ

នៅក្នុងការកែសម្រួលទម្រង់ការងារច្បាប់ដែលមានស្រាប់ ឬបង្កើតទម្រង់ការងារច្បាប់ថ្មី ស្ថាប័ន ឬក្រសួងពាក់ព័ន្ធទាំងអស់ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីធានាឱ្យមានការកែលំអទម្រង់ការងារច្បាប់ មានភាពប្រាកដប្រជា និងស្របទៅតាមគោលការណ៍ស្តីពីការផ្តល់សេវាកម្មសាធារណៈ ។

## ការសម្របសម្រួលការប្រតិបត្តិ

ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលត្រូវបានរដ្ឋាភិបាលផ្តល់ភារកិច្ច និងតួនាទីក្នុងការរិះរកគំនិតផ្តួចផ្តើមការសម្របសម្រួល ការជំរុញ និងអង្កេតតាមដានមើលបទពិសោធន៍ និងការប្រតិបត្តិផ្នែកបច្ចេកទេសដើម្បីធ្វើយ៉ាងណាឱ្យការអនុវត្តគោលការណ៍សេវាកម្មសាធារណៈនេះប្រកបដោយជោគជ័យ ។

ក្រសួង-ស្ថាប័ន និងអាជ្ញាធរខេត្ត-ក្រុង ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីឱ្យដំណើរការអនុវត្តន៍មានប្រសិទ្ធភាព ទទួលបានផ្លែផ្កា និងដោយជោគជ័យ ។ លើសពីនេះទៅទៀត ក្រសួង-ស្ថាប័ន និងអាជ្ញាធរខេត្ត-ក្រុង ត្រូវទទួលខុសត្រូវលើគុណភាព និងការផ្តល់សេវាកម្មសាធារណៈជាមួយនឹងសិទ្ធិសំរេចប្រកបដោយសមត្ថភាពខ្ពស់ ។ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងស្ថាប័ន-ក្រសួងនានា ត្រូវតែសហការគ្នាក្នុងការផ្សព្វផ្សាយគោលនយោបាយ និងបណ្តុះបណ្តាលមន្ត្រីរាជការឱ្យបានយល់ដឹងពីគោលនយោបាយនេះ ។ គោលនយោបាយនេះត្រូវតែដាក់ បញ្ចូលក្នុងកម្មវិធីសិក្សានៅសាលាភូមិន្ទរដ្ឋបាលផងដែរ ។

ដើម្បីអនុវត្តគោលនយោបាយផ្តល់សេវាកម្មសាធារណៈនេះឱ្យបានជោគជ័យ គឺតម្រូវឱ្យមានការចូលរួមយ៉ាងសកម្មពីស្ថាប័ន ឬក្រសួងនានា អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ សង្គមស៊ីវិល កងកម្លាំងប្រដាប់អាវុធ និងអ្នកពាក់ព័ន្ធទាំងអស់រួមទាំងដៃគូអភិវឌ្ឍន៍ប្រទេសកម្ពុជានាពេលកន្លងមក ដោយឈរលើទស្សនៈមួយ គឺដើម្បីបំរើផលប្រយោជន៍ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង។

## អត្ថន័យនៃពាក្យគន្លឹះ

| | |
|---|---|
| **គុណភាពល្អ :** | សំដៅទៅលើសេចក្តីពេញចិត្តក្នុងការផ្តល់សេវាកម្មដល់អតិថិជន នៅពេលសេវានោះអាចឆ្លើយតបទៅតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ (ដូចជា នីតិវិធី ពេលវេលា និងតំលៃ) និងតម្រូវការ និងការរំពឹងទុករបស់អ្នកប្រើប្រាស់។ |
| **តំលៃថោក :** | សំដៅទៅលើការចំណាយលើថ្លៃសេវាកម្ម ដែលបានកំណត់ក្នុងអត្រាសមស្របអនុលោមទៅតាមទីកន្លែង និងលទ្ធភាពចំណាយរបស់អ្នកប្រើប្រាស់។ |
| **រយៈពេលខ្លី :** | សំដៅទៅលើនីតិវិធីនៃការផ្តល់សេវាកម្ម តាមរយៈគំរោងប្រតិបត្តិដោយលុបបំបាត់នូវកិរិយាធិបតេយ្យដែលមិនចាំបាច់។ |
| **សាមញ្ញ :** | មានន័យថាជាលក្ខខណ្ឌទាំងឡាយ ដែលអ្នកប្រើប្រាស់សេវាកម្មស្វែងរកដើម្បីឱ្យយល់ពីរបៀបប្រើប្រាស់សេវាកម្មនោះ ទាំងទម្រង់បែបបទ និងនីតិវិធី។ |
| **អាចជឿជាក់បាន :** | ការផ្តល់សេវាកម្មត្រូវគោរពទៅតាមបទបញ្ញត្តិ និងនីតិវិធីដែលបានកំណត់ជាមុន ហើយដែលបានណែនាំជាសាធារណៈ។ ប្រសិនបើអ្នកផ្តល់សេវាកម្មប្រព្រឹត្តផ្ទុយពីអ្វីដែលរំពឹងទុកនោះ អតិថិជន ឬអ្នកប្រើប្រាស់ទាំងអស់នឹងត្រូវបាត់បង់ជំនឿទុកចិត្ត។ |
| **ការឆ្លើយតបទៅនឹងតម្រូវការ និងពេលវេលា :** | ប្រភេទសេវាកម្ម នីតិវិធី និងពេលវេលានៃការផ្តល់សេវាត្រូវបានកំណត់ដោយផ្អែកលើការទាមទារ ឬចង់បានរបស់អ្នកប្រើប្រាស់ដែលស្ថិតនៅក្រោមគំរោងអាទិភាព។ |
| **អាចទទួលយកបាន :** | អ្នកផ្តល់សេវាកម្មត្រូវផ្តល់ការសម្របសម្រួលដល់អ្នកប្រើប្រាស់សេវាកម្មតាមរយៈការប្រាស្រ័យទាក់ទង បែបផែន ឬការអនុវត្តនានា និងការទទួល |



## 2.3

## ការប្រឈមមុខចំបងៗក្នុងការផ្តល់សេវាកម្មសាធារណៈថ្នាក់មូលដ្ឋាន

ទោះបីជាមានសេវាកម្មសាធារណៈផ្សេងៗជាច្រើនត្រូវបានផ្តល់ជូននៅថ្នាក់ឃុំក៏ដោយ ការរៀបចំរបស់ស្ថាប័ន ដើម្បីផ្តល់សេវាកម្មទាំងនោះមិនបានធ្វើឱ្យគេយល់ច្បាស់នៅឡើយទេ ។ លើសពីនេះទៅទៀត ការចូលរួមដោយផ្ទាល់ពីក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងការផ្គត់ផ្គង់សេវាកម្មទាំងនោះមិនត្រូវបានគេមើលឃើញថាមានលក្ខណៈជាប្រព័ន្ធនោះទេ ។ មេរៀនជាច្រើន ដែលបានមកពីការស្រាវជ្រាវស្តីពីការផ្តល់សេវាកម្មថ្នាក់មូលដ្ឋាន និងតួនាទីរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់បានបង្ហាញឱ្យឃើញថា ការផ្តល់សេវាកម្មថ្នាក់មូលដ្ឋានអាចមានលក្ខណៈល្អប្រសើរជាងមុន តាមរយៈការចូលរួមរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ មានប្រសិទ្ធភាពច្រើនជាងមុន ។ ការផ្តល់សេវាកម្មសាធារណៈថ្នាក់មូលដ្ឋានប្រកបដោយប្រសិទ្ធភាពមួយបែបទៀត នោះគឺការទាមទារឱ្យមានការចូលរួមពីផ្នែកពាក់ព័ន្ធនានា រួមទាំងការធ្វើផែនការ ការធ្វើគំរោងថវិកា ការផ្តល់ហិរញ្ញវត្ថុ ផលិតកម្ម និងការត្រួតពិនិត្យ និងការវាយតំលៃ ។ ទាំងអ្នកមានតម្រូវការ និងទាំងអ្នកផ្គត់ផ្គង់ ទាមទារឱ្យមានសេវាកម្មសាធារណៈនេះ ។ គេបានបង្ហាញឱ្យឃើញថា តម្រូវការរបស់អ្នកប្រើប្រាស់ផ្សេងៗត្រូវបានកំណត់ជារួម ជាជាងឱ្យបុគ្គលម្នាក់ៗបង្ហាញពីតម្រូវការរបស់ពួកគេចំពោះសេវាកម្មសាធារណៈនោះ ។ តួនាទីមួយដែលអាជ្ញាធរមូលដ្ឋានអាចបង្ហាញនៅក្នុងដំណើរការនេះ គឺត្រូវប្រមូលផ្តុំតម្រូវការសេវាកម្មសាធារណៈទាំងអស់របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ពីព្រោះអាជ្ញាធរមូលដ្ឋានមានភាពជិតស្និទ្ធជាមួយប្រជាពលរដ្ឋជាងថ្នាក់ខេត្ត ឬថ្នាក់មជ្ឈឹម ដូច្នេះពួកគេអាច ប៉ាន់ប្រមាណតម្រូវការរបស់ប្រជាពលរដ្ឋមានប្រសិទ្ធភាពជាង ។

ការប្រឈមមុខចំបងៗ ដែលទាក់ទងនឹងសេវាកម្មសាធារណៈបង្ហាញជាសង្ខេបដូចខាងក្រោម :

- ❑ មានកង្វះខាតជាទូទៅក្នុងការអះអាង ឬបង្ហាញឱ្យបានលំអិតនូវអ្វីដែលជាភារកិច្ចជំរើស និងអ្វីដែលជាភារកិច្ចចាំបាច់ក្នុងការផ្តល់សេវាកម្ម ។ ចំណុចនេះបានបង្ហាញពីផលប៉ះពាល់អវិជ្ជមានចំពោះការទទួលខុសត្រូវ និងលទ្ធភាពបង្កើតទំនាក់ទំនងរវាងមុខងារ និងការរៀបចំមូលនិធិ ។

- មានផលវិបាកសំរាប់អាជ្ញាធរតាមលំដាប់ថ្នាក់នីមួយៗក្នុងការឆ្លើយតប និងផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធផលដល់ផ្នែកផ្សេងៗគ្នាទាំងទំហំ និងសមត្ថភាពផ្តល់សេវាកម្មរបស់ក្រុមនីមួយៗ ។
- អាជ្ញាធរថ្នាក់ខេត្តពុំមានរង្វាន់លើកទឹកចិត្តដើម្បីអភិវឌ្ឍកម្មវិធី-គម្រោងអភិវឌ្ឍន៍ឱ្យបានល្អនោះទេ ដោយកង្វះខាតមូលនិធិ ។ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈថ្នាក់ខេត្តពឹងផ្អែកលើហិរញ្ញវត្ថុ និងគំរោងថៃទាំតាមផ្នែកនានារបស់រដ្ឋាភិបាលថ្នាក់មជ្ឈឹមតែប៉ុណ្ណោះ ។ គម្រោងផ្តល់សេវាកម្មសាធារណៈដែលមានតម្លាភាព និងបានអនុម័តរួចហើយនោះលែងមានតទៅទៀតហើយ ។
- ប្រព័ន្ធផ្ទេរសេវាកម្ម និងប្រព័ន្ធផ្តល់សេវាកម្មបែបមជ្ឈការមិនទាន់បំពេញតម្រូវការឱ្យបានគ្រប់គ្រាន់ ហើយការងារអាទិភាពនានាក្នុងមូលដ្ឋាន ភាពបត់បែន និងការកែតម្រូវផ្សេងៗមិនត្រូវ បានធានានៅឡើយ ។
- មានផលវិបាកក្នុងការវិនិច្ឆ័យគុណភាពនៃការផ្តល់សេវាកម្ម ហើយពេលខ្លះមិនអាចទទួលយកបាន ។ ប្រព័ន្ធត្រួតពិនិត្យការបំពេញការងារនៅមានកំរិតខ្សោយនៅឡើយ ។
- ការចំណាយក្រៅផ្លូវការផ្សេងៗក្លាយទៅជារឿងសាមញ្ញទៅហើយនៅតាមផ្នែកមួយចំនួន ។ ត្រូវតែមានការបញ្ជាក់ឱ្យបានច្បាស់នូវតំបន់ និងផ្នែកទាំងឡាយដែលត្រូវធ្វើការចំណាយទៅលើទាំងផ្លូវការ និងមិនផ្លូវការ និងបញ្ជាក់ឱ្យបានច្បាស់ពីទីកន្លែងដែលសេវាកម្មត្រូវបានផ្តល់ជូនដោយមិនគិតកំរៃ ។


LPP

# ម៉ូឌុលទី ៣

# អ្វីទៅជា កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន

## គោលបំណងរបស់ម៉ូឌុល

ដើម្បីឱ្យសិក្ខាកាមយល់ច្បាស់ថាតើកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានជាអ្វី ដែលធ្វើឱ្យពួកគេរួមសហការគ្នាក្នុងកំឡុងពេលអនុវត្តការងារ ។

## ការរំពឹងទុករបស់ម៉ូឌុល

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងយល់ដឹងពីមូលដ្ឋានគ្រឹះស្តីពី :

- ហេតុផល និងបទបញ្ញត្តិច្បាប់ស្តីពីការទទួលខុសត្រូវក្នុងសង្គម និងការផ្តល់សេវាកម្មសំខាន់ៗថ្នាក់ឃុំ
- កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានជាអ្វី? តើវាផ្តល់នូវអ្វីខ្លះ? តើត្រូវធ្វើអ្វីខ្លះក្រោយពីកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាននេះ?
- គោលទស្សនៈនិងយុទ្ធសាស្ត្រ គោលបំណងនិងលទ្ធផលរំពឹងទុក និងវិធីសាស្ត្ររបស់របាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋ
- ផ្នែកផ្សេងៗមួយចំនួនទៀតរបស់កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន




3.1

## សេចក្តីផ្តើម

សិទ្ធិចូលរួមរបស់ប្រជាពលរដ្ឋក៏រិតអប្បបរមាក្នុងសង្គមប្រជាធិបតេយ្យ គឺដើម្បីបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំ និងអ្នកតំណាងនៅក្នុងអំឡុងពេលបោះឆ្នោត ។ ឧទាហរណ៍ ក្នុងប្រទេសកម្ពុជាប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសមន្ត្រីក្រុមប្រឹក្សាឃុំ-សង្កាត់ និងអ្នកតំណាងរាស្ត្រ ។ សេចក្តីរំពឹង គឺថានៅពេលជាប់ឆ្នោតហើយថ្នាក់ដឹកនាំរដ្ឋាភិបាលនឹងតាក់តែងគោលនយោបាយ រៀបចំកម្មវិធីនយោបាយផ្សេងៗ និងធ្វើសេចក្តីសំរេចដោយអនុលោមទៅតាមមតិសាធារណៈភាគច្រើន ឬយ៉ាងហោចណាស់ត្រូវផ្អែកលើតម្រូវការរបស់ ប្រជា

ពលរដ្ឋដែលបានសំដែងចេញមក។ ប៉ុន្តែការពិត ការចូលរួមក្នុងវិស័យនយោបាយតាមរយៈការបោះឆ្នោត បានផ្តល់ឥទ្ធិពលតិចតួចណាស់ដល់ប្រជាពលរដ្ឋ ក្នុងនាមជាអ្នកធ្វើសេចក្តីសំរេចចិត្តនោះ។ ប្រសិទ្ធភាពនៃការបោះឆ្នោតដែលគេដឹងជាទូទៅថាជាយន្តការសំខាន់ សំរាប់ការទទួលខុសត្រូវនោះ បានស្តែងឱ្យឃើញថាជាឧបករណ៍ដ៏កំសោយ និងគ្មានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងមន្ត្រីរដ្ឋាភិបាល និងបុគ្គលិកទាំងអស់ដែលត្រូវទទួលខុសត្រូវរាល់ទង្វើរបស់ពួកគេ។

របាយការណ៍អភិវឌ្ឍន៍របស់ធនាគារពិភពលោកនៅឆ្នាំ២០០១សន្និដ្ឋានថា : តាមទស្សនៈរបស់ប្រជាពលរដ្ឋក្រីក្រនៅលើពិភពលោកបង្ហាញថា នៅមានវិបត្តិផ្នែកអភិបាលកិច្ច។ ស្ថាប័នទាំងឡាយរបស់រដ្ឋ មិនថាតំណាងដោយក្រសួងនានារបស់រដ្ឋាភិបាលថ្នាក់មជ្ឈិម ឬថ្នាក់បន្ទាប់នោះទេ រចនាសម្ព័ន្ធទាំងនោះជារឿយៗមិនបានឆ្លើយតប ហើយក៏គ្មានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋក្រីក្រដែរ។ ជាងនេះទៀត របាយការណ៍បានបង្ហាញយ៉ាងលំអិតថា ភាពក្រអឺតក្រទម និងការមាក់ងាយត្រូវបានប្រព្រឹត្តមកលើប្រជាពលរដ្ឋក្រីក្រទាំងនោះ។

ប្រជាពលរដ្ឋក្រីក្ររំពឹងតិចតួចណាស់លើចំណាត់ការរបស់ស្ថាប័នរដ្ឋពាក់ព័ន្ធនឹងប្រព័ន្ធយុត្តិធម៌ ឧក្រិដ្ឋកម្ម ការរំលោភសិទ្ធិ និងអំពើពុករលួយ។ វាគ្មានអ្វីភ្ញាក់ផ្អើលទេ ដែលបុរសនិងស្ត្រីក្រីក្រខ្វះជំនឿទុកចិត្តទៅលើស្ថាប័នរបស់រដ្ឋ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ពួកគាត់នៅតែបង្ហាញឆន្ទះធ្វើជាដៃគូជាមួយស្ថាប័នទាំងនោះ ដោយសង្ឃឹមថានឹងមានច្បាប់ដែលមានភាពយុត្តិធម៌ជាងនេះ។ [*Narayan, et al 2000:172*] ។ សំរាប់ប្រជាពលរដ្ឋភាគច្រើន ការប្រឈមមុខដោយផ្ទាល់របស់រដ្ឋ ឬរដ្ឋាភិបាល គឺការផ្តល់សេវាកម្មសាធារណៈ និងការមិនពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះស្ថាប័នសេវាកម្មសាធារណៈដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវ។ ប្រជាពលរដ្ឋក្រីក្រជឿជាក់ថា ស្ថាប័នរបស់រដ្ឋ (ទាំងផ្នែកផ្តល់សេវាកម្មផ្តល់ការការពារ ឬប្រព័ន្ធយុត្តិធម៌ ឬជាអ្នកធ្វើសេចក្តី សំរេចផ្នែកនយោបាយ) គ្មានការទទួលខុសត្រូវចំពោះបុគ្គលណាម្នាក់ឡើយ ឬមានការទទួលខុសត្រូវចំពោះតែអ្នកមាន និងអ្នកមានអំណាចតែប៉ុណ្ណោះ [*Narayan: 2000:177*] ។ ដោយសារតែមានចំណាប់អារម្មណ៍ខ្លាំង ក្នុងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការងារអភិបាលកិច្ចថ្នាក់មូលដ្ឋាននៅទូទាំងពិភពលោក យន្តការបែបប្រជាធិបតេយ្យមួយចំនួនកំពុងត្រូវបានអនុវត្ត ដើម្បីសម្រួលឱ្យមានការចូលរួមយ៉ាងផុលផុសរបស់ប្រជាពលរដ្ឋ នៅក្នុងដំណើរការនៃការ

សំរេចចិត្តថ្នាក់មូលដ្ឋាន និងដើម្បីឱ្យអាជ្ញាធរទាំងអស់មានការទទួលខុសត្រូវ និងឆ្លើយតបចំពោះប្រជាពលរដ្ឋ។

នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន មានកំណើនពីការព្រួយបារម្ភជុំវិញការអនុវត្តការងារ និងការទទួលខុសត្រូវរបស់ភ្នាក់ងាររដ្ឋាភិបាលដែលមានភារៈផ្តល់សេវាកម្ម បង្កើតគោលនយោបាយ និងធ្វើសេចក្តីសំរេចចិត្តជាពិសេស សំរាប់ប្រជាពលរដ្ឋក្រីក្រនិងអ្នកទន់ខ្សោយ។ កត្តាចង្អុលបង្ហាញពីការបំពេញភារកិច្ចភាគច្រើនផ្តោតទៅលើធនធាន និងក៏រិតនៃការចំណាយ ប៉ុន្តែលើសពីនេះទៀត គឺនៅមានផលវិបាកក្នុងការស្វែងរកព័តិមាន បង្ហាញពីគុណភាពនៃការផ្តល់សេវាកម្មព័តិមានពីភាពសមរម្យរបស់គោលនយោបាយ និងនីតិវិធីដែលបានបង្កើត និងការយល់ដឹងពីចំណុចខ្លាំង និងចំណុចខ្សោយក្នុងការ បំពេញមុខងារខាងក្នុងរបស់អាជ្ញាធរមូលដ្ឋាន។ អត្រាចេះដឹងទៅលើការផ្តល់សេវាកម្មសាធារណៈនៅមានក៏រិតនៅឡើយ នៅក្នុងប្រទេសនេះ ជាពិសេសពួកគេមិនបានដឹងច្បាស់ ថាអ្វីដែលពួកគេធ្វើនោះអាចឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកទាំងនោះដែរឬទេ។

ការយល់ដឹងពីបញ្ហានេះ តាម**របាយការណ៍ស្តីពីភាពជឿនលឿននៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិរបស់ប្រទេសកម្ពុជាថ្មីៗនេះ** នាំឱ្យមានការប្រឈមមុខជាមួយអង្គការក្រៅរដ្ឋាភិបាល ដែលមានភារៈជួយធ្វើការត្រួតពិនិត្យសកម្មភាពកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាលក្នុងប្រទេសកម្ពុជា។ ជំរើសមួយ ដែលផ្តល់អនុសាសន៍តាមរយៈរបាយការណ៍ គឺចង់ឱ្យអង្គការក្រៅរដ្ឋាភិបាលរៀបចំ **ការស្ទាបស្ទង់លើកម្មវិធីប័ណ្ណព័តិមានសហគមន៍** ដើម្បីធ្វើយ៉ាងណាឱ្យសាធារណៈជនយល់ច្បាស់ពីបញ្ហាសំខាន់ៗដូចជា វិមជ្ឈការ និងដើម្បីពាំនាំ ការព្រួយបារម្ភទាំងឡាយត្រឡប់ទៅឱ្យអ្នកបង្កើតគោលនយោបាយទាំងអស់នោះវិញ។ ក្រៅពីនេះ របាយការណ៍ក៏បាន បញ្ជាក់ផងដែរថា វាជាបញ្ហាសំខាន់ដើម្បីកំណត់ពីមធ្យោបាយដែលប្រជាពលរដ្ឋក្រីក្រ និងក្រុមដែលងាយទទួលរងគ្រោះអាចចូលរួមក្នុងដំណើរការនេះ ពីព្រោះបញ្ហាទាំងនេះ ប៉ះពាល់ដល់ប្រជាពលរដ្ឋក្រីក្រទាំងនោះ មុនគេ។

តម្រូវឱ្យមានការគិតឡើងវិញ ដើម្បីរិះរកវិធីផ្សេងៗធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋមានឱកាសបញ្ចេញសំលេងរបស់ពួកគាត់ឱ្យសាធារណៈបានដឹង។ ហេតុនេះ យើងត្រូវការកសាងបណ្តាញការងារមូលដ្ឋានឱ្យបានរឹងមាំដើម្បីទាមទារឱ្យមានការគាំទ្រដល់ប្រជាពលរដ្ឋក្រីក្រ និងការឆ្លើយតបដោយយុត្តិធម៌ និងការទទួលខុសត្រូវ។

ការចូលរួមដ៏មានអត្ថប្រយោជន៍របស់ប្រជាពលរដ្ឋនឹងនាំឱ្យមានតម្រូវការសេវាកម្ម និងសេចក្តីរំពឹងច្រើន និងបង្កើនសម្ពាធទៅលើប្រព័ន្ធរដ្ឋបាលនិងនយោបាយ ។ ដរាបណាប្រព័ន្ធនោះមិនអាចឆ្លើយតបបានទេ សកម្មភាពចូលរួមកាន់តែច្រើន នាំឱ្យមានភាពមិនពេញចិត្តកាន់តែច្រើន ហើយអាចនាំឱ្យមានភាពព្រងើយកន្តើយ ឬការដកថយ ឬអាចនាំឱ្យមានការប្រឈមមុខកាន់តែខ្លាំងឡើង ដែលអាចបង្កឱ្យមានអស្ថេរភាពនយោបាយ ។

ជាការឆ្លើយតបនឹងចំណោត់ការដើម្បីពង្រឹងសង្គមស៊ីវិល ការចូលរួមរបស់ប្រជាពលរដ្ឋ ឥទ្ធិពលនៅក្នុងការធ្វើវិមជ្ឈការ និង**គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់** ជាអ្នកនាំមុខគេក្នុងការអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ច មូលដ្ឋានក្នុងប្រទេសកម្ពុជា។ វិធីសាស្ត្រនេះត្រូវបានគេយកធ្វើជាគំរូ បន្ទាប់ពីប័ណ្ណព័ត៌មានសហគមន៍ ត្រូវបានស្វាគមន៍ជាអន្តរជាតិ ហើយបានអនុវត្តមុនគេនៅទីក្រុងបឹងហ្គាឡូ ប្រទេសឥណ្ឌា ហើយ ការស្ទង់មតិរកភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ត្រូវបានអនុវត្តនៅប្រទេសហ្វីលីពីន។ នៅក្នុងការអនុវត្ត ជាអន្តរជាតិ ប័ណ្ណព័ត៌មានសហគមន៍ និងការស្ទង់មតិជាធម្មតា ត្រូវបានអនុវត្តជាលំហាត់ថ្នាក់ជាតិ ដោយមានការប្រមូលទិន្នន័យពីខាងក្រៅនៅថ្នាក់ភូមិ។ ប៉ុន្តែលក្ខណៈពិសេសរបស់កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន គឺបានអនុវត្តលំហាត់ស្តីពី ប័ណ្ណព័ត៌មានសហគមន៍ថ្នាក់មូលដ្ឋាន ដោយមានការប្រមូលផ្តុំប្រជាពលរដ្ឋ តាមឃុំ ធ្វើការវិភាគ និងអនុវត្តទៅតាមលទ្ធផលដែលស្តែងឱ្យឃើញតាមរយៈគំនិតផ្តួចផ្តើម។ លំហាត់នេះ បានអនុញ្ញាតិឱ្យប្រជាពលរដ្ឋវាស់វែងក៏រិតការងាររបស់ក្រុមប្រឹក្សាឃុំ ហើយវាជាឧបករណ៏មួយ សំរាប់ឱ្យ ប្រជាពលរដ្ឋចូលរួមនៅក្នុងសកម្មភាពត្រួតពិនិត្យ និងវាយតំលៃពីអភិបាលកិច្ចល្អតាមមូលដ្ឋាន ដែលជាសិទ្ធិ មូលដ្ឋានរបស់អង្គការក្រៅរដ្ឋាភិបាលបានកំពុងតែជំរុញ។

## 3.2 បទបញ្ញត្តិសំរាប់គណនេយ្យភាពសង្គម និងការផ្តល់សេវាកម្មចំបងនៅថ្នាក់ឃុំ ប្រទេសកម្ពុជា

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភាជាតិកាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ បានកំណត់ថានីតិវិធីរដ្ឋបាល និងការគ្រប់គ្រងឃុំ-សង្កាត់ត្រូវគោរពទៅតាមគោលនយោបាយវិមជ្ឈការរបស់រដ្ឋាភិបាល។

**មាត្រាទី១** នៃច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់បានបញ្ជាក់យ៉ាងច្បាស់ថា ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវទទួលខុសត្រូវប្រជាពលរដ្ឋទាំងអស់នៅក្នុងឃុំរបស់ខ្លួន។
**មាត្រាទី១២** បានបញ្ជាក់ថា ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវជំរុញ និងសម្របសម្រួលឱ្យមានដំណើរការលទ្ធិប្រជាធិបតេយ្យនៅក្នុងឃុំតាមរយៈការបង្កើតដំណើរការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ សង្គមស៊ីវិល និងសហគមន៍នានា។ សេចក្តីសំរេច និងការគ្រប់គ្រងរដ្ឋបាលរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបើកចំហ និងមានតម្លាភាព។ ដូច្នេះប្រជាពលរដ្ឋនៅក្នុងឃុំ-សង្កាត់អាចចូលរួមនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ និងចូលរួមរិះរកគំនិតផ្តួចផ្តើមដើម្បីធ្វើផែនការអភិវឌ្ឍន៍។
**មាត្រាទី៦៦** នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់បានបញ្ជាក់ថា ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវត្រួតពិនិត្យ គ្រប់គ្រង និងវាយតំលៃការអនុវត្តផែនការ កម្មវិធី គំរោង និងការផ្តល់សេវាកម្មដោយមានគណនេយ្យភាព និងប្រកបដោយតម្លាភាព។

អង្គការសង្គមស៊ីវិលទាំងអស់អាចចូលរួមក្នុងការរៀបចំធ្វើផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់និងកម្មវិធីវិនិយោគ ហើយត្រូវទទួលខុសត្រូវតំណាងឱ្យផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន និងជាពិសេសសំរាប់អ្នកពាក់ព័ន្ធគោលដៅនានា ដូចជាស្ត្រី យុវជន និងក្រុមជនជាតិភាគតិច និងអ្នកដទៃផ្សេងៗទៀត។ អង្គការសង្គមស៊ីវិលទាំងអស់ត្រូវចូលរួមចែករំលែកចំណេះដឹង យោបល់ក្នុងរៀបចំធ្វើផែនការអភិវឌ្ឍន៍ឃុំ។ ដូចបានបញ្ជាក់នៅក្នុង**ប្រកាសអន្តរក្រសួងលេខ ៩៨** របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្តីពីការធ្វើផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ជំហានដំបូងនៅក្នុងដំណើរការធ្វើផែនការអភិវឌ្ឍន៍ គឺការប៉ាន់ប្រមាណក៏រិតប្រជាពលរដ្ឋបច្ចុប្បន្នដែលអាចប្រើប្រាស់សេវាកម្មសង្គមជាមូលដ្ឋាន **[មាត្រាទី១៣]**។

នៅក្នុងមាត្រាទី២៦នៃច្បាប់ដដែលនេះបញ្ជាក់យ៉ាងច្បាស់ថា នៅចុងបញ្ចប់នៃឆ្នាំសារពើពន្ធនីមួយៗ ប្រធានឃុំ ឬចៅសង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកធ្វើផែនការ និងគ្រប់គ្រងគំរោងថវិកាត្រូវដាក់ជូនរបាយការណ៍ប្រចាំឆ្នាំទៅក្រុមប្រឹក្សាឃុំ-សង្កាត់។ នៅក្នុងរបាយការណ៍គួរមានការពណ៌នាអំពីបញ្ហាទាំងឡាយដែលបានជួបប្រទះក្នុងពេលផ្តល់សេវាកម្មសង្គមសំខាន់ៗជូនប្រជាពលរដ្ឋនៅក្នុងឃុំ-សង្កាត់ ព្រមទាំងបង្ហាញអនុសាសន៍នានាដើម្បីកែលំអសកម្មភាពផ្តល់សេវាកម្មនោះឱ្យបានប្រសើរជាងមុន។ ជាងនេះទៀតនៅក្នុងមាត្រាទី៣០ បានបញ្ជាក់ពីសិទ្ធិរបស់ប្រជាពលរដ្ឋម្នាក់ៗក្នុងការចូលរួមគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ទោះបីជាប្រជាពលរដ្ឋទាំងអស់នោះមិនអាចចូលរួមក្នុងការបោះឆ្នោតក៏ដោយ។

នៅក្នុងជំហានដំបូងនៃ**ដំណើរការធ្វើផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់** ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវធ្វើការប៉ាន់ប្រមាណក៏រិតប្រជាពលរដ្ឋបច្ចុប្បន្នដែលអាចប្រើប្រាស់សេវាកម្មសង្គមជាមូលដ្ឋាន ហើយនៅចុងបញ្ចប់នៃឆ្នាំ

សារពើពន្ធនីមួយៗ ត្រូវធ្វើការត្រួតពិនិត្យឡើងវិញ និងរាយការណ៍ពីបញ្ហាទាំងឡាយដែលបានជួបប្រទះក្នុងដំណើរការផ្តល់សេវាកម្មសង្គមជាមូលដ្ឋានដល់ប្រជាពលរដ្ឋនៅក្នុងឃុំ-សង្កាត់ ព្រមទាំងផ្តល់អនុសាសន៍ដើម្បីកែលំអសកម្មភាពផ្តល់សេវាកម្មទាំងនោះ។

**យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិ**របស់រាជរដ្ឋាភិបាលកម្ពុជា បានគូសបញ្ជាក់ថា ការបង្កើនក៏រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមជនបទ គឺជាសកម្មភាពអាទិភាពក្នុងការផ្តល់សេវាកម្មក៏រិតមូលដ្ឋានប្រកបដោយប្រសិទ្ធភាព។ វាជាកត្តាដ៏សំខាន់ឆ្ពោះទៅរកភាពជោគជ័យរបស់គំនិតផ្តួចផ្តើម។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ចង់ឃើញក្រុមប្រឹក្សាតាមមូលដ្ឋានធ្វើជាគំរូនៅក្នុងការផ្តល់សេវាកម្ម និងការអភិវឌ្ឍមូលដ្ឋាន។ ចក្ខុវិស័យនេះមានសារសំខាន់ចំពោះការអភិវឌ្ឍ ការទទួលខុសត្រូវក្នុងមូលដ្ឋានពីព្រោះនៅពេលក្រុមប្រឹក្សាទាំងនោះ ត្រូវបានគេផ្តល់ការទទួលខុសត្រូវក្នុងការផ្តល់សេវាកម្មជូនប្រជាពលរដ្ឋ ក្រុមប្រឹក្សាត្រូវធានាថាមានធនធានគ្រប់គ្រាន់សំរាប់ការបំពេញការងារនោះ។ ទោះជាយ៉ាងនេះក្តីច្បាប់នៅតែមានលក្ខណៈទូលំទូលាយក្នុងការកំណត់ការទទួលខុសត្រូវឱ្យបានជាក់លាក់។ ដូច្នេះវាជាការសំខាន់ណាស់ដែលត្រូវយល់ដឹងពីមធ្យោបាយផ០០ផលៃសេវាកម្មក្នុងមូលដ្ឋានពេលបច្ចុប្បន្ន និងមធ្យោបាយដែល ក្រុមប្រឹក្សាឃុំ-សង្កាត់អាចធ្វើអន្តរាគមន៍ដើម្បីកែលំអលំហូរនៃការផ្តល់សេវាកម្ម។

**3.3**

## កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន

## តើកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានគឺជាអ្វី?

- ជាការប៉ាន់ប្រមាណដែលត្រូវបានចងក្រងជាឯកសារនិងមានលក្ខណៈជាប្រព័ន្ធទៅលើសេវាកម្មសង្គម និងបញ្ហាអភិបាលកិច្ចផ្សេងទៀតតាមរយៈការផ្តល់ព័ត៏មានត្រឡប់ពីប្រជាពលរដ្ឋ។
- ជាការវាយតំលៃ អំពីការពេញចិត្តរបស់ប្រជាពលរដ្ឋទៅលើការផ្តល់សេវាកម្ម និងកំណត់រកនូវការលំបាកដែលប្រឈមមុខ។
- ជាការប្រមូលនិងការរៀបចំព័ត៏មានត្រឡប់របស់ប្រជាពលរដ្ឋ ដែលលទ្ធផលរបស់វាជាចំណុចរៀនសូត្រ សំរាប់យកទៅអនុវត្តលើការគាំទ្រការតស៊ូមតិនៅក៏រិតមូលដ្ឋាន។
- ជាព័ត៏មានត្រឡប់ដែលត្រូវបានចងក្រងហើយអាចជឿជាក់បានអំពីបញ្ហារបស់អ្នកផ្តល់សេវាកម្ម ដែលប្រជាពលរដ្ឋទូទៅធ្លាប់ជួបប្រទះ។
- ជាឧបករណ៏វាយតំលៃសាមញ្ញ ដែលត្រូវបានរៀបចំជាទម្រង់សំរាប់ទំនាក់ទំនងតាមបែបសាមញ្ញ។
- ជាការសម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋដើម្បីពង្រឹងអភិបាលកិច្ចនៅថ្នាក់ឃុំ។
- ជាចំណុចចាប់ផ្តើមសំរាប់ធ្វើសកម្មភាពកែលំអរនិងឆ្លុះបញ្ចាំង។
- ជាការរៀបចំព័ត៏មានត្រឡប់របស់សាធារណៈដែលជាបែបបទនៃការបញ្ចេញយោបល់ ដើម្បីទាមទារគណនេយ្យភាពសាធារណៈឱ្យកាន់តែខ្លាំងក្លាឡើង។
- ជាជំនួយសំរាប់ពង្រឹងលើការផ្តល់សេវាកម្ម និងអភិបាលកិច្ចនៅថ្នាក់ឃុំ។
- មិនមែនជាការធ្វើឱ្យអាម៉ាស់ ឬសរសើរអ្នកផ្តល់សេវាកម្ម និងអ្នកដើរតួរសំខាន់លើអភិបាលកិច្ចមូលដ្ឋាននោះទេ។
- មិនដូចនឹងបទពិសោធន៍អន្តរជាតិដែលមានការផ្តួចផ្តើមជាប្រព័ន្ធ (ដូចជាប័ណ្ណរបាយការណ៏ពីប្រទេសឥណ្ឌានិងប្រទេសហ្វីលីពីន) កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ជាបែបបទគំរូរបស់ប្រទេសកម្ពុជា វាគឺជាទម្រង់បែបបទក្នុងស្រុក ដែលប្រជាពលរដ្ឋ ក្នុងប្រទេសបង្កើតឱ្យមានការរៀបចំ និងធ្វើសកម្មភាពសំរាប់យកលទ្ធផលបញ្ចូលទៅក្នុង កម្មវិធីមតិ ប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។

## តើកម្មវិធីមតិប្រជាពលរដ្ឋស្ដីពីអភិបាលកិច្ចមូលដ្ឋានផ្ដល់នូវអ្វីខ្លះ?

- កំរិតនៃការពេញចិត្តរបស់ប្រជាពលរដ្ឋលើគុណភាពនៃសេវាកម្ម ឬក៏ការអនុវត្តនៅក្នុងបញ្ហាអភិបាលកិច្ច។
- ការប្រៀបធៀបលើការពេញចិត្តរវាងអ្នកទទួលផល និងអ្នកផ្ដល់សេវាកម្ម។
- មូលហេតុនៃការផ្ដល់សេវាកម្ម ឬការអនុវត្តមិនបានល្អ។
- អនុសាសន៍សំរាប់ពង្រឹងការផ្ដល់សេវាកម្ម ឬក៏ជំរុញការអនុវត្តលើបញ្ហាអភិបាលកិច្ចដែលត្រូវបានគេផ្ដល់ឱ្យ។
- ជួយសម្រួលដល់សង្គមស៊ីវិលនៅថ្នាក់ឃុំ ដើម្បីប៉ាន់ប្រមាណនូវបញ្ហាអភិបាលកិច្ចសំខាន់ៗដែលប្រជាពលរដ្ឋទូទៅ ធ្លាប់បានជួបប្រទះ។
- ទម្រង់សំខាន់ៗ ស្ដីពីការរំលេចនូវបែបផែនគំរូរបស់ប្រទេសកម្ពុជា ដែលធ្វើឱ្យដំណើរការប័ណ្ណរបាយការណ៍មានលក្ខណៈជារបាយការណ៍ក្នុងស្រុក។ នៅក្នុងបែបបទគំរូនេះ ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជាបង្កើតការយល់ដឹង ហើយនឹងអនុវត្តទិន្នន័យដែលពួកគេប្រមូលបាន។ នេះជាការប្រែប្រួលដ៏សំខាន់មួយ ដែលចេញពីបទពិសោធន៍អន្តរជាតិចំពោះប័ណ្ណព័ត៌មានសហគមន៍ ហើយប័ណ្ណព័ត៌មានសហគមន៍នេះភាគច្រើនជាការអនុវត្តដែលផ្ដួចផ្ដើម មានលក្ខណៈជាតិ ដែលមានអ្នកស្រាវជ្រាវមកពីខាងក្រៅរៀបចំការអនុវត្តនេះ។ កម្មវិធីមតិប្រជាពលរដ្ឋស្ដីពីអភិបាលកិច្ចមូលដ្ឋានអាចប្រកាសយ៉ាងពេញទំហឹងថា ជាគោលបំណងរបស់អន្តរជាតិលើកទី១ ដើម្បីធ្វើឱ្យប័ណ្ណព័ត៌មានសហគមន៍មានលក្ខណៈក្នុងស្រុក ដោយមានការថ្លឹងថ្លែងជាលក្ខណៈជាតិ។

## តើត្រូវធ្វើអ្វីបន្ទាប់ពីបានកម្មវិធីមតិប្រជាពលរដ្ឋស្ដីពីអភិបាលកិច្ចមូលដ្ឋាន?

- ពិភាក្សាលទ្ធផលជាមួយទីភ្នាក់ងារផ្ដល់សេវាកម្ម ឬក៏អង្គការពាក់ព័ន្ធ ឬក៏ជាមួយក្រុមប្រឹក្សាឃុំ
- ផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយ រួមបញ្ចូលទាំងការផ្សព្វផ្សាយជាលក្ខណៈសិល្បៈ។
- គៀងគរអង្គការសហគមន៍មូលដ្ឋាន ដើម្បីឱ្យផ្សព្វផ្សាយការរកឃើញ និងបង្កើតកត្តាជំរុញផ្នែកសង្គមក្នុងគោលបំណងនៃកំណែទម្រង់និងការផ្លាស់ប្ដូរ។
- តាមដានត្រួតពិនិត្យសកម្មភាព ដើម្បីពង្រឹងសេវាកម្ម និងបញ្ហានានាដែលកំពុងលើកឡើងនៅក្នុងកម្មវិធីមតិប្រជាពលរដ្ឋស្ដីពីអភិបាលកិច្ចមូលដ្ឋាន។

# 3.4

# គោលគំនិត និងយុទ្ធសាស្ត្រនៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន

## គោលគំនិត

កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន គឺជាយន្តការដែលបញ្ចូលរបៀបថ្មី ហើយឈានមុខគេបង្អស់ ដែលកម្មវិធីនេះប្រមូលផ្តុំនូវការយល់ឃើញរបស់អ្នកប្រើប្រាស់ ភាពងាយស្រួល ការពេញ ចិត្ត និងភាពសមរម្យនៃសេវាកម្ម ព្រមទាំងទៅលើគុណភាពនៃការចូលរួមនៅពេលប្រជុំក្រុមប្រឹក្សាឃុំ។ កម្មវិធីនេះជាទិន្នន័យនិងព័ត៌មានដ៏ពិសេសវិសាលស្តីអំពីការពេញចិត្តរបស់ប្រជាពលរដ្ឋ ដែលត្រូវប្រើធ្វើជាចំណុចរៀនសូត្រ ដើម្បីបង្កើតកត្តាជំរុញដែលអាចចែករំលែកបាន ហើយនាំឱ្យមន្ត្រីថ្នាក់ឃុំ និងអ្នកផ្តល់សេវាកម្មមានការឆ្លើយតបជាវិជ្ជមានទៅនឹងការទាមទាររបស់ប្រជាពលរដ្ឋ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាកម្ម និងការរៀបចំការប្រជុំក្រុមប្រឹក្សាឃុំ។

កម្មវិធីនេះ វាផ្តល់បែបបទដែលអាចផ្លាស់ប្តូរបានក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាង ប្រជាពលរដ្ឋនិងរដ្ឋាភិបាល។ វាជំរុញឱ្យមានភាពស្របគ្នាទៅនិងប្រជាធិបតេយ្យតាមបែបតំណាង ដែលប្រជា ពលរដ្ឋទទួលបានឱកាសទូលំទូលាយក្នុងការបង្ហាញតម្រូវការរបស់ពួកគេអំឡុងពេលបោះឆ្នោតជ្រើសរើស តាមអណិត្ត ហើយបន្ទាប់មកទៀត វាធ្វើឱ្យមន្ត្រីរបស់រដ្ឋមានគណនេយ្យភាពចំពោះភាពជាតំណាង ដែលត្រូវបានប្រជាជនបោះឆ្នោតឱ្យ។ របាយការណ៍វាយតំលៃនេះ ជំរុញឱ្យប្រជាពលរដ្ឋចូលរួមនៅក្នុងបរិបទវិមជ្ឈការ ដែលស្ថិតនៅក្នុងគំរោងការសិទ្ធមនុស្សដ៏ទូលំទូលាយ។

តាមរយៈកម្មវិធីនេះ នឹងធ្វើឱ្យប្រជាពលរដ្ឋចូលរួមដោយបង្កើតព័ត៌មាន និងប្រើប្រាស់ព័ត៌មានដើម្បីឱ្យមានឥទ្ធិពលលើគោលនយោបាយ និងការធ្វើផែនការ។ កម្មវិធីនេះ ជួយជំរុញការងារជាច្រើនលើសពីគោលគំនិតដែលត្រូវការឱ្យមានការចូលរួមនៅក្នុងការអនុវត្តគំរោង និងរៀបចំផែនការអភិវឌ្ឍទៅទៀត។ លទ្ធផលនៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាននេះ អាចបំរើ ឱ្យមានមូលដ្ឋានគ្រឹះសំរាប់ធ្វើការពិភាក្សាជាក់លាក់ជាមួយមន្ត្រីរដ្ឋាភិបាល និងអ្នកធ្វើសេចក្តីសំរេចចិត្ត ផ្សេងទៀត។ លទ្ធផលនឹងត្រូវចែករំលែកទៅឱ្យអ្នកតំណាងរបស់ប្រជាពលរដ្ឋ អង្គការក្រៅរដ្ឋាភិបាល និង តាមបណ្តាញផ្សព្វផ្សាយព័ត៌មានផ្សេងៗ។ អង្គការក្រៅរដ្ឋាភិបាលទាំងឡាយ ឬក្រុមអង្គការក្រៅរដ្ឋាភិបាលដែលប្រើប្រាស់កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាននេះ រំពឹងថានឹងត្រូវធ្វើការបណ្តុះបណ្តាលរៀបចំ គៀងគរបណ្តាញផ្សព្វផ្សាយព័ត៌មានទៅដល់ក្រុមចាប់អារម្មណ៍សាធារណៈផ្សេងទៀត និង

ប្រជាពលរដ្ឋគ្រប់ស្រទាប់ ដើម្បីសម្របសម្រួលយន្តការ នៃការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ ក្នុងកិច្ចការអភិវឌ្ឍន៍ ព្រមទាំងលើកកំពស់ដល់ពួកគេផ្ទាល់។

កម្មវិធីដែលមានការផ្តួចផ្តើមនេះ ត្រូវធ្វើជាខ្នាតគំរូសំរាប់វាស់វែងភាពប្រសើរឡើង និងជាការអនុវត្តរយៈពេលកន្លងមកផងដែរ។ លទ្ធផលនៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាននេះ អាចប្រើជាចំណុចរៀនសូត្រសំរាប់គាំទ្រដល់កំណែទម្រង់ និងការផ្លាស់ប្តូរ។ ពិតមែនហើយ របាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋ អាចមើលឃើញធាតុបន្ថែម ដើម្បីធ្វើឱ្យមានប្រតិកម្ម សំរាប់កសាងចំណេះដឹងលើអភិបាលកិច្ចដែលមានការឆ្លើយតប។ ជាកិច្ចចាប់ផ្តើម អ្នកអនុវត្តមកពីខាងក្រៅ អាចប្រើគំនិតផ្តួចផ្តើមនេះ ដើម្បីបង្កើត និងធ្វើឱ្យអង្គការសង្គមស៊ីវិលនៅមូលដ្ឋាន និងប្រជាពលរដ្ឋ កាន់តែសកម្មឡើងក្នុងការទាមទារឱ្យមានការផ្តល់សេវាកម្មប្រកបដោយគណនេយ្យភាព និងមានប្រសិទ្ធិភាព។

យោងតាមចំណេះដឹងដែលផ្ទេរជូនអង្គការសង្គមស៊ីវិលនៅមូលដ្ឋាននឹងអាចធ្វើការប្រកបដោយឯករាជ្យភាពជាមួយប្រជាពលរដ្ឋ។ នៅខណៈដែលមានការយល់ដឹង និងមានការកើនឡើងលើភាពជាម្ចាស់ ពេលនោះប្រជាពលរដ្ឋខ្លួនឯងអាចចូលរួមពាក់ព័ន្ធ ឬក៏ចរចារយ៉ាងសកម្មជាមួយនឹងរដ្ឋបាលថ្នាក់មូលដ្ឋាន ដើម្បីឱ្យមានការផ្តល់សេវាកម្មមូលដ្ឋានត្រូវនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ ដោយហេតុថា ពេលកន្លងមកនេះក្រុមប្រឹក្សាឃុំគួរតែមានព័ត៌មានគ្រប់គ្រាន់សំរាប់ប្រជាពលរដ្ឋ មិនគ្រាន់តែមានការឆ្លើយតបចំពោះប្រជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យមានការត្រួតពិនិត្យ និងការសម្របសម្រួលការទទួលខុសត្រូវលើការផ្តល់សេវាកម្មរបស់ភ្នាក់ងារជំនាញ វិសហមជ្ឈការនានារបស់រដ្ឋាភិបាល ដែលទទួលខុសត្រូវក្នុងការផ្តល់សេវាកម្មនៅលើដែនដីឃុំ។

លទ្ធផលដែលចង់បានលើការធ្វើអន្តរាគមន៍របស់គំរោងកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានអាចនឹង ចំណាយរយៈពេលខ្លី ឬវែងដើម្បីរៀបចំសំភារៈ។ វាពឹងផ្អែកជាចំបងលើកំរិតនៃសមត្ថភាព និងការភ្ញាក់ រលឹករបស់ប្រជាពលរដ្ឋមូលដ្ឋាន ឬក៏រដ្ឋបាលថ្នាក់មូលដ្ឋាន។

## កំរិតនៃសមត្ថភាពនិងការភ្ជាប់រលឹក

| | | | | |
|---|---|---|---|---|
| ក្រុមប្រឹក្សាឃុំខ្លួនឯងផ្ទាល់យល់ដឹង និងអាចឆ្លើយតបនៅក្នុងការសម្របសម្រួល និងការផ្តល់សេវាកម្មសាធារណៈនៅមូលដ្ឋាន | | | | ក្រុមប្រឹក្សាឃុំ |
| ប្រជាពលរដ្ឋមានភាពសកម្មលើការបញ្ចេញយោបល់ដែលទាមទារឱ្យផ្តល់សេវាកម្មមានប្រសិទ្ធិភាពហើយទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំប្រកបដោយឯករាជភាព | | | ក្រុមប្រជាពលរដ្ឋ → | ក្រុមប្រឹក្សាឃុំ |
| អង្គការក្រៅរដ្ឋាភិបាលនៅមូលដ្ឋានអាចធ្វើការឯករាជ្យជាមួយប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ ដើម្បីផ្តល់សេវាកម្ម | | អង្គការក្រៅរដ្ឋាភិបាលនៅមូលដ្ឋាន → | ក្រុមប្រជាពលរដ្ឋ → | ក្រុមប្រឹក្សាឃុំ |
| ត្រូវការជ្រុំជ្រែងពីខាងក្រៅ | អង្គការក្រៅរដ្ឋាភិបាលថ្នាក់ជាតិ → | អង្គការក្រៅរដ្ឋាភិបាលនៅមូលដ្ឋាន → | ក្រុមប្រជាពលរដ្ឋ → | ក្រុមប្រឹក្សាឃុំ |

## ការស្វែងរកអន្តរាគមន៍

## យុទ្ធសាស្ត្រ

កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ដែលត្រូវបានគាំទ្រដោយ**គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់** គឺជាយុទ្ធសាស្ត្ររកឃើញថ្មីសម្រាប់ធ្វើការបង្កើនឥទ្ធិពលរបស់ប្រជាពលរដ្ឋ ក្នុងការធ្វើឱ្យប្រសើរឡើងនូវការឆ្លើយតបរបស់ភ្នាក់ងារផ្តល់សេវាកម្មនានា ព្រមទាំងការធានាឱ្យមានគណនេយ្យភាពខ្ពស់ពីសំណាក់រដ្ឋាភិបាល ដោយចាប់ផ្តើមពីថ្នាក់ឃុំ-សង្កាត់ឡើងទៅ។ កម្មវិធីនេះ បង្ហាញមិនមែនត្រឹមតែជាការពិគ្រោះយោបល់របស់ប្រជាពលរដ្ឋក្នុងការធ្វើផែនការអភិវឌ្ឍន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការសហការគ្នា ក្នុងការសម្រេចចិត្តដែលត្រូវការនូវឥទ្ធិពល និងអំណាចរបស់ពួកគេផងដែរ។ លើសពីនេះទៀត វាក៏ជួយលើកស្ទួយសមត្ថភាពនៃភាគី ក្នុងការទាមទារឱ្យក្លាយជាកម្លាំងចំបងមួយ ក្នុងការជំរុញឱ្យមានការឆ្លើយតបពីរដ្ឋបាលថ្នាក់មូលដ្ឋាន។

និយាយជារួម កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ប្រមូលផ្តុំនូវទស្សនៈរបស់អ្នកទទួលផល អំពីការយល់ដឹង ភាពងាយស្រួល ការពេញចិត្តនិងភាពសមរម្យនៃសេវាកម្មផ្សេងៗ និងគុណភាព នៃការចូលរួមចំណែកនៅក្នុងអភិបាលកិច្ចមូលដ្ឋាន ព្រមទាំងប្រមូលចងក្រងព័ត៌មានទាំងនោះ ដើម្បីបង្កើតកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាននេះ។ របាយការណ៍ស្តីពីការចូលរួមមតិទាំងនេះ នឹងត្រូវបានលើកយកមកពិភាក្សាដោយប្រជាពលរដ្ឋខ្លួនគេផ្ទាល់ ជាមួយនឹងអ្នកធ្វើការសម្រេចចិត្ត និងអ្នកផ្តល់សេវាកម្មដែលពាក់ព័ន្ធចំនួនទៀត។ វាក៏បានកសាងមូលដ្ឋាន ដែលមានផ្លែផ្កា ឬលទ្ធភាពល្អក្នុងការផ្តល់នូវចំណុចរៀនសូត្រ និងការយល់ដឹងនានាដល់ប្រជាពលរដ្ឋ ដើម្បីទាមទារ នូវសេវាកម្មមូលដ្ឋានជាច្រើន។

តាមរយៈការអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន អាចផ្តល់ការយល់ដឹងអំពីសេវាកម្មសង្គមផ្សេងៗ ដែលមានស្រាប់នៅក្នុងឃុំ-សង្កាត់ ដល់ប្រជាពលរដ្ឋព្រមទាំងផ្តល់ដល់ពួកគេនូវឱកាស ដើម្បីធ្វើការវាយតំលៃលើការអនុវត្តជារួមរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ តាមរយៈកំរិតនៃការពេញចិត្តរបស់ប្រជាពលរដ្ឋទៅលើសេវាកម្មសង្គមសំខាន់ៗ ដែលមាននៅក្នុងឃុំ-សង្កាត់។ បន្ទាប់មក ពួកគេនឹងបញ្ចេញទស្សនៈផ្សេងៗ ស្តីអំពីរបៀបដែលបញ្ហាមួយចំនួនអាចត្រូវបានធ្វើឱ្យប្រសើរឡើង និងស្នើសុំឱ្យមានកត្តាជួយសម្របសម្រួល ដែលប្រជាពលរដ្ឋនៅតាមឃុំ-សង្កាត់អាចមានលទ្ធភាពកាន់តែប្រសើរឡើង ក្នុងការទទួលបាននូវសេវាកម្មសង្គមនានា។ ជំហានដ៏សំខាន់មួយដែលត្រូវបានអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលជាដៃគូរបស់**គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់** ចំពោះការអនុវត្តកម្មវិធីនេះ គឺដើម្បីតម្រង់ទិសដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ដល់អ្នកដឹកនាំក្រៅផ្លូវការសំខាន់ៗ និង ប្រជាពលរដ្ឋ ស្តីអំពីហេតុផលសំរាប់ការអនុវត្តគំនិតផ្តួចផ្តើមទាំងនោះ។ វិធានការនេះត្រូវបានគេចាត់ទុកថាសំខាន់ ខ្លាំងណាស់ក្នុងការពិចារណាអំពីការគាំទ្ររបស់រដ្ឋបាលថ្នាក់មូលដ្ឋាននិងប្រជាពលរដ្ឋ ដែលជាយន្តការដ៏សំខាន់ សំរាប់ភាពជ័យជំនះនៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាននេះ។ ក្នុងអំឡុងពេលនៃការអនុវត្តនេះ ប្រជាពលរដ្ឋនៅតាមឃុំ-សង្កាត់ជាច្រើន សម្តែងនូវការពេញចិត្ត និងការមិនពេញចិត្តរបស់ពួកគេ ចំពោះសេវាកម្មសង្គម និងគំរោងហេដ្ឋារចនាសម្ព័ន្ធនានា បង្ហាញនូវហេតុផលលើការមិនពេញចិត្តរបស់ពួកគេ បញ្ជាក់យ៉ាងច្បាស់នូវកង្វះខាត និងចំណុចខ្សោយនានា និងការធ្វើឱ្យរំខានដល់ការផ្តល់សេវាកម្ម ហើយបន្ទាប់មកទៀតគឺផ្តល់នូវអនុសាសន៍មួយចំនួនស្តីអំពីវិធី ដើម្បីធ្វើឱ្យប្រសើរឡើង។ យុទ្ធសាស្ត្រក្នុងការអនុវត្តនេះ គឺត្រូវបណ្តុះបណ្តាលដល់អង្គការក្រៅរដ្ឋាភិបាលនៅតាម បណ្តាខេត្តនានា ដែលកំពុងធ្វើការជាមួយអង្គការសហគមន៏មូលដ្ឋាននៅតាមឃុំ-សង្កាត់ផ្សេងទៀត តាមរយៈសកម្មភាពរៀនសូត្រផ្សេងៗ ដែលត្រូវបានផ្តល់ជូនគ្រប់គំរោងទាំងអស់។ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកទាំងនេះ នឹងត្រូវបានគេបណ្តុះបណ្តាលឱ្យដឹងពីមូលហេតុ ទស្សនៈ និងវិធីសាស្ត្រនៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។ បន្ទាប់មកទៀត ពួកគេនឹងបណ្តុះបណ្តាល និងជួយប្រជាពលរដ្ឋនៅតាមឃុំ-សង្កាត់ឱ្យចេះអនុវត្តកម្មវិធីនេះ សំរាប់ការប្រមូលនិងការវិភាគទិន្នន័យ និងការវាយតំលៃការបង្ហាញតាមរយៈការប្រជុំ និងវេទិកានានា។ ដូចគ្នានេះដែរ អង្គការក្រៅរដ្ឋាភិបាលនានានឹងបណ្តុះណ្តាលហើយបង្ហាត់បង្ហាញអង្គការសហគមន៏ មូលដ្ឋានឱ្យចេះផ្សារភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់តាមរយៈការពិភាក្សានានា និងបែបបទផ្សេងៗ នៃការងារដែលពាក់ពន្ធ័ជាមួយនឹងការគាំទ្រការតស៊ូមតិជាសាធារណៈនៅមូលដ្ឋាន។ ក្រៅពីការពង្រឹងសមត្ថភាពរបស់ អ្នកអនុវត្តនៅតាមតំបន់ និងការបង្កើតព្រមទាំងការបង្ហាត់បង្រៀនដល់ក្រុមស្រាវជ្រាវឃុំ-សង្កាត់ ដើម្បីឱ្យចេះអនុវត្ត ការស្រាវជ្រាវ និងដឹកនាំគំនិតផ្តួចផ្តើម ស្តីពីការគាំទ្រការតស៊ូមតិ អ្នកអនុវត្តកម្មវិធីនេះ សហការជិតស្និទ្ធជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់។

## 3.5

## គោលបំណង លទ្ធផល និងវិធីសាស្ត្រ

## គោលបំណង និងលទ្ធផល

កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន មានគោលបំណងចំបង គឺផ្តល់នូវការវាយតំលៃ ដែលត្រូវបានចងក្រងជាឯកសារ និងរៀបចំជាប្រព័ន្ធទៅលើសេវាកម្មសង្គមសំខាន់ៗ សេវាកម្មរដ្ឋបាល គំរោងកសាង ហេដ្ឋារចនាសម្ព័ន្ធ ការចំណាយថវិកា ឬការអនុវត្តនានា។ល។ នៅតាមបណ្តាឃុំ-សង្កាត់ ក៏ដូចជា ទៅលើការពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីជំរុញឱ្យមានការចូលរួម ពីប្រជាពលរដ្ឋនៅ ក្នុងការប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។ ដូចគ្នានេះដែរ កម្មវិធីមតិប្រជាពលរដ្ឋ ស្តីពីអភិបាលកិច្ចមូលដ្ឋាន ខឹតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីបង្កើតក្រុមអ្នកអនុវត្តការងារនៅថ្នាក់ឃុំ-សង្កាត់ ដែលផ្សារភ្ជាប់ទៅនឹង គណនេយ្យភាពសង្គម។ ជាដំបូង គំរោងនឹងត្រូវបានវាយតំលៃ ពីរបៀប ដែលធ្វើឱ្យមានលទ្ធផលប្រសើរឡើង ឬរបៀបដែលនឹងត្រូវពង្រឹង គោលនយោបាយមួយចំនួនរបស់ រដ្ឋាភិបាល ដែលកើតចេញពីយុទ្ធនាការ និងការបញ្ចុះបញ្ចូលរបស់ប្រជាពលរដ្ឋ។ ចុងក្រោយ គំរោង នេះ បង្កើតឱ្យមានការពិភាក្សាដែលប្រកបដោយ ការស្ថាបនា និងការភ្ជាប់ទំនាក់ទំនង រវាងប្រជាពលរដ្ឋ ក្រុមការងារនៅតាមសហគមន៍មួយផ្នែក ហើយមួយផ្នែកទៀតរវាងមន្ត្រីក្រុមប្រឹក្សាឃុំ-សង្កាត់ និង អ្នកផ្តល់សេវាកម្មផ្សេងៗទៀត។ គំរោងនេះក៏ ត្រូវបានគេសង្ឃឹមផងដែរថា វានឹងមានឥទ្ធិពលលើគំនិត ផ្តួចផ្តើមតាមវិស័យនិមួយៗ ដើម្បីធ្វើឱ្យការផ្តល់ សេវាកម្មបានកាន់តែល្អប្រសើរ ឡើង។ នៅទីបំផុត កម្មវិធី មតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានរំពឹងថា នឹងបង្កើននូវការយល់ដឹងដល់ ប្រជាពលរដ្ឋដែលថា ការចូលរួម គឺជាកត្តាសំខាន់សំរាប់លទ្ធិប្រជាធិបតេយ្យ ដ៏រឹងមាំមួយនៅក្នុងប្រទេសកម្ពុជា។

### គំរោងកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានមាន គោលបំណង ៣ ដូចខាងក្រោម :

១. ដើម្បីបង្កើតប្រព័ន្ធសំរាប់ជួយសម្រួលដល់ការវាយតំលៃសេវាកម្មសង្គមនានា ដែលត្រូវបានចងក្រងជាឯកសារនិងរៀបចំជាប្រព័ន្ធ និងទិដ្ឋភាពផ្សេងៗទៀតនៃអភិបាលកិច្ចល្អ គឺប្រើប្រាស់ព័ត៌មានត្រឡប់របស់ប្រជាពលរដ្ឋ។

២. ដើម្បីបង្កើតទិន្នន័យ និងព័ត៌មានគំរូដើម្បីវាស់វែងការរីកចំរើន និងការអនុវត្តកន្លងមក។

៣. ដើម្បីលើកស្ទួយសង្គមស៊ីវិល ការពិភាក្សារបស់រដ្ឋាភិបាលស្តីអំពីបញ្ហាសំខាន់ៗដែលមានគោល បំណងនៅក្នុងកំណែទម្រង់ស្ថាប័ន។

### លទ្ធផលរំពឹងទុកនៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន :

១. បង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋលើការចូលរួមពេញលេញ ដែលជាធាតុដ៏សំខាន់មួយ នៅក្នុង លទ្ធិប្រជាធិបតេយ្យ។

២. ការវាយតំលៃពីទំហំនៃការផ្តល់សេវាកម្មសាធារណៈ ព្រមទាំងធាតុផ្សេងៗទៀតនៃអភិបាលកិច្ចមូលដ្ឋាន (ឧទាហរណ៍ដូចជាការចូលរួម)។

៣. រៀបចំក្រុមសង្គមស៊ីវិលនៅតាមមូលដ្ឋាន ដើម្បីបង្កើតជាសម្ពាធក្នុងការវាយតំលៃទៅដល់ទីភ្នាក់ងារ អង្គភាពនានារបស់រដ្ឋាភិបាល ព្រមទាំងក្រុមពាក់ព័ន្ធដទៃទៀត ដើម្បីឱ្យឆ្លើយតបជាវិជ្ជមានទៅតាមការទាមទាររបស់ប្រជាពលរដ្ឋ ក្នុងការកែលំអការផ្តល់សេវាកម្ម និងកំណែទម្រង់ផ្សេងៗ។

## វិធីសាស្រ្តមួយចំនួន

កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានរួមមានជំហានសំខាន់ចំនួន៤ គឺ :




វិធីសាស្រ្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន
កំណត់យកចំណុចសាមញ្ញមួយចំនួនដូចខាងក្រោម :

- ❑ ការវាយតំលៃឱ្យបានឆាប់រហ័សទៅលើភាពសមរម្យ
- ❑ កំណត់ និងជ្រើសរើស ឃុំ-សង្កាត់ព្រមទាំងសេវាកម្មចាំបាច់មួយឬច្រើន
- ❑ កំណត់ទំហំការងារ និងគោលបំណង
- ❑ ជ្រើសរើស និងរៀបចំក្រុមអនុវត្តការងារនៅមូលដ្ឋាន និងក្រុមស្រាវជ្រាវឃុំ-សង្កាត់
- ❑ បង្កើតបញ្ជីសំណួរ
- ❑ រៀបចំការបណ្តុះបណ្តាល និងការហ្វឹកហ្វឺន

- បង្កើតគំរូសំណាក
- ដំណើរការវាស់ស្ទង់កម្មវិធីមតិប្រជាពលរដ្ឋស្ដីពីអភិបាលកិច្ចមូលដ្ឋាន
- ដំណើរការវិភាគលើទិន្នន័យនៃកម្មវិធីមតិប្រជាពលរដ្ឋស្ដីពីអភិបាលកិច្ចមូលដ្ឋាន
- ការផ្សព្វផ្សាយលទ្ធផលនៃកម្មវិធីមតិប្រជាពលរដ្ឋស្ដីពីអភិបាលកិច្ចមូលដ្ឋាន គឺដាក់ជូនក្រុមប្រឹក្សាឃុំ ការប្រជុំជាសាធារណៈ និងបណ្ដាញផ្សព្វផ្សាយព័ត៌មាន។
- កំណែទម្រង់ ឬផ្លាស់ប្ដូរការតស៊ូមតិ ដោយផ្អែកលើលទ្ធផលនៃរបាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋ
- បង្កើតក្រុមជំរុញការងារថ្នាក់មូលដ្ឋាន
- ផ្ដល់ជំនួយបច្ចេកទេស និងត្រួតពិនិត្យលើការអនុវត្តន៍នៃកម្មវិធីមតិប្រជាពលរដ្ឋស្ដីពីអភិបាលកិច្ចមូលដ្ឋាន
- ផ្ដួចផ្ដើមសកម្មភាពរៀនសូត្រស្ដីអំពីការគាំទ្រការតស៊ូមតិថ្នាក់មូលដ្ឋាន

មានច្រកចូលជាច្រើនសំរាប់គំរោងកម្មវិធីមតិប្រជាពលរដ្ឋស្ដីពីអភិបាលកិច្ចមូលដ្ឋាន។ វាអាចជាការស្ទាប់ស្ទង់ ដែលមានការផ្ដួចផ្ដើមទៅលើសេវាកម្មសង្គមជាមូលដ្ឋាន សេវាកម្មផ្នែករដ្ឋបាលផ្សេងៗ គំរោងហេដ្ឋារចនាសម្ព័ន្ធ ផ្សេងៗ ការចំណាយថវិកា និងដំណើរការ។ល។ ដែលមួយណាក៏ដោយឱ្យតែទាក់ទងខ្លាំងជាមួយ ប្រជាពលរដ្ឋនៅមូលដ្ឋាន ដោយមិនគិតថាអ្នកណាកំពុងធ្វើ ឬកំពុងផ្ដល់សេវាកម្មទាំងនោះឡើយ។ ដំណើរការចូលរួមមួយសំរាប់ការជ្រើសរើសឃុំ-សង្កាត់ណាមួយជាគោលដៅត្រូវធ្វើឡើងដោយប្រើ ឧបករណ៍វាយតំលៃដែលឆាប់រហ័សមួយ ដើម្បីវាយតំលៃលើភាពសមស្របរបស់ឃុំ-សង្កាត់សំរាប់អនុវត្ត កម្មវិធីមតិប្រជាពលរដ្ឋស្ដីពីអភិបាលកិច្ចមូលដ្ឋាន។

### នីតិវិធីអនុវត្តជាក់ស្ដែងសំរាប់ការប្រតិបត្តិគំរោង

១. ការធ្វើអង្កេតចោះៗទៅតាមផ្ទះសម្ភែងមួយចំនួន ក្នុងគោលបំណងវាយតំលៃទៅលើសេវាកម្មតាមរយៈការវាស់វែងផ្សេងៗនៃការយល់ដឹង ភាពងាយស្រួល និងការពេញចិត្ត។

២. ការស្ទាបស្ទង់ពីគោលគំនិតរបស់ប្រជាពលរដ្ឋ អំពីដំណើរការទូទៅរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។

៣. ការស្ទាបស្ទង់ពីប្រជាពលរដ្ឋលើការរីកចំរើននៃជីវភាពរបស់ពួកគេ ដែលស្ថិតក្រោមកំណែទម្រង់អភិបាលកិច្ចមូលដ្ឋាន។

ក្នុងដំណាក់កាលនៃការអនុវត្តន៍ការងារនៅតាមតំបន់ ទាំងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក អង្គការសង្គមស៊ីវិល ឬក្រុមប្រជាពលរដ្ឋនឹងចូលរួមអនុវត្តគំរោងរបាយណ៍ការវាយតំលៃរបស់ប្រជាពលរដ្ឋ ដោយធ្វើការ

ចាត់ចែង និងរៀបចំក្រុមស្រាវជ្រាវឃុំ-សង្កាត់មួយ ដោយមានការបណ្តុះបណ្តាលនៅតាមមូលដ្ឋាន ស្តីអំពីដំណើរការនានារបស់គំរោងកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន សម្របសម្រួលការប្រមូលទិន្នន័យជាក់ស្តែងចាត់ចែងនិងវិភាគទិន្នន័យ និងបញ្ចូលទិន្នន័យទាំងនោះឱ្យទៅជាកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ធ្វើការបង្ហាញកម្មវិធីនេះ ទៅដល់ក្រុមអ្នកធ្វើការសម្រេចចិត្តសំខាន់ៗ នៅថ្នាក់ឃុំ-សង្កាត់ ព្រមទាំងការបើកយុទ្ធនាការ គាំទ្រការតស៊ូមតិជាសាធារណៈ ដើម្បីលើកឡើងនូវបញ្ហាទាំងឡាយ ដែលបានកំណត់នៅក្នុងកម្មវិធី នេះ។

អំឡុងពេលអនុវត្តន៏ការងារ នៅតាមឃុំ-សង្កាត់ និមួយៗ អ្នកអនុវត្តការងារនឹងជួយសម្របសម្រួលដល់ការជ្រើសរើស និងការរៀបចំក្រុមប្រជាពលរដ្ឋ ដែលរស់នៅតាមតំបន់នោះ ឱ្យធ្វើជាដៃគូសហការដែលនឹងត្រូវបង្កើតទៅជាក្រុមស្រាវជ្រាវឃុំ-សង្កាត់ ដោយមានភារកិច្ចអនុវត្តការងារ ផ្នែកស្ទាបស្ទង់ការចូលរួមនៅតាមឃុំ-សង្កាត់។ នៅក្នុងឃុំ-សង្កាត់ និមួយៗ ក្រុមស្រាវជ្រាវឃុំនឹងទទួលការបណ្តុះបណ្តាលបន្តពីបណ្តាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក នានានៅក្នុងបណ្តាខេត្តមួយចំនួន។ គោលគំនិតនៃការបង្កើតក្រុមស្រាវជ្រាវឃុំ គឺដើម្បីបង្កើតរចនា សម្ព័ន្ធប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដែលជាក្រុមជួយជំរុញនៅក្នុងឃុំនិមួយៗ ដើម្បីកត់ត្រាជាប្រចាំ នូវរាល់បញ្ហាពាក់ព័ន្ធទាំងឡាយ ដែលមានផលប៉ះពាល់ដល់ការរស់នៅរបស់គេ ហើយបង្កើតការគាំទ្រ ការតស៊ូមតិជាសាធារណៈសំរាប់ប្រជាពលរដ្ឋសាមញ្ញ ដើម្បីទាមទារដំណោះស្រាយ និងភាពប្រសើរឡើង។

អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនានារួមគ្នាជាមួយសមាជិករបស់ក្រុមស្រាវជ្រាវឃុំ នឹងជួយសម្រួលដល់ការវាយតំលៃរាល់សេវាកម្មនៅក្នុងបណ្តាឃុំគោលដៅ។ ការវាយតំលៃនេះរួមមាន ការរៀបចំព័តិមាននៃសេវាកម្មតាមមូលដ្ឋានដែលមានស្រាប់ ការកំណត់អ្នកទទួលផល ឬអ្នកប្រើប្រាស់សេវាកម្មទាំងអស់និងការប្រឈមមុខ ឬបញ្ហាសំខាន់ៗ ក្នុងការផ្តល់សេវាកម្មដែលបានកំណត់ទុក។ ដោយផ្អែកលើទិន្នន័យទាំងនេះ អ្នកអនុវត្តន៏ការងារ និងអ្នកស្ទាបស្ទង់ អាចបង្កើតនូវកាលវិភាគពង្រាងសំរាប់ការសម្ភាសន៏មួយដែលតម្រូវឱ្យសាកល្បងជាមុន មុនពេលអនុវត្តជាក់ស្តែង។

នៅថ្នាក់ឃុំ-សង្កាត់ របាយការណ៏វាយតំលៃរបស់ប្រជាពលរដ្ឋអាច ត្រូវបានគេយកមកអនុវត្ត ដោយផ្អែកលើការប៉ាន់ប្រមាណថា :

- នៅទីនោះ មានអង្គការធ្វើការនៅតាមឃុំ-សង្កាត់មួយចំនួន ដែលនឹងធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលជាដៃគូដទៃ ទៀត នៅក្នុងដំណាក់កាលនៃការអនុវត្តការងារនៅតាម តំបន់នេះ។ បើសិនមិនមានអង្គការទាំងនោះទេ នោះគួរតែ មានប្រជាពលរដ្ឋនៅតាមឃុំ-សង្កាត់យ៉ាងហោចណាស់ ១០ នាក់ ដែលចាប់អារម្មណ៏ឱ្យធ្វើការសាកសួរព័តិមាននៅតាម តំបន់នោះ។
- ក្រុមសម្របសម្រួលរបស់ កម្មវិធីមតិប្រជាពលរដ្ឋស្តីពី អភិបាលកិច្ចមូលដ្ឋានមួយក្រុមនឹងធ្វើការទូទាំងខេត្ត ឬឃុំ-សង្កាត់ ដែលជាតំបន់គោលដៅក្នុងអំឡុងពេល នៃការ ស្រាវជ្រាវនៅក្នុងតំបត់នោះ ដើម្បីផ្តល់នូវជំនួយការ បច្ចេកទេស ហើយដើម្បីជួយសម្របសម្រួលដល់ការ ដោះស្រាយបញ្ហា ដែលទាក់ទងទៅនឹងបញ្ហានៅក្នុងតំបន់

ព្រមទាំងកង្វល់ដែលប្រជាពលរដ្ឋអាចនឹងជួបប្រទះ ក្នុងអំឡុងពេលធ្វើការងារ នេះ។

- ដៃគូអនុវត្តការងារ សហគមន៍ ឬក្រុមប្រជាពលរដ្ឋទាំងអស់ នឹងត្រូវគេលើកទឹកចិត្តឱ្យរៀបចំកម្មវិធីការងាររបស់គេ ក៏ ដូចជាសកម្មភាពផ្សេងៗ ដែលនឹងត្រូវរៀបចំឡើង ដើម្បី ធ្វើចប់សព្វគ្រប់ទាន់ពេលវេលា។

| | |
|---|---|
| **អ្នកអនុវត្ត** | អង្គការក្រៅរដ្ឋាភិបាលថ្នាក់ខេត្តនិងថ្នាក់ជាតិ អង្គការសង្គមស៊ីវិលនិងក្រុមប្រជាពលរដ្ឋអាចសម្របសម្រួល និងអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។ អង្គការទាំងនេះត្រូវបានលើកទឹកចិត្តឱ្យអនុវត្តគំនិតផ្តួចផ្តើមរបស់កម្មវិធីដោយផ្អែកលើឆន្ទៈរបស់ពួកគេ ដើម្បីធ្វើរបាយការណ៍នេះ នៅកន្លែងណាដែលពួកគេធ្វើការ។ |
| **តំបន់ជាគោលដៅ** | តំបន់គោលដៅនៃគំនិតផ្តួចផ្តើមនេះ គឺនៅតាមឃុំ-សង្កាត់។ ចំពោះការជ្រើសរើសឃុំ-សង្កាត់ ក្រុមគោលដៅមន្ត្រី ក្រុមប្រឹក្សាឃុំ-សង្កាត់ តំណាងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ក្រុមស្រាវជ្រាវឃុំ ព្រមទាំងថ្នាក់ដឹកនាំមូលដ្ឋានទាំងអស់ ត្រូវបានអញ្ជើញនិងលើកទឹកចិត្តឱ្យចូលរួមក្នុងដំណើរការវាយតម្លៃ ភាពសមស្របដែលនាំទៅរកការកំណត់ឃុំ-សង្កាត់ជាគោលដៅ។ ការវាយតម្លៃនឹងត្រូវធ្វើតាមរបៀបប័ណ្ណដាក់ពិន្ទុចំពោះការវាយតម្លៃបន្ទាន់។ ដំណើរការនៃការជ្រើសរើសនេះ ត្រូវមើលទៅលើលក្ខខណ្ឌដំបូង ដែលត្រូវគ្នានឹងឆន្ទៈរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីឆ្លើយតបទៅនឹងព័ត៌មានត្រឡប់របស់ប្រជាពលរដ្ឋនៅក្នុងឃុំ-សង្កាត់ ព្រមទាំងវត្តមាន និងភាពរឹងមាំរបស់អង្គការសង្គមស៊ីវិលនៅតាមឃុំ-សង្កាត់។ អ្នកអនុវត្តន៍ការងារអាចជ្រើសរើសឃុំ-សង្កាត់គោលដៅដែលមានស្រាប់ ឃុំ-សង្កាត់ថ្មីណាមួយដែលពួកគេមានគម្រោងធ្វើការជាមួយ គឺត្រូវចាប់ផ្តើមអនុវត្តពី១ឃុំរហូតដល់ចំនួនឃុំដែលគេយល់ថាអាចគ្រប់គ្រងបាន។ |
| **ក្រុមជាគោលដៅនិងអ្នកទទួលផល** | ចុងក្រោយបង្អស់ អ្នកទទួលផលនៃគម្រោងនេះ គឺជាប្រជាពលរដ្ឋធម្មតា (អ្នកប្រើប្រាស់សេវាកម្ម) នៅក្នុងឃុំ-សង្កាត់ ដែលមានចំណេះដឹង និងការយល់ដឹងអំពីសិទ្ធិនិងការទទួលខុសត្រូវរបស់ពួកគេក្នុងនាមជាប្រជាពលរដ្ឋ ដើម្បីធ្វើការផ្លាស់ប្តូរ និងកែលំអ តាមរយៈការផ្តល់ព័ត៌មាននិងការអប់រំ និងតាមរយៈការអនុវត្តគំនិតផ្តួចផ្តើមនានា ដើម្បីទាមទារឱ្យមានការឆ្លើយតបនិងមានគណនេយ្យភាពពីអ្នកដែលពួកគេបានបោះឆ្នោតឱ្យកាន់អំណាច។ កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ក៏ត្រូវកំណត់គោលដៅរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលមានមូលដ្ឋាន នៅតាមបណ្តាខេត្ត និងស្រុក ដែលមានសមត្ថភាពក្នុងការជំរុញឱ្យមានគណនេយ្យភាព ចំពោះកិច្ចការសង្គមរបស់គេ អាចនឹងត្រូវកែលំអតាមរយៈសកម្មភាពរៀនសូត្រផ្សេងៗ។ រដ្ឋបាលមូលដ្ឋាន ក្នុងស្រុកក៏ដូចជាទីភ្នាក់ងារផ្តល់សេវាកម្មដែរ គឺជាគោលដៅគាំទ្រ |

| | |
|---|---|
| | ការតស៊ូមតិចំពោះ គំនិតផ្តួចផ្តើមដោយសុំឱ្យមានគណនេយ្យភាព ចំពោះកិច្ចការសង្គមនេះ។ ចុងក្រោយបង្អស់ បណ្តាញផ្សព្វផ្សាយព័ត៌មាន ដែលមានទ្រង់ទ្រាយធំ ត្រូវបានកំណត់គោលដៅថា ជាយន្តការសំរាប់ការគាំទ្រ ហើយត្រូវបានគេរំពឹងថានឹងដើរតួនាទីសំខាន់មួយក្នុងការ បញ្ជាក់ប្រាប់ឱ្យច្បាស់ អំពីបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងការគាំទ្រការតស៊ូមតិដែល បានកំណត់ដោយកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។ |

## ផែនការអនុវត្តសកម្មភាព

ដើម្បីសម្របសម្រួលដល់ការអនុវត្តការងារស្រាវជ្រាវនៅតាមមូលដ្ឋាន និងសកម្មភាពនៃការគាំទ្រការតស៊ូមតិ ឬគាំទ្រមតិផ្សេងៗឱ្យបានរលូន អ្នកអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ត្រូវតែរៀបចំផែនការសកម្មភាព ដើម្បីដឹកនាំការអនុវត្តតាមតំបន់គោលដៅផ្សេងៗ។ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកត្រូវបែងចែកពេលឱ្យបានគ្រប់គ្រាន់ក្នុងការបង្កើតផែនការសកម្មភាពនានា ដែលអាចបត់បែនបានដោយធ្វើការពិចារណាទៅលើការពិតជាក់ស្តែង ដែលអាចកើតឡើងដោយមិនបានគ្រោងទុកនៅក្នុងមូលដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយ សូមជូនជាយោបល់ថា គ្រប់អ្នកអនុវត្តផែនការសកម្មភាពទាំងអស់យ៉ាងហោចណាស់ត្រូវតែបញ្ចូលភារកិច្ចដូចខាងក្រោម :

១. រៀបចំការវាយតំលៃឱ្យបានឆាប់រហ័សនៅតាមបណ្តាឃុំ-សង្កាត់ស្តីអំពីភាពសមស្របនៃគំនិតផ្តួចផ្តើមរបស់កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។

២. កំណត់អត្តសញ្ញាណ និងជ្រើសរើសអ្នកអនុវត្តការងារនៅក្នុងមូលដ្ឋាន ឬក្រុមស្រាវជ្រាវឃុំ ឬក្រុមប្រជាពលរដ្ឋនៅតាមឃុំ-សង្កាត់ ឱ្យយកគំនិតផ្តួចផ្តើមរបស់កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន យកទៅអនុវត្ត។

៣. កំណត់អត្តសញ្ញាណ និងជ្រើសរើសឃុំ-សង្កាត់ជាគោលដៅ ព្រមទាំងចរចារ និងបញ្ចុះបញ្ចូលជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់សុំការយល់ព្រម ដើម្បីផ្សព្វផ្សាយគំនិតផ្តួចផ្តើមរបស់កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។

៤. កំណត់អត្តសញ្ញាណ ជ្រើសរើស និងធ្វើឱ្យសេវាកម្មសំខាន់នានាឱ្យមានសុពលភាព ព្រមទាំងរៀបចំបញ្ជីរសំណួរ។

៥. រៀបចំអនុស្សារណៈនៃការព្រមព្រៀងជាបន្ទាន់សំរាប់អ្នកម៉ៅការ ប្រសិនបើចាំបាច់

៦. បើកវគ្គបណ្តុះបណ្តាលតំរងទិសឱ្យស្គាល់ពីគោលគំនិត និងវិធីសាស្ត្រមួយចំនួន ដល់ក្រុមអនុវត្តការងារ អង្គការក្រៅរដ្ឋាភិបាល ក្រុមស្រាវជ្រាវឃុំ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអ្នកផ្តល់សេវាកម្ម ។

៧. ធ្វើឱ្យក្រុមប្រឹក្សាឃុំចូលរួមក្នុងរាល់ដំណាក់កាលនៃដំណើរការទាំងអស់ ។

៨. ជំរុញឱ្យមានកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាននៅតាមឃុំ-សង្កាត់និងជាសាធារណៈ ។

៩. ធ្វើផែនការស្តីពីការស្ទាបស្ទង់ទៅលើការចូលរួមមតិនៅតាមតំបន់ពិតប្រាកដ រួមមានការពន្យល់ណែនាំអំពីការស្ទាបស្ទង់និងវិធីសាស្ត្រគំរូ ការណែនាំដល់អ្នកឆ្លើយសំនួរ ការដាក់ភារកិច្ចឱ្យសមាជិកក្រុមស្រាវជ្រាវឃុំ ធ្វើសមាហរណកម្មនិង ធ្វើឱ្យទិន្នន័យនិងព័ត៌មានផ្សេងៗមានសុពលភាព ។ល ។

១០. ជួយបច្ចេកទេសនៅតាមមូលដ្ឋាន ដោយបង្ហាត់បង្ហាញ និងណែនាំដល់អ្នកអនុវត្តការងារនៅក្នុងមូលដ្ឋាន ដើម្បីណែនាំពីការបង្កើតបញ្ជីសំណួរ ការអនុវត្តការស្ទាបស្ទង់មតិនៅតាមមូលដ្ឋាន ការវិភាគទិន្នន័យធ្វើឱ្យលទ្ធផលផ្សេងៗមានសុពលភាព និងរៀបចំលទ្ធផលកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ដើម្បីពន្យល់ និងបង្ហាញក្នុងអំឡុងពេលអនុវត្តការងារ ។

១១. ពន្យល់ណែនាំ បើកវេទិកាសាធារណៈ និងពិភាក្សា ដើម្បីបង្ហាញជូន និងធ្វើឱ្យលទ្ធផលរកឃើញមួយចំនួនទៀត ដែលទទួលបានពីកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានមានសុពលភាព ។

១២. ផ្សព្វផ្សាយព័ត៌មានអំពីលទ្ធផលកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានដល់អ្នកចូលរួម និងបណ្តាញផ្សព្វផ្សាយព័ត៌មាននានា ។

១៣. បណ្តុះបណ្តាលអំពីការតស៊ូមតិដល់ប្រជាពលរដ្ឋថ្នាក់ក្រោម និងការប្រើប្រាស់លទ្ធផលកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ជាចំណុចរៀនសូត្រសំរាប់ យុទ្ធនាការតស៊ូមតិនានា ដើម្បីលើកឡើងនូវបញ្ហាទាំងឡាយ ដែលបានកំណត់នៅក្នុងកម្មវិធីនេះ ។

១៤. ផ្សព្វផ្សាយវិធីសាស្ត្រ និងបទពិសោធន៍នានានៃការអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ជូនដល់ក្រុមអ្នកគាំទ្រជាទ្រង់ទ្រាយធំ ដើម្បីលើកទឹកចិត្តឱ្យមានការអនុវត្តឡើងវិញនូវដំណើរការដែលទាក់ទងនឹងអ្នកចូលរួម និងបណ្តាញផ្សព្វផ្សាយព័ត៌មាននានា និងជួបប្រជុំរួមគ្នាមួយនៅតាមឃុំ-សង្កាត់ ។

១៥. ពិនិត្យ និងវាយតំលៃសកម្មភាពនានា និងធានាឱ្យបាននូវនិរន្តរភាព ។

១៦. ពង្រឹងបណ្តាញក្រុមការងារនៅតាមមូលដ្ឋាន ។

១៧. ធ្វើការជាមួយបណ្ដាញផ្សព្វផ្សាយព័ត៌មាន និងអង្គការក្រៅរដ្ឋាភិបាលដទៃទៀត លើការគាំទ្រគោលនយោបាយ ។

## ឯកសារយោង


1. Narayan 2000: Voice of the poor

2. Royal Government of Cambodia, 2004: progress report on implementation of national poverty reduction strategy



# ម៉ូឌុលទី ៤

# ការអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន

ការអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន

## គោលបំណងរបស់ម៉ូឌុល

ដើម្បីធ្វើឱ្យសិក្ខាកាមយល់ដឹងអំពីដំណើរការ និងសកម្មភាពនៅក្នុងការអនុវត្ត កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។

## ការរំពឹងទុករបស់ម៉ូឌុល

ត្រូវបានរំពឹងទុកថា នៅទីបញ្ចប់នៃផ្នែកនេះ សិក្ខាកាមនឹងមានចំណេះដឹងជាមូលដ្ឋានស្តីពី :

- វដ្តនៃដំណើរការក្នុងការអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន និងលំហូរនៃសកម្មភាព ដែលតម្រូវដើម្បីអនុវត្ត។
- ការពិណនាលំអិតពីរបៀបសកម្មភាពនិមួយៗដែលនឹងត្រូវធ្វើ។
- ឱវាទមួយចំនួនសំរាប់ភាពជោគជ័យ។
- ការគ្រប់គ្រង និងអនុវត្តន៍កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។




4.1

## ដំណើរការនៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន




## ដំណាក់កាល និងបណ្តុំនៃសកម្មភាព

បណ្តុំសកម្មភាពគេមិនចាំបាច់ដាក់ទៅតាមលំដាប់លំដាប់លំដោយនៃការអនុវត្តទេ គឺមានន័យថា គេអាចបត់បែនបាន។ សកម្មភាពខ្លះគេអាចអនុវត្តវាជាបន្តឥតឈប់ ហើយអនុវត្តគ្រប់ដំណាក់កាលទាំងអស់ រីឯសកម្មភាពខ្លះទៀត គេអាចអនុវត្តវាក្នុងពេលដំណាលគ្នាតែម្តង។ ការអនុវត្តសកម្មភាពទាំងនោះ គឺវាអាស្រ័យទៅលើ ថាតើអ្នកណាជាអ្នកអនុវត្តវា។

### ដំណាក់កាលទី ១ : ការបណ្តុះបណ្តាល ការរៀបចំ និងការណែនាំដំបូង

- ការប៉ាន់ប្រមាណយ៉ាងឆាប់រហ័សនៅក្នុងឃុំដើម្បីកំណត់នូវភាពសមស្របក្នុងដំណើរការនៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។
- ការកំណត់ និងជ្រើសរើសបណ្តាឃុំដែលជាក្រុមគោលដៅ
- ការចរចារ និងបណ្តុះបណ្តាលដើម្បីទទួលការយល់ព្រម និងចាប់ផ្តើមដំណើរការ
- ការកំណត់ ការជ្រើសរើស និងការបញ្ជាក់ពីសេវាកម្មជាមូលដ្ឋាន
- ការបង្កើតបញ្ជីសំណួរ
- ការជ្រើសរើសអង្គការអនុវត្តក្នុងស្រុក
- ការរៀបចំបង្កើតក្រុមអ្នកស្រាវជ្រាវថ្នាក់ឃុំ

- ការរៀបចំកិច្ចសន្យា និងអនុស្សារណៈយោងផ្លូវការ
- ការបើកវគ្គបណ្ដុះបណ្ដាលគ្រូបង្គោល ស្ដីអំពីគោលគំនិត និងវិធីសាស្ត្រ។
- ការជុំរុញកម្មវិធីមតិប្រជាពលរដ្ឋស្ដីពីអភិបាលកិច្ចមូលដ្ឋានក្នុងចំណោមក្រុមប្រឹក្សាឃុំ និងសាធារណៈជន។

### ដំណាក់កាលទី២ : ការធ្វើអង្កេតលើការវាយតំលៃរបស់ប្រជាពលរដ្ឋ (សកម្មភាពចុះដល់កន្លែង)

- រៀបចំផែនការសកម្មភាពសំរាប់ការធ្វើអង្កេតលើការវាយតំលៃរបស់ប្រជាពលរដ្ឋនៅតាមតំបន់គោលដៅ។
- គ្រោងសំណាក់នៃអ្នកផ្ដល់ចម្លើយ
- ផ្ដល់ការបណ្ដុះបណ្ដាល ការហ្វឹកហ្វឺន និងការណែនាំដំបូង
- បញ្ចាក់ពីលទ្ធផល វិភាគទិន្នន័យ និងសរសេររបាយការណ៍វាយតំលៃកម្មវិធីនេះ
- ត្រួតពិនិត្យ និងបន្តផ្ដល់ជំនួយគាំទ្រផ្នែកបច្ចេកទេស

### ដំណាក់កាលទី ៣ : ការបង្ហាញលទ្ធផល ការធ្វើវេទិកាពិភាក្សា ការពិគ្រោះ និងយុទ្ធនាការនៃការតស៊ូមតិ

- ប្រជុំជាមួយក្រុមប្រឹក្សាឃុំ និងអ្នកផ្ដល់សេវាកម្មដទៃទៀត
- ការរៀបចំការងារតស៊ូមតិ
- បង្កើត និងពង្រឹងបណ្ដាញការងារក្នុងស្រុកព្រម និងរក្សានិរន្តរភាព

### ដំណាក់កាលទី ៤ : ការវាយតំលៃលើដំណើរវិវត្តន៍ និងការរីកចំរើន

- សកម្មភាពនៃការវាយតំលៃ
- ការផ្សព្វផ្សាយ និងការផ្សាយបន្ត




**4.2**

### តើត្រូវអនុវត្តសកម្មភាពនីមួយៗយ៉ាងដូចម្ដេច?

**សកម្មភាពដែលរៀបរាប់ខាងក្រោមនេះ មិនត្រូវបានរៀបចំទៅតាមលំដាប់លំដោយនោះទេ!**

សកម្មភាពទាំងឡាយមិនចាំបាច់រៀបទៅតាមលំដាប់លំដោយនោះទេ គឺអាចបត់បែនបាន។ សកម្មភាពខ្លះគេអាចអនុវត្តវាជាបន្ត ហើយឆ្លងកាត់គ្រប់ដំណាក់កាលទាំងអស់ រីឯសកម្មភាពខ្លះទៀតគេអាចអនុវត្តវាព្រមពេលជាមួយគ្នាតែម្តង។ អង្គការអនុវត្តសកម្មភាពអាចជ្រើសរើស ថាតើគេចង់អនុវត្តសកម្មភាពណាមុនអាស្រ័យទៅតាមភាពងាយស្រួលសំរាប់ពួកគេ។ សកម្មភាពទាំងនេះ គឺវាអាស្រ័យទៅលើថាតើអ្នកណាជាអ្នកអនុវត្តវា ។

## សកម្មភាព ទី១ : ការប៉ាន់ប្រមាណភ្លាមៗរបស់ឃុំចំពោះភាពសមស្របសំរាប់កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន

អង្គការអនុវត្តនៃគំនិតផ្តួចផ្តើមកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន គួរតែប៉ាន់ប្រមាណភ្លាមៗ ដើម្បី កំណត់ភាពសមស្របក្នុងការអនុវត្តដំណើការនេះនៅក្នុងឃុំ។ ការប៉ាន់ប្រមាណនេះ គឺជាឱកាសសំរាប់ធ្វើការសង្កេត និងវាយតំលៃទៅលើទស្សនះរបស់ក្រុមប្រឹក្សាឃុំ ប្រជាពលរដ្ឋនៅក្នុងឃុំ និងអ្នកអភិវឌ្ឍន៍ក្នុងមូលដ្ឋាន ដែលទាក់ទងទៅនឹងការជ្រើសរើសឃុំសំរាប់ ដំណើការកម្មវិធីនេះ។ វាទាមទារឱ្យមានការប្រើប្រាស់និតិវិធីដែលមានការចូលរួម ដើម្បីបង្កលក្ខណ:ឱ្យក្រុមប្រឹក្សា ឃុំ-សង្កាត់ ថ្នាក់ដឹកនាំក្នុងរដ្ឋអំណាចមូលដ្ឋាន អ្នកតំណាងសង្គមស៊ីវិល និងប្រជាពលរដ្ឋ ដើម្បីប៉ាន់ប្រមាណទៅលើភាពសមស្របក្នុងការឈានទៅកំណត់ជ្រើសរើសឃុំគោលដៅ សំរាប់អនុវត្តគំនិតផ្តួចផ្តើមរបាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋ។ ការប៉ានប្រមាណនេះ ត្រូវបានធ្វើឡើងតាមរយ:ការប្រើប្រាស់ប័ណ្ណដាក់ពិន្ទុ និងត្រូវមើលបណ្តាលក្ខខណ្ឌដែលមានជាមុនមួយចំនួនដូចខាងក្រោមនេះ តើអាចបំពេញបានដែរឬទេ :

- ឆន្ទ:របស់មន្ត្រីក្រុមប្រឹក្សាឃុំក្នុងការឆ្លើយតបទៅនិងព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋ
- កំរិតនៃភាពប្រែប្រួលរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ
- វត្តមាន និងភាពខ្លាំងរបស់អង្គការសង្គមស៊ីវិលក្នុងស្រុកដែលមាននៅក្នុងឃុំ
- សេវាកម្មសង្គមជាមូលដ្ឋានដែលមានស្រាប់
- ភាពសមស្រប
- ពេលវេលា
- ភាពសាទរ

❑ កក្តាជំរុញដទៃទៀត

បុគ្គលិកត្រូវគាំទ្រនៅក្នុងការរៀបចំប័ណ្ណដាក់ពិន្ទុ និងសំនួរ និងការរៀបចំការណាត់ជួបជាមុន។ អង្គការអនុវត្តក្រៅរដ្ឋាភិបាលគួរតែរៀបចំការប្រជុំដាច់ដោយឡែកជាមួយមន្ត្រីក្រុមប្រឹក្សាឃុំនានា ឬប្រជុំរួមគ្នាក៏អាចធ្វើទៅបានដែរ។ ក្រៅពីបុគ្គលិកនេះ អង្គការអនុវត្តក្រៅរដ្ឋាភិបាលអាចស្នើសុំមេភូមិ ក្រុមប្រឹក្សាឃុំ អង្គការសង្គមស៊ីវិលនៅក្នុងស្រុក ឬក៏ប្រជាពលរដ្ឋឱ្យជួយក្នុងការត្រៀមរៀបចំនេះ។

## សកម្មភាព ទី២ : អត្តសញ្ញាណកម្ម និងការជ្រើសរើសឃុំគោលដៅ

ឃុំគឺជាចំណុចគោលដៅតំបូង និងជាចំណុចចាប់ផ្តើមក្នុងការអនុវត្តគំនិតផ្តួចផ្តើមនេះ។ បន្ទាប់ពីសកម្មភាពនៃការប៉ាន់ប្រមាណភ្លាមៗត្រូវបានបញ្ចប់ អង្គការអនុវត្តសកម្មភាពនេះអាចកំណត់បានថា តើឃុំណាខ្លះដែលមានលក្ខណៈសមស្របសំរាប់ដំណើការកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។ ការជ្រើសរើស នឹងត្រូវធ្វើឡើងដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់។ អង្គការអនុវត្តសកម្មភាពនេះអាចជ្រើស រើសយកឃុំដែលខ្លួនកំពុងធ្វើការនៅក្នុងនោះស្រាប់ ឬក៏ឃុំថ្មីផ្សេងទៀត ដែលគេមានផែនការ នឹងត្រូវធ្វើការជាមួយ ដើម្បីធ្វើជាឃុំគោលដៅ។ ធ្វើរបៀបនេះ គេអាចចាប់ផ្តើមពីឃុំមួយប៉ុណ្ណោះជាដំបូង រហូតទាល់តែ មានការពេញចិត្តទៅនឹងចំនួនឃុំដែលគេចង់បាន សំរាប់ធ្វើជាឃុំគោលដៅ។ ចំនួនអតិបរិមានៃឃុំដែលកំណត់ ជាឃុំគោលដៅអាស្រ័យទៅលើការវាយតំលៃអំពីសមត្ថភាពនៃការគ្រប់គ្រងរបស់ឃុំទាំងនោះ។ ការជ្រើស យកឃុំរវាងពី ៣ ទៅ ៥ ឃុំ គួរតែជាចំនួនដែលអាចគ្រប់គ្រងបានដោយ អង្គការអនុវត្តសកម្មភាពនេះ។ ការដាក់កំរិតក្នុងការជ្រើសរើសគួរតែផ្អែកទៅលើលទ្ធផលនៃការប៉ាន់ប្រមាណភ្លាមៗ ឬក៏ព័ត៌មានពី ការអង្កេតដើមដំបូង ដែលក្នុងនោះអង្គការអនុវត្តសកម្មភាព បានបង្កើតឱ្យមានជាលក្ខណៈវិនិច្ឆ័យបែបងាយ ណាមួយទៅតាមការចង់បានរបស់ខ្លួន។ ក្នុងករណីដែលគេចង់ជ្រើសរើសយកឃុំថ្មី នោះអង្គការអនុវត្ត សកម្មភាពអាចពឹងពាក់ក្រុមប្រឹក្សាឃុំ ដើម្បីយល់ព្រមនិងអនុម័តជាផ្លូវការ ឬរដ្ឋអំណាចថ្នាក់ស្រុក ឬក៏ការិយាល័យរដ្ឋបាលមូលដ្ឋានខេត្តឱ្យជួយ។ ជាដំបូងទាន អង្គការអនុវត្តសកម្មភាព គួរតែទទួលយក ចំនួនឃុំឱ្យបានច្រើនយកមកធ្វើការពិចារណា ហើយបន្ទាប់មកឆ្លងកាត់ការពិនិត្យ ការវិភាគ ជ្រើសយក ឃុំក្នុងចំនួនណាមួយដែលខ្លួនចង់បានមកធ្វើជាឃុំគោលដៅសំរាប់ការអនុវត្តគំនិតផ្តួចផ្តើមនេះ។ ឃុំទាំងឡាយដែលបានជ្រើសរើស ត្រូវតែបំពេញបានតាមលក្ខណៈវិនិច្ឆ័យ យ៉ាងហោចណាស់ចំនួនពាក់កណ្តាល ក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងអស់ដែលរៀបរាប់ដូចខាងក្រោម ។

**លក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើសក្រុមឃុំគោលដៅ :**

- ឆន្ទៈរបស់ក្រុមប្រឹក្សាឃុំក្នុងការឆ្លើយតបទៅនឹងព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋ
- ភាពនាំមុខក្នុងការដឹកនាំរបស់ប្រធានក្រុមប្រឹក្សាឃុំ
- កំរិតនៃភាពប្រែប្រួល ឬភាពសកម្មរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ
- វត្តមាន និងភាពខ្លាំងរបស់អង្គការក្រៅរដ្ឋាភិបាល អង្គការសហគមន៍មូលដ្ឋាន ។ល ។
- ភាពមានស្រាប់ ឬភាពអាចរកបាននៃសេវាកម្មជាមូលដ្ឋាន
- តម្រូវការក្នុងស្រុកខ្ពស់
- កំរិតអភិវឌ្ឍន៍ទាបពេក
- ការមិនពេញចិត្តក្នុងកំរិតខ្ពស់
- ភាពសមស្រប
- ពេលវេលា
- ភាពសាទរ
- ភាពដែលរកបាននូវប្រព័ន្ធផ្សព្វផ្សាយ
- កត្តាជួយដទៃទៀត

**កំណត់សំគាល់** ការកំណត់ និងការជ្រើសរើសឃុំគោលដៅ គឺទាក់ទងយ៉ាងខ្លាំងទៅនឹងភាពងាយស្រួល ឬសុគ្រស្វាញនៃការអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។ ចំនួនឃុំដែលត្រូវ ជ្រើសរើសគួរតែមានលក្ខណៈសមស្របទៅនឹងសមត្ថភាពក្នុងការអនុវត្ត សកម្មភាពការងាររបស់អង្គការអនុវត្ត សមត្ថភាពនិងចំនួនបុគ្គលិក ប្រភពធនធានហិរញ្ញវត្ថុ ពេលវេលារួមទាំងសមត្ថភាពក្នុងការគ្រប់គ្រងផងដែរ ។

អង្គការអ្នកអនុវត្តសកម្មភាពត្រូវតែប្រកាសឱ្យច្បាស់ថា រាល់ការពាក់ព័ន្ធទៅនឹងនយោបាយ មិនត្រូវបានពិចារណានៅក្នុងលក្ខណៈវិនិច្ឆ័យសំរាប់ការជ្រើសរើសនេះទេ ។

## សកម្មភាព ទី៣ : ការចរចារ និងការបញ្ចុះបញ្ចូលដើម្បីការយល់ព្រម និងចាប់ផ្តើម

## ការចរចារ និងការបញ្ចុះបញ្ចូល

សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការចូលរួម ត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញ ហើយច្បាប់និងគោលនយោបាយនានាដែលទាក់ទងនឹងវិមជ្ឈការត្រូវបានសំរេចដោយរដ្ឋាភិបាល។

ចាប់តាំពីដំណាក់កាលសាកល្បងមក ក្រសួងមហាផ្ទៃបានផ្តល់ភាពត្រឹមត្រូវស្របច្បាប់ និងការលើកទឹកចិត្តចំពោះគំនិតផ្តួចផ្តើមនៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាននេះ។ យ៉ាងណាក៏ដោយ ក៏អង្គការអ្នកអនុវត្តសកម្មភាពផ្ទាល់ត្រូវពិភាក្សា និងពិគ្រោះយោបល់ជាមួយ**ក្រុមប្រឹក្សាឃុំ** ឬក៏**មេឃុំ** ដែលទាក់ទងទៅនឹងការចាប់ផ្តើមដំណើការសកម្មភាពការងារនេះនៅក្នុងឃុំដែលខ្លួនធ្វើការ។ អង្គការអ្នកអនុវត្តសកម្មភាពផ្ទាល់ គួរតែរៀបចំ**ការប្រជុំពិសេសជាផ្លូវការមួយ**ជាមួយក្រុមប្រឹក្សាឃុំ ឬក៏លើក ជាសំណើសុំដាក់បញ្ហានេះជារបៀបវារៈមួយនៃ**ការប្រជុំជាទៀងទាត់របស់ក្រុមប្រឹក្សាឃុំ**។ បន្ទាប់ពីការ ចំណាយពលយ៉ាងច្រើនបំផុតត្រឹមកន្លះម៉ោង ក្នុងការធ្វើបទបង្ហាញអំពីគំនិតផ្តួចផ្តើម នៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន រួចមក គេត្រូវបញ្ចុះបញ្ចូលក្រុមប្រឹក្សាឃុំ ដើម្បីឱ្យទទួលការយល់ព្រមគាំទ្រលំដំណើរការអនុវត្តសកម្មភាពនេះ។ នៅក្នុងករណីខ្លះទៀត អង្គការអនុវត្ត សកម្មភាពនេះ អាចនឹងពិភាក្សាជាមួយមេឃុំ មុនពេលដែលត្រូវលើកយករឿងនេះ ទៅដាក់ក្នុងរបៀបវារៈប្រជុំជាផ្លូវការរបស់ក្រុមប្រឹក្សាឃុំ។ ប្រសិនបើចាំបាច់ អង្គការអ្នកអនុវត្តសកម្មភាពផ្ទាល់ ត្រូវស្វែងរកការអនុម័តយល់ព្រមទៅលើគំរោងការងាររបស់ខ្លួនពីសំណាក់**រដ្ឋអំណាចថ្នាក់ស្រុក** ឬក៏**ការិយាល័យរដ្ឋបាលមូលដ្ឋានខេត្ត**។

ត្រូវពន្យល់អំពីគំរោងការងាររបស់ខ្លួនឱ្យបានច្បាស់លាស់។ ត្រូវកត់សំគាល់ថា គឺមានបំណងដើម្បីដាក់ពិន្ទុទៅលើគុណភាពនៃសេវាកម្មដោយមិនគិតថា សេវាកម្មនោះត្រូវបានផ្តល់ទៅឱ្យអ្នកណាឡើយ។ គេគួរតែមើលឱ្យឃើញថា គឺជាយន្តការនៃការគាំទ្រដល់អ្នកផ្តល់សេវាកម្មជាជាងការស្វែងរកចាប់កំហុស។ ត្រូវផ្តល់ការពន្យល់បែបងាយមួយទៅដល់ក្រុមប្រឹក្សាឃុំ ដើម្បីឱ្យពួកគាត់យល់ថា គ្រោងការគំនិតផ្តួចផ្តើមនេះគឺមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងសកម្មភាពអភិវឌ្ឍន៏ដទៃទៀត ហើយក៏ត្រូវញ្ជាក់ឱ្យច្បាស់ផងដែរថា ការងារនេះមិនជាប់ទាក់ទងទៅនឹងរឿងនយោបាយ ឬក្រុមគណបក្សនយោបាយណាមួយឡើយ។ ធ្វើយ៉ាងណាឱ្យគេមើលថា គំនិតផ្តួចផ្តើមនេះ គឺជាយន្តការដ៏ល្អមួយសំរាប់ប្រមូលមតិយោបល់សាធារណៈជន ដែលបានផ្តល់នូវគំនិតដើម្បីឆ្លុះបញ្ចាំងក្នុងន័យស្ថាបនាទៅលើអ្វីដែលក្រុមប្រឹក្សាឃុំបានធ្វើ ហើយជួយដល់ក្រុមប្រឹក្សាឃុំក្នុងការធ្វើផែនការ និងរៀបចំគំរោងការងាររបស់ខ្លួនឱ្យបានកាន់តែប្រសើរជាងមុន។ ត្រូវធ្វើឱ្យប្រាកដថា ក្រុមប្រឹក្សាឃុំស្វាគមន៏ដល់គំនិតផ្តួចផ្តើមនេះ ដោយគ្មានការភ័យខ្លាច និងដោយមានការចាប់អារម្មណ៏ ហើយមិនចាត់ទុកថា វាគឺជារឿងដែលធ្វើឱ្យពួកគាត់មានការអៀនខ្មាស់ និងទទួលការស្តីបន្ទោសពីសារណៈជននោះឡើយ។

**តើគំនិតផ្តួចផ្តើមនៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំដោយរបៀបណា?**

ចំណុចទាក់ទងមួយចំនួនសំរាប់អង្គការអនុវត្តសកម្មភាពផ្ទាល់ត្រូវបានគេពន្យល់ដូចខាងក្រោម :

- វាជួយឱ្យក្រុមប្រឹក្សាឃុំយល់ដឹងពីតម្រូវការ និងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋ។
- វាជួយបង្កើតឱ្យមានចំណងទាក់ទងរវាងក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ។
- វាជួយក្រុមប្រឹក្សាឃុំសំរេចជោគជ័យលើការងាររបស់ខ្លួនតាមរយៈយន្តការត្រួតពិនិត្យ និងឆ្លុះបញ្ចាំងប្រកបដោយការស្ថាបនា ពោលគឺជាមធ្យោបាយដ៏ល្អបំផុតក្នុងការធានាឱ្យមានជោគជ័យ។
- វាប្រាប់ក្រុមប្រឹក្សាឃុំឱ្យដឹងអំពីអ្វីដែលត្រូវ និងអ្វីដែលខុស។
- វាជួយកំចាត់វប្បធម៌អសកម្មរបស់ប្រជាពលរដ្ឋក្នុងការចូលរួម ហើយកសាងនូវស្មារតីយល់ដឹង និងលើកទឹកចិត្តពួកគេឱ្យចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការអនុវត្តសកម្មភាពអភិវឌ្ឍន៍នានានៅក្នុងឃុំរបស់ខ្លួន។
- វាជួយបង្កើនប្រសិទ្ធភាពនៃការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំដែលនឹងជួយឱ្យពួកគេអាចជាប់ឆ្នោតជាថ្មីទៀតនៅអណត្តិក្រោយ។
- វាជួយផ្តល់ក្រុមប្រឹក្សាឃុំនូវគំនិតស្ថាបនាក្នុងការផ្សព្វផ្សាយក្នុងនាមជាអ្នកតំណាងឱ្យប្រជាពលរដ្ឋ។
- វាជួយដល់ក្រុមប្រឹក្សាឃុំក្នុងការសំរេចចិត្តដោយឈរលើទស្សនៈរបស់សាធារណៈជនជាមូលដ្ឋាន។
- វាជួយយ៉ាងសម្បើមក្នុងការកសាងភាពខ្លាំងដល់ក្រុមប្រឹក្សាឃុំទៅលើការងារត្រួតពិនិត្យ និងសហការជាមួយអ្នកផ្តល់សេវាកម្មដទៃទៀត ។

កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន មិនមែនជាឧបករណ៍សំរាប់ទប់ទល់ធម្មតា ទៅនឹងរដ្ឋអំណាចមូលដ្ឋាននោះទេ ប៉ុន្តែវាជួយបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំមិនមែនតែកិច្ចការ រដ្ឋបាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកិច្ចការផ្តល់សេវាកម្មទៀតផង។ វាក៏ជួយផងដែរក្នុងការលើកស្ទួយ កេរ្តិ៍ឈ្មោះរបស់ក្រុមប្រឹក្សាឃុំក្នុងន័យថា ជារដ្ឋអំណាចមូលដ្ឋាន ដែលចេះឆ្លើយតបទៅនឹងតម្រូវការរបស់ ប្រជាពលរដ្ឋ។ ចំណុចពិសេស និងសំខាន់របស់របាយការណ៍តំលៃរបស់ប្រជាពលរដ្ឋគឺការលើកស្ទួយឱ្យមាន តម្លាភាព ការឆ្លើយតប និងការចូលរួម។

**កំណត់សំគាល់** ការទទួលយកគំនិតផ្តួចផ្តើមនេះពីសំណាក់ក្រុមប្រឹក្សាឃុំ ដោយភាពងាយស្រួលឬពិបាក គឺវាអាស្រ័យទៅលើប្រវត្តិការងារជាដៃគូរវាងអង្គការអនុវត្តសកម្មភាព ជាមួយនឹងក្រុមប្រឹក្សាឃុំនាពេលកន្លងមក នៅក្នុងការអនុវត្តសកម្មភាពអភិវឌ្ឍន៍ផ្សេងៗដែលមាននៅក្នុង ឃុំ។ ប្រវត្តិនៃការសហការល្អ និងធ្លាប់មានជំនឿទុកចិត្ត នឹងជួយឱ្យក្រុមប្រឹក្សាឃុំកាត់បន្ថយ ឬលុបបំបាត់បាននូវអារម្មណ៍សង្ស័យ និងភាពមិនប្រាកដប្រជាផ្សេងៗ ហើយកសាងនូវបរិយាកាស

ការងារល្អមួយដែលគំរោងកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាននេះចង់បាន ដើម្បី ប្រតិបត្តិការងារបានល្អ ។

## ការចាប់ផ្តើមដំណើរការ

តាមធម្មតា ពិធីសម្ពោធដំណើរការចាប់ផ្តើមនៃគំរោងកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ត្រូវបានរៀបចំឡើងនៅថ្នាក់ជាតិ ឬថ្នាក់ខេត្ត ប្រសិនបើអង្គការអនុវត្តសកម្មភាព យល់ថាវាជាការចាំបាច់ដែលត្រូវធ្វើ។ នៅក្នុងករណីភាគច្រើន អង្គការទាំងឡាយ ច្រើនតែចាប់ផ្តើមដំណើរការការងាររបស់ខ្លួនតែម្តង។ បន្ទាប់ពីការឯកភាពគ្នាជាមួយក្រុមប្រឹក្សាឃុំ អង្គការអនុវត្តសកម្មភាពត្រូវការបញ្ជាក់ឡើងវិញក្រៅផ្លូវការ ពីសមាជិកក្រុមប្រឹក្សាឃុំដោយផ្ទាល់មាត់ ឬសំបុត្រ អំពីកាលវិភាគសំរាប់ការអនុវត្តសកម្មភាពកម្មវិធីនេះ ក្នុងបំណងដើម្បីធ្វើឱ្យមានកិច្ចសហការល្អ និងដើម្បីឱ្យសមាជិកក្រុមប្រឹក្សាឃុំចូលរួមដោយពេញលេញជាមួយសមាជិកក្រុមដទៃនៅក្នុងការអនុវត្តសកម្មភាពគំរោងនេះ។



### គំណែន និងការប្រើបណ្តាញព័ត៌មាន នៅទីនេះ!

វាជាប្រការសំខាន់ណាស់ក្នុងការប្រើប្រាស់បណ្តាញផ្សព្វផ្សាយព័ត៌មាន ក្នុងដំណាក់កាលការចាប់ផ្តើមដំបូងនៃការអនុវត្តសកម្មភាពគំរោង។ វាជាមធ្យោបាយដើម្បីជួយផ្តល់ព័ត៌មានអំពីសកម្មភាពជាវិជ្ជមានទាំងឡាយរបស់គំរោង ទៅដល់រដ្ឋអំណាចមូលដ្ឋានទាំងថ្នាក់ជាតិ និងថ្នាក់ស្រុក។ វាក៏ជួយផងដែរក្នុងការជំរុញធ្វើឱ្យមន្ត្រីរដ្ឋាភិបាល និងសមាជិកក្រុមប្រឹក្សាឃុំមានការជឿទុកចិត្តទៅលើភាពស្មោះត្រង់ បំណងល្អ សារៈសំខាន់ និងផលប្រយោជន៍នៃគំនិតផ្តួចផ្តើមរបស់គំរោងនេះតាមរយៈបណ្តាញព័ត៌មាន។ នៅក្នុងតួនាទីដ៏សំខាន់មួយបណ្តាញផ្សព្វផ្សាយព័ត៌មាន អាចជួយបង្កឱ្យមានបរិយាកាសល្អ ក្នុងដំណើរការអនុវត្តសកម្មភាពគំរោង។ បណ្តាញផ្សព្វផ្សាយព័ត៌មានក៏ជួយផ្សព្វផ្សាយនូវព័ត៌មាន ឬសារផ្សេងៗទៅកាន់សាធារណៈជនផងដែរ។ ការនេះវានឹងជួយរួមចំណែកលើកកំពស់ការយល់ដឹងរបស់សាធារណៈជនទៅលើប្រធានបទការងាររបស់គំរោង ហើយអាចបញ្ចុះបញ្ចូលឱ្យពួកគេមានចំណាប់អារម្មណ៍ និងត្រៀមខ្លួនប្រកបដោយភាពស្វាហាប់ដើម្បីរួមចំណែកនៅក្នុងដំណើរការការងារនេះ។

## សកម្មភាព ទី៤ : អត្តសញ្ញាណកម្ម ការជ្រើសរើស និងវាយតំលៃសកម្មភាពចំបងៗ

មានចំណុចចាប់ផ្តើមជាច្រើនសំរាប់ការអនុវត្តកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាននេះ ។ គេអាចចាប់ផ្តើមដោយធ្វើការសិក្សាស្វែងយល់លំអិតនៅក្នុងផ្នែកសេវាកម្មសង្គមជាមូលដ្ឋាន គំរោងហេដ្ឋារចនាសម្ព័ន្ធ គំរោងចំណាយថវិកា និងការប្រតិបត្តិការងារផ្សេងៗជាដើម ។ល ។ ដែលមានការទាក់ទងយ៉ាងជិតស្និទទៅនឹងប្រជាពលរដ្ឋ ដោយមិនគិតថា អ្នកណាជាអ្នកធ្វើ ឬជាអ្នកផ្តល់សេវាកម្មទាំងនោះទេ ។ គោលបំណងតំបូងរបស់កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាននេះ គឺកំណត់ចំនួនសេវាកម្មសង្គមជាមូលដ្ឋានទាំងឡាយ និងបញ្ហាផ្សេងៗមួយចំនួនដែលទាក់ទងនឹងការប្រតិបត្តិការងាររបស់ក្រុមប្រឹក្សាឃុំ ។ ប្រភេទសេវាកម្មដែលត្រូវធ្វើការវាយតំលៃ ត្រូវតែមានការកំណត់ និងជ្រើសរើសទៅតាមវិធីដែលមានការចូលរួម ។ ជាឧទាហរណ៍ ការកំណត់ជ្រើសរើសសេវាកម្មដែលត្រូវវាយតំលៃ គួរតែត្រូវបានធ្វើឡើងតាមរយៈការប្រជុំពិគ្រោះយោបល់ជាមួយសមាជិកក្រុមប្រឹក្សាឃុំ ប្រធានភូមិ និងប្រជាពលរដ្ឋ ។ ជាការពិតការកំណត់ជ្រើសរើសប្រភេទសេវាកម្មដែលត្រូវវាយតំលៃ គួរតែធ្វើឡើងដោយផ្អែកទៅលើភាពជាក់ស្តែងនៃវត្តមានរបស់សេវាកម្មទាំងនោះនៅនឹងកន្លែង ជាពិសេសគឺនៅតាមតំបន់ជនបទ ។ នៅក្នុងករណីនេះ វត្តមាននៃសេវាកម្មដែលមាននៅក្នុងតំបន់នឹងក្លាយជាលក្ខណ្ឌដែលត្រូវបំពេញមុនគេ នៅក្នុងដំណើការនៃការជ្រើសរើស ។

**ឧទាហរណ៍អំពីសេវាកម្មមួយចំនួនដែលគួរតែជ្រើសរើសសំរាប់ការវាយតំលៃការសង្កេត :**

- សេវាកម្មសុខភាព
- ការអប់រំកំរិតបឋមសិក្សា
- ប្រព័ន្ធទឹកស្អាតសំរាប់ផឹក
- ធារាសាស្ត្រខ្នាតតូច
- គំរោងផ្លូវថ្នល់ជនបទ
- ការប្រជុំក្រុមប្រឹក្សាឃុំ
- សេវាកម្មផ្នែករដ្ឋបាល ជាដើម ។ល ។

នៅក្នុងឃុំនីមួយៗ អង្គការអនុវត្តសកម្មភាពផ្ទាល់អាចនឹងជ្រើសរើសយកប្រភេទសេវាកម្មចំនួន ២ ឬ ៣ សំរាប់ធ្វើការអង្កេត ។ សេវាកម្មដែលបានជ្រើសរើសអាចនឹងមិនដូចគ្នារវាងពីឃុំមួយទៅឃុំមួយទៀត វាអាស្រ័យលើវត្តមានជាក់ស្តែង និងភាពអាចប្រើប្រាស់បាននៃសេវាកម្មនោះ ។ នៅក្នុងឃុំខ្លះទៀត ប្រភេទសេវាកម្មដែលបានជ្រើសរើសអាចនឹងដូចគ្នា ប៉ុន្តែក្នុងចំនួនខុសគ្នាដោយអាស្រ័យទៅតាមទំហំនៃឃុំ និងកត្តា

ដទៃទៀត ។ ការកំណត់ជ្រើសរើសប្រភេទសេវាកម្មត្រូវតែមានលក្ខណៈទាក់ទង និងសមស្របទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នោះ ក៏ដូចជាតម្រូវការរបស់ឃុំផងដែរ ។ វាគួរតែធ្វើឡើង ដោយអនុលោមទៅតាមអណត្តិរបស់ឃុំ ឬក៏ស្ថិតនៅក្រោមការគ្រប់គ្រង ឬត្រួតពិនិត្យរបស់ក្រុមប្រឹក្សាឃុំ ។ ផ្អែកទៅលើហេតុផលនេះហើយ ទើបបានជាការជ្រើសរើសតម្រូវឱ្យមានការចូលរួមពីក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ ជាពិសេសគឺស្ត្រី ។

**កំណត់សំគាល់** នៅក្នុងករណីទូទៅភាគច្រើន សេវាកម្មទាំងឡាយមិនត្រូវបានផ្តល់ឱ្យដោយក្រុមប្រឹក្សាឃុំទេ ប៉ុន្តែក្រុមប្រឹក្សាឃុំមានតួនាទីស្របច្បាប់ក្នុងការពាក់ព័ន្ធ សហការណ៏ និងសម្របសម្រួលលើដំណើការនៃការផ្តល់សេវាកម្មទាំងនេះ ។ ហេតុដូច្នេះហើយ ទើបក្រុមប្រឹក្សាឃុំក៏ត្រូវមានចំណែកទទួលខុសត្រូវផងដែរចំពោះមុខសាធារណៈជន ចំពោះការផ្តល់សេវាកម្ម ទោះបីជាក្នុងករណីដែលពួកគាត់មិនមែនជាអ្នកផ្តល់សេវាកម្មដោយផ្ទាល់ទៅប្រជាពលរដ្ឋក៏ដោយ ។

## សកម្មភាព ទី៥ : ការគ្រោងបញ្ជីសំណួរ

បញ្ជីរសំណួរគួរតែធ្វើឡើងសំរាប់សេវាកម្មមួយមុខៗ សំរាប់សេវាកម្មនិមួយៗ ។ ចំនួនសេវាកម្មដែលត្រូវជ្រើសរើសនៅក្នុងឃុំនិមួយៗ កំណត់ចំនួនប្រភេទផ្សេងៗនៃបញ្ជីសំណួរដើម្បីប្រើសំរាប់ឃុំនិមួយៗនោះ ។

### ឧទាហរណ៍ :

ប្រសិនបើអង្គការអនុវត្តមួយជ្រើសរើសយកឃុំចំនួន ៣ ដើម្បីអនុវត្តគំរោងកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ហើយនៅក្នុងឃុំនីមួយៗគេកំណត់យកប្រភេទសេវាកម្មចំនួន ២ ដើម្បីធ្វើការវាយតំលៃ ដែលក្នុងនោះ មានប្រភេទសេវាកម្មខ្លះដូចគ្នា ហើយខ្លះខុសគ្នារវាងពីឃុំមួយទៅឃុំមួយ ហេតុដូច្នេះ ចំនួនប្រភេទ បញ្ជីសំណួរដែលនិងត្រូវបង្កើត គឺវាអាស្រ័យទៅនឹងចំនួនសរុប នៃប្រភេទសេវាកម្មទាំងអស់ដែលបានជ្រើសរើស ។ (សូមមើលឧទាហរណ៍ក្នុងតារាងខាងក្រោម) :

| ឃុំ | ប្រភេទសេវាកម្មក្នុងឃុំនីមួយៗ | ចំនួនសរុបនៃសេវាកម្មខុសគ្នា |
|---|---|---|
| ឃុំ ក | • សេវាកម្មសុខភាព<br>• អប់រំកំរិតបឋម | ជារួម →<br>• សេវាសុខភាព<br>• អប់រំកំរិតបឋម<br>• ប្រព័ន្ធទឹកស្អាតសំរាប់ផឹក<br>• គំរោងផ្លូវថ្នល់ជនបទ |
| ឃុំ ខ | • សេវាកម្មសុខភាព<br>• ប្រព័ន្ធទឹកស្អាតសំរាប់ផឹក | |
| ឃុំ គ | • អប់រំកំរិតបឋម | |

| | | |
|---|---|---|
| | • គំរោងផ្លូវថ្នល់ជនបទ | |

មានប្រភេទសេវាកម្មចំនួន ៤ ខុសៗគ្នានៅក្នុងករណីនេះ ហេតុដូច្នេះ អង្គការអនុវត្តសកម្មភាពផ្ទាល់ត្រូវធ្វើប្រភេទបញ្ជីសំណួរចំនួន ៤ ខុសៗគ្នាផងដែរ សំរាប់ការធ្វើអង្កេតទៅលើអត្រានៃសេវាកម្ម។ ចំនួនបញ្ជីសំណួរដែលប្រើប្រាស់ គឺអាស្រ័យទៅតាមចំនួនសរុបនៃអ្នកឆ្លើយចំពោះប្រភេទសេវាកម្មនីមួយៗ និងសំរាប់គ្រប់ការអង្កេតទាំងអស់ដែលនឹងត្រូវធ្វើនៅក្នុងឃុំគោលដៅដែលបានជ្រើសរើសរួច។

មធ្យោបាយល្អមួយនៃការគ្រោងបញ្ជីសំណួរ ត្រូវឱ្យសមាជិកជាដៃគូទាំងអស់ និងក្រុមស្រាវជ្រាវថ្នាក់ឃុំចូលរួមពិភាក្សានៅក្នុងដំណើរការនេះ ហើយដើម្បីឱ្យពួកគេមានការយល់ដឹងអំពីការងារដែលត្រូវធ្វើ និងងាយស្រួលក្នុងការដេញដោលសាកសួរព័ត៌មានលំអិតបន្ថែម ទៅតាមការចាំបាច់នៅក្នុងអំឡុងពេលនៃការធ្វើអង្កេត។ បញ្ជីសំណួរដែលល្អ គឺជាបញ្ជីរសំណួរដែលងាយយល់និងសួរ ហើយមានន័យទាក់ទងទៅនឹងបញ្ហាដែលជាប្រធានបទនៃការស្វែងយល់។ មានគោលការណ៍ណែនាំមួយចំនួនសំរាប់ពិចារណា នៅពេលបង្កើតបញ្ជីសំណួរសំរាប់ការធ្វើអង្កេត។

**គោលការណ៍ណែនាំសំរាប់ការគ្រោងបញ្ជីសំណួរនៃការអង្កេត៖**

- រៀបចំនៅក្នុងរបៀប និងទម្រង់បែបសាមញ្ញ។
- ចាប់ផ្តើមដោយសេចក្តីផ្តើមសមស្របត្រឹមត្រូវ និងមានគោលបំណងច្បាស់លាស់។
- ប្រើប្រាស់ភាសាក្នុងស្រុកដែលអ្នកឆ្លើយងាយយល់។
- សំណួរគួរតែមានលក្ខណៈសាមញ្ញ និងងាយយល់ - សួរហើយពន្យល់។
- ពាក្យបច្ចេកទេស និងពាក្យពិបាកផ្សេងៗគួរតែកែសំរួលឱ្យងាយយល់។
- ព្យាយាមប្រើប្រាស់សំណួរបើកឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។
- គ្រប់សំណួរទាំងអស់ត្រូវមានលក្ខណៈទាក់ទិន និងមានប្រយោជន៍ចំពោះប្រធានបទនៃការស្វែងយល់។

សំណួរគួរតែជីករកមូលហេតុផ្សេងៗសំរាប់អ្នកដែលមិនសូវសប្បាយចិត្ត ដោយលើកឡើងឱ្យគេមើលឃើញពីភាពខ្វះខាត ភាពខ្សោយ និងការរំខាននានានៅក្នុងការផ្តល់សេវាកម្ម ហើយស្នើសុំអនុសាសន៍ដើម្បីកែលំអ។ បញ្ជីសំណួរដែលបង្កើតឡើងសំរាប់ប្រភេទសេវាកម្មជាក់លាក់ណាមួយ ត្រូវតែអនុលោមទៅតាមគោលដៅចំបងនៃការពិចារណាអំពីប្រភេទសេវាកម្មនោះ។ តារាងខាងក្រោម ចំពោះគោលដៅសំរាប់ការប៉ាន់ប្រមាណ ដោយយោងទៅតាមប្រភេទនីមួយៗនៃសេវាកម្មសង្គមជាមូលដ្ឋាន។

| សេវាកម្មជាមូលដ្ឋាន | គោលដៅនៃការពិចារណា |
|---|---|
| ការអប់រំកំរិតបឋម | គុណភាព និងភាពគ្រប់គ្រាន់នៃចំនួនថ្នាក់រៀន សៀវភៅនិងសំភារៈសិក្សាដទៃទៀត បុគ្គលិកលក្ខណៈនិងការគោរពម៉ោងពេលរបស់ |

| | |
|---|---|
| | គ្រូបង្រៀន ។ |
| ប្រព័ន្ធទឹកស្អាតសំរាប់ផឹក | **ស្នប់ដៃ និងអណ្តូង** : ការជីកឬខួង ចំងាយពីផ្ទះទៅអណ្តូង ប្រសិទ្ធភាពនៃ ការប្រើប្រាស់អណ្តូង ចំណង់ចំណូលចិត្តរបស់អ្នកប្រើ ការគ្រប់គ្រង និងថែរក្សា ។ |
| សេវាកម្មសុខភាពជាមូលដ្ឋាន | ការចាក់ថ្នាំបង្ការ សេវាកម្មប្រឹក្សាយោបល់សុខភាពម្តាយនិងទារក សេវាកម្មពន្យាកំណើត ការផ្តល់ថ្នាំដោយឥតគិតថ្លៃពីសំណាក់មជ្ឈមណ្ឌលសុខភាពនៅក្នុងឃុំ ។ |
| ធារាសាស្ត្រខ្នាតតូច | ចរន្តទឹកក្រោមដី ប្រឡាយទឹក ស្ថានីយ៏បូមទឹក ការគ្រប់គ្រង ការចែកចាយទឹក ការរៀបចំសំណង់ធារាសាស្ត្រ ការប្រើប្រាស់និង ការប្រមូលថ្លៃឈ្នួល ។ |
| ផ្លូវថ្នល់នៅតាមជនបទ | ផ្លូវពីកសិដ្ឋានទៅកាន់ទីផ្សារ ឬផ្លូវតូចចេញពីឃុំទៅរកផ្លូវធំ : សំណង់ផ្លូវថ្នល់ ការធ្វើបដិភាគរបស់ប្រជាពលរដ្ឋក្នុងស្រុក ផ្លូវដែលអាចធ្វើដំណើរបាន ការថែទាំ ។ |

## សកម្មភាព ទី៦ : ការជ្រើសរើសអង្គការអនុវត្តនៅមូលដ្ឋាន

អង្គការអនុវត្តសកម្មភាពក្នុងស្រុក គឺមានន័យសំដៅដល់អង្គការក្រៅរដ្ឋាភិបាលនានា ដែលធ្វើការទាក់ទងទៅនឹងវិមជ្ឈការ អភិបាលកិច្ចល្អ កំណែទម្រង់សាធារណៈ ហើយមានចំណេះដឹងខ្លះៗអំពីការងារក្រុមប្រឹក្សាឃុំ និងបញ្ហានៅក្នុងសហគមន៏របស់ខ្លួន ជាពិសេស ចំណេះដឹងស្តីអំពីការផ្តល់សេវាសង្គម ។ អង្គការអនុវត្តសកម្មភាពក្នុងស្រុក ក៏មានន័យសំដៅដល់អង្គការសង្គមស៊ីវិល អង្គការសហគមន៏មូលដ្ឋាន និងក្រុមប្រជាពលរដ្ឋក្នុងឃុំ ឬភូមិ ។ ពួកគេគឺជាអ្នកអនុវត្តដ៏សកម្មបំផុតដែលគំរោងចង់បាន ។ ទាក់ទងទៅនឹងបញ្ហាដែលថា តើអ្នកណាជាអ្នកជ្រើសរើសអ្នកណានោះ គឺវាអាស្រ័យទៅលើគំរិតនៃការណែនាំឱ្យស្គាល់គំរោងរសបាយការណ៏វាយតំលៃរបស់ប្រជាពលរដ្ឋ និងថាតើអ្នកណាជាអ្នកចាប់ផ្តើមប៉ុណ្ណោះ ។ លក្ខណៈវិនិច្ឆ័យមួយចំនួនត្រូវតែបង្កើតដាច់ខាត ក្នុងការជ្រើសរើសអង្គការអនុវត្តសកម្មភាព ឬអង្គការដៃគូ ។ ខាងក្រោមគឺជាលក្ខណៈវិនិច្ឆយ័ :

**លក្ខណៈវិនិច្ឆ័យមួយចំនួនសំរាប់ការជ្រើសរើសអង្គការអនុវត្តសកម្មភាព ឬអង្គការដៃគូ :**

- ពួកគេត្រូវតែជាអង្គការក្រៅរដ្ឋាភិបាល អង្គការសង្គមស៊ីវិល អង្គការសហគមន៏មូលដ្ឋាន ឬជាក្រុមប្រជាពលរដ្ឋ ។
- មានមូលដ្ឋាននៅក្នុងខេត្ត ស្រុក ឬឃុំ ជាកន្លែងដែលគំរោងរបាយការណ៏វាយតំលៃរបស់ប្រជាពលរដ្ឋបោះទីតាំង ។
- ធ្វើការពាក់ព័ន្ធទៅនឹងផ្នែកវិមជ្ឈការ អភិបាលកិច្ចល្អ កំណែទម្រង់រដ្ឋបាលសាធារណៈ ។
- មានការយល់ដឹងខ្លះៗអំពីការងារក្រុមប្រឹក្សាឃុំ បញ្ហានៅក្នុងសហគមន៏ ជាពិសេសគឺបញ្ហានៃការផ្តល់សេវាកម្មសង្គម ។
- ធ្វើការជាមួយក្រុមប្រឹក្សាឃុំ

## សកម្មភាព ទី៧ : ការចាត់ចែងក្រុមស្រាវជ្រាវថ្នាក់ឃុំ

សមាជិកក្រុមស្រាវជ្រាវថ្នាក់ឃុំ គឺជាអ្នកអនុវត្តសកម្មភាពនៃការធ្វើអង្កេតជាក់ស្តែងនៅតាមមូលដ្ឋានដោយផ្ទាល់។ ហេតុដូច្នេះហើយ ការជ្រើសរើស និងការរៀបចំបង្កើតសមាជិកក្រុមស្រាវជ្រាវថ្នាក់ឃុំ គឺជារឿងសំខាន់។ បញ្ជីសំណួរគ្រាន់តែជាឧបករណ៍សំរាប់ប្រើប្រាស់ជាមធ្យោបាយដើម្បីស្វែងរកចម្លើយ ប៉ុន្តែវាមិនធានាថា ចំលើយដែលប្រកបដោយគុណភាព និងផ្លែផ្កាគួរជាទីពេញចិត្តនឹងអាចរកបាននោះទេ។ គុណភាពនៃចំលើយដែលយើងនឹងទទួលបាន គឺវាអាស្រ័យទៅលើសមត្ថភាពរបស់សមាជិកក្រុមស្រាវជ្រាវក្នុងការចោទសួរ រុករក និងដេញដោលដើម្បីស្វែងយល់។ ការជ្រើសរើសសមាសភាពក្រុមស្រាវជ្រាវថ្នាក់ឃុំគួរតែមានភាពបត់បែនដោយផ្អែកទៅតាមស្ថានភាពជាក់ស្តែងនៅក្នុងឃុំនិមួយៗ។ អង្គការអនុវត្តសកម្មភាពអាចនឹងបង្កើតលក្ខណៈវិនិច្ឆ័យ និងដំណើរការនៃការជ្រើសរើសទៅតាមការចង់បានរបស់ខ្លួន។

ប្រជាពលរដ្ឋសាមញ្ញដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងឃុំ គឺជាសមាសភាពដែលសមស្របបំផុតសំរាប់ជ្រើសរើសធ្វើជាសមាជិកក្រុមស្រាវជ្រាវថ្នាក់ឃុំ ពីព្រោះពួកគាត់មានការយល់ដឹងអំពីស្ថានភាពនៅក្នុងឃុំជាពិសេស គឺពួកគាត់ស្គាល់អ្នកដទៃទៀតជាច្រើនក្នុងឃុំ ហើយងាយស្រួលក្នុងការទាក់ទងក្នុងអំឡុងពេលអនុវត្តគំរោង។ ហេតុផលមួយទៀត គឺអ្នកឆ្លើយសំណួរអាចនឹងមានអារម្មណ៍ជឿទុកចិត្តក្នុងការឆ្លើយ។ ស្ត្រីគួរតែជាអាទិភាពក្នុងការពិចារណាជ្រើសរើស និងរៀបចំបង្កើតក្រុមស្រាវជ្រាវថ្នាក់ឃុំ។ ការយកសមាជិកក្រុមប្រឹក្សា និងសមាជិកនៃគណៈកម្មាធិការធ្វើផែនការ និងគំរោងថវិការឃុំមកចូលជាសមាជិកក្រុមស្រាវជ្រាវឃុំ គេគួរតែពិចារណាដោយប្រុងប្រយ័ត្ន ពីព្រោះវានឹងអាចធ្វើឱ្យគុណភាពនៃការឆ្លើយសំណួររបស់អ្នកភូមិនៅក្នុងពេលសំភាសន៍នោះមានក៏រិត ឬក៏អ្នកភូមិអាចនឹងបង្ខំចិត្តឆ្លើយតែពីចំណុចវិជ្ជមាន ដែលខុសពីភាពពិតជាក់ស្តែង។

សមាជិកក្រុមប្រឹក្សាឃុំអាចជួយក្នុងការចង្អុលបង្ហាញ ថាក្រុមមនុស្សណាដែលគួរតែជ្រើសរើស ដើម្បីសម្ភាសន៍។ មានរបៀបផ្សេងគ្នាជាច្រើនក្នុងការកំណត់ជ្រើសរើសសមាជិកក្រុមស្រាវជ្រាវថ្នាក់ឃុំ។ អង្គការអនុវត្តសកម្មភាពផ្ទាល់អាចនឹងប្រកាសជាសាធារណៈ ឱ្យមានការដាក់ពាក្យ ឬផ្អែកលើអនុសាសន៍របស់ក្រុមប្រឹក្សាឃុំ ឬក៏ស្វែងរកសកម្មជននៅក្នុងឃុំដើម្បីបំពេញការងារ។ បន្ទាប់ពីជ្រើសរើសបានហើយ អង្គការអនុវត្តសកម្មភាពផ្ទាល់អាចចុះកិច្ចសន្យាជាមួយអ្នកនោះ ដើម្បីទទួលស្គាល់ជាផ្លូវការ។ មានចំណុចគួរពិចារណាមួយចំនួន នៅក្នុងអំឡុងពេលជ្រើសរើសសមាជិកក្រុមស្រាវជ្រាវថ្នាក់ឃុំ។ ចំណុចទាំងនេះមានបង្ហាញនៅក្នុងតារាងខាងក្រោម :

| សមាជិកក្រុមស្រាវជ្រាវថ្នាក់ឃុំ តែត្រូវជ្រើសរើស ត្រូវផ្អែកទៅលើលក្ខណៈវិនិច្ឆ័យមួយចំនួនដូចខាងក្រោម : | ក្រុមមនុស្សមួយចំនួនដែលមានលក្ខណៈសម្បត្តិសមស្របសំរាប់ជ្រើសរើសធ្វើជាសមាជិកក្រុមស្រាវជ្រាវ : | វិធីសាស្ត្រផ្សេងៗមួយចំនួនក្នុងការជ្រើសរើសសមាជិកក្រុមស្រាវជ្រាវ : |
|---|---|---|
| • មានចំណេះដឹងអំពីស្ថានភាពភូមិ និងឃុំ<br>• ផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត<br>• ចេះអាន និងសរសេរ<br>• ស្ត្រីជាអាទិភាព<br>• ផ្អែកលើសមត្ថភាព<br>• ជាអ្នកដែលមិនមានមុខតំណែងជាផ្លូវការណាមួយជាសាធារណៈ<br>• ជាអ្នកសកម្មចូលរួមក្នុងការងារអភិវឌ្ឍន៍។<br>• មានអាយុពី ២០ឆ្នាំទៅ ៤០ឆ្នាំ<br>• មានទំនាក់ទំនងល្អជាមួយអ្នកដទៃ<br>• មានឆន្ទៈក្នុងការចូលរួម<br>• ជាពលរដ្ឋសាមញ្ញធម្មតា<br>• ជាអ្នកមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងឃុំនីមួយៗ | • ប្រធានក្រុមនៅក្នុងភូមិនីមួយៗរបស់ឃុំ<br>• សមាជិកនៃក្រុមប្រឹក្សានិងគណៈកម្មាធិការធ្វើផែនការ និងគំរោងថវិកា<br>• សកម្មជននៅក្នុងសមហគមន៍<br>• ស្ត្រី<br>• គ្រូបង្រៀន<br>• ពលរដ្ឋសកម្មសាមញ្ញធម្មតា | • ត្រូវប្រកាសដាក់ពាក្យជាទូទៅ សំភាសន៍ ជ្រើសរើស និងចុះកិច្ចសន្យា។<br>• មេឃុំចូលរួមក្នុងដំណើការសំភាសន៍ និងជ្រើសរើសសមាជិកក្រុមស្រាវជ្រាវ<br>• សមាជិកក្រុមប្រឹក្សាឃុំចង្អុលបង្ហាញ ហើយអង្គការអនុវត្តសកម្មភាពផ្ទាល់ជាអ្នកជ្រើសរើសចេញពីបញ្ជីដែលក្រុមប្រឹក្សាឃុំផ្តល់អនុសាសន៍ឱ្យ។<br>• បេក្ខជនចូលរួមមកប្រឡងធ្វើតេស្តសាកល្បង។<br>• ត្រូវកំណត់ និងអញ្ជើញបេក្ខជនមកសំភាសន៍។<br>• ត្រូវជ្រើសរើសចំនួនមនុស្សច្រើនចេញពីសហគមន៍ ហើយសំភាសន៍។ |

ក្រុមស្រាវជ្រាវថ្នាក់ឃុំ គួរតែមានចំនួនប្រហែល ១០ នាក់ប៉ុណ្ណោះបានហើយ ដែលជាអ្នកសហការណ៍ ឬជាអ្នកស្រាវជ្រាវ។ ក្នុងចំណោម ១០ នាក់នេះ ពួកគេត្រូវតែបោះឆ្នោះជ្រើសរើសម្នាក់ធ្វើជាប្រធានក្រុម។ ស្ត្រីគេគួរតែលើកទឹកចិត្តចូលជាសមាជិកក្រុម។ ការបង្កើតក្រុមស្រាវជ្រាវ គឺមានបំណងបង្កើតជាក្រុមប្រជាជនដែលជាកម្លាំងនៅក្នុងឃុំនិមួយៗ ដើម្បីធ្វើការទៅលើបញ្ហាទាំងឡាយក្នុងមូលដ្ឋាន ហើយជះឥទ្ធិពលទៅដល់ពួកគេ និងដើម្បីអនុវត្តការតស៊ូមតិថ្នាក់មូលដ្ឋានក្នុងការទាមទារដំណោះស្រាយ និងការកែលំអ។ ក្រុមស្រាវជ្រាវថ្នាក់ឃុំ អាចបង្កើតបណ្តាញថ្នាក់មូលដ្ឋានរឹងមាំរបស់ប្រជាពលរដ្ឋដែលចិតក្នុងឃុំនិមួយៗ។

## សកម្មភាព ទី៨ : ការរៀបចំអនុស្សរណយោគយល់ និងកិច្ចសន្យាជាផ្លូវការ

បន្ទាប់ពីការឯកភាពគ្នា បើសិនចាំបាច់ អនុស្សរណយោងមួយ គួរតែរៀបចំឡើង និងចុះហត្ថលេខាដោយក្រុមប្រឹក្សាឃុំ ឬមេឃុំ និងអង្គការដែលត្រូវអនុវត្តសំរាប់ឃុំនិមួយៗ។ បើសិនជាអង្គការអនុវត្តគឺជាអង្គការក្រៅរដ្ឋាភិបាលជាតិ នោះគឺអាចធ្វើការផ្ទាល់ជាមួយក្រុម

> អនុស្សរណ ជាមួយក្រុមប្រឹក្សាឃុំ និងកិច្ចសន្យាជាមួយក្រុមស្រាវជ្រាវឃុំ គឺប្រសើរបំផុត។ ទោះចង់ ឬមិនចង់ អ្នកត្រូវតែមានវា ដោយផ្អែកទៅតាមប្រភេទនៃអង្គការអនុវត្តរបស់អ្នក។ ជួនកាលបែបផ្លូវការខ្លាំងពេកអាចរិតត្បិតទៅដល់លទ្ធភាព និងផលិតភាពដែលធ្លាប់មាន។

ស្រាវជ្រាវឃុំនៅមូលដ្ឋានខ្លួនដោយខ្លួនឯង ឬធ្វើកិច្ចសន្យាបន្ត ជាមួយអង្គការក្រៅរដ្ឋាភិបាលមូលដ្ឋានថ្នាក់ខេត្តដើម្បីធ្វើការងារនេះ។ នៅក្នុងករណីនេះ គេត្រូវការរៀបចំអនុស្សរណយោងមួយនិងកិច្ចសន្យាជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនោះ ដែលជាអង្គការអនុវត្ត។ ក្នុងករណីអ្នកចាប់ផ្តើម គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ ទាំងនេះក៏ត្រូវតែមានអនុស្សរណយោងមួយជាមួយនឹងឃុំគោលដៅ និងកិច្ចសន្យាជាមួយនឹងសមាជិកម្នាក់ៗរបស់ក្រុមស្រាវជ្រាវឃុំ។ បន្ទាប់ពីការជ្រើសរើស អង្គការអនុវត្តទាំងនោះអាចចុះហត្ថលេខាជាមួយនឹងសមាជិកក្រុមស្រាវជ្រាវឃុំ ដើម្បីទទួលស្គាល់ជាផ្លូវការ។

ដូចដែលបានរៀបរាប់ខាងលើ អង្គការអនុវត្តចាំបាច់ត្រូវរៀបចំអនុស្សរណយោងមួយជាផ្លូវការនិងកិច្ចសន្យាដែលស្របគ្នា។ កិច្ចសន្យាត្រូវតែច្បាស់លាស់ ហើយអនុស្សរណយោងគួរតែសមញ្ញ ច្បាស់លាស់ និងមិនស្មុគស្មាញពេញ ដូចនេះគេអាចទទួលយកដោយភាគីទាំងសងខាង។ ឯកសារទាំងឡាយអាចបញ្ចូលព័ត៌មានពីគោលបំណង ការទទួលខុសត្រូវ ការគាំទ្រហិរញ្ញវត្ថុ រយៈពេលកំណត់ និងទំហំការងារជាដើម ។ល។

## សកម្មភាព ទី៩ : បណ្តុះបណ្តាលគ្រូបង្គោលលើគោលគំនិត និងវិធីសាស្ត្រ

លក្ខខណ្ឌចំបងសំរាប់ការជោគជ័យនៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន គឺវគ្គបណ្តុះបណ្តាល និង ការណែនាំការងារឱ្យបានត្រឹមត្រូវចំពោះអង្គការអនុវត្ត អង្គការសង្គមស៊ីវិល ក្រុមស្រាវជ្រាវឃុំ ក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្ម។ បញ្ហាទាំងនេះ គឺទាមទារអ្នកពាក់ពន្ធ័ទាំងអស់ ចូលរួមនៅក្នុងដំណើរការ ដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាល ស្តីពីគោលគំនិតកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន និងវិធីសាស្ត្រ។ ការណ៏នេះអាចតម្រូវឱ្យមានមេរៀនបណ្តុះបណ្តាលវែងមួយ ឬជាស៊េរីនៃវគ្គបណ្តុះបណ្តាលនៅថ្នាក់ជាតិ ឬ ក៏នៅថ្នាក់តំបន់។ ព្រឹត្តិការណ៏នៃការរៀនសូត្រ អាចបញ្ចូលជាមេរៀន ការសំដែង សិក្ខាសាលា ការបង្ហាញ ជាខ្សែភាពយន្ត លំហាត់នៃការវាស់វែង និងការហ្វឹកហ្វឺន។

### មុនពេលវគ្គបណ្តុះបណ្តាលគ្រូបង្គោល ចំណុចទាំងឡាយខាងក្រោមគួរត្រូវពិចារណា :

- ការបណ្តុះបណ្តាល ចាំបាច់ត្រូវតែធ្វើឡើងនៅក្នុងរយៈពេលសមស្រប និងតាមវិធីសាស្ត្រចូលរួម ដើម្បីបង្កើនកំរិតការយល់ដឹង និងការស្រូបយកគំនិត។
- ពេលវេលា និងប្រធានបទ ចាំបាច់ត្រូវតែសមស្របសំរាប់មនុស្សធម្មតា ដែលមិនធ្លាប់បានគេឱ្យចូលរួមនៅក្នុងសកម្មភាពអស់ទាំងនេះ។
- ក្រុមប្រឹក្សាឃុំ និងមេឃុំ ចាំបាច់ត្រូវតែអញ្ជើញឱ្យចូលរួមវគ្គបណ្តុះបណ្តាល និងធ្វើជាអធិបតីនៅក្នុងពិធីបើកវគ្គ ដើម្បីទាញចេញជាផលប្រយោជន៍ពីការស្ញើចសរសើរ និងទទួលស្គាល់របស់ពួកគេ។

- ការបណ្ដុះបណ្ដាល គួរតែប្រព្រឹត្តឡើងគៀកទៅនឹងតារាងពេលវេលានៃការវាស់វែង ដើម្បីរក្សាព័ត៌មានឱ្យបានច្បាស់នៅក្នុងចិត្តរបស់សិក្ខាកាម។
- តារាងពេលវេលានៃការបណ្ដុះបណ្ដាលការណែនាំការងារ គួរតែអាចផ្លាស់ប្ដូរបាន ព្រោះប្រជាជននៅតាមកន្លែងផ្សេងៗគ្នាអាចជាប់រវល់នៅក្នុងពេលខុសៗគ្នា។
- ការបណ្ដុះបណ្ដាល គួរតែទូលំទូលាយនៅក្នុងខ្លឹមសារ ឬគួរតែតំណាងឱ្យការបន្តសកម្មភាពនៃបំប៉នសមត្ថភាព។ ខ្លឹមសារគួរតែបញ្ចូល ចំណេះដឹងអំពីការងារនៅមូលដ្ឋាន បច្ចេកទេសស្រាវជ្រាវនិងវាស់វែង ការណែនាំការងារសំរាប់ប្រជាជនធម្មតា កំណែនព័ត៌មាន និងការ សម្របសម្រួលការងារឥស្សិមតិ។

## សកម្មភាព ទី១០ : ការជំរុញកម្មវិធីមតិប្រជាពលរដ្ឋស្ដីពីអភិបាលកិច្ចមូលដ្ឋាននៅក្នុងឃុំ និងនៅសាធារណៈ

ការជំរុញកម្មវិធីមតិប្រជាពលរដ្ឋស្ដីពីអភិបាលកិច្ចមូលដ្ឋាន សំដៅលើសកម្មភាពដែលកំពុងប្រព្រឹត្ដ ដែលធ្វើឆ្លងតាមរយៈដំណើរការ។ ការណ៍នេះ គឺជាការពន្យល់ ពីគោលបំណងជាវិជ្ជមាន គុណសម្បត្តិ និងភាពមាន ប្រយោជន៍ នៃ កម្មវិធីមតិប្រជាពលរដ្ឋស្ដីពីអភិបាលកិច្ចមូលដ្ឋាន ចំពោះអ្នកពាក់ពន្ធ័ទាំងអស់។ ការជំរុញ បង្កើនកិរិតទទួលយក និងការកែប្រែភាពខាងក្នុង របស់ប្រជាជន ហើយកើនឡើងការទទួលស្គាល់របស់ប្រជាជន ក្រុមប្រឹក្សា និងអ្នកផ្ដល់សេវាកម្ម។ ការណ៍នេះ គឺអនុញ្ញាតិឱ្យប្រជាជនផ្ដល់តំលៃទៅដល់កម្មវិធីមតិប្រជាពលរដ្ឋស្ដី ពីអភិបាលកិច្ចមូលដ្ឋាន ដែលជាយន្តការមួយ ដើម្បីជំរុញការចូលរួមរបស់សាធារណ និង អាចធ្វើឱ្យប្រជាពលរដ្ឋផ្ដល់ព័ត៌មានត្រឡប់វិញ ចំពោះការផ្ដល់សេវាកម្ម។ វាក៏អនុញ្ញាតិឱ្យប្រជាជន

> មានឧបករណ៍ និងសកម្មភាពផ្សេងៗ ដើម្បីជំរុញកម្មវិធីមតិប្រជាពលរដ្ឋស្ដីពីអភិបាលកិច្ចមូលដ្ឋាន ដូចជា :
>
> សិទ្ធិបាត
> សិក្ខាសាលា
> ការជជែកគ្នាក្រៅផ្លូវការ
> ការប្រជុំជាសាធារណៈ
> ការប្រជុំក្រុមផ្ដោតលើគោលដៅរួម
> ការប្រជុំក្រុមចំរុះ
> ការប្រជុំថ្នាក់ភូមិ ថ្នាក់ឃុំ ឬថ្នាក់ខេត្ត
> ការផ្សព្វផ្សាយព័ត៌មាន
> ការប្រើប្រាស់រដ្ឋបាលឃុំ : ការប្រជុំក្រុមប្រឹក្សាឃុំ, ដំណើរ ទស្សនៈកិច្ចរបស់ក្រុមប្រឹក្សាឃុំ,
> ការផ្សព្វផ្សាយរបស់មេភូមិ
> សកម្មភាពយុទ្ធនាការ
> ការសំដែង
> អ្នកនាំពាក្យចលត័ និង
> បណ្ដាញសារព័ត៌មាន

ដើម្បីក្លាយជា អ្នកយល់ដឹងអំពីវិធីសាស្ត្របាយការណ៍ វាយតំលៃរបស់ប្រជាពលរដ្ឋ។



### កំណែន និងការប្រើបណ្តាញព័ត៌មាន នៅទីនេះ!

ទោះបីជាមានមធ្យោបាយផ្សេងៗ ដើម្បីជំរុញកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ក៏ដោយ មធ្យោបាយដែលមានប្រសិទ្ធិភាពនោះ គឺតម្រូវឱ្យមានអង្គការអនុវត្តដើម្បីធ្វើការយ៉ាងជិតស្និតជាមួយប្រពន្ធ័ផ្សព្វផ្សាយនោះ។ ការប្រើប្រាស់ប្រពន្ធ័ផ្សព្វផ្សាយ អាចជួយអង្គការអនុវត្តផ្សព្វផ្សាយដល់ប្រជាពលរដ្ឋដ៏ច្រើន និងទាក់ទាញការចាប់អារម្មណ៍ជាជាងការប្រើប្រាស់មធ្យោបាយផ្សេងទៀត។ ការធ្វើការជាមួយប្រព័ន្ធផ្សព្វផ្សាយ អាចធ្វើឱ្យមានទម្រង់ផ្សេងៗនៃព័តិមាន ដែលរួមមានព្រឹត្តិបត្រ័ អត្ថបទកាសែត ការផ្សាយតាមវិទ្យុ ផ្សាយឈុតតាមទូរទស្សន៏ ។ល។ ការងារនេះ ក៏អាចជួយឱ្យអង្គការអនុវត្ត បង្កើតឯកសារ និងទុកដាក់កំណត់ត្រាទាំងឡាយនៃគោលគំនិត និងចម្លើយតបរបស់ប្រជាជនចំពោះគំរោងនោះ។

## សកម្មភាព ទី១១ : រៀបចំផែនការសកម្មភាពសំរាប់ការវាស់វែងវាយតំលៃនៅមូលដ្ឋាន

ការរៀបចំផែនការសកម្មភាពដើម្បីការវាស់វែងជាក់ស្តែងនៅមូលដ្ឋាន គឺជាការគ្រោងពេលវេលាសំរាប់ការវាស់វែង សំរាប់ការយកសំណាកអ្នកផ្តល់ព័តិមាន ការបែងចែកការងារក្នុងចំណោមសមាជិកក្រុមស្រាវជ្រាវឃុំ ការបញ្ជាក់ភាពត្រឹមត្រូវ និងការបូកសរុបទិន្នន័យ ជាដើម។ ការបែងចែកពេលវេលាដើម្បីសកម្មភាពនិមួយៗក្នុងអំឡុងពេលអនុវត្តជាក់ស្តែងសំរាប់ឃុំនិមួយៗ អាចធ្វើតាមតារាងដូចខាងក្រោម :

| **សកម្មភាព** | **ពេលវេលាគ្រោង គិតជាមធ្យម** | **កំណត់សំគាល់** |
|---|---|---|
| ការជ្រើសរើសសមាជិក ក្រុមស្រាវជ្រាវឃុំ | ១ សប្តាហ៍ | *រាប់បញ្ចូលទាំង សេចក្តីប្រកាស ការកំណត់អត្តសញ្ញាណ ការសម្ភាសន៏ និង ការជ្រើសរើស* |
| វគ្គបណ្តុះបណ្តាល ការណែនាំការងារ | ២-៣ ថ្ងៃ | *វគ្គបណ្តុះបណ្តាលនៅក្នុងថ្នាក់ និងលំហាត់ជាក់ស្តែងនៅមូលដ្ឋាន* |
| ការវាស់វែងវាយតំលៃនៅមូលដ្ឋាន | ២-៣ ថ្ងៃ | *អាចប្រែប្រួលបានដោយយោង ទៅតាមអង្គការអនុវត្ត* |
| ការបូកសរុបទិន្នន័យ និងព័តិមាន | ៣ ថ្ងៃ | *រាប់បញ្ចូលទាំង ការបង្កើតតារាង ការវិភាគ* |

| | | |
|---|---|---|
| | | *និងការសរសេរ របាយការណ៍* |
| ការរៀបចំការប្រជុំ ឬការពិគ្រោះជាមួយក្រុមប្រឹក្សាឃុំ | ១ ថ្ងៃ | *បង្ហាញ និងបញ្ជាក់ភាពត្រឹមត្រូវ ពីលទ្ធផល* |

ការរៀបចំ និងការប្រតិបត្តិសកម្មភាពនិមួយៗក្នុងអំឡុងពេលធ្វើការងារនៅមូលដ្ឋាន គួរតែផ្អែកទៅលើស្ថានការជាក់ស្តែង។ តារាងពេលវេលាសំរាប់សកម្មភាពទាំងឡាយនៅមូលដ្ឋាន គួរតែលៃតម្រូវឱ្យស៊ីគ្នាទៅនឹងពេលវេលាទាំងឡាយដែលប្រជាជនមានពេលទំនេរពីការងាររបស់គាត់នៅស្រែចំការ។ ចន្លោះពីសកម្មភាពមួយទៅសកម្មភាពមួយ មិនគួរវែងពេកទេ បើពុំនោះទេ អ្វីទាំងឡាយដែលពាក់ពន្ធ័នៅក្នុងការវាស់វែងមុខជាត្រូវបាត់បង់ការផ្តោតអារម្មណ៍។

## សកម្មភាព ទី១២ : *ការយកសំណាកអ្នកផ្តល់ព័ត៌មាន*

ចំនួនអ្នកផ្តល់ព័ត៌មានក្នុងមួយឃុំ ប្រែប្រួលពីឃុំមួយទៅឃុំមួយ អាស្រ័យទៅតាមទំហំរបស់ឃុំ និងចំនួនភូមិនៅក្នុងឃុំនិមួយៗ។ អង្គការអនុវត្តគួរតែមើលដើម្បីធ្វើការងារជាមួយគ្រួសារពី ២០ ទៅ ៣០ គ្រួសារក្នុងមួយភូមិ ដូចនេះចំនួនសរុបនៃអ្នកផ្តល់ព័ត៌មានក្នុងឃុំនិមួយៗ គឺស្មើ ពី២០ ទៅ ៣០ គ្រួសារ គុណនឹងចំនួនភូមិនៅក្នុងឃុំនិមួយៗ។

របៀបនៃការជ្រើសរើសអ្នកផ្តល់ព័ត៌មានអាចខុសគ្នា អាស្រ័យទៅតាមអង្គការអនុវត្ត។ បញ្ហានេះរួមមានការជ្រើសរើសដោយចោះៗ ការជ្រើសរើសដោយចៃដន្យ ការជ្រើសរើសតាមបែបធម្មតា ការជ្រើសរើសតាមបែបជាតំណាង ការជ្រើសរើសទៅតាមតំបន់ និងការជ្រើសរើសដោយប្រើឆ្នោតផ្សងសំណាង។ តារាងខាងក្រោមឆ្លុះបញ្ចាំងពីចំនួន និងរបៀបផ្សេងៗគ្នានៅក្នុងការជ្រើសរើសក្រុមស្រាវជ្រាវឃុំ និងសកម្មភាពក្រុមស្រាវជ្រាវឃុំ។

| | |
|---|---|
| ទំហំនៃក្រុមស្រាវជ្រាវឃុំ | ១០ នាក់ |
| អ្នកផ្តល់ព័ត៌មានដែលត្រូវសម្ភាសន៍ដោយសមាជិកក្រុមស្រាវជ្រាវឃុំម្នាក់ | ១៥ - ២០ នាក់ |
| ពេលវេលាដែលត្រូវចំណាយជាមួយអ្នកផ្តល់ព័ត៌មាន ម្នាក់ៗ | ៣០ នាទី |
| ចំនួននៃអ្នកផ្តល់ព័ត៌មានក្នុងមួយឃុំ | ២០ - ៣០ គ្រួសារក្នុងមួយភូមិ គុណនឹងចំនួនភូមិក្នុងមួយឃុំ |
| របៀបនៃការជ្រើសរើសអ្នកផ្តល់ព័ត៌មាន | ១. ការជ្រើសរើសដោយចោះៗ<br>២. ការជ្រើសរើសដោយចៃដន្យ<br>៣. ការជ្រើសរើសតាមបែបធម្មតា |

| | |
|---|---|
| | ៤. ការជ្រើសរើសតាមបែបជាតំណាង<br>៥. ការជ្រើសរើសទៅតាមតំបន់<br>៦. ការជ្រើសរើសដោយប្រើឆ្នោតផ្សងសំណាង |

## សកម្មភាព ទី១៣ : ការបណ្តុះបណ្តាល ការហ្វឹកហាត់ និងការណែនាំការងារ

វគ្គបណ្តុះបណ្តាលស្តីពីការណែនាំការងារសំរាប់ក្រុមស្រាវជ្រាវឃុំ និងអ្នកដទៃផ្សេងទៀត គួរតែមានរយៈពេលពី ២ ទៅ ៣ ថ្ងៃ។ ចំណេះដឹងអំពីបច្ចេកទេសស្រាវជ្រាវ តួនាទីនិងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំនិងវិមជ្ឈការ និងជំនាញប្រាស្រ័យទាក់ទង គឺមានសារៈសំខាន់ណាស់សំរាប់ក្រុមស្រាវជ្រាវឃុំ ដែលជាអ្នកតម្រូវឱ្យមានទំនុកចិត្តក្នុងការស្វែងរកគំនិតយោបល់ពីប្រជាជនទៅលើសេវាកម្មសំខាន់ៗ។ វគ្គបណ្តុះបណ្តាលអាចប្រព្រឹត្តិទៅជាក្រុម ឬពីម្នាក់ទៅម្នាក់។ **បន្ទាប់ពីវគ្គបណ្តុះបណ្តាល អង្គការអនុវត្តគួរតែរៀបចំការប្រជុំមួយ ដើម្បីណែនាំឱ្យស្គាល់នៃក្រុមស្រាវជ្រាវឃុំទាំងអស់ទៅដល់មេឃុំ និងក្រុមប្រឹក្សា។**

### មាតិកានៃវគ្គបណ្តុះបណ្តាលសំរាប់ក្រុមស្រាវជ្រាវឃុំគួរតែបញ្ចូល :

ចំណេះដឹងមូលដ្ឋានស្តីពីវិមជ្ឈការ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ

- របៀបប្រើបញ្ជីរសំណួរ
- ជំនាញប្រមូលទិន្នន័យ
- ការសម្ភាសន៍នៅមូលដ្ឋាន
- ការកត់ត្រា និងការចាត់ចែង
- ការវិភាគទិន្នន័យ
- ការចាត់ចែង និងការសម្របសម្រួលការប្រជុំទូទៅ
- ការប្រាស្រ័យទាក់ទង

### តើអ្នកណាគួរតែចូលរួមនៅក្នុងការណែនាំការងារ?

- ក្រុមស្រាវជ្រាវឃុំ
- ប្រជាពលរដ្ឋទូទៅ
- ក្រុមប្រឹក្សាឃុំ
- មន្ត្រីថ្នាក់ស្រុក
- មន្ត្រីថ្នាក់ខេត្ត
- អ្នកផ្តល់សេវាកម្ម

- អ្នកបណ្តាញសារព័ត៌មាន
- អង្គការក្រៅរដ្ឋាភិបាល និងអង្គការសហគមន៍មូលដ្ឋាន
- ចាស់ព្រឹទ្ធាចារ្យ និងព្រះសង្ឃ

## ដំណាក់ការបីផ្សេងគ្នាសំរាប់ការណែនាំ ការងារដល់ប្រជាពលរដ្ឋ ទូទៅ :

១. ការប្រមូលព័ត៌មានស្តីពីរបាយ ការណ៍ វាយតំលៃរបស់ប្រជា ពលរដ្ឋ តាមរយៈប្រភេទផ្សេងៗ នៃប្រពន្ធ័ផ្សព្វផ្សាយព័ត៌មាន។ ចំពោះអ្នកខ្លះអាចមិនមាន ពេល វេលា ឬក៏ខ្វះមធ្យោបាយដើម្បី ទទួលព័ត៌មាន។

២. អ្នកខ្លះអាចដឹងព័ត៌មានពីការប្រជុំជាសាធារណៈ ឬពីសកម្មភាព ផ្សព្វផ្សាយផ្សេងៗ។

៣. ក្នុងអំឡុងពេលការវាស់វែងនៅ មូលដ្ឋាន អ្នកវាស់វែងគួរតែផ្តល់ ការណែនាំសមរម្យ ដើម្បីណែនាំ ដល់អ្នកផ្តល់ព័ត៌មានដើម្បីយល់ ដឹងពីគោលបំណងឱ្យកាន់តែ ច្បាស់។

# ការណែនាំការងារដល់ប្រជាពលរដ្ឋទូទៅ

ការណែនាំការងារដល់ប្រជាពលរដ្ឋទូទៅ ជាពិសេសអ្នកទាំងឡាយណានៅក្នុងភូមិ ដែលសេវាកម្មសំខាន់ៗនឹងត្រូវវាយតំលៃ គឺមានសារៈសំខាន់ណាស់សំរាប់ការវាស់វែង វាយតំលៃនៅមូលដ្ឋាន។ បើសិនជាប្រជាជនមិនមានការយល់ដឹងពេញលេញពី បំណង និងគោលបំណងនៃរបាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋទេនោះ ពួកគេមិនអាចផ្តល់នូវចម្លើយសំខាន់ៗ ចំពោះការវាស់វែងនេះបានល្អទេ។ អង្គការអនុវត្ត ត្រូវតែធ្វើឱ្យប្រាកដថា ប្រជាពលរដ្ឋទូទៅដែលនឹងក្លាយជាអ្នកផ្តល់ព័ត៌មាន បានយល់ ដឹងច្បាស់ពី :

- បំណង គោលបំណង និងអ្វីទៅជា កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន
- សេវាកម្មសំខាន់នៅមូលដ្ឋាន និងគោលដៅដែលត្រូវគេវាយតំលៃ
- របៀបនៃការប្រមូលព័ត៌មាន
- របៀបនៃការប្រើប្រាស់ព័ត៌មាន
- សិទ្ធិដើម្បីបង្ហាញពីយោបល់ផ្ទាល់ខ្លួន
- សារៈសំខាន់ និងផលប្រយោជន៍
- សេចក្តីសុច្ចិត និងបក្សពួកនិយមរបស់អង្គការ ឬរបស់ក្រុម
- ភាពត្រឹមត្រូវតាមច្បាប់ និងភាពស្របច្បាប់
- ចំណុចវិជ្ជមានផ្សេងទៀត

ការណែនាំការងារដល់ប្រជាពលរដ្ឋទូទៅ គួរតែប្រព្រឹត្តិទៅ តាមរយៈ

- ការប្រជុំជាសាធារណៈ
- ការប្រជុំក្រុមមានគោលដៅរួម ឬការប្រជុំក្រុមធំៗ
- ការប្រជុំថ្នាក់ភូមិ ការប្រជុំថ្នាក់ឃុំ ឬការប្រជុំថ្នាក់ខេត្ត
- ប្រពន្ធ័ផ្សាយ និងការផ្សព្វផ្សាយព័ត៌មាន
- ការប្រើប្រាស់រដ្ឋបាលឃុំ : ការប្រជុំក្រុមប្រឹក្សាឃុំ ដំណើរទស្សនៈកិច្ច របស់ក្រុមប្រឹក្សា ការផ្សព្វផ្សាយរបស់មេភូមិ
- សកម្មភាពយុទ្ធនាការ
- អ្នកនាំពាក្យចល័ត

អ្នកចាត់ចែង គួរតែអញ្ជើញប្រជាពលរដ្ឋទូទៅ ដាច់ដោយឡែកពីគ្នា ឬដាក់បញ្ចូលគ្នា។ បញ្ហានេះ គឺអាស្រ័យទៅនឹងស្ថានការជាក់ស្តែង ឬការពេញចិត្តផ្ទាល់ខ្លួន។

### គំរូណែនាំ និងការប្រើប្រាស់បណ្តាញព័ត៌មាន នៅទីនេះ!

**បណ្តាញព័ត៌មានដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្សាយពីការយល់ដឹងជាសាធារណៈ ដើម្បីផ្តល់ដំណឹងដល់សាធារណៈជនពីសកម្មភាពផ្សេងៗ។ ត្រូវសរសេរអត្ថបទ ឬអញ្ជើញសាធារណៈជនចូលរួមក្នុងការណែនាំការងារ។ បញ្ហានេះអាចឱ្យតំលៃបន្ថែមទៅលើតម្លា ភាព និងភាពបើកចំហ។ ជាមួយនឹងការគ្របដណ្តប់ និងការចូលរួមរបស់បណ្តាញព័ត៌មាន ប្រជាជនអាចមើលឃើញថា បញ្ហាត្រូវបានបើកចំហជាសាធារណៈ។ ដូចគ្នាដែរ គឺមានការអប់រំ បន្ទាប់មក បណ្តាញព័ត៌មានអាចជួយធ្វើឱ្យគំរោងកាន់តែមានការទាក់ទាញ។ វាមានសារៈសំខាន់ណាស់ដែលថា បណ្តាញព័ត៌មានត្រូវដឹងអំពីតារាងពេលវេលាដែលត្រូវផ្សព្វផ្សាយ។**

## សកម្មភាព ទី១៤ : អនុវត្តការវាស់វែងនៅចូលដ្ឋាន

ទំហំរបស់ក្រុមស្រាវជ្រាវឃុំ បើគិតជាមធ្យមគឺមានចំនួន ១០ នាក់ ទោះបីជាចំនួននេះអាចប្រែប្រួលទៅតាមទំហំរបស់ឃុំក៏ដោយ។ នៅក្នុងការវាស់វែងជាក់ស្តែង ក្រុមស្រាវជ្រាវឃុំអាចចែកចេញជាក្រុមតូចៗទៀត ពី ២ ទៅ ៣ នាក់ក្នុងមួយក្រុម ដើម្បីទទួលខុសត្រូវលើភូមិផ្សេងៗគ្នា។ សមាជិកម្នាក់ៗនៃក្រុមទទួលខុសត្រូវដើម្បីសម្ភាសន៏អ្នកផ្តល់ព័ត៌មានពី ១៥ ទៅ ២០ នាក់។ ការងារនេះក៏អាចប្រែប្រួលពីឃុំមួយទៅឃុំមួយ និងពីភូមិមួយទៅភូមិមួយដែរ។

នៅក្នុងឃុំមួយ អាចមានសេវាសង្គមបីប្រភេទដើម្បីជ្រើសរើសយកមកវាយតំលៃ។ ដូចនេះ សមាជិកម្នាក់ៗនៃក្រុមស្រាវជ្រាវឃុំគួរតែបង្កើតបញ្ជីរសំណួរដែលទាក់ទងទៅនឹងការងារនេះ។ ក្រុមស្រាវជ្រាវឃុំគួរតែសួរសំណួរអំពីសេវាសង្គមមួយៗដាច់ពីគ្នា ដើម្បីជៀសវាងការភន្តច្រឡំ។ ពួកគេអាចនិយាយទៅកាន់ក្រុមមនុស្សចាស់ ឬកូនក្មេងនៅក្នុងគ្រួសារ ដោយយោងទៅតាមប្រភេទនៃសេវាកម្ម និងគោលបំណងនៃការសួរ។ រឿងដែលសំខាន់បំផុតនោះ គឺថាពួកគេសួរទៅអ្នកទាំងឡាយណាដែលជាអ្នកប្រើប្រាស់ផ្ទាល់នៃសេវាកម្មប្រភេទនោះ។ ត្រូវព្យាយាមផ្គូរផ្គងសេវាកម្មទៅនឹងអ្នកប្រើប្រាស់ ឬអ្នកប្រើប្រាស់ទៅនឹងសេវាកម្ម ដែលអាចធ្វើឱ្យមានគុណភាព និងលទ្ធផលអាចយកជាការបាន។ ដើម្បីលើកទឹកចិត្តដល់អ្នកផ្តល់ព័ត៌មាន ក្រុមស្រាវជ្រាវឃុំគួរតែចាប់ផ្តើមដោយការណែនាំមួយដ៏សមស្រប។ ពួកគេគួរតែធ្វើឱ្យបានល្អក្នុងការសួរសំណួរក្នុងស្ថានភាពមួយរីករាយ។ ត្រូវធ្វើឱ្យប្រាកដថា អ្នកផ្តល់ព័ត៌មានយល់ពីគោលបំណងនៃការសួរសំណួរដែលនឹងត្រូវបរិយាយឱ្យបានល្អិតល្អន់។

ក្រុមស្រាវជ្រាវឃុំអាចធ្វើការណាត់ជួបជាមុន ឬទៅជួបជាមួយអ្នកផ្តល់ព័ត៌មានដោយព្រាវៗ។ ពួកគេចាំបាច់ត្រូវរៀបចំច្បាប់ចម្លងបញ្ជីរសំណួរឱ្យបានគ្រប់គ្រាន់ ហើយត្រូវមានសំភារៈចាំបាច់ដទៃផ្សេងទៀត។

**កំណត់សំគាល់** ស្ត្រីគួរតែត្រូវបានគេលើកទឹកចិត្តក្នុងការផ្តល់ចម្លើយ។ ទោះជាយ៉ាងណាក៏ដោយ ចូររំលឹកថាស្ត្រីទំនងអាចល្អប្រសើរក្នុងការឆ្លើយតបចំពោះសេវាកម្មសុខភាព និងអប់រំ ចំណែកឯបុរស អាចមានបទពិសោធន៍ច្រើនក្នុងនាមជាអ្នកប្រើប្រាស់ប្រពន្ធ័ស្រោចស្រព ខ្នាតតូច ឬផ្លូវនៅតាមជនបទ។ មិនមែនអ្នកផ្តល់ព័ត៌មានទាំងអស់ សុទ្ធតែជាអ្នកប្រើប្រាស់ច្រើនជាងគេនៃសេវាកម្មទាំងអស់នោះទេ។

## សកម្មភាព ទី១៥ : ផ្ទៀងផ្ទាត់ វិភាគ និងរៀបចំរបាយការណ៍

### ការបូកសរុបលទ្ធផល

អង្គការអនុវត្តទទួលខុសត្រូវក្នុងការបង្កើតលទ្ធផលវាស់វែង ដោយមានការចូលរួម និងជំនួយការពីក្រុមស្រាវជ្រាវឃុំ។ បន្ទាប់ពីការវាស់វែងនៅមូលដ្ឋាន មធ្យោបាយដ៏ប្រសើរបំផុតដើម្បីបូកសរុបលទ្ធផល គឺត្រូវឱ្យក្រុមស្រាវជ្រាវ (អ្នកវាស់វែង) បង្កើតតារាងបញ្ជីរសំណួរពេញលេញ។ មេដឹកនាំក្រុមបញ្ជូនព័ត៌មានទៅឱ្យអង្គការអនុវត្តដើម្បីបូកសរុប។ អង្គការអនុវត្ត សមាជិកក្រុមស្រាវជ្រាវឃុំ និងសមាជិកក្រុមប្រឹក្សាឃុំ ត្រូវរៀបចំការប្រជុំ។ ពួកគេទាំងអស់អាចចូលរួមនៅក្នុងការរាប់ ពិនិត្យ វាយតំលៃ និងកែតម្រូវទិន្នន័យ។ ការងារនេះអាចធ្វើឱ្យកាន់តែប្រាកដថា ការមន្ទិលថយចុះ ហើយបង្កើនកិរិតនៃការទទួលស្គាល់។

លទ្ធផលនៃការបង្កើតតារាង គឺត្រូវតែគិតជាភាគរយ ហើយសំណើរនិងដំណោះស្រាយដែលសំណូមពរ គឺត្រូវតែសង្ខេប។ ជាទូទៅ លទ្ធផលនៃការវាស់វែងនឹងត្រូវចែកចេញជាបីផ្នែក គឺ : ការពេញចិត្ត ការមិនពេញចិត្ត និងសំណូមពរ ដោយយោងទៅតាមសេវាកម្មសង្គមនិមួយៗ និងប្រធានបទ។

ក្រុមស្រាវជ្រាវឃុំ គួរតែឱ្យជាប់ពាក់ពន្ធ័ទៅនឹងដំណើរការទាំងមូលនៃការបង្កើតតារាង ការសង្ខេប ការវិភាគ និងការបកស្រាយទិន្នន័យ ទៅជារបាយការណ៍វាយតំលៃ ដូចនេះពួកគេអាចថ្មឹកទៅនឹងរបៀបដែលទិន្នន័យ និងព័ត៌មានត្រូវបានគេរៀបចំ និងបំលែងទៅជារបាយការណ៍វាយតំលៃ។

### ការសរសេររបាយការណ៍

ទំរង់របាយការណ៍ត្រូវតែបង្កើតឡើងសំរាប់ការសរសេររបាយការណ៍។ បន្ទាប់ពីលទ្ធផលត្រូវបានបូកសរុប អង្គការអនុវត្តត្រូវតែបង្កើតរបាយការណ៍មួយស្តីពីការរកឃើញ និងបកស្រាយលទ្ធផលទៅជាអនុសាសន៍។

ក្នុងពេលសរសេររបាយការណ៍ អង្គការអនុវត្តអាចស្វែងរកយោបល់ពីអ្នកដទៃពីរបៀបបកស្រាយលទ្ធផលរកឃើញ។ របាយការណ៍វាយតំលៃគួរតែផ្សព្វផ្សាយជាសាធារណៈបន្ទាប់ពីបញ្ជាក់ឡើងវិញជាមួយក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្ម។

**កំណត់សំគាល់** ជាការប្រសើរក្នុងការផ្តល់ឱ្យក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្មចូលរួមនៅក្នុងការបូកសរុបលទ្ធផល ដូចនេះពួកគេអាចមើលឃើញលទ្ធផលដោយខ្លួនគេផ្ទាល់។ បញ្ហានេះ ជួយជំរុញភាពទុកចិត្តក្នុងចំណោមក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្ម ហើយអាចធានាអះអាងដល់ពួកគេថា លទ្ធផលគឺមិនក្លែងបន្លំទេ។

## សកម្មភាព ទី១៦ : ការត្រួតពិនិត្យ និងជំនួយបច្ចេកទេសបន្ត

ការត្រួតពិនិត្យជួយដល់ការអនុវត្តបានត្រឹមត្រូវ ដូចនេះ សកម្មភាពនេះគួរតែធ្វើផែនការ និងអនុវត្តឱ្យបានត្រឹមត្រូវនៅក្នុងគ្រប់ដំណាក់កាលនៃដំណើរការ។ ការត្រួតពិនិត្យ គឺជាសកម្មភាពដែលកំពុងបន្ត។

ការត្រួតពិនិត្យនិងការទស្សនៈកិច្ចនៅមូលដ្ឋាន គួរតែធ្វើឡើងតាមពេលកំណត់ទៀងទាត់ ដើម្បីហ្វឹកហាត់ និងផ្តល់យោបល់ដល់អង្គការអនុវត្តនៅក្នុងមូលដ្ឋាន ចំពោះការណែនាំស្តីពីបញ្ជីរសំណួរ ប្រតិបត្តិការណ៍វាស់វែងនៅមូលដ្ឋាន ការវិភាគទិន្នន័យនិងការសរសេររបាយការណ៍ ការរៀបចំសំរាប់ការឡើងបង្ហាញការតស៊ូមតិជាដើម ។ល។

## សកម្មភាព ទី១៧ : ការប្រជុំជាមួយក្រុមប្រឹក្សា-សង្កាត់ និងអ្នកផ្តល់សេវាកម្ម

ត្រូវប្រជុំជាផ្លូវការនៅការិយាល័យរបស់ឃុំ ដើម្បីបង្ហាញពីរបាយការណ៍វាយតំលៃ និងសំណូមពររបស់ប្រជាជនចំពោះក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្ម។

អ្នកផ្តល់សេវាកម្ម ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល អង្គការសហគមន៍មូលដ្ឋាន ក្រុមប្រឹក្សាឃុំ មេភូមិ និងអ្នកសំរេចចិត្តសំខាន់ៗ គួរតែមានវត្តមាននៅតាមបណ្តាការងារទាំងអស់នៅថ្នាក់ឃុំ។ សមាសភាព និងចំនួនអ្នកចូលរួមនៅក្នុងការប្រជុំ ត្រូវតែកំណត់ឱ្យបានច្បាស់លាស់។ ភាពលំអិតនៃការប្រជុំ ត្រូវតែកត់ត្រាឱ្យបានត្រឹមត្រូវ និងផ្សព្វផ្សាយទៅដល់អ្នកដែលបានចូលរួម និងទៅដល់អ្នកពាក់ព័ន្ធទាំងឡាយផ្សេងទៀត។

**មុនពេលការប្រជុំ អង្គការអនុវត្តគួរតែឆ្លើយនូវសំណួរដូចខាងក្រោម ៖**

1. តើរបាយការណ៍ធ្វើរួចរាល់ហើយឬនៅ?
2. តើមានណាត់ជួបជាមួយក្រុមប្រឹក្សាឃុំដែរ ឬទេ?
3. តើប្រជាជនដែលពាក់ពន្ធ័ទាំងអស់ត្រូវបានអញ្ជើញហើយឬនៅ? ដូចជា បុគ្គលក្រុមប្រឹក្សាឃុំ អ្នកផ្តល់សេវាកម្ម បណ្តាញផ្សាយព័តិមាន ។ល។
4. តើប្រជាជនដែលបានអញ្ជើញកំពុងតែមក?
5. តើនរណាធ្វើជាគណៈអធិបតីនៅក្នុងការប្រជុំនេះ?
6. តើនរណាជាអ្នកធ្វើកំណត់ហេតុ?
7. តើយើងមានវិធីប្រសើរយ៉ាងម៉េច សំរាប់ការបង្ហាញ?
8. តើយើងដឹងច្បាស់លាស់ពីអ្វីខ្លះដែលប្រជាជនចង់បាន?
9. តើយើងបានត្រៀមការជជែកវែកញែកអ្វីខ្លះ?
10. តើយើងមានការណែនាំ និងបទបញ្ជាអ្វីខ្លះសំរាប់ការប្រជុំ?
11. តើធ្វើនៅពេលណា កន្លែងណា មនុស្សប៉ុន្មាននាក់ ការរៀបចំភស្តុភា និងឯកសារផ្សេងៗមានសព្វគ្រប់ហើយឬនៅ?

លទ្ធផលរកឃើញនៅក្នុងរបាយការណ៍វាយតំលៃ និងយោបល់របស់ប្រជាជននៅក្នុងឃុំ គួរតែបង្ហាញដោយសុភាពរាបសារ ។ នៅក្នុងការប្រជុំ ត្រូវព្យាយាមវែកញែក ដើម្បីត្រិះពិចារណាទៅលើចំណុចទាំងឡាយដែលត្រូវកែលំអដោយក្រុមប្រឹក្សាឃុំ ឬអ្នកផ្តល់សេវាកម្ម ។ ត្រូវកត់ត្រារាល់ការសន្យាទាំងអស់ ។

ក្រុមប្រឹក្សាឃុំ អាចប្រើប្រាស់ព័តិមានសំរាប់ការធ្វើផែនការអភិវឌ្ឍន៏ឃុំរបស់ខ្លួន ។ ទាំងនេះគឺឆ្លុះបញ្ចាំងទៅលើតួនាទី និងការទទួលខុសត្រូវរបស់មេឃុំ ជំទប់ទី១ ជំទប់ទី២ និង អ្នកដទៃផ្សេងទៀត ដែលថិតនៅក្នុងរចនាសម្ពន្ទ័រដ្ឋបាលរបស់ឃុំ ដែលជាមុខងារតួនាទីនិងការទទួលខុសត្រូវ ដែលត្រូវតែបែងចែកឱ្យដាច់ពីគ្នា ។ នៅក្នុងលំនាំនេះ បុគ្គលក្រុមប្រឹក្សាអាចធ្វើការងារបែបស្ពាបនាជាមួយគ្នា និងពង្រឹងលទ្ធផលការងារទៅវិញទៅមក ។

បន្ទាប់ពីការប្រជុំ អង្គការអនុវត្តគួរតែមានផែនការតាមដានមួយច្បាស់លាស់ និងមានការប្រាស្រ័យទាក់ទងល្អជាមួយក្រុមប្រឹក្សាឃុំ អ្នកផ្តល់សេវាកម្ម ប្រជាជន និងបណ្តាញផ្សព្វផ្សាយព័តិមាន ។

## កំណែន និងការប្រើបណ្តាញព័តិមាន នៅទីនេះ!

បណ្តាញផ្សព្វផ្សាយព័តិមានអាចមានសារៈសំខាន់ណាស់ ក្នុងន័យជាសាក្សីក្នុងការប្រជុំ ។ បណ្តាញផ្សព្វផ្សាយព័តិមានអាចចាប់យករូបភាព និងចងក្រងជាឯកសារនូវព្រឹត្តិការណ៏នោះ ហើយជួយកត់ត្រាអ្វីទាំងអស់ដែលបានកើតឡើង ដូចជាការពិភាគ្សា ការលុបចោលការឯកភាពនិងការសន្យា ក៏ដូចជាដើរតួនាទីជាសាក្សីចំពោះសកម្មភាពនាពេលខាងមុខ ។ វត្តមានរបស់បណ្តាញផ្សព្វផ្សាយព័តិមាន អាចធ្វើឱ្យប្រាកដថា ក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្មឆ្លើយតបជាផ្លូវការចំពោះបញ្ហាទាំងឡាយដែលកើតមានឡើង ជាជាងការព្យាយាមមិនឆ្លើយតប ។

**កំណត់សំគាល់** ត្រូវធ្វើឱ្យប្រាកដថា អ្នកចូលរួមទាំងអស់នៅក្នុងការប្រជុំមានឥរិយាបទត្រឹមត្រូវ។ ត្រូវជៀសវាងការវាយប្រហារជាបុគ្គល ការស្រែកគំហ៊ក ការខឹងសម្បារ ឬការស្តីបន្ទោស។ មិនត្រូវភ្ជាប់បញ្ហាជាក់លាក់ណាមួយទៅនឹងភាពជាអ្នកដឹកនាំក្នុងជួររដ្ឋាភិបាល។ ការបកស្រាយនិងឥរិយាបទទាំងនេះ អាចនាំទៅដល់ភាពតានតឹង ឬធ្វើឱ្យលទ្ធផលនៃការប្រជុំទៅជាមោឃៈ ដែលឈានទៅរកផលមិនជាទីគាប់ចិត្ត។ ការប្រជុំគួរតែផ្តើមសេចក្តី និងការណែនាំដ៏ល្អ បន្ទាប់មកទើបចូលទៅចំណុចដែលត្រូវពិភាក្សា។

## សកម្មភាព ទី១៨ : ការតស៊ូមតិ

### វគ្គបណ្តុះបណ្តាលការតស៊ូមតិដល់ប្រជាជននៅថ្នាក់មូលដ្ឋាន

បន្ទាប់ពីការវាស់វែងត្រូវបានបញ្ចប់ភ្លាមៗ ហើយកម្មវិធីនេះត្រូវបានបង្កើតឡើង វគ្គបណ្តុះបណ្តាលការតស៊ូមតិដល់ប្រជាជននៅថ្នាក់មូលដ្ឋាន គួរតែធ្វើឡើងដើម្បីបង្កើតជាបណ្តាញមូលដ្ឋានជាមួយនឹងចំណេះដឹងនិងវិធីដើម្បីបញ្ចុះបញ្ចូលរដ្ឋអំណាចមូលដ្ឋាន និងអ្នកផ្តល់សេវាកម្ម។ ទាំងនេះអាចធ្វើឡើងនៅកំរិតមួយដែលប្រជាជនធម្មតាអាចរៀនសូត្របាន។

ក្រុមគោលដៅនៃវគ្គបណ្តុះបណ្តាលការតស៊ូមតិដល់ប្រជាជននៅថ្នាក់មូលដ្ឋាន គឺមានសមាជិកក្រុមស្រាវជ្រាវឃុំ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអង្គការសហគមន៍មូលដ្ឋាន។ វគ្គបណ្តុះបណ្តាលស្តីពីការតស៊ូមតិនៅថ្នាក់មូលដ្ឋាន អាចធ្វើឡើងដោយអង្គការអនុវត្តច្រើន ឬចាត់ចែងឡើងរួមគ្នាដោយអង្គការអនុវត្តផ្សេងៗ។ ពួកគេគួរតែផ្តោតទៅលើសកម្មភាពអនុវត្តផ្ទាល់ ដែលប្រជាជនអាចធ្វើទៅបានយ៉ាងពិតប្រាកដ និងអាចជួយអនុវត្តវគ្គបណ្តុះបណ្តាលបាន ជាជាងវគ្គបណ្តុះបណ្តាលដែលមានតែទ្រឹស្តីប៉ុណ្ណោះ។ វគ្គបណ្តុះបណ្តាលអាចរៀបចំឡើងដោយថ្នាក់ខេត្ត ឬថ្នាក់តំបន់ ដោយផ្អែកទៅតាមចំនួនសិក្ខាកាមនៅក្នុងខេត្តនិមួយៗ។ សមាជិកសកម្មរបស់ក្រុមស្រាវជ្រាវឃុំ ឬថ្នាក់ដឹកនាំសហគមន៍ដែលមានសក្តានុពលគួរតែជាអាទិភាពដើម្បីជាអ្នកចូលរួម។

### បង្កើតយុទ្ធនាការការតស៊ូមតិរបស់ប្រជាជនថ្នាក់មូលដ្ឋាន

ក្រុមស្រាវជ្រាវឃុំ ឬក្រុមរបស់ប្រជាពលរដ្ឋ ត្រូវតែបានលើកទឹកចិត្ត ដើម្បីបង្កើតយុទ្ធនាការការតស៊ូមតិថ្នាក់មូលដ្ឋាន ឬសកម្មភាពដែលប្រើលទ្ធផលនៃរបាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋ។ លទ្ធផលនៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន គេអាចយកមកប្រើ ជាប្រភពសំរាប់សកម្មភាពការតស៊ូមតិជាច្រើន។ សកម្មភាព ត្រូវបានបង្កើតឡើង ដោយប្រជាជន នៅនឹងមូលដ្ឋាន ទោះជាយ៉ាងនេះក្តី ដាច់ខាតត្រូវតែសហការ និងគាំទ្រឱ្យបានល្អ។

ការតស៊ូមតិថ្នាក់មូលដ្ឋាន ត្រូវតែសហការណ៍ និងគាំទ្រឱ្យបានល្អ!

# តើត្រូវប្រើលទ្ធផលកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋានយ៉ាងដូចម្តេច?

លទ្ធផលរបាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋ នឹងទុកជាមូលដ្ឋានសំរាប់ការពិភាក្សាស៊ីជម្រៅ ជាមួយមន្ត្រីរដ្ឋាភិបាលមូលដ្ឋាននិងអ្នកសំរេចចិត្តដទៃផ្សេងទៀត។ លទ្ធផលទាំងនេះ គេក៏ត្រូវចែករំលែកជាមួយនឹងអង្គការប្រជាជន អង្គការក្រៅរដ្ឋាភិបាលផ្សេងៗ និងបណ្តាញផ្សព្វផ្សាយព័ត៌មាន។ អង្គការក្រៅរដ្ឋាភិបាល ឬក្រុមប្រជាពលរដ្ឋដែលប្រើរបាយការណ៍វាយតំលៃ ត្រូវបានគេរំពឹងថាដើម្បីរៀនសូត្រ និងប្រើប្រាស់បណ្តាញផ្សព្វផ្សាយព័ត៌មាន ក្រុមសាធារណៈជនដែលចូលចិត្តផ្សេងទៀត និងប្រជាពលរដ្ឋទូទៅ ដើម្បីសម្របសម្រួលយន្តការសំរាប់ធ្វើឱ្យប្រជាពលរដ្ឋបង្កើតជាមតិ និងអាចបញ្ចេញយោបល់ដោយខ្លួនគាត់។ របាយការណ៍តំបូង អាចប្រើជាបទដ្ឋានប្រៀបធៀប ដើម្បីវាស់វែងការរីកចំរើន និងស្នាដៃដែលបានធ្វើកន្លងទៅ។ លទ្ធផលនៃរបាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋ នឹងត្រូវប្រើប្រាស់ជាចំណុចចាប់ផ្តើម ក្នុងការតស៊ូមតិដើម្បីវេទិការនិងការផ្លាស់ប្តូរ។

## លទ្ធផល នៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន គេអាចប្រើសំរាប់ការតស៊ូមតិ នៅក្នុងមធ្យោបាយដូចខាងក្រោម៖

- ដើម្បីបញ្ចូលក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្ម ទៅក្នុងការបូកសរុបលទ្ធផល ដូចនេះ ពួកគេអាចអានរបាយការណ៍វាយតំលៃដោយខ្លួនគេ។ ពិសេស បញ្ហានេះបានផ្តល់ដល់ក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្មនូវភាពជឿជាក់ និងទំនុកចិត្តថា លទ្ធផល និងរបាយការណ៍មិនត្រូវបានគេប្រឌិតឡើងនោះទេ។
- ដើម្បីរៀបចំការប្រជុំ ជាមួយក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្ម ដើម្បីបង្ហាញពីតម្រូវការ និងដើម្បីចរចារសំរាប់ធ្វើការផ្លាស់ប្តូរ។
- ដើម្បីចាត់ចែងវេទិការក្នុងការផ្តល់ព័ត៌មានដល់ប្រជាជន និងដើម្បីពិភាក្សាគ្នាពីបញ្ហាទាំងឡាយដែលមានឥទ្ធិពលទៅដល់ពួកគេ ដែលបង្កើតជាកម្លាំងមួយទៀមទារការផ្តល់សេវាកម្ម ប្រកបដោយប្រសិទ្ធិភាព។
- ដើម្បីផ្ញើរបាយការណ៍ជូនដល់ប្រជាជនដែលពាក់ពន្ធ័ ក្រុមប្រឹក្សាឃុំ អ្នកផ្តល់សេវាកម្ម ផ្នែករដ្ឋបាលមូលដ្ឋានថ្នាក់ខេត្ត រដ្ឋអំណាចស្រុក ឬតំណាងថ្នាក់ខេត្ត និងបណ្តាញផ្សព្វផ្សាយព័ត៌មាន ដែលជាអ្នកអាចមានឥទ្ធិពលទៅលើការកែលំអរបស់សេវាកម្ម។
- នៅក្នុងព្រឹត្តិការណ៍ផ្សេងទៀត គឺដើម្បីណាត់ជួបជាមួយក្រុមប្រឹក្សាឃុំ និង ឬជាមួយអ្នកផ្តល់សេវាកម្ម ដើម្បីពិភាក្សាឱ្យស៊ីជម្រៅឈានទៅកាន់ការរីកចំរើន។
- លទ្ធផលគេអាចប្រើក្នុងការបង្ហាញទៅដល់អ្នកធ្វើសេចក្តីសំរេចចិត្ត នៅថ្នាក់ឃុំ ឬរដ្ឋអំណាចដែលមានសមត្ថភាព។

- ដើម្បីលើកឡើងនូវបញ្ហាទាំងឡាយ ដែលដកចេញពីរបាយការណ៍ហើយដាក់ទៅក្នុងរបៀបវារៈនៃការប្រជុំរបស់ក្រុមប្រឹក្សាឃុំ ការប្រជុំថ្នាក់ស្រុក ឬការប្រជុំផ្នែកបច្ចេកទេស ។
- ដើម្បីរក្សាទុករបាយការណ៍ ជាឧបករណ៍មួយសំរាប់ការពិនិត្យប្រៀបធៀប និងការវាស់វែង ហើយសំរាប់ត្រួតពិនិត្យកំរិតនៃការរីកចំរើន ។
- ដើម្បីប្រើបញ្ហាទាំងឡាយនៅក្នុងរបាយការណ៍ ជាចំណុចចាប់ផ្តើមសំរាប់បង្កើតភាពជាដៃគូររវាងក្រុមប្រឹក្សាឃុំ អ្នកផ្តល់សេវាកម្ម និងប្រជាពលរដ្ឋ ដើម្បីដោះស្រាយជាមួយនឹងបញ្ហារួម ។
- ដើម្បីប្រើលទ្ធផលជាភស្តុតាង ក្នុងការទៀមទារការចូលរួមរបស់ប្រជាជនសំរាប់ការត្រួតពិនិត្យ ឬចូលរួមក្នុងការសំរេចចិត្តទៅលើការផ្តល់សេវាកម្មចំបងនៅថ្នាក់មូលដ្ឋាន ។
- ដើម្បីប្រើរបាយការណ៍ជាភស្តុតាង ក្នុងការគាំទ្រការតស៊ូមតិលើគោលនយោបាយ ឬប្រើសំរាប់ជាប្រភពនៃភស្តុតាងសំរាប់ការតស៊ូមតិតាមផ្នែក ។
- ជាជាងគ្រាន់តែជាការត្អូញត្អែរនិងទៀមទារ របាយការណ៍អាចជាប្រភពមូលដ្ឋានមួយ សំរាប់ការអភិវឌ្ឍមេរៀន ឬសំរាប់ជាសម្ភារៈរៀនសូត្រដើម្បីបង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្ម ។
- របាយការណ៍នេះ គឺជាភស្តុតាងដើម្បីបង្កើតជាសេចក្តីថ្លែង ឬជាលិខិតបណ្តឹង ដើម្បីធ្វើកំណែនការគាំទ្រក្នុងការតស៊ូមតិដើម្បីផ្លាស់ប្តូរ ។
- លើសពីនេះ លទ្ធផលគេអាចប្រើប្រាស់សំរាប់ :
    - សរសេរសំបុត្រផ្លូវការជូនដល់ក្រុមប្រឹក្សាឃុំ និង ឬអ្នកផ្តល់សេវាកម្ម
    - ជាព័ត៌មានដើម ក្នុងការវាយតំលៃទៅលើសេវាកម្ម
    - បង្កើតបទដ្ឋានវាស់វែង សំរាប់អ្នកផ្តល់សេវាកម្ម
    - ជាប្រភពក្នុងការបង្កើតអត្ថបទសំរាប់បណ្តាញផ្សព្វផ្សាយព័ត៌មាន
    - ជាព័ត៌មានដើម្បីរៀបចំសន្និសិទកាសែតក្នុងការបង្ហាញពីបញ្ហាដល់សាធារណៈជន
    - ជាសក្តុតាងដ៏រឹងមាំដើម្បីយុទ្ធនាការ ការស្រាយបំភ្លឺ ឬការជំទាស់ក្នុងការទៀមទារការផ្លាស់និងការកែលំអ
    - បង្កើតជាអនុសាសន៍សំរាប់ការកែលំអស្នាដៃការងាររបស់ក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្ម ការកែលំអគោលនយោបាយដើម្បីស្នាដៃការងារកាន់តែប្រសើរ ឬដើម្បីគុណភាពរបស់សេវាកម្ម ។

**ធ្វើការងារជាមួយបណ្តាញផ្សព្វផ្សាយព័ត៌មាន និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកផ្សេងទៀត ចំពោះការតស៊ូមតិទៅលើគោលនយោបាយក្នុងការកែលំអគ្រោងការរបស់គោលនយោបាយ**

នៅថ្នាក់ជាតិ អង្គការអនុវត្តគួរតែធ្វើការជាមួយបណ្តាញផ្សព្វផ្សាយព័ត៌មាន និងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត ដោយបកប្រែលទ្ធផលរកឃើញទៅជាភស្តុតាងសំរាប់ការតស៊ូមតិលើគោលនយោបាយ ។

លទ្ធផលនៃការវាស់វែងវាយតំលៃ ត្រូវបានគេគ្រោងទុកជាមុន ដើម្បីទុកប្រើជាមូលដ្ឋានសំរាប់ការពិភាក្សាស៊ីជម្រៅជាមួយក្រុមប្រឹក្សាឃុំ អ្នកផ្តល់សេវាកម្ម និងអ្នកធ្វើសេចក្តីសំរេចចិត្តផ្សេងទៀតនៅថ្នាក់ឃុំ ។ លទ្ធផលគេក៏ត្រូវចែករំលែកផងដែរ ជាមួយនឹងក្រុមប្រជាពលរដ្ឋ អង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត និងបណ្តាញផ្សព្វផ្សាយព័ត៌មាន ក្នុងការប៉ាន់ប្រមាណថា ទាំងនេះនឹងប្រើដើម្បីអប់រំ និងធ្វើកំណែនក្រុមសាធារណៈជនដែលចាប់អារម្មណ៍ផ្សេងទៀត និងប្រជាពលរដ្ឋទូទៅ ដើម្បីសម្របសម្រួលយន្តការក្នុងការជួយប្រជាពលរដ្ឋក្នុងការប្រកាស ឬសម្តែងចេញដោយខ្លួនគេចំពោះការតស៊ូមតិដើម្បីការផ្លាស់ប្តូរ ។

**កំណែន និងការប្រើបណ្តាញព័ត៌មាន នៅទីនេះ!**

សកម្មភាពការតស៊ូមតិណាក៏ដោយ ដែលអ្នកបានធ្វើ អ្នកគួរតែធ្វើឱ្យប្រាកដថា បណ្តាញផ្សព្វផ្សាយព័ត៌មានត្រូវបានគេប្រាប់ឱ្យដឹង និងចូលរួម គឺជាឧបករណ៍ដ៏មានថាមពលដែលអាចជួយពាំនាំទៅដល់ក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្ម។ ទាំងនេះអាចដាក់បន្ថែមនូវសម្ពាធ និងបង្កើតជាផលសំរេចវិជ្ជមានកាន់តែប្រាកដប្រជាថែមទៀត ។

## សកម្មភាព ទី១៩ : ការបង្កើត និងការពង្រឹងបណ្តាញមូលដ្ឋាន និងការរក្សានិរន្តរភាព

ដើម្បីបង្កើតការតស៊ូមតិកាន់តែរឹងមាំ ត្រូវលើកទឹកចិត្តប្រជាជនឱ្យសម្តែងមតិដោយខ្លួនគេផ្ទាល់ ។ នឹងមានតម្រូវការមួយដើម្បីបង្កើតនិងពង្រឹងបណ្តាញមូលដ្ឋាន និងធ្វើឱ្យពួកគេកាន់តែសកម្ម ដែលជាចលនានៅថ្នាក់មូលដ្ឋានមួយ ដើម្បីទៀមទារអភិបាលកិច្ចល្អ និងការផ្តល់សេវាកម្មល្អ។ សំរាប់ហេតុផលនេះ ការប្រជុំការបង្កើនសមត្ថភាព និងការហ្វឹកហាត់ គួរតែគេបន្តផ្តល់ដល់បណ្តាញមូលដ្ឋាននេះ ហើយសមាជិកគួរតែឱ្យចូលរួមក្នុងរាល់សកម្មភាពដែលទាក់ទងទៅនឹងអភិបាលកិច្ចមូលដ្ឋាន នៅក្នុងតំបន់របស់ពួកគេរៀងៗខ្លួនដើម្បីឱ្យពួកគេលើកទឹកចិត្តនិងរៀនសូត្រធ្វើការងារជាក្រុម ។ ត្រូវបង្កើតបណ្តាញជាមួយភាពត្រឹមត្រូវនៃការត្រួតពិនិត្យជាប់លាប់នៃការផ្តល់សេវាកម្ម និងស្នាដៃការងាររបស់ក្រុមប្រឹក្សាឃុំ ។

## សកម្មភាព ទី២០ : សកម្មភាពវាយតំលៃ

ការវាយតំលៃពាក់កណ្តាលពេលកំណត់ និងការវាយតំលៃចុងក្រោយ ត្រូវតែមានរួចជាស្រេច ដើម្បីវាស់វែងការជោគជ័យនិងផលប៉ះពាល់ និងដើម្បីកំណត់ការអនុវត្តដែលប្រសើរបំផុត និងបទពិសោធន៍រៀនសូត្រ ។

## សកម្មភាព ទី២១ : ការផ្សព្វផ្សាយ និងអនុវត្តន៍បន្ត

ដើម្បីធ្វើឱ្យប្រជាពលរដ្ឋយល់ដឹងពីគំនិតផ្តួចផ្តើមនេះ មានតម្រូវការមួយដើម្បីផ្សព្វផ្សាយ និងអនុវត្តបន្តនូវវិធីសាស្រ្តកម្មវិធី បទពិសោធន៍ លទ្ធផលរកឃើញ បទពិសោធន៍រៀនសូត្រ និងការអនុវត្តប្រសើរបំផុត ទៅដល់ក្រុមអ្នកពាក់ពន្ធ័ កាន់តែទូលំទូលាយដើម្បីអនុវត្តបន្ត។ មានមធ្យោបាយជាច្រើនដើម្បីផ្សព្វផ្សាយកម្មវិធីនេះ។

- សន្និបាត សិក្ខាសាលា ការប្រជុំ
- ការបង្ហាញ ការជជែកក្រៅផ្លូវការ
- ការបោះពុម្ពផ្សព្វផ្សាយ និងការចែកចាយ
- ការផ្សព្វផ្សាយព័ត៌មាន
- សកម្មភាពយុទ្ធនាការ
- អ្នកនាំពាក្យចល័ត
- **បណ្តាញផ្សព្វផ្សាយព័ត៌មាន**



**គំណែន និងការប្រើបណ្តាញព័ត៌មាន នៅទីនេះ!**

បណ្តាញផ្សព្វផ្សាយព័ត៌មាននឹងជួយដល់ការផ្សព្វផ្សាយកាន់តែទូលំទូលាយពីរបាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋ។ ការងារនេះអាចធ្វើឡើងតាមរយៈអត្ថបទបោះពុម្ពស្តីពីបទពិសោធន៍រៀនសូត្រ ការអនុវត្តដែលប្រសើរបំផុត បទពិសោធន៍ វិធីសាស្រ្ត ។ល។ ដែលផ្សាយតាមវិទ្យុនិងទូរទស្សន៍ ។ល។

### នៅពេលណាដែលត្រូវប្រើប្រាស់បណ្តាញផ្សព្វផ្សាយព័ត៌មាន តាមរយៈដំណើរការកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន

ចំនួននៃសកម្មភាពកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ចាំបាច់ត្រូវធ្វើតាមរយៈបណ្តាញផ្សព្វផ្សាយព័ត៌មាន

#### ការចរចារ និងការបញ្ចុះបញ្ចូលដើម្បីការយល់ព្រមនិងដំណើរការចាប់ផ្តើម

ក្នុងអំឡុងពេលបញ្ចុះបញ្ចូល និងដំណើរការចាប់ផ្តើម វាគឺជាសារៈសំខាន់មួយដើម្បីធ្វើឱ្យបណ្តាញផ្សព្វផ្សាយព័ត៌មានចូលរួម។ ការណ៍នេះជួយផ្តល់ព័ត៌មានដល់រដ្ឋាភិបាលទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់មូលដ្ឋាន អំពីកត្តាវិជ្ជមានដែលមាននៅក្នុងកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។ បណ្តាញផ្សព្វផ្សាយព័ត៌មាន អាចជួយបញ្ចុះបញ្ចូលមន្ត្រីទាំងឡាយ និងក្រុមប្រឹក្សាឃុំ ហើយជួយពាំនាំភាពស្មោះត្រង់ បំណងដ៏ល្អ សារៈសំខាន់និងភាពមានប្រយោជន៍នៃរបាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋ។ ទាំងនេះអាចជួយធ្វើឱ្យក្រុមប្រឹក្សាឃុំ និងមន្ត្រីរដ្ឋាភិបាលផ្សេងទៀតមាន

អារម្មណ៍កាន់តែទុកចិត្តជាមួយដំណើរការនេះ ដែលអាចឈានទៅរកការយល់ព្រមព្រៀងចំពោះគំរោងកាន់តែឆាប់ ។ បណ្តាញផ្សព្វផ្សាយព័ត៌មានក៏អាចបង្ហាញដំណើរការចាប់ផ្តើម និងផ្សព្វផ្សាយសារព័ត៌មានកាន់តែទូលំទូលាយដល់សាធារណៈជន ។ ការណ៍នេះអាចផ្តល់ចំណេះដឹងជាសាធារណៈ និងធ្វើឱ្យប្រជាជននៅមូលដ្ឋានដឹងថា គំរោងនេះត្រូវបានអនុវត្តជំនួសឱ្យពួកគេផ្ទាល់ ។

## ការលើកតំកើងកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាននៅក្នុងឃុំ និងជាសាធារណៈ

ទោះបីជាមានមធ្យោបាយផ្សេងៗ នៃការលើកតំកើងកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន ក៏ដោយ ក៏វាទៀមទារអង្គការអនុវត្តធ្វើការយ៉ាងជិតស្និតជាមួយបណ្តាញផ្សព្វផ្សាយព័ត៌មាន ដែលជាបណ្តាញផ្សព្វផ្សាយព័ត៌មាន អាចជួយអង្គការអនុវត្តជ្រាបទៅដល់ស្រទាប់ប្រជាជនកាន់តែទូលំទូលាយ និងទាក់ទាញការយកចិត្តទុដាក់កាន់តែខ្លាំង បន្ទាប់មកវាអាចធ្វើតាមរយៈមធ្យោបាយ ផ្សេងទៀត ។ ការធ្វើការងារជាមួយមធ្យោបាយផ្សេងៗ នៃបណ្តាញផ្សព្វផ្សាយព័ត៌មាន ធ្វើឱ្យមាន ទម្រង់ព័ត៌មានផ្សេងៗ ដែលរួមមាន ព្រឹត្តិបត្រ័ព័ត៌មាន អត្ថបទកាសែត វិទ្យុ ឬឈុតក្នុងទូរទស្សន៍ ជាដើម ។ល ។ លើសពីនេះ ការណ៍នេះអាចជួយអង្គការអ្នកអនុវត្តដើម្បីកត់ត្រាជាឯកសារ និងរក្សា កំណត់ត្រានៃគោលគំនិតនិងចម្លើយតបរបស់ប្រជាជនដែលទាក់ទងទៅនឹងគំរោងនោះ ។

## ការបណ្តុះបណ្តាល ការហ្វឹកហាត់ និងណែនាំការងារ

បណ្តាញផ្សព្វផ្សាយព័ត៌មានជានិច្ចជាកាល ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ចំណេះដឹងដល់សាធារណៈជន ដូចនេះ ធ្វើឱ្យពួកគេបានដឹងព័ត៌មានស្តីពីសកម្មភាពផ្សេងៗ ។ ត្រូវសរសេរអត្ថបទ ឬអញ្ជើញពួកគេឱ្យចូលរួមក្នុងការណែនាំការងារ ដែលជាប្រការដ៏ល្អសំរាប់បន្ថែមតំលៃទៅឱ្យតម្លាភាព និងភាពបើកចំហ ។ ជាមួយការគ្រប់ដណ្តប ឬការពាក់ពន្ធ័របស់បណ្តាញផ្សព្វផ្សាយព័ត៌មាន ប្រជាជនអាចមើលឃើញថា បញ្ហាត្រូវបានលាតត្រដាង ។ ក្រៅពីការជួយដល់ការអប់រំ ការណ៍នេះ អាចធ្វើឱ្យគំរោងកាន់តែមានការទាក់ទាញ ។ សំខាន់បំផុតនោះ បណ្តាញផ្សព្វផ្សាយព័ត៌មានត្រូវការ ចង់ដឹងពីកម្មវិធីពេលវេលាដែលពាក់ពន្ធ័ ។

### របៀបធ្វើកំណែនបណ្តាញ ផ្សព្វផ្សាយព័ត៌មាន

- ត្រូវរកមើលអ្នកពាក់ពន្ធ័នឹងបណ្តាញផ្សព្វផ្សាយ ព័ត៌មាន រួចហើយទាក់ទងជាមួយពួកគេ ។
- ត្រូវភ្ជាប់ចំណងមិត្តភាពជាមួយអ្នកពាក់ពន្ធ័បណ្តាញផ្សព្វផ្សាយព័ត៌មាន ។
- ត្រូវធ្វើបញ្ជីឈ្មោះ ហើយរក្សាទុករាល់ទំនាក់ទំនងជាមួយអ្នកពាក់ពន្ធ័នឹងបណ្តាញផ្សព្វផ្សាយព័ត៌មានដែលអ្នកបានជួប
- ត្រូវសរសេរអត្ថបទសំរាប់ការផ្សព្វផ្សាយព័ត៌មាន
- ត្រូវធ្វើការណាត់ជួបដើម្បីសម្ភាសន៍
- ត្រូវប្រាប់ដល់បណ្តាញផ្សព្វផ្សាយព័ត៌មានឱ្យបានច្បាស់លាស់ពីរបាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋ
- ត្រូវផ្តល់ដល់បណ្តាញផ្សព្វផ្សាយព័ត៌មាននូវតារាងពេលវេលារបស់សកម្មភាព
- ត្រូវរក្សាការប្រាស្រ័យទាក់ទងនិងទំនាក់ទំនងល្អ
- ត្រូវដឹងអំពីប្រភេទផ្សេងៗរបស់បណ្តាញផ្សព្វផ្សាយព័ត៌មាន
- ត្រូវបង្កើតព័ត៌មាននិងឯកសារឱ្យមានជាស្រេច និងងាយរក
- ត្រូវអញ្ជើញពួកគេចូលរួមក្នុងពិធី ក៏ដូចជាក្នុងការងារ

### ការប្រជុំជាមួយក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្ម

បណ្តាញផ្សព្វផ្សាយព័ត៌មានអាចជាសាក្សីដ៏សំខាន់បំផុតចំពោះការប្រជុំពេញអង្គ។ ពួកគេអាចផ្តិតយករូបភាព និងបង្កើតឯកសារទៅលើព្រឹត្តិការណ៍ទាំងនោះ។ ពួកគេអាចជួយកត់ត្រារាល់បញ្ហាដូចជាការពិភាក្សា ការបរិយាយល្អិតល្អន់ ការឯកភាពនិងការសន្យា និងជាសាក្សីសំរាប់សកម្មភាពនាពេលខាងមុខ។ វត្តមានរបស់បណ្តាញផ្សព្វផ្សាយព័ត៌មានអាចធ្វើប្រាកដថា ក្រុមប្រឹក្សាឃុំនិងអ្នកផ្តល់សេវាកម្មផ្តល់ការឆ្លើយតបជាផ្លូវការចំពោះបញ្ហាទាំងឡាយ ដែលកើតមានឡើង ជាជាងការជៀសវាងមិនឆ្លើយតប។

### ការតស៊ូមតិ

សកម្មភាពអ្វីក៏ដោយដែលអ្នកបានធ្វើនៅក្នុងការតស៊ូមតិ អ្នកគួរតែប្រាប់និងអញ្ជើញដល់បណ្តាញផ្សព្វផ្សាយព័ត៌មាន ដែលជាមធ្យោបាយដ៏មានឥទ្ធិពល អាចជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្មចំពោះការទទួលខុសត្រូវក្នុងការឆ្លើយតប។ ទាំងនេះបន្ថែមសម្ពាធ និងផលសំរេចកាន់តែប្រាកដប្រជា។

### ការផ្សព្វផ្សាយ និងអនុវត្តបន្ត

បណ្តាញផ្សព្វផ្សាយព័ត៌មានអាចជួយ ផ្សព្វផ្សាយកាន់តែទូលំទូលាយពីកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។ ពួកគេអាចជួយបង្កើតអត្ថបទបោះពុម្ពលើបទពិសោធន៍រៀនសូត្រការអនុវត្តដ៏ ប្រសើរបំផុត បទពិសោធន៍ វិធីសាស្ត្រ ។ល។ ឬព័ត៌មានសំរាប់ផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ជាដើម។




**4.3**

## ឱវាទមួយចំនួនដើម្បីការជោគជ័យ

ខាងក្រោមនេះ គឺជាឱវាទខ្លះៗសំរាប់ការជោគជ័យ ដែលចេញពីឱវាទនេះ អង្គការអនុវត្តរបាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋអាចទទួលបាននូវផលប្រយោជន៍។

- ត្រូវអញ្ជើញក្រុមប្រឹក្សាភិបាលឃុំឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាល ឬការណែនាំការងាររបស់គំរោងជាផ្លូវការ ដើម្បីធ្វើឱ្យពួកគេកាន់តែថ្នឹកជាមួយសកម្មភាព និងមានឆន្ទៈដើម្បីចូលរួម បន្ទាប់មកដើម្បីចាប់ផ្តើមប្រតិបត្តិគំរោងតែម្តង។ ត្រូវធ្វើការណែនាំការងារដល់ក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋឱ្យបានត្រឹមត្រូវ។

- នៅក្នុងការយកសំណាកនៃអ្នកផ្តល់ព័ត៌មាន បើអាចទៅរួច ត្រូវផ្គូរផ្គងការវាយតំលៃរបស់សេវាកម្មណាមួយជាមួយនឹងអ្នកផ្តល់ព័ត៌មាន ដែលជាអ្នកប្រើប្រាស់តំបូងបង្អស់នៃសេវាកម្មនោះ ដូចនេះគឺដើម្បីកើនឡើងព័ត៌មានកាន់តែសំខាន់ពីការវាស់វែងនៃវាយតំលៃ។
- ការប្រជុំពេញអង្គសំរាប់ការបង្ហាញរបាយការណ៍ការវាយតំលៃ គួរតែបញ្ចូលការចូលរួមរបស់អ្នកផ្តល់សេវាកម្ម ដែលទាក់ទងទៅនឹងសេវាកម្មដែលបានកំណត់នៅក្នុងឃុំនិមួយៗ។ ការប្រជុំគួរតែកត់ត្រាទុកជាឯកសារឱ្យបានត្រឹមត្រូវ។
- ទិន្នន័យ និងព័ត៌មានចេញពីការវាស់វែងនៃវាយតំលៃ ត្រូវតែបំលែងឱ្យទៅជារបាយការណ៍វាយតំលៃ។ ក្រៅពីការប្រើប្រាស់លទ្ធផលដែលជាមូលដ្ឋានសំរាប់ការពិភាក្សាស៊ីជម្រៅនៅថ្នាក់មូលដ្ឋាន និងសំរាប់គោលបំណងនៃការតស៊ូមតិ វាគួរតែប្រើជាមូលសព្ទ័សំរាប់ការបង្កើតសម្ភារៈសិក្សា ដើម្បីកែលំអលើចំណុចខ្សោយ ដែលបានរកឃើញនៅក្នុងការវាស់វែងនៃការវាយតំលៃ និងដើម្បីបង្កើនសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំផងដែរ។ អត្តសញ្ញាណកម្មនៃបញ្ហា និងការកសាងសមត្ថភាព គួរតែកើតឡើងដំណាលគ្នា។
- ចុងក្រោយបំផុត ផលប៉ះពាល់នៃកម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន នឹងត្រូវពឹងផ្អែកទៅលើចំណុចខ្លាំង ការប្តេជ្ញាចិត្ត និងការស៊ូទ្រាំរបស់អង្គការអនុវត្ត និងក្រុមស្រាវជ្រាវឃុំ។ ការអភិវឌ្ឍ ជំនាញរបស់ក្រុមស្រាវជ្រាវឃុំ គឺមានសារៈសំខាន់ជាបន្ទាន់ ដើម្បីអាចឱ្យពួកគេចរចារជាមួយ ទីភ្នាក់ងារផ្តល់សេវាកម្មនៅថ្នាក់ស្រុកនិងថ្នាក់ខេត្ត ដើម្បីជួបនិងចរចារជាមួយថ្នាក់ដឹកនាំដែលជាប់ដោយការបោះឆ្នោតនៅក្នុងឃុំ និងដើម្បីធ្វើកំណែនសហគមន៍របស់គេរៀងៗខ្លួនដើម្បីគាំទ្រ កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន។
- ក្រុមស្រាវជ្រាវឃុំ គេគួរតែបង្កើតឡើងជាផ្លូវការ ដើម្បីអាចបង្កើតចលនាថ្នាក់មូលដ្ឋានមួយ ដែលអាចបង្កើនឥទ្ធិពលទៅលើក្រុមប្រឹក្សាមូលដ្ឋាន ហើយធ្វើឱ្យរស់រវើកនៃការចូលរួមរបស់ប្រជាជន។ វាត្រូវតែច្បាស់លាស់ ថាសម្ព័ន្ធនយោបាយ គឺមិនត្រូវយកមកពិចារណាទេក្នុងអំឡុងពេលជ្រើសរើសក្រុមស្រាវជ្រាវឃុំ។ ក្រុមស្រាវជ្រាវឃុំ គេត្រូវតែឱ្យចូលរួមនៅក្នុងការគ្រោង និងរៀបចំគំរោងជាពិសេស ការគ្រោងឧបករណ៍អនុវត្តសំរាប់ការវាស់វែងវាយតំលៃជាក់ស្តែងនៅមូលដ្ឋាន ដូចជាបញ្ជីរសំណួរ និងទម្រង់របាយការណ៍ ជាដើម។ នៅមូលដ្ឋាន ក្រុមស្រាវជ្រាវឃុំ ត្រូវតែមានទំនុកចិត្តដើម្បីអនុវត្តការវាស់វែងស្រាវជ្រាវ ហើយក៏ដូចគ្នាដែរ ពួកគេត្រូវតែបានទទួលការបណ្តុះបណ្តាលឱ្យបានល្អ។ បញ្ជីរសំណួរ និងសម្ភារៈត្រូវតែឱ្យមានគ្រាប់គ្រាន់។
- កម្មវិធីមតិប្រជាពលរដ្ឋស្តីពីអភិបាលកិច្ចមូលដ្ឋាន មិនគួរទុកគ្រាន់តែជាគំនិតផ្តួចផ្តើមប៉ុណ្ណោះទេ។ ឧបករណ៍ ដែលមានប្រសិទ្ធិភាពនៅក្នុងការត្រួតពិនិត្យស្នាដៃការងារ នៃគោលនយោបាយ

របស់រដ្ឋាភិបាល គឺការផ្តល់សេវាកម្ម។ ទោះជាយ៉ាងណាក៏ដោយ មានគំនិតផ្តួចផ្តើមជាច្រើនទាក់ទាងនឹងគណនេយ្យភាពសង្គម ថិតនៅក្នុងដំណាក់កាលនិមួយៗ នៃដំណើរការអភិវឌ្ឍន៍នៅក្នុងឃុំ ហើយទាំងនេះគេក៏គួរតែស្វែងរកដែរ។ ឧទាហរណ៍ ការចូលរួមរបស់ប្រជាជននៅក្នុងការធ្វើផែនការអភិវឌ្ឍន៍ គេគួរតែបង្កើនឡើងថែមទៀត ដើម្បីធ្វើឱ្យប្រាកដថាតម្រូវការរបស់ប្រជាជនត្រូវបានគេដាក់ជាអាទិភាព។ លើសពីនេះ ប្រជាពលរដ្ឋគួរតែខំប្រឹងប្រែងដោយរៀបចំឡើងដើម្បីធ្វើឱ្យប្រាកដថាអាទិភាពរបស់ប្រជាជន គឺបានឆ្លុះបញ្ចាំងនៅក្នុងផែនការដែលគេអាចអនុវត្តតាមរយៈការចាត់ចែងថវិកា។ នៅក្នុងករណីជាច្រើន ផែនការនៅតែជាផែនការពីព្រោះគេមិនបានប្រែក្លាយវាឱ្យទៅអាទិភាពថវិកាទេ។

- នៅក្នុងមាត្រា ២៦ នៃច្បាប់រដ្ឋបាលនិងគ្រប់គ្រងឃុំ-សង្កាត់ លើកទឹកចិត្តថា មេឃុំ និងគណៈកម្មាធិការធ្វើផែនការនិងធ្វើថវិកា ត្រូវតែបញ្ជូនរបាយការណ៍ឆ្នាំទៅឱ្យក្រុមប្រឹក្សាឃុំ គឺថាក្នុងចំណោមរឿងទាំងឡាយផ្សេងទៀត គួរតែបញ្ចូលការពិណនាស្តីពីបញ្ហានៅក្នុងការផ្តល់សេវាកម្មសង្គមចំបង និងជម្រើសផ្សេងៗសំរាប់ការកែលំអ។ ជាការអនុវត្ត យ៉ាងណាក៏ដោយ ក្រុមប្រឹក្សាឃុំខ្វះខាតវិធីសាស្ត្រច្បាស់លាស់មួយដើម្បីប្រមូលព័ត៌មានទៅតាមលំនាំនេះ។ ក្រុមស្រាវជ្រាវឃុំ ផ្តល់នូវសក្តានុពល ដើម្បីបង្កើតជាព័ត៌មានដែលត្រូវការ ជាពិសេសគឺទាក់ទងទៅនឹងជម្រើសសំរាប់ការកែលំអនៅក្នុងការផ្តល់សេវាកម្ម។ គំរូនេះ គួរតែចែករំលែកជាមួយនឹងទីភ្នាក់ងារជំនួយអន្តរជាតិ និងអង្គការផ្តល់ជំនួយផ្សេងទៀត ដើម្បីអាចធ្វើឱ្យគំរូនេះបង្កប់នៅក្នុងអន្តរាគមន៍ជំនួយអភិវឌ្ឍន៍។


សំណង់សាលារៀន


សាលាបឋមសិក្សា

# ម៉ូឌុលទី ៥

# បំណែកស្រាយនៅក្នុងគណនេយ្យភាពសង្គម

## គោលបំណងរបស់ម៉ូឌុល

ផ្តល់ការយល់ដឹងទូលំទូលាយដល់អ្នកចូលរួមអំពីយន្តការគណនេយ្យភាពសង្គម និងបទពិសោធន៍ការិត អន្តរជាតិ។

## ការរំពឹងទុករបស់ម៉ូឌុល

សង្ឃឹមថា តាមរយៈអំណានលើខ្លឹមសារទាំងឡាយដែលមាននៅក្នុងម៉ូឌុលនេះ សិក្ខាកាមនឹងអាចយល់បាន ទូលំទូលាយនូវ ៖

- បញ្ញត្តិ និងនិយមន័យនៃគណនេយ្យភាពសង្គម និងយន្តការនានា និងទំហំគណនេយ្យភាពសង្គម
- បរិបទច្បាប់នៃគណនេយ្យភាពសង្គមនៅប្រទេសកម្ពុជា
- ឧបករណ៍សំរាប់លើកកំពស់គណនេយ្យភាព
- បទពិសោធន៍ពីការសិក្សានានា នៅបឹងហ្គាឡូ ប្រទេសឥណ្ឌាដែលនិយាយពីប័ណ្ណព័ត៌មានសហគមន៍។

*នៅទីបំផុតនៃកម្មវិធីបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងត្រូវសិក្សាជាមួយសៀវភៅនេះ ដូចជាការងារផ្ទះ។ នៅថ្ងៃបន្ទាប់មកទៀត គេនឹងសួរសិក្ខាកាមអស់ទាំងនេះ ពីអ្វីដែលគេបានយល់ដឹងតាមរយៈសៀវភៅនេះ។ ការពិភាក្សានៅក្នុងថ្នាក់រៀន នឹងត្រូវបានរៀបចំឡើងដើម្បីផ្លាស់ប្តូរចំណេះដឹងគ្នា។*

**កំណត់សំគាល់**

សំភារៈសំរាប់អាន និងសិក្សាដែលមាននៅក្នុងម៉ូឌុលនេះ ត្រូវបានគេទទួលស្គាល់ និងផ្សព្វផ្សាយជាអន្តរជាតិ ។ សំភារៈទាំងនេះត្រូវបានគេដកស្រង់ដោយភ្ជាប់ទៅនឹងការដឹងគុណចំពោះអ្នកនិពន្ធ និងអ្នកបោះពុម្ពផ្សាយ ។

# បំណាកស្រាយ ទី១

## បញ្ញត្តិគណនេយ្យភាពសង្គម

នៅជុំវិញពិភពលោក ការកើនឡើងនៃការយកចិត្តទុកដាក់ទៅលើវិមជ្ឈការ និងប្រជាធិបតេយ្យ បាននាំទៅរកបញ្ហាចំបងៗ សំរាប់ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចមូលដ្ឋាន។ ថ្វីត្បិតតែបើគេក្រឡេកមួយភ្លែតទៅឃើញថា ប្រធានបទនេះ ហាក់ដូចជាមានភាពរលូនទៅមុខក៏ដោយ តែតាមការពិតទៅ សញ្ញាណគោលលដៅនីមួយៗដែលស្ថិតក្នុងរង្វង់នៃសញ្ញាណគណនេយ្យភាពសង្គម នៅតែមានភាពប្រទាំងប្រទើសគ្នា។ សំណើពីរខាងក្រោមនេះ មានបំណងបង្កឱ្យមានការជជែកដេញដោល ដើម្បីបង្កើតបានភាពត្រឹមត្រូវ ផលចំណេញ និងហានិភ័យនៃគណនេយ្យភាពសង្គម។

ការប្រឈមជាគន្លឹះមួយសំរាប់សតវត្សទី ២១ គឺជាការស្ថាបនាទំនាក់ទំនងថ្មី រវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាលមូលដ្ឋានរបស់ពួកគេ។ នេះបានន័យថា ជាការងាររបស់សមីការទាំងសងខាង ដែលជាការដើរហួសពីគោលបំណងរបស់សង្គមស៊ីវិល ឬ "មូលដ្ឋានរដ្ឋ " ដើម្បីផ្តោតទៅលើមុខប្រសព្វនៃគោលបំណងនេះតាមរយៈការចូលរួម ការឆ្លើយតប និងគណនេយ្យភាព។

ការលើកកំពស់គណនេយ្យភាពរបស់រដ្ឋាភិបាលមូលដ្ឋានទាំងឡាយចំពោះប្រជាពលរដ្ឋ អាចនឹងជាការនិយមមួយនៃសំណើរបស់អ្នកផ្តល់ជំនួយ និងអ្នកទ្រឹស្តីនិយមទាំងឡាយនៃលោកខាងលិច។ បញ្ញត្តិទាំងនេះជារឿយៗ តែងតែមានការហ្វឹកហាត់បន្តិចបន្តួចនៅក្នុងតថភាពនៃបរិបទនយោបាយ និងវប្បធម៌នៃប្រទេសកំពង់អភិវឌ្ឍន៍មួយចំនួន។ ភាពប្រថុយប្រថាននៃទម្រង់ថ្មីស្រឡាងនៃគណនេយ្យភាព និងការចូលរួមមានភាពសំខាន់ជាងផលកំរៃ។ ម្យ៉ាងទៀតគេឃើញមានតឹកតាងដ៏តិចតួចនៃទំនោរនៃការអភិវឌ្ឍន៍ភាពក្រីក្រ និងលទ្ធផលទាំងឡាយនៃអភិបាលកិច្ច។

ការទោមនស្សរបស់ប្រជាពលរដ្ឋក្រីក្រ ទៅលើស្ថាប័នផ្តល់សេវាកម្មសាធារណៈនានា ជាប់ទាក់ទងយ៉ាងទូលំទូលាយទៅនឹងបញ្ហា ការបញ្ចេញមតិនិងគណនេយ្យភាព។ អ្នកក្រីក្រមួយចំនួនមានជំនឿថា ស្ថាប័នរដ្ឋទាំងស្ថាបន័ផ្តល់សេវាកម្មនានា ស្ថាប័នដែលផ្តល់ការការពារពីប៉ូលីសឬស្ថាប័នយុត្តិធម៌ ឬទាំងអ្នកធ្វើការសំរេចចិត្តនយោបាយ គឺស្ថាប័នទាំងនោះ អ្នកទាំងនោះ ពុំមានការទទួលខុសត្រូវចំពោះអ្នកណាម្នាក់ឡើយ ឬស្ថាប័នទាំងនោះ អ្នកទាំងនោះ ទទួលខុសត្រូវតែចំពោះអ្នកមានទ្រព្យ និងអ្នកមានអំណាចតែប៉ុណ្ណោះ។

# បំណាក់ស្រាយ ទី២

## តើគណនេយ្យភាពសង្គមគឺជាអ្វី?

គណនេយ្យភាពសង្គម គឺជាការខិតចូលទៅជិតគណនេយ្យភាព

- ដែលអាស្រ័យទៅនឹងការចូលរួមរបស់ប្រជាពលរដ្ឋ
- ដែលប្រជាពលរដ្ឋសាមញ្ញ និង/ឬ អង្គការរបស់ពួកគេចូលរួមដោយផ្ទាល់ ឬមិនផ្ទាល់ ក្នុងការធ្វើឱ្យមានគណនេយ្យភាពយ៉ាងពិតប្រាកដ។

យន្តការនៃគណនេយ្យភាពសង្គម អាចត្រូវបានរដ្ឋ ប្រជាពលរដ្ឋ ឬទាំងរដ្ឋទាំងប្រជាជន ធ្វើការផ្ដួចផ្ដើម ឬគាំទ្រ ក៏ប៉ុន្តែ ជារឿយៗ យន្តការទាំងនេះត្រូវបានគេទាមទារឱ្យមានដំណើរការពីក្រោមទៅលើ។ យន្តការនានានៃគណនេយ្យភាពសង្គម មានរួមបញ្ចូលសកម្មភាពទាំងឡាយ និងឧបករណ៍ទាំងឡាយ ដែលប្រជាពលរដ្ឋ អង្គភាពក្រៅរដ្ឋាភិបាល និងបណ្ដាញផ្សព្វផ្សាយព័ត៌មានអាចប្រើប្រាស់ ដើម្បីធ្វើឱ្យអាជ្ញាធរសាធារណៈប្រកាន់ខ្ជាប់នូវការទទួលខុសត្រូវ។ គណនេយ្យភាពសង្គម សំដៅទៅលើលំដាប់សកម្មភាព និងយន្តការទូលំទូលាយ ដែលប្រជាពលរដ្ឋ សហគមន៍ បណ្ដាញផ្សព្វផ្សាយព័ត៌មានឯករាជ្យ និងអង្គការសង្គមស៊ីវិល ធានាអាចយកទៅប្រើប្រាស់ដើម្បីធ្វើឱ្យមន្ត្រីរដ្ឋ និងមន្ត្រីរាជរដ្ឋាភិបាល ប្រកាន់យកភាពទទួលខុសត្រូវ។ ទាំងនេះមានរួមបញ្ចូលក្នុងចំណោមសកម្មភាពដទៃទៀត ការចូលរួមក្នុងការធ្វើថវិកា ការតាមដាននៃការចំណាយសាធារណៈ ការពិនិត្យមើលការផ្ដល់សេវាកម្មសាធារណៈ គណៈកម្មការសាធារណៈ និងក្រុមប្រឹក្សាពិគ្រោះយោបល់របស់ប្រជាពលរដ្ឋ។ ភាពជាក់ស្ដែងណែនាំថាយន្តការគណនេយ្យភាពសង្គម អាចរួមចំណែកក្នុងការកែលំអអភិបាលកិច្ច បង្កើនការអភិវឌ្ឍន៍ ប្រសិទ្ធិភាពតាមរយៈការផ្ដល់សេវាកម្មល្អប្រសើរ និងការបំពាក់អំណាចដល់ប្រជាពលរដ្ឋ។

តើគណនេយ្យភាពសង្គមធ្វើការផ្លាស់ប្ដូរដូចម្ដេចខ្លះ?

- ពីការចំលងតាមទៅ "ការបញ្ចេញសំលេង" ដោយប្រជាពលរដ្ឋ
- ពី "ការប្រកួកប្រកាស"ទៅរក "ការគិតគូរ" -ត្រូវការបរិមាណសំឡេង និងការផ្ដល់មតិបកមកវិញ
- ពី "ប្រតិកម្ម" ទៅរកការ "ផ្ដល់ព័ត៌មានពីសកម្មភាព"
- ពីការឆ្លើយតបមួយសំណើទៅរកសកម្មភាពដែលមានការរៀបចំត្រឹមត្រូវ
- ពីការប្រឈមមុខទៅរកដំណោះស្រាយ "ឈ្នះ-ឈ្នះ"

***ប្រភព : ទំព័រវើលបែ : ការចូលរួម និងការចូលរួមរបស់ប្រជាពលរដ្ឋ***

# បំណាកស្រាយ ទី៧

## ការបង្កើតនៅវិចនៃយន្តការគណនេយ្យភាពសង្គម




គណនេយ្យភាពសង្គមរួមបញ្ចូលទាំងសកម្មភាពទាំងឡាយច្រើនស្មុគស្មាញ ដែលជាសក្តានុពលប្រជាពលរដ្ឋអាចធ្វើឱ្យមន្ត្រីរដ្ឋាភិបាល និងអ្នកការិយាល័យធិបតេយ្យទាំងឡាយប្រកាន់នូវការទទួលខុសត្រូវ។ សកម្មភាពទាំងនេះ អាចនឹងត្រូវបានអនុវត្តដោយអ្នកពាក់ពន្ធ័ជាច្រើន (ដូចជា ប្រជាពលរដ្ឋក្នុងសហគមន៍ សមាជិកសភា អង្គការសង្គមស៊ីវិល បណ្តាញផ្សព្វផ្សាយព័ត៌មាន)។ សកម្មភាពទាំងនេះ អាចកើតឡើងនៅក្នុងកំរិតផ្សេងគ្នា (ពីមូលដ្ឋានដល់ថ្នាក់ជាតិ) ដើម្បីដោះស្រាយបញ្ហាជាច្រើនយ៉ាង (ដូចជានយោបាយសាធារណៈ ក្រមសីលធម៌នយោបាយ ចំណាយសាធារណៈ ការផ្តល់សេវាកម្មសាធារណៈ) និងប្រើប្រាស់នូវយុទ្ធសាស្ត្រផ្សេងគ្នា (ដូចជាការស្រាវជ្រាវ ការត្រួតពិនិត្យ ការចូលរួមក្នុងការធ្វើផែនការ ការអប់រំប្រជាពលរដ្ឋ ការពង្រីកការផ្សព្វផ្សាយ ការកសាងសម្ព័ន្ធភាព)។ ថ្វីបើមានភាពប្លែកគ្នាយ៉ាងនេះក៏ដោយក៏គោលបំណងនៃគណនេយ្យភាព ជាទៀងទាត់ តែងតែធ្វើឱ្យមានភាពសំខាន់នូវដំណើរការនៃផលប្រយោជន៍រួម ប្រព្រឹត្តទៅប្រកបដោយភាពច្បាស់លាស់និងអាចទទួលយកបាន។ លើសពីការតស៊ូមតិតែមួយមុខប៉ុណ្ណោះ ជារឿយៗ គេត្រូវតែព្យាយាមកសាងមូលដ្ឋាននៃតឹកតាងដែលអាចឱ្យជឿជាក់បាន សំរាប់ការចូលរួមរបស់សាធារណជន។ ជាធម្មតា គេប្រមូលផ្តុំធាតុសំខាន់ៗទាំងឡាយ និងបង្កើតជាប្លុកមួយចំនួន (ឬទាំងអស់) ដូចតទៅ :

### ការប្រមូលកម្លាំងជុំវិញចំណុចចូល

ជំហានទីមួយនៃគំនិតផ្តួចផ្តើមនៃគណនេយ្យភាពសង្គម ភាគច្រើនគឺជាការធ្វើអត្តសញ្ញាណកម្មទៅលើចំណុចចូលនិងការបង្កើតយុទ្ធសាស្ត្រ ដែលតាមរយៈនេះបញ្ហាជាអាទិភាពមួយអាចនឹងត្រូវបានដោះស្រាយ។

អាចជាបញ្ហាដែលមានចរិតច្បាស់លាស់ ឬក៏ទូទៅ នឹងអាចត្រូវបានគេធ្វើការកំណត់ក្នុងកំរិតមូលដ្ឋានថ្នាក់តំបន់ ឬថ្នាក់ជាតិ ។ ឧទាហរណ៍ នៅក្នុងករណីនៃភាពទន់ខ្សោយក្នុងការផ្តល់សេវាកម្មសុខភាពសក្តានុពលនៃចំណុចចូលអាចរួមបញ្ចូលទាំងការដាក់ទុនថវិកាទៅលើសុខាភិបាលជាតិ អំពើពុករលួយប្រសិទ្ធិផលនៅក្នុងប្រព័ន្ធចែកចាយថ្នាក់ជាតិ ឬនៅក្នុងការបំពេញភារកិច្ចរបស់អ្នកផ្តល់សេវាកម្មថ្នាក់មូលដ្ឋាន ឬក៏របស់គណៈកម្មការគ្រប់គ្រងសុខភាពភូមិ។ អ្វីៗទាំងអស់នេះ គឺជាទំនាស់ ដ៏ធ្ងន់ធ្ងរក្នុងការផ្តល់សេវាកម្មសុខភាព។ យុទ្ធសាស្ត្រដ៏មានសក្តានុពលនានា ដើម្បីដោះស្រាយបញ្ហាទាំងនេះ អាចរួមបញ្ចូលជាអាទិ៍ ការវិភាគថវិកា សកម្មភាពតស៊ូមតិ ការត្រួតពិនិត្យទុនដាក់ចូលសំរាប់សេវាកម្មសុខភាព និងការចំណាយ ការចូលរួមវាយតំលៃទៅលើសេវាកម្មសុខភាពមូលដ្ឋានជាដើម។

## ការកសាង និងការទទួលបានព័ត៌មាន / តឹកតាងមូលដ្ឋាន :

ការទទួលបាន ឬការបង្កើតព័ត៌មានពាក់ព័ន្ធ និងការកសាងមូលដ្ឋានតឹកតាងគួឱ្យទុកចិត្តបាន ដែលអាចនឹងប្រើប្រាស់សំរាប់ធ្វើឱ្យមន្ត្រីរដ្ឋមានការទទួលខុសត្រូវ គឺទិដ្ឋភាពដ៏សំខាន់នៃគណនេយ្យភាពសង្គម។ គំនិតផ្តួចផ្តើមនានានៃគណនេយ្យភាពសង្គម ជារឿយៗ តែងតែជាប់ទាក់ទងនឹងការទទួលបាន (១)ទិន្នន័យ / ព័ត៌មានពីភាគីអ្នកផ្តល់ (ពីរដ្ឋាភិបាល និងអ្នកផ្តល់សេវាកម្ម និង (២) ទិន្នន័យ/ព័ត៌មានពីភាគីអ្នកត្រូវការ (ពីអ្នកប្រើប្រាស់សេវាកម្មរបស់រដ្ឋាភិបាល សហគមន៍ និងប្រជាពលរដ្ឋ)។ ការទទួលបានព័ត៌មានពីភាគីអ្នកផ្តល់ " (ដូចជាព័ត៌មានស្តីពីគោលនយោបាយ ការសន្យា ផ្តល់ថវិកា និងគណនីកំណត់ត្រាទុនបញ្ចូល លទ្ធផល និងការចំណាយ ការធ្វើសវកម្មជាដើម) នោះតម្លាភាពក្នុងរដ្ឋាភិបាល និងសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការផលិត និងការផ្តល់ទិន្នន័យ និងគណនី គឺជាការចាំបាច់បំផុត។ ចំពោះព័ត៌មានពីភាគីអ្នកត្រូវការវិញ " ធានាភាពដ៏ទូលំទូលាយនៃវិធីសាស្ត្រ និងឧបករណ៍នៃការចូលរួម (ដូចជាប័ណ្ណដាក់ពិន្ទុរបស់សហគមន៍ ប័ណ្ណព័ត៌មានសហគមន៍របស់ប្រជាពលរដ្ឋ ការពិនិត្យតាមដានការចូលរួម និងបច្ចេកទេសវាយតំលៃ) ត្រូវបានបង្កើតឡើងដើម្បីបង្កើតទិន្នន័យដែលមានប្រយោជន៍ក្នុងការប្រើប្រាស់ ក្នុងពេលព្រមគ្នា សំរាប់ការបង្កើតចំណេះដឹង និងលើកកំពស់ ការតៀងគរកំលាំង និងអង្គការស្ថាប័ននៅថ្នាក់មូលដ្ឋាន។

## ការវិភាគព័ត៌មាន :

ទិន្នន័យ / ព័ត៌មានពាក់ព័ន្ធនៅពេលដែលបានទទួលហើយនឹងអាចត្រូវបានគេបកស្រាយ និងវិភាគដើម្បីធ្វើឱ្យមានប្រយោជន៍ក្នុងកិច្ចប្រតិបត្តិការ។ រឿងនេះអាចទាក់ទងទៅនឹងការធ្វើការជាមួយអ្នកឯកទេស ដែលបានទទួលការបណ្តុះបណ្តាលរួចហើយ (ដូចជាអ្នកដែលអាចជួយក្នុងការ " បើកកាយ " ថវិកា ឬបំបែកគណនីហិរញ្ញវត្ថុ) ឬក៏ការប្រើប្រាស់វិធីសាស្ត្រចូលរួមដើម្បីជួយសមាជិកសមាគម ឬក្រុមអ្នកប្រើប្រាស់ធ្វើការវិភាគទិន្នន័យថ្នាក់មូលដ្ឋាន ឬរួមគ្នាវាយតំលៃលើសេវាកម្មសាធារណៈ។ ក្នុងករណីផ្សេងទៀត

គោលបំណងនៃការវិភាគ គឺជាការបង្កើតគំហើញដ៏មានប្រយោជន៍ ដែលអាចធ្វើឱ្យអ្នកចូលរួមចំណែកបានយល់ដឹង និងអាចយកទៅប្រើប្រាស់បន្តសំដៅទៅរកការតវ៉ាតែមួយប៉ុណ្ណោះក្នុងការពិភាក្សាជាក់ស្តែង។

## ការបង្កើតព័ត៌មានសាធារណៈ និងការផ្សព្វផ្សាយ

ការទទួលបានព័ត៌មាន និងគំហើញនានាក្នុងវិស័យសាធារណៈ និងការបង្កើតការពិភាក្សាដេញដោលជាសាធារណៈជុំវិញរឿងនេះ (ព័ត៌មាន និងគំហើញ) គឺជាធាតុសំខាន់នៃគំនិតផ្តួចផ្តើមភាគច្រើននៃគណនេយ្យភាពសង្គម។ ការធ្វើថវិកាឱ្យមានភាពល្អិតល្អន់ ការរកឃើញ ការពិនិត្យឡើងវិញនូវចំណាយសាធារណៈ សវនកម្ម ឬលទ្ធផលនៃការវាយតំលៃលើគំរោងកម្មវិធី ព័ត៌មាននេះអាចធ្វើឱ្យមានសារៈសំខាន់ និងផលប៉ះពាល់ នៅពេលដែលព័ត៌មាននេះចូលយ៉ាងទូលំទូលាយក្នុងជួរសាធារណជន ហើយនៅពេលដែលព័ត៌មាននេះបំរើដល់ការផ្តល់ព័ត៌មាន និងការបង្កើតសន្ទុះសំរាប់ការធ្វើសកម្មភាព។ យុទ្ធសាស្ត្រ និងយន្តការប្រាស្រ័យទាក់ទងដ៏មានប្រសិទ្ធិភាព គឺទិដ្ឋភាពសំខាន់នៃគណនេយ្យភាពសង្គមនេះឯង។ ទាំងនេះអាចរួមបញ្ចូលទាំងការរៀបចំការប្រជុំសាធារណៈ និងការបង្កើតព្រិត្តិការណ៍ផ្សេងៗ ក៏ដូចជាការប្រើប្រាស់ជាយុទ្ធសាស្ត្រនូវទម្រង់ប្រព័ន្ធផ្សព្វផ្សាយបែបទំនើប និងទាំងបែបបូរាណ។ ការផ្សព្វផ្សាយព័ត៌មាន ពាក់ព័ន្ធទៅមន្ត្រីនានារបស់រដ្ឋាភិបាល ដែលជាអ្នកមានតំណែងក្នុងការអនុវត្តរឿងនេះ (ការធ្វើអន្តរកម្មដោយផ្ទាល់ជាមួយអ្នកសំរេចចិត្តទាំងនោះទៅលើមូលដ្ឋានដែលមានស្រាប់) ក៏ជាទិដ្ឋភាពដ៏សំខាន់នៃគណនេយ្យភាពសង្គមផងដែរ។

## ការបង្កើតការគាំទ្ររបស់សាធារណជន :

ប្រជាពលរដ្ឋដែលបានទទួលព័ត៌មានពីសិទ្ធិនិងការទទួលខុសត្រូវរបស់ពួកគេ នឹងមានការចូលរួមក្នុងផលប្រយោជន៍ និងក្នុងការគៀងគរពួកគេក្នុងការបង្កើតជាសម្ព័ន្ធភាព និងភាពជាដៃគូជាមួយអ្នកចូលរួមដទៃទៀត (ដូចជា មន្ត្រីការិយាធិបតេយ្យ បណ្តាញផ្សព្វផ្សាយព័ត៌មាន សមាជិកសភាជាដើម) គឺជាទិដ្ឋភាពចំបងនៃគណនេយ្យភាពសង្គម។ ជាគំនិតនិយម ជំហានទីមួយនៃគំនិតផ្តួចផ្តើមគណនេយ្យភាពសង្គម គឺជាវិភាគទានទៅដល់ប្រជាពលរដ្ឋដែលទទួលបានព័ត៌មាន ការចូលរួម នឹងទៅដល់ប្រជាពលរដ្ឋដែលរៀបចំសកម្មភាពរួមគ្នា និងសមត្ថភាពរបស់អង្គការសង្គមស៊ីវិលក្នុងការសម្រួល និងគាំទ្រការគៀងគរកម្លាំង គឺជាសារៈសំខាន់មួយដើម្បីភាពជោគជ័យនៃគំនិតផ្តួចផ្តើមគណនេយ្យភាពសង្គម។ ជាថ្មីម្តងទៀត ការបានទៅដល់ជនក្រីក្រ និងជនដែលត្រូវគេមិនអើពើនោះ ត្រូវទាមទារឱ្យមានការប្រឹងប្រែងជាក់លាក់ និងការប្រឈមមុខដ៏ធំធេង។

## ការចរចាដើម្បីការផ្លាស់ប្ដូរ

ធាតុដែលសំខាន់ និងប្រឈមមុខបំផុតនៃយុទ្ធសាស្ត្រគណនេយ្យភាពសង្គម គឺជាសមត្ថភាពក្នុងការធ្វើឱ្យមានការឆ្លើយតបរបស់មន្ត្រីសាធារណៈ និងធ្វើឱ្យមានផលប៉ះពាល់ទៅលើការផ្លាស់ប្ដូរដោយពិតប្រាកដ។ តាមធម្មតា យុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពខ្លាំងបំផុតនោះ តែងតែជាប់ទាក់ទងដោយផ្ទាល់ទៅនឹងអន្តរកម្ម និងការចរចាជាមួយដៃគូរដ្ឋាភិបាលដែលមានការពាក់ព័ន្ធ ហើយក្នុងករណីខ្លះ ជាមួយស្ថាប័នកម្មនៃយន្តការនានាសំរាប់ការពិគ្រោះយោបល់ និងការជជែកពិភាក្សាគ្នា។ ដូចដែលបានរៀបរាប់ពីខាងលើថា ក្នុងការចរចាដើម្បីរកការផ្លាស់ប្ដូរ ប្រជាពលរដ្ឋប្រើប្រាស់គ្រប់មធ្យោបាយទាំងផ្លូវការ និងក្រៅផ្លូវការ ដើម្បីបញ្ចុះបញ្ចូល ដាក់សម្ពាធ ផ្ដល់រង្វាន់ និងអនុមតិ។ ទាំងនោះ ជាឧទាហរណ៍ ដោយរាប់បញ្ចូលទាំងការបង្កើតគំនាបពីសាធារណជន (ដូចជាតាមរយៈការឃោសនាតាមបណ្ដាញផ្សព្វផ្សាយព័ត៌មាន និងការប្រជុំជាសាធារណៈ) ឬក្នុងពេលដែលចាំបាច់នោះ ការជ្រើសរើសយកមធ្យោបាយផ្លូវការសំរាប់ការអនុវត្តច្បាប់ (ដូចជា តាមរយៈដំណើរការផ្លូវច្បាប់ និងតុលាការ)។ លំហ និងឱកាសសំរាប់ការចរចាក៏ដូចជាលទ្ធភាពសំរាប់រិះរកមធ្យោបាយផ្លូវការសំរាប់អនុមតិ មានភាពប្រែប្រួលយ៉ាងធំធេងពីបរិបទនៃប្រទេសមួយទៅប្រទេសមួយទៀត។ នៅក្នុងបរិបទនៃប្រទេសកំពុងអភិវឌ្ឍមួយចំនួន ក្រុមប្រជាពលរដ្ឋបានមើលឃើញថា កំណែទម្រង់ផ្នែកច្បាប់ និង/ឬស្ថាប័ន គឺជាការចាំបាច់សំរាប់ការធ្វើឱ្យងាយស្រួលដល់ការចរចាប្រកបដោយខ្លឹមសារ។

# បំណាកស្រាយ ទី៤

## ទំហំនៃគណនេយ្យភាពសង្គម

យន្តការគណនេយ្យភាពសង្គមអាចនឹងមានទំហំប្លែកគ្នាទៅតាមលក្ខណវិនិច្ឆ័យ ៦ យ៉ាង គឺ : យន្តការដាក់ទណ្ឌកម្ម និងការផ្តល់រង្វាន់ យន្តការវិធានប្រតិបត្តិនិងមូលដ្ឋានបំពេញការងារ កំរិតស្ថាបនកម្ម ជម្រៅនៃការចូលពាក់ព័ន្ធ ការគិតគូរលើការចូលរួម និងផ្នែកនានានៃរដ្ឋាភិបាល ។ ទំហំនីមួយៗនៃទំហំទាំងនោះ មានសារៈសំខាន់សំរាប់គោលបំណងក្នុងការធ្វើផែនការ និងសំរាប់ការវាយតំលៃពីភាពដែលអាចធ្វើឱ្យបាន និងនិរន្តរភាពនៃយន្តការណាមួយ អាចនឹងមានសំរាប់បរិបទនៃប្រទេស និងស្ថាប័នណាមួយ ។

| ទំហំខុសៗគ្នាទាំង ៦ យ៉ាង នៃគណនេយ្យភាពសង្គម |
|---|
| រចនាសម្ព័ន្ធលើកទឹកចិត្ត : ការដាក់ទណ្ឌកម្ម ឬផ្តល់រង្វាន់ ? |
| តើយន្តការគណនេយ្យភាពសង្គមតម្រង់ឆ្ពោះទៅរកការផ្តល់រង្វាន់ ឬការធ្វើទោសមានវិសាលភាពប៉ុណ្ណា? យន្តការដែលដែលផ្អែកយ៉ាងខ្លាំងទៅលើការដាក់ទោស អាចគំរាមកំហែងដល់មន្ត្រីសាធារណៈទាំងឡាយ និងបង្កឱ្យមានការគាំងដំណើរ ។ ការផ្តល់រង្វាន់មិនអាចកែប្រែឥរិយាបទមនុស្សខិលខូចនោះទេ ។ យន្តការគណនេយ្យភាពដែលរឹងមាំបំផុតនោះផ្តោតផ្តួលទៅលើតុល្យភាពរវាងការដាក់ទណ្ឌកម្ម និងការផ្តល់រង្វាន់ ។ |
| គណនេយ្យភាព : វិធានការសំរាប់ប្រតិបត្តិ ឬ មូលដ្ឋានការងារ ? |
| ការផ្តោតទៅលើវិធានការសំរាប់ប្រតិបត្តិទាក់ទងទៅនឹងអ្វីដែលគេហៅថា "ការគ្រប់គ្រងសាធារណៈរបៀបចាស់" បានស្ថិតនៅក្នុងសញ្ញាណចាស់នៃការិយាធិបតេយ្យ និងសកម្មភាពប្រកបដោយវិចារណញ្ញាណ ។ យន្តការនានាដែលសំលឹងទៅរកការជំរុញការកែលំអការងារ គឺជាលក្ខណៈវិនិច្ឆ័យនៃ "ការគ្រប់គ្រងសាធារណៈរបៀបថ្មី" និងផ្តោតទៅលើលទ្ធផលដែលបានបំពេញតាមរយៈការវាយតំលៃលើការបំពេញការងារ ។ យុទ្ធសាស្ត្រល្អប្រសើរ ដែលងាកទៅរកគណនេយ្យភាព គឺផ្តោតទៅលើការចូលរួមរបស់ប្រជាពលរដ្ឋទាំងក្នុងការអនុវត្តវិធានការនានា និងទៅលើការកែលំអការងារ ។ |
| ស្ថាបនកម្ម : ទាប ឬ ខ្ពស់ ? |
| យន្តការគណនេយ្យភាពមួយចំនួន គឺជាគំនិតផ្តួចផ្តើមពិសេសដែលធ្វើឡើងដោយន័យល្អសំរាប់មន្ត្រីសាធារណៈដោយគ្មានដាក់បញ្ចូលជាអចិន្ត្រៃយ៍ទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋឡើយ ។ តើយន្តការគណនេយ្យភាពនៃការចូលរួមដែលមានចែងក្នុងច្បាប់ដែលទាមទារឱ្យទីភ្នាក់ងារសាម៉ីនីមួយៗ ឬក៏ទីភ្នាក់ងាររដ្ឋាភិបាលទាំងមូល ចូលទាក់ទងនឹងអ្នកពាក់ព័ន្ធក្នុងសង្គមនៅពេលណាមួយជាក់លាក់ក្នុងដំណើរការគោលនយោបាយសាធារណៈមានវិសាលភាពយ៉ាងដូចម្តេច ? |

### ការពាក់ព័ន្ធ ៈខាងក្រៅ និងខាងក្នុង ?

យន្តការគណនេយ្យភាពមួយចំនួនទាក់ទងទៅនឹងការពិគ្រោះយោបល់ និងសិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធក្នុងសង្គម ក៏ប៉ុន្តែ ភាគតិចទាក់ទងនឹងការអញ្ជើញអ្នកទាំងនោះទៅក្នុង "ផ្ទះបាយ" ដើម្បីសង្កេតដំណើរការរៀបចំផែនការជាជំហានៗរបស់រដ្ឋាភិបាល ។ តើយន្តការលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងកុះករ ជាជាងការចូលរួមបន្តិចបន្តួច មានវិសាលភាពដូចម្តេច ?

### ការរួមបញ្ចូល : វរជន ឬ ការរួមបញ្ចូល ?

មាននិន្នាការមួយនៃយន្តការគណនេយ្យភាព ដើម្បីឱ្យក្រុមតូចនៃអង្គការក្រៅរដ្ឋាភិបាលដែលមានឥរិយាបទល្អ មានវិជ្ជាជីវៈថ្នាក់កណ្តាល និងអ្នកនយោបាយមជ្ឈករចូលរួម ។ តើយន្តការដែលលើកកំពស់យ៉ាងពិតប្រាកដនូវការចូលរួមរបស់ក្រុមប្រជាពលរដ្ឋដែលមានសំឡេងទន់ខ្សោយ ឬក្រុមដែលមានផលប្រយោជន៍ច្រើនបែប និងមានការប្រមើលទៅមុខដ៏ត្រឹមត្រូវនោះ មានវិសាលភាពដូចម្តេច ?

### ផ្នែករបស់រដ្ឋាភិបាល : នីតិប្រតិបត្តិ នីតិបញ្ញត្តិ ឬ តុលាការ ?

ជារឿយៗ យន្តការគណនេយ្យភាពមានទំនោរតម្រង់ទិសទៅរកផ្នែកនីតិប្រតិបត្តិ ។ ដូចនេះ ការកែទម្រង់ផ្នែកនីតិប្រតិបត្តិ គឺជាការប្រឈមមុខយ៉ាងសំខាន់ ហើយក៏មានសារៈសំខាន់ដូចគ្នាដែរនោះ គឺសំរាប់កំណែទម្រង់ផ្នែកនីតិបញ្ញត្តិ និងតុលាការ ។ គេអាចមានការលំបាកក្នុងការជ្រៀតចូលទៅក្នុងផ្នែកតុលាការ ចំណែកឯ ផ្នែកនីតិបញ្ញត្តិវិញ ជារឿយៗក៏ជា "កន្លែងយករំមាស" ដែលបិទជិតសំរាប់កំណែទម្រង់ដើម្បីងាកទៅរកគណនេយ្យភាពផងដែរ ។

# បំណាកស្រាយ ទី៥

## គណនេយ្យភាពសង្គម : កត្តាជាយុទ្ធសាស្ត្រសំរាប់ការជោគជ័យ

ការវិវត្តរបស់គំនិតផ្តួចផ្តើមគណនេយ្យភាពសង្គមស្ថិតនៅឆ្ងាយពីអ្វីដែលជាប្រព័ន្ធ។ មួយផ្នែកធំ វិធានការនានាដែលដាក់ចុះដោយក្រុមប្រជាពលរដ្ឋដើម្បីលើកកំពស់គណនេយ្យភាព ត្រូវបានឆ្លើយតបតាមកាលៈទេសៈនៃស្ថានភាពពិសេសដាច់ដោយឡែក។ ដូចនេះ ជោគជ័យរបស់ពួកគេក៏ទាក់ទងយ៉ាងខ្លាំងទៅនឹងកត្តាមួយចំនួន។ កត្តាមួយចំនួនត្រូវបានលើកយកមកពិភាក្សាដូចខាងក្រោម :

### បរិបទនយោបាយ និងវប្បធម៌

ព្រំដែនសំរាប់គណនេយ្យភាពសង្គមត្រូវបានកំណត់យ៉ាងទូលំទូលាយដោយបរិបទនយោបាយ និងវប្បធម៌ដែលមានស្រាប់។ ឧទាហរណ៍ ភាពអាចធ្វើទៅបាន និងភវនីយភាពនៃជោគជ័យរបស់គំនិតផ្តួចផ្តើមគណនេយ្យភាពសង្គមទាក់ទងយ៉ាងខ្លាំងទាំងទៅនឹងរបបនយោបាយប្រជាធិបតេយ្យ មានប្រព័ន្ធពហុបក្ស មានការធានានយោបាយ និងសិទ្ធិពលរដ្ឋ (រួមបញ្ចូលទាំងការទទួលបានព័ត៌មាន និងសេរីភាពក្នុងការបញ្ចេញមតិ ការធ្វើសមាគម និងការប្រជុំ) ទាំងលើការមានវប្បធម៌នយោបាយតម្លាភាព និងសុចរិតភាព។ គេអាចគិតគូរដល់អាទិភាពរបស់កត្តាជាដើមចមទាំងនេះ ហើយបើគ្មានវត្តមាននៃហានិភ័យជាសក្តានុពលនោះ កត្តាទាំងនោះត្រូវតែបានគេយកទៅគិតគូរនៅពេលគេរៀបចំផែនការសំរាប់គំនិតផ្តួចផ្តើមគណនេយ្យភាពសង្គម។ កត្តាច្បាប់ ស្ថាប័ន និង សង្គមវប្បធម៌អាចនឹងមានឥទ្ធិពលយ៉ាងសំខាន់ទៅលើជោគជ័យនៃសកម្មភាពគណនេយ្យភាពសង្គម។ បរិបទមិនអំណោយផលមិនមានន័យថា សកម្មភាពគណនេយ្យភាពសង្គមមិនត្រូវបានគេធ្វើនោះទេ។ ទោះជាយ៉ាងណាក៏ដោយក្នុងកាលៈទេសៈបែបនេះ ការវិភាគលើកត្តាគន្លឹះដែលមានឥទ្ធិពលលើបរិស្ថានសំរាប់គណនេយ្យភាពសង្គម (និងហានិភ័យដែលគេតម្រូវ) អាចនឹងត្រូវបានគេទទួលរ៉ាប់រង ហើយយុទ្ធសាស្ត្រធុនល្មមសំរាប់បំបាត់ការរាំងរាទាំងឡាយនោះត្រូវបានគេបង្កើតឡើង។

### ការទទួលបានព័ត៌មាន

ដូចបានរៀបរាប់ពីខាងលើភាពជួនល្មម និងគួរឱ្យជឿបាននៃឯកសារ និងទិន្នន័យសាធារណៈ គឺជាការសំខាន់ក្នុងការកសាងគណនេយ្យភាពសង្គម។ ព័ត៌មានបែបនេះ គឺជាមូលដ្ឋានសំរាប់សកម្មភាពនានានៃគណនេយ្យភាពសង្គម ហើយបើដូចនេះ គុណភាព និងភាពទទួលបានព័ត៌មាន គឺជាកត្តាកំណត់យ៉ាងសំខាន់សំរាប់ការជោគជ័យរបស់យន្តការគណនេយ្យភាពសង្គម។ ក្នុងករណីខ្លះ ការខិតខំដើម្បីគណនេយ្យភាពសង្គមត្រូវការផ្តោតទៅលើច្បាប់ស្តីពី

សេរីភាពព័ត៌មានពេញលេញ ដំណោះស្រាយការខ្វះខាតឆន្ទៈនយោបាយក្នុងការមិនលាក់លៀម ឬពង្រឹងសមត្ថភាពបច្ចេកទេសនៃស្ថាប័នសាធារណៈក្នុងការកត់ត្រា គ្រប់គ្រង និងបង្កើតភាពងាយស្រួលមនៃទិន្នន័យពាក់ព័ន្ធ។

## តួនាទីរបស់បណ្តាញផ្សព្វផ្សាយព័ត៌មាន

បណ្តាញផ្សព្វផ្សាយព័ត៌មានដើរតួយ៉ាងសំខាន់ក្នុងការលើកកំពស់គណនេយ្យភាពសង្គម។ ក្នុងប្រទេសមួយចំនួនបណ្តាញផ្សព្វផ្សាយព័ត៌មានឯករាជ្យ គឺជាកម្លាំងឈានមុខក្នុងការផ្តល់ព័ត៌មាន អប់រំប្រជាពលរដ្ឋ ពិនិត្យតាមដានការបំពេញភារកិច្ចរបស់រដ្ឋាភិបាល និងក្នុងការបង្ហាញអំពីភាពអសកម្មនានា។ បណ្តាញផ្សព្វផ្សាយព័ត៌មានថ្នាក់មូលដ្ឋាន (ជាពិសេស វិទ្យុឯកជន និងរបស់សហគមន៍) ផ្តល់នូវមធ្យោបាយដ៏សំខាន់ដែលជាមួយនោះប្រជាពលរដ្ឋសាមញ្ញអាចបញ្ចេញទស្សនៈពួកគេ និងពិភាក្សាលើបញ្ហាសាធារណៈទាំងឡាយ។ វិសាលភាពដែលបណ្តាញផ្សព្វផ្សាយព័ត៌មានមានភាពឯករាជ្យ ហើយអ្នកគ្រប់គ្រងមានចរិតពហុបក្សនិយម (ដែលផ្ទុយនឹងបណ្តាញផ្សព្វផ្សាយព័ត៌មានដែលនៅក្នុងដៃជនមួយក្រុមតូច) គឺជាកត្តាដ៏សំខាន់ដែលអាចជាវិភាគទានដល់គណនេយ្យភាពនៃប្រព័ន្ធនយោបាយ។ ធាតុរួមនៃភាពជោគជ័យរបស់ការផ្តួចផ្តើមគណនេយ្យភាពសង្គម គឺជាយុទ្ធសាស្ត្រសំរាប់ប្រើប្រាស់ទម្រង់នៃបណ្តាញផ្សព្វផ្សាយព័ត៌មានទាំងបែបបូរាណ និងបែបទំនើបដើម្បីបង្កើនចំណេះដឹងជុំវិញបញ្ហាសាធារណៈក្នុងការផ្សព្វផ្សាយគំហើញទាំងឡាយ និងបង្កើតជាថ្នាលសំរាប់ការជជែកដេញដោលជាសាធារណៈ។

## សមត្ថភាពសង្គមស៊ីវិល

សមត្ថភាពរបស់អ្នកដើរតួជាសង្គមស៊ីវិល ក៏ជាកត្តាសំខាន់មួយដែរសំរាប់ការជោគជ័យរបស់គណនេយ្យភាពសង្គម។ កំរិតនៃការរៀបចំរបស់អង្គការសង្គមស៊ីវិល ទំហំនៃសមាជិកភាពរបស់អង្គការទាំងនោះបច្ចេកទេស និងការប៉ិនប្រសប់របស់អង្គការទាំងនោះក្នុងការតស៊ូមតិ សមត្ថភាពរបស់ពួកគេក្នុងការកៀងគរ និងប្រើប្រាស់ដោយប្រសិទ្ធភាពនូវបណ្តាញផ្សព្វផ្សាយព័ត៌មាន ភាពស្របច្បាប់ និងភាពជាតំណាងរបស់ពួកគេ និងកំរិតនៃការឆ្លើយតបនិងគណនេយ្យភាព ចំពោះសមាជិកពួកគេទាំងអស់នោះ ជាចំណុចកណ្តាលរបស់ជោគជ័យនៃសកម្មភាពគណនេយ្យភាពសង្គម។ នៅក្នុងបរិបទមួយចំនួន ត្រូវទាមទារឱ្យមានការប្រឹងប្រែងក្នុងការលើកកំពស់បរិស្ថានដែលអាចធ្វើបានសំរាប់សង្គមស៊ីវិល និងក្នុងការកសាងសមត្ថភាព (ទាំងការរៀបចំស្ថាប័ន និងបច្ចេកទេស) របស់អង្គការសង្គមស៊ីវិល។

## សមត្ថភាពរបស់រដ្ឋ

ជោគជ័យរបស់ការផ្តួចផ្តើមគណនេយ្យភាពសង្គមអាស្រ័យផងដែរទៅលើសមត្ថភាព និងប្រសិទ្ធភាពរបស់រដ្ឋ។ ការផ្តួចផ្តើមគណនេយ្យភាពសង្គមនឹងមានន័យតិចតួច ជាឧទាហរណ៍នៅក្នុងខណៈដែលម៉ាស៊ីនរដ្ឋ

ដួលរលំ ឬក៏លែងប្រើការបាន។ មុខងារនៃរដ្ឋបាលសាធារណៈដែលមានសមត្ថភាពមួយចំនួនដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ គឺជាអ្វីដែលគេត្រូវការជាមុន។ ទិដ្ឋភាពដទៃទៀតរបស់សមត្ថភាពរដ្ឋដែលមានឥទ្ធិពលទៅលើការផ្តួចផ្តើមគណនេយ្យភាពសង្គម (និងដែលអាចទាមទារឱ្យមានសមត្ថភាពបង្កើតការវិនិយោគ) រួមបញ្ចូលភាពប្រសប់ក្នុងការធ្វើកំណត់រឿង និងបង្កើតគណនីអត្ថិភាព នៃកតិកាយន្តការគណនេយ្យភាព ការរំលែកអំណាចនិងធនធាន ឆន្ទៈនិងសមត្ថភាព ក្នុងការកសាងភាពជាដៃគូ និងវប្បធម៌នយោបាយ ឬរដ្ឋបាលដែលឱ្យតំលៃទៅលើសញ្ញាណនៃសុចរិតភាព គណនេយ្យភាព និងភាពត្រឹមត្រូវរបស់ផ្នែកសាធារណៈ។

## សហការរួមរបស់រដ្ឋ-សង្គមស៊ីវិល

ដោយលើសលប់បំផុត ជោគជ័យនៃការផ្តួចផ្តើមគណនេយ្យភាពសង្គម អាស្រ័យទៅលើទម្រង់មួយចំនួននៃអន្តរកម្មដ៏មានប្រសិទ្ធភាពរវាងសង្គមស៊ីវិលនិងរដ្ឋ។ លទ្ធផលដ៏មានសារៈសំខាន់អាចនឹងសំរេចបាននៅពេលដែលប្រជាពលរដ្ឋ អ្នកនយោបាយ និងមន្ត្រីការិយាធិបតេយ្យទាំងអស់ មានការលើកទឹកចិត្តក្នុងការធ្វើសកម្មភាព។ លោកអាគែម៉ាន់ (Ackerman) (ឆ្នាំ ២០០៤) បញ្ជាក់ថា "សកម្មភាពឯកត្តោភាគីរបស់រដ្ឋតែងតែបញ្ចប់ដោយមានការសម្របសម្រួល ចំណែកឯសកម្មភាពឯកត្តោភាគីរបស់សង្គមវិញជារឿយៗ តែងតែបញ្ចប់ដោយការបង្ក្រាបនិងអំពើហិង្សាដែលធ្វើឡើងដោយរដ្ឋ " ហើយ "លទ្ធផលដែលមានផ្លែផ្កាបំផុត កើតឡើងនៅពេលដែលភាគីទាំងពីរ (រដ្ឋ និង សង្គមស៊ីវិ) ចូលរួមយ៉ាងសកម្ម" ។

គាត់បានបញ្ជាក់ថា ការចូលរួមទាំងសងខាងដូចនេះមិនចាំបាច់ពឹងផ្អែកទៅលើការព្រមព្រៀង ឬសេចក្តីទុកចិត្ត និងក៏ដូចគ្នាដែរ "វិវាទ និង ការមន្ទិល" អាចនាំទៅរកសហការរួមរបស់រដ្ឋ-សង្គមស៊ីវិលដ៏មានប្រសិទ្ធភាព។ អ្វីដែលជាមេរៀននោះ គឺថា ការផ្តួចផ្តើមគណនេយ្យភាពសង្គមអាចបញ្ចូលទាំងភាគីរដ្ឋនិងសង្គមស៊ីវិល និងផ្តោតទៅលើការឈមមុខរវាងភាគីទាំងពីរ។

## ការបង្កើតស្ថាប័ន

កិច្ចការពិសេស ឬច្រកតែមួយនៃការផ្តួចផ្តើមគណនេយ្យភាពសង្គមអាចមានភាពខុសគ្នា។ បទពិសោធន៍បង្ហាញថា ផលប៉ះពាល់អាចនឹងមានភាពធំធេង និង អាចមាននិរន្តរភាពនៅពេលដែលយន្តការគណនេយ្យភាពសង្គមមានលក្ខណៈជា "ស្ថាប័នកម្ម" អាចនិយាយបានទៀតថា ការបញ្ចូលទៅក្នុងការអនុវត្តជាប្រព័ន្ធដោយស្ថាប័នសង្គមស៊ីវិលនិងរដ្ឋ។ ដូចដែលបានរៀបរាប់ពីខាងដើមថា យន្តការ "ខាងក្រៅ" នៃគណនេយ្យភាពសង្គមអាចនឹងមានប្រសិទ្ធភាពទៅបាន នៅពេលមានការបូកបញ្ចូលជាមួយយន្តការ "ខាងក្នុង" ទៅនឹងរដ្ឋ។ យោលទៅតាមលោកហ្វក (fox) (ឆ្នាំ២០០០) ថា "សង្គមស៊ីវិល

ទាមទារការទទួលខុសត្រូវរបស់រដ្ឋយ៉ាងច្រើននៅពេលដែលពួកគេឱ្យអំណាចធ្វើការត្រួតពិនិត្យ និងថ្លឹងថ្លែងដោយខ្លួនឯង ”។ ជាលទ្ធផល ហួសពីការស្វែងរកលទ្ធផលប្រតិបត្តិការជាក់លាក់ ការផ្តួចផ្តើមគណនេយ្យភាពសង្គម អាចយកចិត្តទុកដាក់ផងដែរទៅលើកត្តាស្ថាប័ន និងស្វែងរកឱកាស ដើម្បីធ្វើឱ្យមានឥទ្ធិពលយូរអង្វែងលើការអភិវឌ្ឍស្ថាប័ន និង/ឬកំណែទម្រង់។

ជារឿយៗ ការផ្តួចផ្តើមគណនេយ្យភាពសង្គមកំណត់តម្រូវការដើម្បីធ្វើឱ្យមានការប្រែប្រួលរបស់ស្ថាប័ននៅក្នុងទីភ្នាក់ងាររបស់រដ្ឋាភិបាល និងកិច្ចការសាធារណៈ (ដូចជា ការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយារបស់បុគ្គលិកជួរមុខ ការលើកទឹកចិត្ត និងការដាក់ទោសនៃអង្គការដោយឡែកណាមួយ របៀបគ្រប់គ្រងរបស់អង្គការនោះ ឬដំណើរការធ្វើសេចក្តីសំរេចចិត្តជាដើម)។ គេអាចធ្វើដំណើរទៅមុខទៀត និងដើរតួសំខាន់ផងដែរ ក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរទាំងនេះ (ដូចជា ដោយការចូលរួមជាមួយបុគ្គលិកនៃមណ្ឌលសុខភាព ដើម្បីស្វែងរកជាទៀងទាត់និងក្រសោបទាំងប្រព័ន្ធផ្តល់គំនិតបកមកវិញ ការធ្វើឱ្យគណៈកម្មការតម្លាភាពប្រជាពលរដ្ឋនៅក្នុងការសំរេចចិត្តរបស់រដ្ឋាភិបាលមូលដ្ឋាន ឬការបញ្ចូលក្រុមត្រួតពិនិត្យសង្គមដើម្បីវាយតំលៃការបំពេញភារកិច្ចរបស់កម្មវិធី ឬគោលនយោបាយជាតិនៅលើមូលដ្ឋាន ដែលមានស្រាប់)។ ការដែលអាចធ្វើទៅបាន ការធ្វើស្ថាបនកម្មផ្នែកច្បាប់នៃយន្តការចូលរួមពីកំរិតកម្មវិធីផ្ទាល់ខ្លួន និងទីភ្នាក់ងារឆ្ពោះទៅរកកំរិតប្រព័ន្ធទាំងមូលអាចនឹងត្រូវបានគេចាត់ទុកថាជាមធ្យោបាយមួយសំរាប់លើកកំពស់ភាពយូរអង្វែងនៃប្រសិទ្ធភាព និងនិរន្តរភាព។

# បំណាក់ស្រាយ ទី៦

## ឧបករណ៍លើកកំពស់គណនេយ្យភាព

### ការធ្វើថវិកាដោយមានការចូលរួម

ការធ្វើថវិកាដោយមានការចូលរួមកំពុងតែលេចចេញពីយន្តការដ៏សំខាន់មួយ ដើម្បីជួយឱ្យប្រជាពលរដ្ឋចូលរួមក្នុងការរៀបចំថវិកា។ យន្តការនេះទាក់ទងទៅនឹងការដែលសង្គមស៊ីវិលរួមចំណែកក្នុងការធ្វើថវិកាសាធារណៈ-ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលស្នើឱ្យមានគំរោងចំណាយ រៀបចំកន្សោមអាទិភាព និងសំរេចថាគំរោងណាមួយដែលទទួលបានមូលនិធិ។

### ការធ្វើផែនការដោយមានការចូលរួម

គេអាចមើលឃើញថា វិមជ្ឈការ គឺជាដំណើរការមួយដែលធ្វើការប្រែប្រួលតាមក៏រិតនៃការរំលែកមុខងារនិងហិរញ្ញវត្ថុទៅដល់អង្គភាពមូលដ្ឋាន។ ការធ្វើផែនការដោយមានការចូលរួម គឺជាផ្នែកមួយនៃដំណើរការវិមជ្ឈការ និងឆ្ពោះទៅរកការកំណត់បញ្ហាសំខាន់ៗ កំណត់អាទិភាពរួម ការលំអិត និងអនុម័តយុទ្ធសាស្រ្តអភិវឌ្ឍសង្គមសេដ្ឋកិច្ច ។

### ប័ណ្ណព័តិមានសហគមន៍

ប័ណ្ណព័តិមានសហគមន៍ គឺជាឧបករណ៍មួយសំរាប់សម្រួលដល់ការកែលំអការផ្តល់សេវាកម្ម សាធារណៈ។ ប័ណ្ណព័តិមានសហគមន៍ គឺជាការវាយតំលៃរបស់សាធារណជនប្រើប្រាស់ទៅលើ សេវាកម្មសាធារណៈតាមរយៈវិធីធ្វើអង្កេត។ កម្មវិធីប័ណ្ណព័តិមានសហគមន៍ បង្ហាញពីបទពិសោធន៍ជាក់ស្តែងរបស់ប្រជាពលរដ្ឋជាមួយ នឹងភាពទូលំទូលាយនៃសេវាកម្មសាធារណៈ។

### ប័ណ្ណពិន្ទុរបស់សហគមន៍

ដំណើរការប័ណ្ណពិន្ទុរបស់សហគមន៍ គឺជាឧបករណ៍ពិនិត្យតាមដានរបស់សហគមន៍មូលដ្ឋាន ដែលជាការលាយចូលគ្នានៃបច្ចេកទេសនានានៃសវនកម្មសង្គម ការពិនិត្យតាមដានរបស់សហគមន៍ និងប័ណ្ណព័តិមានសហគមន៍។ ក៏ដូចជាប័ណ្ណព័តិមានសហគមន៍ផងដែរ ដំណើរការប័ណ្ណពិន្ទុ គឺជាឧបករណ៍ ដើម្បីធ្វើឱ្យមានការទទួលខុសត្រូវសាធារណៈ និងសង្គមដ៏ពិតប្រាកដ និងការឆ្លើយតបពីអ្នកផ្តល់សេវាកម្ម។

## សវនកម្មសង្គម

សវនកម្មសង្គមត្រូវបានគេកំណត់ថា ជាការពិនិត្យពិច្ច័យ និងការវិភាគស៊ីជម្រៅទៅលើការងារសេវាកម្មសាធារណៈប្រៀបធៀបទៅនឹងទំនាក់ទំនងសង្គមរបស់វា។ គឺជាឧបករណ៍មួយ ដែលតាមរយៈនោះស្ថាប័ននានារបស់រដ្ឋាភិបាលអាចធ្វើផែនការគ្រប់គ្រង និងវាស់វែងសកម្មភាពទាំងឡាយណាដែលមិនទាក់ទងនឹងលុយកាក់ និងពិនិត្យតាមដាននូវផលវិបាកទាំងខាងក្នុងនិងខាងក្រៅ នៃប្រតិបត្តិការរបស់ស្ថាប័នអង្គការសង្គមស៊ីវិល និងស្ថាប័នពាណិជ្ជកម្ម។

## វិធីសាស្ត្រវាយតំលៃលើផលប៉ះពាល់សង្គម

ការវាយតំលៃលើផលប៉ះពាល់សង្គមត្រូវបានគេកំណត់ថាជាការប្រឹងប្រែងក្នុងការវាយតំលៃ ឬប៉ាន់ប្រមាណជាមុននូវផលវិបាកទាំងឡាយរបស់សង្គម ដែលអាចនឹងអនុលោមតាមសកម្មភាពជាក់លាក់នានានៃគោលនយោបាយ (ក្នុងនោះមានរួមបញ្ចូលទាំងកម្មវិធីនានា និងការអនុម័តគោលនយោបាយថ្មី) និងសកម្មភាពជាក់លាក់នានារបស់រដ្ឋាភិបាល។ នេះគឺជាដំណើរការមួយដែលផ្តល់ជាក្របខណ្ឌការងារមួយសំរាប់រៀបចំអាទិភាព ការប្រមូល ការវិភាគ និងការបញ្ចូលព័ត៌មានសង្គម និងការចូលរួមទៅក្នុងការរៀបចំ និងការផ្តល់អន្តរាគមន៍សំរាប់ការអភិវឌ្ឍ។

## វិធីសាស្ត្រអង្កេត

ក្នុងន័យនៃការផ្លាស់ប្តូរសេចក្តីប្រាថ្នារបស់ប្រជាពលរដ្ឋ វិធីសាស្ត្រអង្កេត គឺជាការរ៉ាប់រងរបស់រដ្ឋក្នុងការផ្តល់វិធី និងមធ្យោបាយនានាសំរាប់លើកកំពស់តួនាទីរបស់ប្រជាពលរដ្ឋក្នុងដំណើរការនៃការសំរេចចិត្ត និងធ្វើឱ្យការរួមការងាររវាងរដ្ឋ និងសង្គមស៊ីវិលមានភាពប្រសើរឡើង។ ការអង្កេតរបស់ប្រជាពលរដ្ឋត្រូវបានគេគិតថាជាការសំខាន់ក្នុងបរិបទនេះ។

## កតិកាប្រជាពលរដ្ឋ

កតិកាប្រជាពលរដ្ឋ គឺជាការសរសេរ សេចក្តីប្រកាសដោយស្ម័គ្រចិត្ត ដែលធ្វើឡើងដោយអ្នកផ្តល់សេវាកម្មដោយគូសបញ្ជាក់ពីបទដ្ឋាននៃការផ្តល់សេវាកម្ម ដែលគេអាចជឿទុកចិត្តបាន បញ្ជាក់ពីជំរើសសមស្របរបស់អតិថិជន បញ្ជាក់ពីផ្លូវសំរាប់ធ្វើឱ្យមានភាពត្រឹមត្រូវឡើងវិញ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។ បើដូចនេះ កតិកាប្រជាពលរដ្ឋអាចត្រូវគេយកទៅប្រើប្រាស់ជាឧបករណ៍សំរាប់ការលើកកំពស់បទដ្ឋាននៃការផ្តល់សេវាកម្ម និងធ្វើឱ្យគណនេយ្យភាពសាធារណៈមានភាពធំធាត់ឡើង។

## ការប៉ាន់ប្រមាណរបស់ប្រជាពលរដ្ឋ

ការប៉ាន់ប្រមាណរបស់ប្រជាពលរដ្ឋ គឺជាការប៉ាន់ប្រមាណមួយដែលរៀបចំឡើងដោយប្រើភាសាអ្នកស្រុក តាមរយៈដំណើរការចូលរួមមួយដោយប្រើប្រាស់បទដ្ឋានជាក់លាក់ដូចគ្នា ក៏ប៉ុន្តែពឹងផ្អែកលើអត្រាទីផ្សារ និងអង្គភាពក្នុងមូលដ្ឋាន។ ការប្រតិបត្តិការងារសាធារណៈតាមរយៈការប៉ាន់ប្រមាណរបស់ប្រជាពលរដ្ឋ តម្រូវឱ្យមានដំណើរការចូលរួម ដែលធ្វើឱ្យការងារសាធារណៈអាចរ៉ាប់រងបាននៅថ្នាក់មូលដ្ឋាន តាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការរៀបចំការប៉ាន់ប្រមាណការងារប្រតិបត្តិ និងពិនិត្យតាមដាន។

## យន្តការគណនេយ្យភាពសង្គមដទៃទៀត រួមមាន :

- ❑ ការវិភាគថវិកាឯករាជ្យ
- ❑ អង្កេតតាមដានចំណាយសាធារណៈ
- ❑ គណៈវិនិច្ឆ័យប្រជាពលរដ្ឋ
- ❑ វេទិកាប្រជាពលរដ្ឋ
- ❑ នាទីប្រជាពលរដ្ឋ
- ❑ ការស៊ើបអង្កេតរបស់សារព័ត៌មាន
- ❑ សិទ្ធិចំពោះនិចលភាពព័ត៌មាន

# បំណាកស្រោយ ទី៧

## បទពិសោធន៍ពីប្រទេសផ្សេងៗ

### គំនិតផ្តួចផ្តើមថវិការបស់នារីៈអាព្រិចខាងត្បូង

គំនិតផ្តួចផ្តើមនេះវិភាគទៅលើផែននៃចំណាយសាធារណៈ ដែលនឹងអាចមានផលប៉ះពាល់ទៅលើលក្ខខណ្ឌសេដ្ឋកិច្ច និងសង្គមរបស់ស្ត្រី។ គោលបំណងរបស់គំនិតផ្តួចផ្តើមនេះ គឺពិនិត្យតាមដានទង្វើរបស់រដ្ឋាភិបាលកណ្តាលទៅលើសមភាពយេនឌ័រ ដោយធ្វើការតាមដានលើការចំណាយ ដែលគេយកទៅចាយវាយលើវិធានការធ្វើឱ្យមានគោលនយោបាយចំណាប់អារម្មណ៍លើយេនឌ័រ និងសេវាកម្មសាធារណៈ។ គំនិតផ្តួចផ្តើមមួយរបស់អង្គការសង្គមស៊ីវិលដែលគេយកទៅធ្វើដូចគ្នានៅប្រទេសអូស្ត្រាលីសំរាប់វិភាគថវិកាដែរនោះ ត្រូវបានគេយកទៅបណ្តុះគំនិតសំរាប់កម្មវិធីដូចគ្នាដទៃទៀត នៅកាណាដា ក្រូអាស៊ី ចាម៉ៃកា ម៉ូសំប៊ិច រូស្ស៊ី តង់សានី និងអ៊ូកង់ដា។ ចំណុចដែលគេយកចិត្តទុកដាក់នោះ គឺការវិភាគលើថវិកាក្រោយពេលចំណាយ ដោយហេតុថា ការចូលទៅពិនិត្យថវិការបស់រដ្ឋាភិបាលមានការរឹតត្បិតនៅពេលដែល រដ្ឋាភិបាលមិនទាន់បានបោះផ្សាយជាសាធារណៈ។

### ការចូលរួមក្នុងការធ្វើថវិកាក្រុង : ប្រទេសប្រេស៊ីល

ការចូលរួមក្នុងការធ្វើថវិកា គឺជាដំណើរការមួយដែលតាមរយៈនោះ គេបង្កើតបានជាសភាតំបន់ និងក្រុមប្រឹក្សា ចូលរួមធ្វើថវិកាដែលចូលរួមក្នុងការលៃលកដាក់ធនធាន ហើយធ្វើការពិនិត្យតាមដានការប្រើប្រាស់ធនធាននោះ។ សមាសភាពនៃក្រុមប្រឹក្សា មានអ្នកតំណាងដែលជ្រើសរើសដោយការបោះឆ្នោតមកពីអង្គការសហជីពក្រុង សមាគមក្នុងសង្កាត់ និងរដ្ឋាភិបាលមូលដ្ឋាន។ ក្រុមប្រឹក្សានេះទទួលខុសត្រូវលើការរៀបចំបន្តការជួបប្រជុំពិគ្រោះយោបល់ ធ្វើការបង្ហាញពីអ្វីដែលជាអាទិភាពជូនទៅរដ្ឋាភិបាលក្រុង និងក្នុងកិច្ចសហការជាមួយតំណាងរដ្ឋាភិបាល ធ្វើការបង្កើតនិងពិនិត្យតាមដានថវិកាក្នុងមូលដ្ឋាន។ ចាប់ផ្តើមដំបូងនៅព័រតូអាឡឺគ្រេ ការចូលរួមក្នុងការធ្វើថវិកា ក្នុងពេលបច្ចុប្បន្ននេះ កំពុងតែធ្វើឡើងនៅក្នុងក្រុងប្រហែល ៨០។ បច្ចុប្បន្ន ដំណើរនេះកំពុងតែត្រូវគេយកទៅអនុវត្តក្នុងកំរិតរដ្ឋ ដែលគ្របដណ្តប់លើទីក្រុងប្រហែល ៥០០។

### កម្មវិធីកែលំអការបំពេញកិច្ចការស៊ីវិល : ប្រទេសកាណា

សភាស្រុកនៅប្រទេសកាណាត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៨៩ ដែលផ្តល់នូវយន្តការគន្លឹះពីរសំរាប់កែលំអការឆ្លើយតប និងការបំពេញភារកិច្ចរបស់រដ្ឋាភិបាល។ យន្តការទីមួយ គឺការលើកកំពស់ការចូលរួមរបស់

ប្រជាពលរដ្ឋក្នុងការគ្រប់គ្រងថ្នាក់មូលដ្ឋាន តាមរយៈការចូលរួមដោយផ្ទាល់ និងតាមរយៈតំណាង។ យន្តការទីពីរ គឺការប្រមើលរកការបង្កើតសេវាកម្មសាធារណៈឱ្យទៅជា "សេវាកម្មប្រកបដោយមនសិការ និងមានការឆ្លើយតប"កាន់តែច្រើន តាមរយៈកំណែទម្រង់កិច្ចការស៊ីវិល។ កំណែទម្រង់នេះពាក់ព័ន្ធនឹងទីភ្នាក់ងារទាំងឡាយរបស់រដ្ឋាភិបាលក្នុងការរៀបចំផែនការកែលំអ ការបំពេញភារកិច្ចរបស់ខ្លួនផ្ទាល់ ដែលបង្កើតបានជាមូលដ្ឋានសំរាប់ការព្រមព្រៀងបំពេញភារកិច្ចរវាងបុគ្គលិក និងការគ្រប់គ្រង។ ដំណើរការផែនការកែលំអការបំពេញភារកិច្ចប្រើប្រាស់វិធីសាស្ត្រស្វ័យវង្វាយតំលៃ និងការគ្រប់គ្រងដោយមានការចូលរួម ដែលត្រូវបានបំពេញបន្ថែមដោយការអង្កេតលើការពេញចិត្តរបស់អតិថិជន ដើម្បីលើកទឹកចិត្តបុគ្គលិកក្នុងការរិះរកវិធីដោយខ្លួនឯងដើម្បីដោះស្រាយបញ្ហាប្រឈមមុខ។

## ប័ណ្ណព័ត៌មានសហគមន៍: បំបែ ប៊ីងហ្គាឡូ កាល់កាត់តា ប្រទេសឥណ្ឌា

តាមពិធីការនៃការអង្កេតតាមបែបគុណភាព ទៅលើការពេញចិត្តរបស់អតិថិជនចំពោះសេវាកម្មសាធារណៈ ត្រូវបានធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាលនៅក្នុងទីក្រុងមួយចំនួន ដែលប្រជាពលរដ្ឋទទួលបានកំរៃចំណូលតិច។ ការអង្កេតបង្កើតជា "ប័ណ្ណព័ត៌មានសហគមន៍" ទៅលើការមើលឃើញទៅលើគុណភាព ភាពសមរម្យ នៃសេវាកម្មមួយចំនួនរបស់ក្រុង។ ប័ណ្ណព័ត៌មានសហគមន៍នេះត្រូវបានគេប្រើប្រាស់ដើម្បីដាក់គំនាបទៅលើមន្ត្រី ដែលជើសរើសដោយការបោះឆ្នោត ដោយបង្ហាញឱ្យពួកគេឃើញពីទំហំនៃការថ្នាំងថ្នាក់ចិត្តរបស់សាធារណជន ដោយសង្ឃឹមថា ជាលទ្ធផលនឹងមានការឆ្លើយតបពីសំណាក់ផ្នែកខ្លះនៃមន្ត្រីសាធារណៈដែលទទួល ខុសត្រូវក្នុងការផ្តល់សេវាកម្ម។ ការអង្កេតក៏ត្រូវបានគេយកទៅប្រើប្រាស់សំរាប់ការអប់រំតាមបណ្តាញ ផ្សព្វផ្សាយព័ត៌មានដល់ក្រុមផលប្រយោជន៍សាធារណៈដទៃទៀត និងប្រជាពលរដ្ឋ។

## មជ្ឈមណ្ឌលព័ត៌មានប្រជាពលរដ្ឋ : ប្រទេសរ៉ូម៉ានី

ជាផ្នែកមួយនៃកំណែទម្រង់សាធារណៈទូទៅក្នុងប្រទេសរ៉ូម៉ានី រដ្ឋាភិបាលបានបង្កើតមជ្ឈមណ្ឌលព័ត៌មានប្រជាពលរដ្ឋ និងផ្នែកទំនាក់ទំនងសាធារណៈជាតិមួយដែលមានក្រុមប្រឹក្សាចំនួនប្រាំបីនៅក្នុងស្រុកជាមួយនឹងគោលបំណងដើម្បីសេវាកម្មសាធារណៈជាមិត្តភាព ហើយប្រជាពលរដ្ឋដែលអាចទៅបាន និងដោយចំហរ។ លទ្ធផលទូទៅ គឺមិនបានលើកទឹកចិត្ត ដោយសារមន្ត្រីដែលត្រូវបានចាត់តាំងនោះ គឺថិតនៅក្នុងរដ្ឋាភិបាល ប្រាក់ផ្តល់ឱ្យទាបដែលនាំឱ្យមានការប្រព្រឹត្តិខុសសីលធម៌របស់បុគ្គលិក ការនិយមច្បាប់ហួសប្រមាណនៅក្នុងអាកប្បកិរិយាសេវាកម្មស៊ីវិល ហើយការផ្តល់របបខ្ពស់សំរាប់ថ្នាក់ដឹកនាំជាន់ខ្ពស់។ ទោះយ៉ាងណាក៏ដោយ មជ្ឈមណ្ឌលបានកែលំអតម្លាភាពយ៉ាងច្រើនរបស់រដ្ឋាភិបាលថ្នាក់ក្រោម និងលើកទឹកចិត្តការជាប់ទាក់ទងទៅប្រជាពលរដ្ឋឆ្លងកាត់មន្ត្រីទំនាក់ទំនង និងធ្វើបដ្ឋនាលិខិត។

## ច្បាប់ស្តីពីសិទ្ធិនៃចូលរួមរបស់ប្រជាពលរដ្ឋ : ប្រទេស បូលីវី

ច្បាប់ស្តីពីនៃសិទ្ធិចូលរួលរបស់ប្រជាពលរដ្ឋនៅឆ្នាំ ១៩៩៤ ផ្តល់អំណាចដល់ក្រុមប្រឹក្សាក្រុង ដែលបានជ្រើសរើស តាមលទ្ធិប្រជាធិបតេយ្យ ដើម្បីបង្កើតនិងអនុវត្តកម្មវិធី និងនយោបាយអភិវឌ្ឍន៍ក្នុងស្រុកជាមួយនិង ការផ្ទេរហិរញ្ញវត្ថុពីរដ្ឋាភិបាលថ្នាក់ក្រោម។ បន្ថែមលើនេះ ច្បាប់ផ្តល់សិទ្ធិអំណាចដល់អង្គភាព សង្គមស៊ីវិល ដើម្បីចូលរួមក្នុងការអភិវឌ្ឍផែនការក្រុងប្រាំឆ្នាំ។ ក្រុមទាំងនេះត្រូវបានផ្តល់យុត្តាធិការលើអាណាខេត្ត ដែនដី និងសិទ្ធិដែលបានដាក់ឱ្យ និងការងារគ្រប់ដណ្តប់លើរឿងរ៉ាវបរិស្ថាន ផលិតកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងសង្គមជាច្រើន។ ជាបន្ថែមទៀត គណៈកម្មាធិការដ៏ប្រុងប្រយ័ត្ននេះធ្វើសកម្មភាពជាអ្នកឃ្លាំមើលលើ ក្រុមប្រឹក្សាក្រុង និងធ្វើឱ្យប្រាកដថាអាទិភាពសហគមន៍ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការចំណាយថវិកាក្រុង។

## ការចូលរួមរដ្ឋាភិបាលថ្នាក់ក្រោម : ប្រទេស ពីលីពីន

ក្រមច្បាប់រដ្ឋាភិបាលថ្នាក់ក្រោមនៃឆ្នាំ ១៩៩១ បានបង្កើតនូវក្រុមប្រឹក្សាអភិវឌ្ឍន៍ថ្នាក់មូលដ្ឋានសំរាប់ខេត្ត ទីក្រុង រដ្ឋធានី និងស្រុកនិមួយៗ។ ការទទួលខុសត្រូវបឋមរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ថ្នាក់មូលដ្ឋាន គឺធ្វើពង្រាងផែនការអភិវឌ្ឍន៍ចំរុះផ្នែក រួមបញ្ចូលការធ្វើផែនការប្រើប្រាស់ដីធ្លីសំរាប់រដ្ឋាភិបាលថ្នាក់មូលដ្ឋាន។ យ៉ាងហោចណាស់មួយភាគបួននៃសមាជិកទាំងអស់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ថ្នាក់មូលដ្ឋានត្រូវតែមកពីផ្នែកឯកជន ការចាត់ចែងរបស់ប្រជាពលរដ្ឋនិងអង្គការក្រៅរដ្ឋាភិបាល។ ក្រុមប្រឹក្សាអភិវឌ្ឍន៍ថ្នាក់មូលដ្ឋានបានក្លាយជាយន្តការ សំរាប់អង្គការសង្គមស៊ីវិលកៀងគរប្រជាជននៅក្នុងស្រុក ដើម្បីទាមទារយ៉ាងហោចណាស់នូវសេវាកម្មបឋម និងធ្វើអាទិភាពគំរោងថ្នាក់មូលដ្ឋាន។ បណ្តាញអង្គការជាតិ (ត្រូវបានគេហៅថា BATMAN) បានធ្វើការពង្រឹងការអន្តរកម្មសង្គមស៊ីវិល រដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងផែនការ។

## វិទ្យុសហគមន៍ : ទីក្រុងការណាតាកា ប្រទេសឥណ្ឌា

វិទ្យុសហគមន៍ដែលផ្តួចផ្តើមគំនិតដោយប្រជាពលរដ្ឋ ក្នុងគោលបំណងអប់រំក្រុមមនុស្សភាគតិច ថាតើរចនាសម្ព័ន្ធរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ជាពិសេស គួតែធ្វើការងារដើម្បីកែប្រែច្បាប់របស់ប្រទេសឥណ្ឌាក្នុងទស្សវត្ស ៧៣ ដែលផ្តល់នូវវត្តមានស្ត្រីយ៉ាងច្រើនក្នុងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន។ ជាមួយនឹងចរិតលក្ខណៈនៃសាច់រឿងដែលពាក់ពន្ធ័ទៅនឹងប្រជាពលរដ្ឋក្នុងស្រុក បង្ហាញគោលរឿងប្រឌិតស្តីអំពីតួនាទី ការទទួលខុសត្រូវនិងមុខងាររដ្ឋាភិបាលថ្នាក់មូលដ្ឋានទៅក្នុងដំណើររឿងនៃឧបកថានិមួយៗ។ វិទ្យុអាចផ្សព្វផ្សាយដល់ប្រជាជន ៩៨ ភាគរយ ដោយរាប់បញ្ចូលទាំងអ្នកមិនចេះអាន។ ជាពិសេសស្ត្រី គឺជាគោលដៅ។

ពួកគេអាចស្តាប់ក្នុងខណៈដែលពួកគេធ្វើការងារប្រចាំថ្ងៃនៅផ្ទះ ហើយនិងទទួលបាននូវព័ត៌មានចេញពីការផ្សាយស្តីអំពីតួនាទីវេទិកាការថ្នាក់ស្រុក សិទ្ធិនារី និងការផ្តល់សេវាកម្ម។

## ការប្រមូលផ្តុំអ្នកក្រីក្រ : ប្រទេសថៃ

បណ្តាញវាយប៉ាយកសិករនេះ បានរៀបចំយុទ្ធនាការរំដើបរំជួលដ៏ធំមួយ ធ្វើបាតុកម្មអង្គុយ ដើម្បីទាមទារការឆ្លើយតបពីមន្ត្រីរដ្ឋាភិបាលអំពីផលប៉ះពាល់ដល់សហគមន៍ក្រីក្រជនបទ ដូចជាការយកកន្លែងធ្វើជាទំនប់ ការទទួលយក និងសិទ្ធិទាក់ទងទៅនឹងធនធានក្នុងមូលដ្ឋានដូចជា ដី ទឹក និងព្រៃឈើ។ យុទ្ធនាការធ្វើឡើងសំដៅដល់អ្នកធ្វើគោលនយោបាយបន្តពីថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិនៅក្នុងកំណែនដ៏ធំ ដែលមានប្រជាកសិករចំនួនម្ភៃពាន់នាក់ (២០.០០០ នាក់) ក្នុងឆ្នាំ ១៩៩៧ ចូលរួមអង្គុយចំនួនកៅសិបប្រាំបួនថ្ងៃ។ ការគ្របដណ្តប់គោលបំណងដោយបណ្តាញផ្សព្វផ្សាយព័ត៌មាន និងភាពដឹកនាំដែលជាស្ពានចម្លង ផ្នែកវប្បធម៌ ពីទីក្រុងទៅជនបទ គឺជាធាតុដ៏សំខាន់នៃទំហំបង្កើនការយល់ដឹងនៃចលនានេះ។

## ការប៉ាន់ប្រមាណភាពក្រីក្រដោយមានការចូលរួម : ប្រទេស អ៊ុយហ្គាន់ដា

ការប៉ានប្រមាណភាពក្រីក្រដោយមានការចូលរួម គឺជាប់ពាក់ពន្ធ័ទៅនឹងការប្រើប្រាស់វិធីសាស្ត្រតាមបែបចូលរួមនិងស្រាវជ្រាវផ្នែកគុណភាព សំរាប់ការពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីអំពីគោលទស្សនៈរបស់ប្រជាជនមូលដ្ឋាន និងអាទិភាពក្នុងការកាត់បន្ថយភាពក្រីក្រ។ ការប៉ាន់ប្រមាណរបស់ប្រទេសអ៊ុយហ្គាន់ដានេះ គឺជាលំហាត់ពិភាក្សាមួយដ៏ទូលាយ ដែលបង្កើតឱ្យមានព័ត៌មានលាយឡំគ្នាប្រកបដោយគុណភាពអំពីបទពិសោធន៍ ការស៊ីជម្រៅ និងទូលំទូលាយនៃភាពក្រីក្រ។ វាបានស្វែងរកការកសាងនូវប្រព័ន្ធជាតិដើម្បីធ្វើសមាហរណការត្រួតពិនិត្យភាពក្រីក្រទាំងបរិមាណនិងគុណភាព ហើយដើម្បីផ្តល់ព័ត៌មានអំពីគោលនយោបាយកាត់បន្ថយភាពក្រីក្រ។ វាត្រូវបានផ្តួចផ្តើមគំនិតដោយម្ចាស់ជំនួយទ្វេរភាគី (ដោយមានការគាំទ្រខ្លះពីធនាគាពិភពលោក) និងអង្គការក្រៅរដ្ឋាភិបាលដែលដឹកនាំដោយអង្គការ អុកស្វាម។ ការប៉ាន់ប្រមាណនេះបានផ្តោតទៅលើការបង្កើតភាពម្ចាស់ការរបស់រដ្ឋាភិបាល ដែលគេដាក់ឱ្យឋិតនៅក្រោមក្រសួងហិរញ្ញវត្ថុ ផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច។

# បំណាក់ស្រាយ ទី៩

## ករណីសិក្សា ៖ ទីក្រុងបឹងហ្គាឡូ ប្រទេសឥណ្ឌា ៖ បណ្ណព័ត៌មានសហគមន៍

*សង្គមស៊ីវិលធ្វើការបណ្តាក់តភ្ជាប់ជាមួយរដ្ឋាភិបាលដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងសំរាប់ទាំងអស់គ្នា ។*

### ប្រវត្តិដើម

នៅក្នុងទីក្រុងបឹងហ្គាឡូ មានរបាយការណ៍បីត្រូវបានគេរៀបចំឡើងឆ្លងកាត់គំនិតផ្តួចផ្តើមរបស់សង្គមស៊ីវិល ក្នុង ឆ្នាំ១៩៩៤ ឆ្នាំ១៩៩៩ និងឆ្នាំ២០០៣ ។ បណ្ណព័ត៌មានសហគមន៍ដំបូង វាយតំលៃទាបបំផុតដល់អ្នកផ្តល់សេវាកម្មធំៗនៃទីក្រុង ដែលបង្កើតនូវភាពអាម៉ាស់ ។ ទោះយ៉ាងណា បញ្ហានេះមិនធ្វើឱ្យមានផលប៉ះពាល់ភ្លាមទេ មានតែអ្នកផ្តល់សេវាកម្មមួយចំនួនតូចទទួលស្គាល់នូវបញ្ហារបស់ពួកគេ ហើយធ្វើការកែតម្រូវ ។ បណ្ណព័ត៌មានសហគមន៍ទីពីរបង្ហាញថា ការកែលំអមួយចំនួនត្រូវបានធ្វើឡើង ប្រហែលដោយសារសកម្មភាពរបស់អ្នកផ្តល់សេវាកម្ម និងសម្ពាធពីសង្គមស៊ីវិល ។ បណ្ណព័ត៌មានសហគមន៍ទីបីបញ្ចេញឱ្យដឹងនូវការកែលំអស្ទើរទូទ្រង់ស្មើរតែទាំងអស់ចំពោះអ្នកផ្តល់សេវា ។ វាមិនគ្រាន់តែមានការកើនឡើងគ្រាប់ជ្រុងជ្រោយនៅក្នុងការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះសេវាកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្លាក់ចុះនូវអំពើពុករលួយទៀតផង ។ សំណួរដ៏ធំនោះ គឺថា តើមូលហេតុអ្វីដែលធ្វើឱ្យមានការភ្ញាក់ផ្អើលជុំវិញបញ្ហានេះ?

បឹងហ្គាឡូ គឺជាទីក្រុងដែលលូតលាស់ផ្នែកឧស្សាហកម្ម មានប្រជាជនរស់នៅជាងបួនលាននាក់នៅក្នុងឆ្នាំ១៩៩៣ ហើយភ្លាមៗនោះបានក្លាយទៅជាមជ្ឈមណ្ឌលព័ត៌មានវិទ្យារបស់ប្រទេសឥណ្ឌា ។ មួយភាគបួននៃប្រជាជននៅក្នុងទីក្រុងនេះ គឺជាអ្នកក្រីក្រ ដែលរស់នៅពាសពេញទីក្រុង ។ អ្នករស់នៅទីក្រុងបឹងហ្គាឡូពឹងផ្អែកលើភ្នាក់ងាររដ្ឋមួយចំនួន ដែលបង្កើតដោយរដ្ឋាភិបាលតាមខេត្ត សំរាប់សេវាកម្មសំខាន់របស់ពួកគេ ដូចជាសាជីវកម្មរដ្ឋធានីដែលផ្តល់ផ្លូវថ្នល់ ភ្លើងតាមដងវិថី ប្រដាប់ដឹកសំរាម ។ នៅពេលដែល ភ្លើងអគីសនីផ្គត់ផ្គង់ដោយទីភ្នាក់ងារដ៏ធំមួយ ទឹក ការដឹកជញ្ជូន ទូរគមនាគមន៍ ការថែទាំសុខភាព ដីក្នុងទីក្រុង និងការធ្វើជំរក គឺជាការទទួលខុសត្រូវរបស់អ្នកផ្តល់សេវាកម្មសាធារណៈធំៗផ្សេងទៀត ។ លក្ខណៈរួមនៃសេវាកម្មទាំងអស់នេះ គឺថាវាជាប្រភពផ្គត់ផ្គង់ដែលយកប្រៀបលើ ឬផ្តាច់មុខតែឯង ។ ប្រជាជនមានជំរើសតិចតួចសំរាប់អ្នកផ្គត់ផ្គង់ផ្សេងទៀត ។ នេះមានបញ្ហាបន្ថែមទៀតដល់អ្នកក្រីក្រ ដូចជាគេមិនបានលៃលកនូវជំរើសផ្សេងទៀតក្នុងការចំណាយខ្ពស់ដែលប្រជាជនអ្នកមានអាចប្រើបាន ក្នុងហេតុការណ៍អ្នកផ្គត់ផ្គង់សេវាកម្មសាធារណៈមិនអាចធ្វើបាន ។ ដូច្នេះ នៅពេលភ្លើងអគ្គីសនីមិនអាចផ្គត់ផ្គង់បានអ្នកមានគេអាចបញ្ឆេះមាស៊ីនភ្លើងរបស់ពួកគេ ។ ពួកគេអាចប្រើប្រាស់រថយន្តផ្ទាល់ខ្លួន នៅពេលសេវាកម្មដឹកជញ្ជូនរបស់រដ្ឋមិនដំណើរការ ។ ជំរើសទាំងនេះ គឺកំរនឹងមានសំរាប់អ្នកក្រីក្រណាស់ ។ អ្នកក្រីក្រទទួលរង

នូវពិការភាពមួយផ្សេង ដែលគេហៅថា កង្វះខាតអនុភាព និងសំលេងដើម្បីដោះបញ្ហារបស់ពួកគេ នៅកំរិតទីភ្នាក់ងារ។ សកម្មភាពរួមប្រជាពលរដ្ឋដើម្បីឱ្យគេដោះស្រាយបញ្ហានេះ គឺវាពិបាកផងដែរ ក្នុងការរៀបចំ និងចំណាយពេលវេលានិងធនធានច្រើន។

## ដំណើរការ

ក្នុងឆ្នាំ ១៩៩៣ ក្រុមប្រជាពលរដ្ឋមួយចំនួនតូចក្នុងទីក្រុងបឹងហ្គាឡូបានធ្វើយុទ្ធនាការស្ទង់មតិមួយ ដើម្បីប្រមូលព័ត៌មានត្រឡប់ស្តីអំពីសេវាកម្មសាធារណៈក្នុងទីក្រុង។ ការងារស្ទង់មតិជាក់ស្តែងត្រូវបានអនុវត្តដោយក្រុមហ៊ុនស្រាវជ្រាវទីផ្សារមួយ សហការីជំនួញ ហើយថ្លៃចំណាយត្រូវបានផ្តល់ដោយជំនួយក្នុងស្រុក។ ការស្ទង់មតិត្រូវបានដំណើរការក្នុងការពិភាក្សាជាក្រុម បន្ទាប់ពីក្រុមប៉ាន់ប្រមាណលើបញ្ហាដែលប្រជាជនបានជួបប្រទះ។ បញ្ជីរសំណួរពោញលេញត្រូវបានបង្កើតឡើង និងបានធ្វើការសាកល្បងមុនដើម្បីធ្វើឱ្យប្រាកដថា ការពាក់ពន្ធ័និងភាពសមរម្យរបស់ពួកគេសំរាប់ការធ្វើសំភាសន៍។ ការសំភាសន៍គ្របដណ្តប់ប្រហែលមួយពាន់ពីរយគ្រួសារដែលជាអ្នកមានចំណូលទាបនិងមធ្យម ដោយសួរសំណួរផ្សេងៗគ្នា។ គោលបំណងនៃការសំភាសន៍ គឺរកឱ្យឃើញថា : ១). តើសេវាកម្មសាធារណៈត្រូវបំពេញបំណងរបស់អ្នកប្រើប្រាស់ដូចម្តេច? ២). តើចំណុចណានៃសេវាកម្មដែលធ្វើឱ្យពេញចិត្ត? ៣). តើថ្លៃចំណាយផ្ទាល់ និងប្រយោលកើតឡើងចំពោះអ្នកប្រើប្រាស់សេវាកម្មនេះដូចម្តេច? ការបំពេញចិត្តត្រូវបានវាស់វែងដាក់ពិន្ទុពី ១ ទៅ ៧ ហើយសរុបលទ្ធផលគិតជាមធ្យមសំរាប់ទំហំផ្សេងៗគ្នា។ អ្នកធ្វើអង្កេតដែលបានបង្ហាត់បង្រៀនត្រូវធ្វើការសំភាសន៍នៅនឹងទីកន្លែង។ លទ្ធផលដែលបានមកពីការវិភាគទិន្ន័យ ត្រូវបានយកទៅប្រើសំរាប់ដាក់ពិន្ទុទៅដល់អ្នកផ្តល់សេវាកម្មផ្សេងៗ ដែលទាក់ទងទៅនឹងអំពើពុករលួយ គុណភាពនៃសេវាកម្ម និងការពេញចិត្តរបស់អ្នកប្រើប្រាស់។ លទ្ធផលសង្ខេបនៃការដាក់ពិន្ទុពីកំរិតគុណភាពទៅតាមទីភ្នាក់ងារនីមួយៗ ត្រូវបានគេហៅថា "បណ្ណ័របាយការណ៍ប្រជាពលរដ្ឋ ស្តីអំពីសេវាកម្មសាធារណៈ"។ ការស្ទាបស្ទង់មតិគ្របដណ្តប់តែផ្ទះសំបែងដែលប្រើប្រាស់ផ្ទាល់នូវសេវាកម្ម និងមានអន្តរអំពើជាមួយទីភ្នាក់ងារតែប៉ុណ្ណោះ ដើម្បីធ្វើឱ្យប្រាកដថាចម្លើយមានអត្ថន័យ។ កំរិតតំណាងនៃសំណាកដែលយកសំរាប់សំភាសន៍ វិជ្ជាជីវនិយម អព្យាក្រឹតភាព ក្នុងការស្ទាបស្ទង់ និងចំនួនអ្នកឆ្លើយតបដ៏ច្រើនដើម្បីឱ្យប្រាកដថា លទ្ធផលរកឃើញគួរឱ្យជឿជាក់។

| ដំណាក់កាលនៃការធ្វើផែនការ និងរៀបចំបណ្ណ័ព័ត៌មានសហគមន៍ |
|---|
| ១. **ការធ្វើផែនការបណ្ណ័ព័ត៌មានសហគមន៍:** តើអ្នកចង់ដឹងអំពីអ្វី? អំពីអ្នកណា? តើអ្នកនឹងប្រើប្រាស់ ព័ត៌មានដូចម្តេច? តើត្រូវប្រមូលទិន្នន័យដូចម្តេច? តើអ្នកធ្វើផែនការប្រមូលទិន្ន័យដូចម្តេច? តើអ្នកនឹងផ្តល់មូលនិធិគំរោងដូចម្តេច? |

២. **ការជ្រើសរើសវិធី :** តើជ្រើសរើសវិធីស្រាវជ្រាវជាគុណភាព ឬជាបរិមាណ?

៣. **ការយកសំណាក :** ជំហានសំខាន់ៗ គឺកំណត់ចំនួនប្រជាជន ជំរឿនសំណាក ប្លង់សំណាក ទំហំសំណាក សំណាកតាមលំដាប់ ឬសំណាកថេរ ថ្លៃចំណាយនៃការយកសំណាក ប្រតិបត្តិការនៃដំណើរការយកសំណាក។

៤. **ការគ្រោងបញ្ជីសំណួរ :** កំណត់ និងរៀបគោលបំណងព័ត៌មានទៅតាមលំដាប់លំដោយ ពីចំណុចសំខាន់មកចំណុចបន្ទាប់បន្សំ ដាក់លេខរៀងនៃប្រភេទព័ត៌មានដែលត្រូវការពីអ្នកឆ្លើយតប ដែលទាក់ទងទៅនឹងគោលបំណងព័ត៌មាននិមួយៗ រៀបចំទៅតាមជំពូកនៃក្រុមនិមួយៗទៅតាមលំដាប់សារៈសំខាន់របស់វាចំពោះការសិក្សាស្រាវជ្រាវ សំរាប់ជំពូកមួយៗនៅក្នុងចម្លើយជាក្រុម គឺមាន : ហេតុអ្វី អ្នកណា និងអ្វី ដាក់នូវចំណុចសំខាន់ៗ ដាក់ជំពូកសំខាន់ៗត្រង់ចំណុចចាប់ផ្តើមនៃបញ្ជីរសំណួរ ដោយប្រើប្រាស់ទាំងសំណួរបើក ឬសំណួរបិទ។

៥. **ការសាកល្បង ការដាក់កូដ និងការវិភាគ :** ធ្វើការសាកល្បងជាមុននូវបញ្ជីរសំណួរ ក្នុងករិតនៃការសាកល្បងក្នុងការស្ទង់មតិសំរាប់ការត្រួតពិនិត្យគុណភាព បញ្ជីសំណួរជាបរិមាណមានច្រើន អាចដាក់លេខកូដជាមុន ហើយអាចបំពេញដោយអ្នកធ្វើការនៅពេលសំភាសន៍។ ត្រូវប្រើប្រាស់គោលការណ៍ណែនាំដ៏តឹងរឹង ដើម្បីប្រមូលទិន្នន័យ ដែលត្រូវតែប្រាប់ឱ្យបានច្បាស់ទៅដល់បុគ្គលិកធ្វើការពេលសំភាសន៍តាមរយៈក្បួនច្បាប់ និងការបណ្តុះបណ្តាលជាក្រុម។ គេអាចវិភាគទិន្នន័យដោយប្រើប្រាស់បច្ចេកទេសផ្សេងៗ ដូចជា មធ្យមភាគ លំដាប់ទិន្នន័យ ភាពញឹកញាប់ និងចំណុចកណ្តាល។ ទិន្នន័យដែលបានប្រមូល នឹងត្រូវគេបង្ហាញជាស៊េរីតារាង។ ការបកស្រាយនៃការវិភាគគួរតែនាំមកនូវលទ្ធផលរកឃើញទាំងអស់ពីគោលទស្សនៈចំរុះ ហើយជួយអតិថិជនឱ្យយល់នូវរឿងរ៉ាវ និងបញ្ហាដែលបានកំណត់។

៦. **ការផ្សព្វផ្សាយលទ្ធផលរកឃើញ :** ត្រូវប្រាស្រ័យទាក់ទងលទ្ធផលស្រាវជ្រាវតាមរយៈ ១). របាយការណ៍ស្រាវជ្រាវគួសបញ្ជាក់ គោលបំណង វិធីសាស្រ្ត លទ្ធផលរកឃើញសំខាន់ៗ និងការគូសបញ្ជាក់ពីលទ្ធផលរកឃើញ ២). ការចេញផ្សាយព័ត៌មាន និង ៣). ការប្រជុំទល់មុខរវាងប្រជាពលរដ្ឋ អ្នកផ្តល់សេវាកម្ម និងមន្រ្តីរដ្ឋាភិបាល។

៧. **ការបង្កើតស្ថាប័ន : ពីទ្រឹស្តីទៅសកម្មភាព :** គំរូរួមបីគឺ : ១). អង្គការសង្គមស៊ីវិលឯករាជ្យទទួលយកគំនិតផ្តួចផ្តើម (ប្រទេសឥណ្ឌា) ២). អ្នកផ្តល់សេវាកម្មស្វែងរកចម្លើយតបពីអតិថិជនដោយផ្ទាល់ (ប្រទេសអង់គ្លេស) ៣). ទីភ្នាក់ងារត្រួតពិនិត្យបានធ្វើការផ្តើមគំនិត (សហរដ្ឋអាមេរិច)។

## លទ្ធផល

### បណ្ណ័ព័តិមានសហគមន៍ទីមួយ ឆ្នាំ (១៩៩៤)

បណ្ណ័ព័តិមានសហគមន៍ទី១ នៅបឹងហ្គាឡូ បញ្ចេញឱ្យឃើញគំរូគួរឱ្យចាប់អារម្មណ៍មួយចំនួននូវសេវាកម្មសាធារណៈរបស់ទីក្រុង។ វាបានបង្ហាញថាកំរិតនៃការបំពេញចិត្តរបស់អ្នកឆ្លើយតបដែលមានចំណូលមធ្យម គឺមិនលើស ២៥ ភាគរយ ចំពោះអ្នកផ្តល់សេវាកម្មទាំងប្រាំពីរដែលបានគ្របដណ្តប់ដោយការស្ទង់មតិ។ ម្យ៉ាងទៀត កំរិតនៃទោមនស្សកើនឡើងច្រើននិងខ្ពស់ជាង គឺខណៈដែលអាជ្ញាធរអភិវឌ្ឍន៍មានអត្រាដល់ ៦៥ ភាគរយ។ ការបំពេញចិត្តរបស់សាធារណៈជន ចំពោះឥរិយាបទបុគ្គលិកនៃទីភ្នាក់ងារទាំងនោះ គឺមានតែ ២៥ ភាគរយប៉ុណ្ណោះ ហើយជាងមួយភាគបួននៃប្រជាជនបានទៅដល់ទីភ្នាក់ងារពីរបី ឬច្រើនដង ដើម្បីដោះស្រាយបញ្ហារបស់ពួកគេ។ ដំណោះស្រាយបញ្ហា គឺ ៥៧ ភាគរយ នៅពេលទីភ្នាក់ទាំងអស់ត្រូវបានគេបូកបញ្ចូលគ្នា។ ជាមធ្យម ១៤ ភាគរយនៃអ្នកឆ្លើយតបបានផ្តល់សំណូក។

### បណ្ណ័ព័តិមានសហគមន៍ទីពីរ ឆ្នាំ (១៩៩៩)

បណ្ណ័ព័តិមានសហគមន៍ទីពីរបានផ្តល់នូវភស្តុតាងថ្មីស្តីអំពីសេវាកម្មរបស់រដ្ឋក្នុងទីក្រុងបឹងហ្គាឡូបន្ទាប់ពីរយៈពេលប្រាំឆ្នាំកន្លងផុត។ វិធីសាស្ត្រស្ទង់មតិត្រូវបានប្រើ ជាពិសេស ដូចជានៅក្នុងឆ្នាំ ១៩៩៣ ប៉ុន្តែសំណាកកើនឡើងដល់ ២.០០០ គ្រួសារ។ លទ្ធផលបានបង្ហាញការអភិវឌ្ឍមួយផ្នែកក្នុងការបំពេញចិត្តសាធារណៈជន របស់ទីភ្នាក់ងារភាគច្រើន ប៉ុន្តែកំរិតនៃការបំពេញចិត្តនៅតែនៅក្រោម ៥០ ភាគរយ ទោះបីមានអ្នកប្រព្រឹត្តល្អជាងមុនក៏ដោយ។ ការរកឃើញនៃការរំខាន គឺកំរិតនៃអំពើពុករលួយនៅក្នុងទីភ្នាក់ងារមួយចំនួនបានកើនឡើង។ អ្នកឆ្លើយតបដែលមានប្រាក់ចំណូលទាបបានបន្តទៅទីភ្នាក់ងារ ដើម្បីដោះស្រាយបញ្ហាញឹកញាប់ជាងដៃគូរបស់គេដែលមានប្រាក់ចំណូលមធ្យម។ របាយការណ៍បានគូសបញ្ជាក់នូវទំនាក់ទំនងច្បាស់លាស់រវាងអំពើពុករលួយជាសាច់ប្រាក់ និងការផ្តល់សេវាកម្មគ្មានប្រសិទ្ធិភាព។ លទ្ធផលរកឃើញអំពីអំពើពុករលួយបានបង្ហាញការពិបាកដើម្បីកំចាត់ចោលដំណើរការដែលធ្វើតាមទំនើងចិត្ត គ្មានតម្លាភាព និងគ្មានឆន្ទៈ។

ការតាមដានសកម្មភាពនៅក្នុងឆ្នាំ ១៩៩៩ ខុសគ្នាយ៉ាងខ្លាំងពីបញ្ហាទាំងនោះក្នុងឆ្នាំ ១៩៩៤។ មុនពេលផ្សព្វផ្សាយលទ្ធផលជាសាធារណៈ បណ្ណ័ព័តិមានសហគមន៍ខ្នាតមធ្យម ត្រូវបានបង្ហាញដល់អ្នកផ្តល់សេវាកម្មធំៗ នៅក្នុងទីក្រុងម្តងមួយៗ។ ការណ៍នេះ ត្រូវបានធ្វើឡើងនៅក្នុងសន្និបាទសំរាប់ថ្នាក់ដឹកនាំដែលជ្រើសរើស មកពីទីភ្នាក់ងារផ្សេងៗ ដើម្បីផ្លាស់ប្តូរបទពិសោធន៍របស់ពួកគេជាមួយការកែទម្រង់តាំងពីបណ្ណ័ព័តិមានសហគមន៍លើកតំបូង។ គោលបំណងនៃការហ្វឹកហ្វឺននេះ គឺជាការរៀនសូត្រពីគ្នាទៅវិញទៅមក។ ការពិភាក្សានេះ បានបង្ហាញថាទីភ្នាក់ងារទាំងឡាយដែលគេត្រូវការជំនួយរបស់ខ្លួន

ឱ្យពាក់ពន្ធ័ទៅនឹង ការកែលំអសេវាកម្មរបស់ពួកគេនៅក្នុងសេវាកម្មផ្សេងៗ។ ព្រឹត្តិការចុងក្រោយ គឺជាការប្រជុំជាសាធារណៈ ជាមួយក្រុមប្រជាពលរដ្ឋ និងព័តិមានដែលជាលទ្ធផល បណ្ណ័ព័តិមានសហគមន៏ ត្រូវបានបង្ហាញដល់ថ្នាក់ដឹកនាំ និង បុគ្គលិកនៃអ្នកផ្តល់សេវាកម្មទាំងអស់។ ថ្នាក់ដឹកនាំនៃទីភ្នាក់ងារ បានថ្លែងទៅកាន់ទីប្រជុំ ហើយពន្យល់អំពីផែនការសាធារណៈរបស់ពួកគេ ដើម្បីដោះស្រាយបញ្ហា ដែលកត់សំគាល់នៅក្នុងប័ណ្ណព័តិមានសហគមន៏។ ព្រឹត្តិការ និងលទ្ធផលបណ្ណ័ព័តិមានសហគមន៏នេះ គឺគ្របដណ្តប់ យ៉ាងទូលំទូលាយនៅក្នុងសារព័តិមាន។

ថ្វីបើបណ្ណ័ព័តិមានសហគមន៏នៃឆ្នាំ ១៩៩៩ បានបង្ហាញតែការកែលំអមួយផ្នែកនៅក្នុងសេវាកម្មទីក្រុង គឺ វាច្បាស់ណាស់ថាអ្នកផ្តល់សេវាកម្មមួយចំនួនមានគំនិតផ្តួចផ្តើមធ្វើសកម្មភាព ដើម្បីកែលំអគុណភាព សេវាកម្ម និងឆ្លើយតបទៅនឹងបញ្ហាជាក់លាក់ដែលលើកឡើងនៅក្នុងប័ណ្ណព័តិមានសហគមន៏។ ឧទាហរណ៏មួយ គឺជាការកែលំអនៅក្នុងនិតិវិធីគិតលុយរបស់ទីភ្នាក់ងារមួយចំនួន។ ម៉្យាងទៀត គឺការកើនឡើងនៃការប្រើ
ប្រាស់វេទិការរួមគ្នាជាមួយនឹងអ្នកប្រើប្រាស់ដើម្បីកែលំអការទទួលខុសត្រូវរបស់បុគ្គលិក។

ក្នុងរយៈពេលពីរ ឬបីខែនៃការចេញបណ្ណ័ព័តិមានសហគមន៏លើកទីពីរ ប្រមុខរដ្ឋថ្មីនៃ **ការណាតាកា** របស់ទីក្រុងបឹងហ្គាឡូដែលជារដ្ឋធានីរបស់ប្រទេសឥណ្ឌា បានប្រកាសនូវការបង្កើតចលនា របៀបវារៈ ការងារ បឹងហ្គាឡូ (BATF) ដើម្បីកែលំអសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធរបស់ទីក្រុង ដោយមានការ ចូលរួមជាសាធារណៈ។ លោកបានបង្កើត (BATF) ដែលជាដៃគូរវាងឯកជន និងរដ្ឋដោយមានការចូលរួម ពីប្រជាពលរដ្ឋ ថ្នាក់ខ្ពស់ក្រៅផ្លូវការជាច្រើនជាសមាជិក រួមជាមួយនឹងប្រធានអ្នកផ្តល់សេវាកម្មផងដែរ។ ផ្ទុយទៅនឹង ការឆ្លើយតបរបស់ទីភ្នាក់ងារ គំរោងដែលរៀបចំដោយប្រមុខរដ្ឋនេះ បានលើកឡើងនូវកំរិត នៃការឆ្លើយតប ជាប្រព័ន្ធតាមរយៈទីភ្នាក់ងារនានា។ លោកបានបង្កើតវេទិកាមួយ ក្នុងគោលបំណងនាំ អ្នកពាក់ព័ន្ធទាំងអស់ មកចូលរួមដោះស្រាយបញ្ហាទាំងឡាយដែលកើតមាននៅក្នុងទីក្រុង និងដើម្បី ទាក់ទាញគំនិតយោបល់ និង មូលនិធិពីវិស័យឯកជន។ នេះជាលើកទីមួយហើយ ដែលប្រមុខរដ្ឋ បានរៀបចំ គំនិតផ្តួចផ្តើម ដើម្បីកែលំអសេវាកម្ម ជាការឆ្លើយតបទៅនឹងយោបល់ត្រឡប់ របស់ប្រជាពលរដ្ឋ។

## បណ្ណ័ព័តិមានសហគមន៏ទីពី (២០០៣)

ដោយធ្វើការប្រៀបធៀបលទ្ធផលរកឃើញទាំងនេះជាមួយ បណ្ណ័ព័តិមានសហគមន៏មុនៗ បានបង្ហាញថា មានការ កែលំអសេវាកម្មសាធារណៈនៅក្នុងទីក្រុង។ ភាពពេញចិត្តរបស់បុគ្គលជាមួយនឹងភ្នាក់ងារ បានបង្ហាញអត្រា នៃសេវាកម្មរបស់ខ្លួនខ្ពស់ជាងភាពពេញចិត្តដោយអន្លើ។ ភាពពេញចិត្តអាចត្រូវបាន វាស់វែងដោយរបៀប ផ្សេងៗគ្នាទៅតាមគុណភាពរបស់សេវាកម្ម ឬទីភ្នាក់ងារ។ វិធានការបួនយ៉ាង

ដែលជាការឆ្លើយតបរបស់ ទីភ្នាក់ងារត្រូវបានអនុវត្ត គឺទំហំនៃបញ្ហា អាកប្បកិរិយារបស់បុគ្គលិក ការចំណាយពេលវេលាចូលរួម ជាមួយបញ្ហា និងការផ្តល់សំណូក ឬការទាមទារសំណូក។ វិធានការទាំងនេះ ឆ្លុះបញ្ចាំងទិដ្ឋភាពខុសៗគ្នា នៃគុណភាពតាមរយៈអ្នកប្រើប្រាស់សេវាកម្ម។ ការកើនឡើងផ្នែកខ្លះ របស់អ្នកប្រើប្រាស់ដែលពេញចិត្ត ចំពោះសេវាកម្ម ឬទីភ្នាក់ងារ គឺជាកត្តាចង្អុលបង្ហាញដោយប្រយោល ចំពោះការកែលំអសេវាកម្ម ឬទីភ្នាក់ងារនោះ។

ភាពពេញចិត្តរបស់អ្នកប្រើប្រាស់ក្នុងចំណោមអ្នករស់នៅក្នុងផ្ទះទូទៅ មានកំរិតចាប់ពី ៩៦ ភាគរយ សំរាប់ សាជីវកម្មដឹកជញ្ជូនទីក្រុងបឹងហ្គាឡូ និង ៧៣ ភាគរយ សំរាប់គណៈក្រុមប្រឹក្សាផ្គត់ផ្គង់ទឹកនិងប្រព័ន្ធលូ បង្ហូរទឹកស្អុយបឹងហ្គាឡូ និងមន្ទីរពេទ្យរដ្ឋ។ ទោះជាយ៉ាងនេះក៏ដោយ ទីភ្នាក់ងារទាំងអស់បានវាស់វែង ក្នុងរបៀបខុសៗគ្នា ទាក់ទងនឹងផ្នែកផ្សេងៗរបស់ប្រជាពលរដ្ឋដែលបានផ្តល់អត្រា "ពេញចិត្តបំផុត"។ ជាមួយគ្នានេះដែរ សាជីវកម្មដឹកជញ្ជូនរដ្ឋធានីបឹងហ្គាឡូ បានទទួលការពេញចិត្តច្រើនបំផុតក្នុងចំណោម អ្នកប្រើប្រាស់ ហើយក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីបឹងហ្គាឡូ ដែលមានចំនួនអ្នកប្រើប្រាស់ច្រើនជាងគេបំផុតនោះ បានទទួលនូវការពេញចិត្តច្រើនផងដែរ។ ការពិតគឺថា ទីភ្នាក់ងារមួយចំនួនដែលទទួលបានចំណែកអ្នក ប្រើប្រាស់ដែលសំដែងភាពពេញចិត្តខ្លះៗ បានបង្ហាញថាត្រូវមានការកែលំអច្រើនជាងនេះទៀត បន្ថែម លើអ្វីដែលទទួលបានរហូតមកដល់ពេលនេះ។ វាជាសញ្ញាបង្ហាញពីការកែលំអសេវាកម្មដែលកំពុងប្រើប្រាស់ ដោយប្រជាពលរដ្ឋមួយចំនួនធំ ប៉ុន្តែបទដ្ឋានគុណភាពដែលសំរេចបាននៅពេលនោះ មិនទាន់ឈានទៅរក ភាពល្អឥតខ្ចោះនៅឡើយទេ។

ការប្រៀបធៀបពីការបំពេញមុខងាររបស់ទីភ្នាក់ងារទាំងអស់កាលពីជាង១០ឆ្នាំកន្លងទៅ បានបង្ហាញឱ្យ ឃើញថា ភាពពេញចិត្តរបស់អ្នកប្រើប្រាស់សេវាកម្មមានការកើនឡើង។ ក្នុងចំណោមទីភ្នាក់ងារទាំង៩ ដែលប្រជាពលរដ្ឋនៅក្នុងទីក្រុងបឹងហ្គាឡូបានផ្តល់យោបល់ឱ្យនោះ បានទទួលអត្រានៃភាពពេញចិត្តលើសពី ៧០ ភាគរយ នៅពេលនេះផ្ទុយទៅនឹងឆ្នាំ ១៩៩៩ ដែលទទួលបានតិចជាង ៤០ ភាគរយ ហើយក្នុងឆ្នាំ ១៩៩៤ ទទួលបានអត្រាទាបបំផុត។ ការកែលំអនេះជាករណីដ៏ពិសេសបំផុតរបស់អាជ្ញាធរអភិវឌ្ឍន៍ទីក្រុង បឹងហ្គាឡូ ដែលធ្វើឱ្យភាពពេញចិត្តរបស់ប្រជាពលរដ្ឋបានកើនឡើងយ៉ាងខ្លាំងពី ១៦ ភាគរយ ទៅ ៨៥ ភាគរយ។ ចំពោះករណីរបស់គណៈក្រុមប្រឹក្សាផ្គត់ផ្គង់ទឹក និងប្រពន្ធ័លូបង្ហូរទឹកស្អុយបឹងហ្គាឡូ និងសាជីវ កម្មរដ្ឋធានីបឹងហ្គាឡូ ការកើនឡើងនៃភាពពេញចិត្តរបស់ប្រជាពលរដ្ឋមានការចាប់អារម្មណ៍តិចតួច ប៉ុណ្ណោះ។ ការថែរក្សាភាពពេញចិត្តកំរិតខ្ពស់ដែលសំរេចបានដោយទីភ្នាក់ងារនានាដូចជា សាជីវកម្មដឹក ជញ្ជូននៃរដ្ឋធានីបឹងហ្គាឡូ ក្រុមហ៊ុនអគីសនីបឹងហ្គាឡូ គឺជាបញ្ហាប្រឈមមុខមួយ។




ការកែលំអនេះជាករណីដ៏ពិសេសបំផុតរបស់អាជ្ញាធរអភិវឌ្ឍន៍ទីក្រុងបឹងហ្គាឡូ ដែលធ្វើឱ្យភាពពេញចិត្តរបស់ប្រជាពលរដ្ឋកើនឡើងពី ១៦ ភាគរយ ទៅ ៨៥ ភាគរយ។ ចំពោះករណីរបស់គណៈក្រុមប្រឹក្សាផ្គត់ផ្គង់ទឹក និងប្រពន្ធ័លូបង្ហូរទឹកស្អុយបឹងហ្គាឡូ និងសាជីវកម្មរដ្ឋធានីបឹងហ្គាឡូ ការកើនឡើងនៃភាពពេញចិត្តរបស់ប្រជាពលរដ្ឋមានការចាប់អារម្មណ៍តិចតួចប៉ុណ្ណោះ។ ការថែរក្សាភាពពេញចិត្តក៏រិតខ្ពស់ដែលសំរេចបានដោយទីភ្នាក់ងារនានាដូចជា សាជីវកម្មដឹកជញ្ជូននៃរដ្ឋធានីបឹងហ្គាឡូ ក្រុមហ៊ុនអគីសនីបឹងហ្គាឡូ គឺជាបញ្ហាប្រឈមមុខមួយ។ ជំហានសំខាន់បន្ទាប់ទៀត គឺត្រូវបង្កើនចំនួនអ្នកប្រើប្រាស់ដែលបង្ហាញភាពពេញចិត្តទាំងស្រុង (សូមមើលតារាងខាងលើ)។




ទន្ទឹមនឹងនេះ ប្រជាពលរដ្ឋក្រីក្រ (អ្នករស់នៅក្នុងផ្ទះរយីករយាក) ក៏បានបង្ហាញពីការកើនឡើងនូវភាពពេញចិត្តរបស់ពួកគេចំពោះសេវាកម្មទាំងនោះដែរ។ អត្រារបស់ពួកគេនៅមានក៏រិតទាបជាងនៅឡើយ ដោយទីភ្នាក់ងារចំនួន ៤ ក្នុងចំណោមទីភ្នាក់ងារទាំង ៦ ទទួលបានអត្រាពេញចិត្តលើសពី ៧០ភាគរយ។

ប្រជាពលរដ្ឋក្រីក្រមិនអាចប្រើប្រាស់សេវាកម្មទាំងមូលបានទេ ដែលប្រការនេះហាក់បីដូចជាផ្ទុយទៅនឹងសមាជិកដទៃដែលរស់នៅក្នុងផ្ទះទូទៅ (ប្រាក់ចំណូលចំនួនពាក់កណ្តាល)។ ចំណុចនេះមិនមែនបង្ហាញថាគ្មានការកែលំអសេវាកម្មនៅក្នុងតំបន់ដែលប្រជាពលរដ្ឋក្រីក្ររស់នៅនោះទេ។ យោបល់ដែលទទួលបានពីប្រជាពលរដ្ឋក្នុងតំបន់ក្រីក្រ បានបង្ហាញគុណភាពសេវាកម្មទាក់ទងទៅនឹងលទ្ធភាពប្រើប្រាស់ទឹកក្នុងបង្គន់សាធារណៈ ហើយការបោសសំអាតសំរាមឱ្យបានទៀងទាត់ ត្រូវបានកែលំអគួរឱ្យកត់សំគាល់ផងដែរ។ ចំពោះបញ្ហាផ្សេងៗដែលតែងតែកើតមានត្រូវបានកាត់បន្ថយផងដែរ បើប្រៀបធៀបទៅនឹងរបាយការណ៍ដែលទទួលបានពីប្រជាពលរដ្ឋរស់នៅក្នុងផ្ទះទូទៅ (សូមមើលតារាងខាងលើ)។

ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ក្រីក្របានជួបប្រទះបញ្ហាជាច្រើន ក្នុងអំឡុងពេលធ្វើទំនាក់ទំនងជាមួយទីភ្នាក់ងារ ជារឿយៗនៅពេលដោះស្រាយបញ្ហានានាជាមួយប៉ូលីសនៅក្នុងទីក្រុងបឹងហ្គាឡូ។ នេះក៏ជាករណីមួយដែលបានកើតឡើងក្នុងឆ្នាំ ១៩៩៩ ផងដែរ។ ការកាត់បន្ថយបញ្ហាបានច្រើនបំផុតទាក់ទងនឹងសេវាកម្មនោះ គឺសេវាកម្មដឹកជញ្ជូន។ ចំពោះគណៈក្រុមប្រឹក្សា ផ្គត់ផ្គង់ទឹក និងប្រពន្ធ័លូបង្ហូរទឹកស្អុយបឹងហ្គាឡូ អាចកាត់បន្ថយបញ្ហាបានតិចតួចប៉ុណ្ណោះ ពីព្រោះមានបញ្ហាគ្រឹះស្ថានមួយចំនួនធ្វើឱ្យប៉ះពាល់ដល់សកម្មភាពផ្តល់សេវាកម្មនៅក្នុងតំបន់ប្រជាពលរដ្ឋក្រីក្ររស់នៅ។

## កត្តាជំរុញឱ្យមានការផ្លាស់ប្តូរ

កត្តាដែលជំរុញឱ្យមានការផ្លាស់ប្តូរនៅក្នុងទីក្រុងបឹងហ្គាឡូ អាចចែកចេញជាពីរប្រភេទ : ប្រភេទទីមួយគឺកើតចេញពីកត្តាតម្រូវការ និងប្រភេទមួយទៀតកើតចេញពីកត្តាផ្គត់ផ្គង់។ តម្រូវការទាមទារឱ្យមានសេវាកម្មល្អប្រសើរ មានទំនោរទៅរកការប្រតិបត្តិពីផ្នែកខាងក្រៅនៃប្រព័ន្ធរដ្ឋាភិបាល។ តម្រូវការរបស់ប្រជាពលរដ្ឋ និងសម្ពាធបណ្តាញផ្សព្វផ្សាយព័ត៌មាន គឺជាឧទាហរណ៍ខ្លះៗ។ ការពិត កត្តាតម្រូវការទាំងអស់គឺជាសារៈធាតុបន្ថែមខាងក្រៅ។ ពួកវាគ្មានតួនាទីផ្ទាល់នៅក្នុងការរៀបចំ ឬផ្តល់សេវាកម្មនោះឡើយ។ សម្ពាធពីខាងក្រៅទាំងអស់នេះអាចមាននិរន្តរភាព ប៉ុន្តែសំរាប់តែសង្គមប្រជាធិបតេយ្យ ដែលមានការអត់ឱនចំពោះការខ្វែងគំនិតគ្នា ឬការមិនយល់ស្របគ្នានៅក្នុងការពិភាក្សាអ្វីមួយតែប៉ុណ្ណោះ។

## ការធ្វើអន្តរាគមន៍ផ្នែកតម្រូវការ

***១. ផលប៉ះពាល់នៃបណ្ណព័ត៌មានសហគមន៍*** បានដាក់សម្ពាធលើអ្នកផ្តល់សេវាកម្មក្នុងទីក្រុងចំនួនបី ប្រភេទ : ទី១) ការបំពេញមុខងារគឺស្ថិតនៅក្រោម "ការត្រួតពិនិត្យពីសាធារណៈ" ទី២) ការប្រៀបធៀបអន្តរទីភ្នាក់ងារដែលធ្វើការដូចជាអ្នកជំនួសឱ្យការប្រកួតប្រជែង និង ទី៣) ជាប្រធានរបស់ទីភ្នាក់ងារមួយចំនួនដែលចាត់ទុករបាយការណ៍នោះជាជំនួយ និងជាសារធាតុបន្ថែមនៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ

ដើម្បីកែប្រែទីភ្នាក់ងាររបស់ពួកគេឱ្យមានការទទួលខុសត្រូវ និងមានតម្លាភាពបន្ថែមទៀត និងដើម្បីផ្តល់សេវាកម្មឱ្យបានទៅតាមការសន្យារបស់ពួកគេ។

***២. សម្ពាធពីក្រុមសង្គមស៊ីវិល :*** ការតស៊ូមតិត្រូវបានធ្វើឡើងតាមរយៈបណ្តាញការងាររបស់សង្គមស៊ីវិល (ក្រុមអ្នកជិតខាងប្រជាពលរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាលនានាពាក់ព័ន្ធនឹងសេវាកម្ម) នៅក្នុងទីក្រុងបឹងហ្គាឡូ ដែលបានចូលរួមក្នុង ទី១ គឺ កិច្ចប្រជុំនិងសិក្ខាសាលាសាធារណៈដែលបានលើកយកបញ្ហាទាក់ទងនឹងប្រជាពលរដ្ឋ និង បណ្ណ័ព័ត៌មានសហគមន៍យកមកពិភាក្សា ទី២ គឺបញ្ហាពាក់ព័ន្ធនឹងអ្នកផ្តល់សេវាកម្មត្រូវបានជជែកវែកញែកយ៉ាងលំអិត និងទី៣ ការធ្វើយុទ្ធនាការទូទាំងទីក្រុង។

***៣. ការដាក់សម្ពាធបន្ថែមតាមរយៈប្រព័ន្ធផ្សព្វផ្សាយ :*** បណ្តាញផ្សព្វផ្សាយព័ត៌មាន គឺជាឧបករណ៍ដែលជំរុញឱ្យមានការផ្លាស់ប្តូរតាមរយៈ ១). បោះពុម្ពផ្សាយលទ្ធផលរកឃើញទាំងឡាយដែលអវិជ្ជមាន និងការកែលំអរបស់អ្នកផ្តល់សេវាកម្ម ២). ទុកចន្លោះបន្ថែមទៀត សំរាប់រាយការណ៍បញ្ហាដែលកើតមានក្នុងសង្កាត់ផ្សេងៗទៀតរបស់ទីក្រុង កំណត់យកបញ្ហាសំខាន់ៗ និងផ្តោតជាសំខាន់ទៅលើបញ្ហាទាំងឡាយដែលបានជ្រើសរើស និង ៣). រៀបចំកិច្ចប្រជុំអន្តរកម្មជាមួយប្រជាពលរដ្ឋ និងមន្ត្រីជាន់ខ្ពស់មកពីក្រុមភ្នាក់ងារសាធារណៈដែលបានជ្រើសរើស។

***៤. តួនាទីក្នុងការពិភាក្សារបស់ម្ចាស់ជំនួយ :*** ទីភ្នាក់ងារផ្តល់ជំនួយបានបញ្ជាក់នៅក្នុងការពិភាក្សារបស់ខ្លួនជាមួយរដ្ឋាភិបាល ពីរបៀបដែលពួកគេផ្តល់ការគាំទ្រចំពោះសារៈសំខាន់នៃយោបល់ត្រឡប់របស់អ្នកប្រើប្រាស់ និងការគាំទ្រចំពោះតម្រូវការដោយចាត់ទុកការដាក់សម្ពាធពីសង្គមស៊ីវិល គឺជាជំនួយដែលនាំទៅរកការទទួលខុសត្រូវ។

## ការធ្វើអន្តរាគមន៍ផ្នែកផ្គត់ផ្គង់

ការផ្គត់ផ្គង់សេវាកម្ម គឺជាកិច្ចការរបស់រដ្ឋាភិបាល។ កត្តាដែលជំរុញឱ្យកើតមានការឆ្លើយតបផ្នែកផ្គត់ផ្គង់ក៏ទាក់ទងជាមួយរដ្ឋាភិបាល និងការគ្រប់គ្រងរបស់ខ្លួនដែរ។ រដ្ឋាភិបាលអាចចាត់វិធានការដោយខ្លួនឯង ឬពួកគេអាចធ្វើសកម្មភាពផ្សេងៗដើម្បីឆ្លើយតបទៅនឹងកត្តាដែលនាំឱ្យមានការផ្លាស់ប្តូរខាងផ្នែកតម្រូវការ។ ការទាក់ទងគ្នារវាងកត្តាផ្គត់ផ្គង់ និងកត្តាតម្រូវការដែលនាំឱ្យកើតមានលទ្ធផលជាវិជ្ជមាន គឺជាលក្ខណៈពិសេសរបស់ទសវត្សន៍មុននៅក្នុងទីក្រុងបឹងហ្គាឡូ។ ជាលទ្ធផល ឥទ្ធិពលខាងផ្នែកតម្រូវការបានបង្ហាញមុននៅក្នុងទីក្រុងទាំងមូល។ ហើយការឆ្លើយតបខាងផ្នែកផ្គត់ផ្គង់បានកើតឡើងតាមក្រោយ។

### ***១. ចលនាររបៀបវារៈការងារបឹងហ្គាឡូ : គំនិតផ្តួចផ្តើមរបស់រដ្ឋ***

ចលនាររបៀបវារៈការងារបឹងហ្គាឡូ បានចាប់ផ្តើមការងាររបស់ខ្លួនដោយយកចិត្តទុកដាក់នៅឆ្នាំ ២០០០ ហើយបានធ្វើកំណែទំម្រង់ជាច្រើននៅក្នុងចំណោមទីភ្នាក់ងារទាំងឡាយ។ កំណែទម្រង់សំខាន់ៗ គឺការយកពន្ធលើទ្រព្យសម្បត្តិ ដែលនាំឱ្យមានកំណើនប្រាក់ចំណូល និងកាត់បន្ថយផលវិបាកនានារបស់ប្រជាពលរដ្ឋ

ហើយការប្រកួតប្រជែងលើទីផ្សារ រហូតមកដល់ពេលនេះមានផលប៉ះពាល់តែមួយគត់ គឺអ្នកផ្ដល់សេវាកម្មពោលគឺប្រព័ន្ធទូរគមនាគមន៍បឹងហ្គាឡូ។ ទូរស័ព្ទចល័តចាប់ផ្ដើមវាយលុកចូលទីផ្សារ នៅក្នុងទសវត្សទី៩០ រួមជាមួយការគ្រប់គ្រងកាកសំណល់ អនាម័យ និងផ្លូវថ្នល់ផងដែរ។ ចលនារបៀបវារៈការងារបឹងហ្គាឡូក៏បានរៀបចំកែប្រែបណ្ណ័ព័តិមានសហគមន៍ ឱ្យមានលក្ខណៈសាមញ្ញជាង ដើម្បីត្រួតពិនិត្យ ភាពជឿនលឿនរបស់ទីភ្នាក់ងារនានានៅក្នុងទីក្រុង។ អស់រយៈពេលជាងបីឆ្នាំ បណ្ណ័ព័តិមានសហគមន៍របស់ខ្លួន (ផ្អែកលើយោបល់ ត្រឡប់ពីសាធារណៈជនតាមរយៈការសំភាសន៍) បានបង្ហាញការឆ្លើយតបជាវិជ្ជមានពីប្រជាពលរដ្ឋ ចំពោះកំណែទម្រង់ទាំងអស់នោះ ហើយក៏មានការកែលំអការងារ របស់ទីភ្នាក់ងារសាធារណៈ និងសេវាកម្ម របស់ពួកគេភាគច្រើនផងដែរ។

***២. ការប្រមូលធនធានតាមរយៈទីភ្នាក់ងារ :*** ការអភិវឌ្ឍស្របគ្នាចាប់តាំងពី ចលនារបៀបវារៈការងារបឹងហ្គាឡូត្រូវបានបង្កើតនោះ គឺការកើនឡើងនៃធនធានដែលយើងមើលឃើញចំពោះទីភ្នាក់ងារផ្ដល់សេវាកម្មចំនួន៧។ គំរោងថ្មីៗ និងការពង្រីកហេដ្ឋារចនាសម្ព័ន្ធ គឺពិតជាត្រូវការធនធានបន្ថែមទៀត។ មានការបង្ហាញយ៉ាងច្បាស់ថា អ្នកដឹកនាំរបស់ទីភ្នាក់ងារផ្សេងៗ បានប្រមូលធនធានបន្ថែមទៀតតាមរយៈប្រភពនានា។ ដូចជាករណីរបស់សាជីវកម្មរដ្ឋធានីបឹងហ្គាឡូ កម្មវិធីកសាងផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធត្រូវបានផ្ដត់ផ្គង់ហិរញ្ញវត្ថុតាមរយៈប្រាក់កម្ចី ដែលបានមកពី សាជីវកម្មអភិវឌ្ឍន៍ទីក្រុងនិងផ្ទះសម្បែង។ ប្រាក់កម្ចីស្រដៀងគ្នានេះដែរអាចខ្ចីបានដោយ BMTC, BWSSB ចំណែក BESCOM បានខ្ចីពីប្រភពផ្សេងៗទៀត។ BDA ជាករណីពិសេស ដែលតម្រូវការមូលនិធិភាគច្រើនសំរាប់ផ្គត់ផ្គង់គំរោងហេដ្ឋារចនាសម្ព័ន្ធថ្មីៗត្រូវបានរៃអង្គាសពីផ្នែកខាងក្នុងរបស់ខ្លួន។ គំរោងថវិកាទាំងនេះបានកើនឡើងពី ៥០ភាគរយ ទៅ ១០០ភាគរយ សំរាប់រយៈពេលបីឆ្នាំចាប់ពីឆ្នាំ ២០០០។ កាបង្កើនសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធតាមរយៈការបង្កើនប្រាក់កម្ចី អាចនឹងត្រូវបានព្យាយាមសំរាប់ឆ្នាំបន្តបន្ទាប់ទៀត។ ប៉ុន្តែត្រូវមានការគាំទ្រជាមុនពីរដ្ឋាភិបាល និងផ្នែក BATF ដើម្បីជួយជំរុញឱ្យដំណើរការនេះឆាប់កើតឡើង។

***៣. តួនាទីរបស់ Lok Ayukta (មន្ត្រីរដ្ឋាភិបាល) :*** មន្ត្រីរដ្ឋាភិបាល (Lok Ayukta) នៅក្នុងរដ្ឋការណាតាកា បានដើរតួជាប្រយោលក្នុងការជំរុញឱ្យមានការទទួលខុសត្រូវនៅក្នុងចំណោមទីភ្នាក់ងារទាំងអស់។ ពួកគេមិនត្រឹមតែមានអំណាចធ្វើការស៊ើបអង្កេតបណ្ដឹងសារទុក្ខពីភ្នាក់ងារសាធារណៈប៉ុណ្ណោះទេ ថែមទាំងជាអ្នកផ្ដួចផ្ដើមក្នុងការស៊ើបអង្កេតសកម្មភាពប្រតិបត្តិ របស់ទីភ្នាក់ងារទាំងនោះដោយផ្ទាល់ទៀតផង។ នៅក្នុងទីក្រុងបឹងហ្គាឡូ មន្ត្រីរដ្ឋាភិបាលពិតជាសកម្មណាស់ចាប់តាំងពីមានការតែងតាំងក្នុងឆ្នាំ២០០០មក។ ការឆ្មក់ចូលក្នុងការិយាល័យ និងការចាត់វិធានការជាបន្តបន្ទាប់ ដើម្បីដាក់ទណ្ឌកម្មទៅលើមន្ត្រីសាធារណៈទាំងអស់ដែលប្រព្រឹត្តអំពើពុករលួយ បាននាំឱ្យមានភាពជាសត្រូវចំពោះទីភ្នាក់ងារ និងនាយកដ្ឋាននានារបស់រដ្ឋាភិបាល។ ភាពសុចរិត និងភាពក្លាហានរបស់ពួកគេត្រូវបានកោតសរសើរ

យ៉ាងខ្លាំងពីសង្គមស៊ីវិល បណ្តាញផ្សព្វផ្សាយព័ត៌មាន និងអ្នកដឹកនាំនយោបាយ។ លើសពីនេះទៀត ពួកអ្នកសង្កេតការទាំងអស់ជឿជាក់ថា ទង្វើរបស់មន្ត្រីរដ្ឋាភិបាលនេះធ្វើឱ្យមានផលប៉ះពាល់គួរឱ្យខ្លាច សូម្បីតែទីភ្នាក់ងារមួយចំនួនដែលមិនត្រូវបានស៊ើបអង្កេតក៏ដោយ។ ការគាំទ្រខ្លាំងពីប្រមុខរដ្ឋ គឺជាកត្តាដ៏សំខាន់ជំរុញឱ្យមន្ត្រីរដ្ឋាភិបាលទាំងនោះធ្វើសកម្មភាពដោយគ្មានញញើត។ តាមរយៈ BATF ប្រមុខរដ្ឋបានជំរុញឱ្យភ្នាក់ងារសាធារណៈទាំងអស់បំពេញមុខងារឱ្យបានល្អ។ តាមរយៈមន្ត្រីរដ្ឋាភិបាល លោកបានបង្កើតឱ្យមានអារម្មណ៍ភ័យខ្លាចក្នុងចំណោមទីភ្នាក់ងារទាំងនោះថា អំពើពុករលួយ និងភាពខ្ជិលច្រអូស មិនត្រូវបានអត់ឱនជាដាច់ខាត។ វិធីសាស្ត្រទាំងពីរនេះបានជួយពង្រឹងគ្នាទៅវិញទៅមក។

***៤. ការគាំទ្រ និងការប្តេជ្ញាចិត្តផ្នែកនយោបាយ*** **:** ការគំរាមកំហែងជារួមតាមរយៈការធ្វើអន្តរាគមន៍ផ្នែកផ្តត់ផ្គង់ផ្សេងៗដែលបានពិភាក្សាខាងលើ គឺជាការគាំទ្រ និងការប្តេជ្ញាចិត្តផ្នែកនយោបាយរបស់ប្រមុខរដ្ឋ។ វាជាកត្តាខ្សោយមួយក្នុងចន្លោះពីឆ្នាំ ១៩៩៤-១៩៩៩។ ការផ្លាស់ប្តូរអ្នកដឹកនាំក្នុងឆ្នាំ១៩៩៩ បានធ្វើឱ្យមានភាពខុសគ្នាក្នុងការសំរេចចិត្ត។ ប្រមុខរដ្ឋថ្មី គឺជាអ្នកដឹកនាំម្នាក់ដែលមានការប្តេជ្ញាចិត្តក្នុងការកែលំអសេវាកម្មសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធ។ នេះគឺជាមូលហេតុដែលនាំឱ្យគាត់មានគំនិតផ្តួចផ្តើមបង្កើតដៃគូដែលមានគំនិតថ្មីរបស់ BATF។ បន្ទាប់មក លោកបានអនុញ្ញាតិឱ្យទីភ្នាក់ងារសាធារណៈទាំងអស់ប្រមូលធនធាន និងសម្របសម្រួលឱ្យមានកិច្ចប្រឹងប្រែងបន្ថែមទៀត។ លោកបានតែងតាំងមន្ត្រីរដ្ឋាភិបាលដែលមានកេរ្តិ៍ឈ្មោះចំពោះសុចរិតភាព និងមានឆន្ទៈក្នុងការដោះស្រាយបញ្ហាពុករលួយ និងការរំលោភអំណាចនៅក្នុងរដ្ឋាភិបាល។ សកម្មភាពដ៏ច្រើនសន្ធឹកសន្ធាប់នេះមិនអាចសំរេចជោគជ័យបានឡើយ បើសិនគ្មានការប្តេជ្ញាចិត្តខាងនយោបាយក្នុងកំរិតខ្ពស់បំផុតនោះទេ។ ភាពក្លាហានរបស់ប្រមុខរដ្ឋមិនមែនទទួលបានតែក្នុងចំណាត់ការតូចៗប៉ុណ្ណោះទេ ប៉ុន្តែក្នុងចំណោមចំណាត់ការខ្លាំងៗភាគច្រើនផងដែរ។ ការប្តេជ្ញាចិត្តផ្នែកនយោបាយអាចប្រែប្រួលទៅតាមការផ្លាស់ប្តូរអ្នកដឹកនាំ និងរដ្ឋាភិបាលដែលលើកយកបញ្ហានានាទាក់ទងនឹងនិរន្តរភាពនៃការធ្វើកំណែទម្រង់។

## បញ្ហាពាក់ពន្ធ័សំខាន់ៗ

ការកែលំអសេវាកម្មដែលបានរាយការណ៍ខាងលើមិនសំរេចបានទាំងអស់នោះទេ។ ចាប់ផ្តើមជាមួយនឹងប័ណ្ណព័ត៌មានសហគមន៍ក្នុងឆ្នាំ ១៩៩៤ ការបកស្រាយបំភ្លឺសេវាកម្មសាធារណៈបានបង្កើតជាចលនាសកម្មភាព ជាបន្តបន្ទាប់ពីអ្នកពាក់ព័ន្ធផ្សេងៗដែលសកម្មភាពទាំងនេះមានគោលដៅតែមួយ ហើយស៊ីគ្នាទៅនឹងការធ្វើ ឱ្យកើតចេញជាលទ្ធផលទាំងនេះ។ ទីភ្នាក់ងារខ្លះបានអនុវត្តជំហាន ដែលអាចធ្វើអោយប្រសើរឡើងនូវសេវាកម្មរបស់គេ ដែលជំហាននេះជាភស្តុតាងពីប័ណ្ណព័ត៌មានសហគមន៍ឆ្នាំ ១៩៩៩ ។ របៀបដែលកត្តាទាំងនេះ និងកត្តាផ្សេងទៀតបានជាប់ពាក់ព័ន្ធ ហើយវាចូលរួមដើម្បីសំរេចបាននូវការផ្លាស់ប្តូរក្នុងទីក្រុងបឹងហ្គាឡូ គឺមិនមានលក្ខណៈងាយស្រួលក្នុងការវាស់វែង និងធ្វើការពន្យល់ឡើយ

វាថែមទាំងគ្មានលទ្ធផល ដើម្បីសន្មតថាជាលទ្ធផលនៃការចូលរួមជាក់លាក់លើសកម្មភាពនីមួយៗនៃសកម្មភាពទាំងនេះ ដើម្បីឱ្យមាន ការផ្លាស់ប្តូរនោះទេ។ មិនចាំបាច់បន្ថែមនូវការឃ្លាំមើលនិងជំហាននៃកត្តាដែលមិនតម្រូវឱ្យមានការសម្រុះ សម្រួលផ្សេងៗ។ ប្រហែលជាមិនងាយស្រួលក្នុងការបង្កើតឡើងវិញនូវក្រុមអ្នកជំរុញឱ្យមានការផ្លាស់ប្តូរ ដែលធ្វើការក្នុងបរិបទមួយ ឬ ក្នុងបរិបទផ្សេងៗទៀត ។ ទោះយ៉ាងណាក៏ដោយ ការចូលរួមចំណែកដោយមានការជួយអន្តរាគមន៍ផ្សេងៗគ្នា នៅក្នុងទីក្រុងបឹងហ្គាឡូ អាចចេញបាននូវចំណុចរៀនសូត្រខ្លះៗ ដើម្បីផ្តល់ដល់អ្នកធ្វើការកំណែទម្រង់ក្នុងការសម្រុះសម្រួលផ្សេងៗទៀត ការពិភាក្សាកន្លងមកនោះ រំលេចនូវការចូលរួមចំណែកដោយមានការអន្តរាគមន៍ផ្សេងៗ ដែលពង្រឹងឱ្យមានការចូលរួមចំណែកបន្ថែមទៀត នៅជុំវិញទីក្រុងបឹងហ្គាឡូ។

ការចូលរួមរបស់អ្នកពាក់ព័ន្ធ គឺនាំឱ្យឥទ្ធិពលដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុង ប័ណ្ណព័ត៌មានសហគមន៍ប្រចាំឆ្នាំ ២០០៣។ ដូចដែលបានកត់ត្រាខាងលើ ឥទ្ធិពលជាក់លាក់នៃកត្តានីមួយៗ គឺមានការលំបាកដើម្បីកំណត់បរិមាណ។ ជាឧទាហរណ៍ : ប្រធានទីភ្នាក់ងារមួយអាចយកប្រាក់កម្ចីសំរាប់ ធ្វើឱ្យប្រសើរឡើងនូវសេវាកម្ម របស់គេ។ ប៉ុន្តែភាពពិតបង្ហាញថា បើគ្មានការគាំទ្រឬការជំរុញពីកត្តាទាំងឡាយដែលបានរៀបរាប់ខាងលើទេនោះ ប្រធានទីភ្នាក់ងារនោះនឹងមិនអាចអនុវត្តសកម្មភាព ដែលតម្រូវការចាំបាច់បានទេ។ ឆន្ទៈខាងនយោបាយរបស់គណៈរដ្ឋមន្ត្រីនឹងធ្វើការងារក្នុងស្ថានភាពជួយសម្រួល។ ជំនួយដែលផ្តល់ឱ្យក្រុមកងកម្លាំង សណ្តាប់ធ្នាប់នៅទីក្រុងបឹងហ្គាឡូ បាននាំមកនូវគំនិតល្អប្រសើរ និងប្រជាពលរដ្ឋជាច្រើនពេញចិត្តនឹង ទីភ្នាក់ងារ (ឧទាហរណ៍ដូចជា : ធ្វើឱ្យប្រសើរឡើងនៅក្នុងការគ្រប់គ្រងកាកសំណល់រឹង ប្រព័ន្ធយកពន្ធបែបសាមញ្ញ ការពង្រឹងនូវនីតិវិធីស្របច្បាប់ ។ល។ ប័ណ្ណព័ត៌មានសហគមន៍ និងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ និងមានកត្តាជំរុញពីខាងក្រៅដែលអាចបង្កើនល្បឿននៃការផ្លាស់ប្តូរបាន។ ការធ្វើឱ្យមានការកែលំអលើ សេវាកម្មសំរាប់ទីភ្នាក់ងារដោយទទួលបានភាពជឿជាក់មិនអាចកើតឡើងបានទេ ប្រសិនបើមិនមានឥទ្ធិពល ចូលរួមពីថាមពលជំរុញឱ្យមានការផ្លាស់ប្តូរ។

គួរមានលក្ខខ័ណ្ឌសាកល្បងខ្លះ ដើម្បីធានាលើភាពអាចទទួលយកបានរបស់ប័ណ្ណព័ត៌មានសហគមន៍។ ភាពគួរឱ្យ ជឿជាក់បាននៃរបាយការណ៍នេះ គឺមានសារៈសំខាន់បំផុតសំរាប់អ្នកដែលប្រើជាឧបករណ៍ និងភ្ជាប់ទំនាក់ទំនងនៅក្នុងការគាំទ្រការតស៊ូមតិ។ ការអនុវត្តកម្មវិធីនេះ គួរតែមិនលំអៀង និងមានឯករាជ្យភាព។ ការរៀបចំលើការវាស់វែង និងការបកស្រាយលទ្ធផលរកឃើញ គួរត្រូវបានធ្វើ ប្រកបដោយបូរណៈភាព ពេញទំហឹង។ ជាទូទៅសមត្ថភាព និងការរៀបចំគ្រប់គ្រងមានលក្ខណៈវិជ្ជាជីវៈ ដើម្បីឱ្យ

ដំណើរការវាស់វែង ឱ្យប្រព្រឹត្តិទៅបាន គឺត្រូវការអនុវត្តសកម្មភាពដូចអន្តរការី (អ្នកនៅកណ្តាល) ។ លក្ខខ័ណ្ឌទាំងនេះអនុវត្ត ដោយមិនបាច់គិតគូថាតើគំនិតផ្តួចផ្តើមនេះ ចេញពីរដ្ឋាភិបាល ឬសង្គមស៊ីវិល ។

ប័ណ្ណព័ត៌មានសហគមន៍មានទំនោរចង់ឱ្យសង្គមស៊ីវិលប្រើប្រាស់ នៅក្នុងសង្គមដែលមានលក្ខណៈប្រជាធិបតេយ្យ បើកចំហដែលគិតលើការពិភាក្សាវែកញែកជាមួយគ្នា ។ នេះមិនមែននិយាយថាប្រព័ន្ធគ្មានប្រជាធិបតេយ្យ មិនអាចបានផលប្រយោជន៍ពីឧបករណ៍នេះបានទេ ប៉ុន្តែវាអាចប្រើបាន ហើយអាចកើតឡើង បានលុះត្រាតែមានចំណាប់អារម្មណ៍ខ្លាំងពីមេដឹកនាំនយោបាយសុខចិត្តស្តាប់ព័ត៌មានត្រឡប់ពីសាធារណៈជន ហើយប្រើប្រាស់លទ្ធផលរកឃើញ ដើម្បីពង្រឹងសេវាកម្មសាធារណៈ ឬក៏លើគ្រប់ទិដ្ឋភាពផ្សេងៗនៃអភិបាលកិច្ច ។

ព័ត៌មានត្រឡប់ចេញពីការស្ទាប់ស្ទង់ជាគំរូនៃគ្រួសារដែលមានប្រាក់ចំណូលទាបស្រដៀងគ្នា ៧០ ភាគរយនៃពួកគេត្រូវទៅកាន់ទីភ្នាក់ងារនានាបីដង ឬច្រើនដង ដើម្បីដោះស្រាយបញ្ហារបស់ពួកគេ ។ សឹងតែ៣នាក់នៃប្រជាជន ដែលមានប្រាក់ចំណូលទាបត្រូវតែធ្វើការសូកប៉ាន់គេ ។ អត្រានៃដំណោះស្រាយរបស់គ្រួសារដែលមានចំណូលទាបមានកំរិតទាបជាងគ្រួសារដែលមានប្រាក់ចំណូលមធ្យម គ្រួសារដែលមានប្រាក់ចំណូលទាប ការពេញចិត្តលើអ្នកផ្តល់សេវាកម្មមិនមានកំរិតដូចគ្រួសារមានប្រាក់ចំណូលមធ្យមដែលពួកគេមានការរំពឹងទុកទាបលើសេវាកម្ម ។ លទ្ធផលរកឃើញរបស់ប័ណ្ណព័ត៌មានសហគមន៍ ត្រូវបានផ្សព្វផ្សាយជាសាធារណៈយ៉ាងទូលំទូលាយនៅតាមសារព័ត៌មានក្នុងទីក្រុងបឹងហ្គាឡូ ។ រដ្ឋាភិបាល និងអ្នកផ្តល់សេវាកម្មត្រូវបានជំរាបជូននូវប័ណ្ណព័ត៌មានសហគមន៍ទាំងមូល ជាបន្តបន្ទាប់ ។ ក្រុមប្រជាពលរដ្ឋត្រូវបានអញ្ជើញឱ្យពិភាក្សាគ្នាអំពីលទ្ធផលរកឃើញ និងវិធីសាស្ត្រស្នើសុំព្រមទាំងមធ្យោបាយ ដើម្បីដោះស្រាយបញ្ហាដែលត្រូវបានគូសបញ្ជាក់ នៅក្នុងកម្មវិធីប័ណ្ណព័ត៌មានសហគមន៍ ។ ព័ត៌មានតាមកាសែត បានដើរតួយ៉ាងសំខាន់ក្នុងការបង្កើតឱ្យមានការយល់ដឹង អំពីលទ្ធផលរកឃើញនៃកម្មវិធីប័ណ្ណព័ត៌មានសហគមន៍ ។ កាសែតដែលនាំមុខគេឈ្មោះថា Time of India បានផ្សព្វផ្សាយលទ្ធផលរកឃើញអំពីភ្នាក់ងារនីមួយៗរាល់សប្តាហ៍ រូបភាពតាមបែបផ្សព្វផ្សាយនេះបានបន្ត អស់រយៈពេលពីរ ឬ បីខែ ។

ក្រោយពីការបោះពុម្ពផ្សព្វផ្សាយរបាយការណ៍នេះ ក្រុមប្រជាពលរដ្ឋដែលបានចាប់ផ្តើមគំនិតផ្តើមមិនបានអនុវត្តសកម្មភាពតាមដាននោះទេ ប៉ុន្តែតម្រូវឱ្យថ្នាក់ដឹកនាំនៃប្រជាពលរដ្ឋអនុវត្តសកម្មភាពមួយចំនួនអំពីរបៀបដែលការងារនេះត្រូវធ្វើស្របជាមួយនឹងការគាំទ្រការតស៊ូមតិ ដើម្បីកំណែទម្រង់ដែលមានការថ្លឹងថ្លែងរួច ។ ភាពលូតលាស់លើការចាប់អារម្មណ៍ពីសាធារណៈនៅក្នុងសេចក្តីប្រឹងប្រែងនេះ បានជំរុញឱ្យថ្នាក់ដឹកនាំនៃក្រុមប្រជាពលរដ្ឋ បានបង្កើតអង្គភាពដែលធ្វើការមិនយកកំរៃថ្មីមួយដែលហៅថា "មជ្ឈមណ្ឌល

កិច្ចការសាធារណៈ" (PAC) នៅក្នុងទីក្រុងបឹងហ្គាឡូនៅឆ្នាំ ១៩៩៤ ដើម្បីពង្រឹងនិងពង្រីកការងារនេះនៅក្នុងប្រទេស។ សកម្មភាពមួយក្នុងចំណោមសកម្មភាពថ្មីៗជាច្រើនរបស់វា គឺត្រូវឆ្លើយតបនឹងសំណើរដែលជាការផ្តល់យោបល់ពីអ្នកផ្តល់សេវាកម្មចំនួន ៣ ប្រចាំទីក្រុង ដែលរឿងរ៉ាវពួកគេត្រូវបានលើកឡើងក្នុងប័ណ្ណព័ត៌មានសហគមន៍។ អ្នកផ្តល់សេវាកម្មមួយក្នុងចំណោមអ្នកផ្តល់សេវាកម្ម ៣ ក្រុម គឺជាទីភ្នាក់ងារដែល ត្រូវបានវាយតំលៃថា មានការផ្តល់សេវាកម្មអន់ជាងគេ ភ្នាក់ងារនេះតម្រូវឱ្យមានការជួយជ្រោមជ្រែងពីមជ្ឈមណ្ឌលកិច្ចការសាធារណៈក្នុងការប៉ាន់ប្រមាណបន្ថែមទៀតលើបញ្ហាទាំងឡាយ និងរកឱ្យឃើញនូវ ដំណោះស្រាយ។ ទោះបីជាប័ណ្ណព័ត៌មានសហគមន៍នេះ មិនបានពញ្ញាក់អ្នកផ្តល់សេវាកម្មទាំងអស់ឱ្យអនុវត្តជំហានសកម្មភាពភ្លាមៗ ដើម្បីបានកែលំអសេវាកម្មរបស់គេក៏ដោយ ក៏មានចំណុចដែលគួរឱ្យជឿជាក់បានដែរថា មានទីភ្នាក់ងារបីក្នុងចំណោមទីភ្នាក់ងារចំនួន ៨ បានផ្តួចផ្តើមគំនិតនិងសុំឱ្យមានការជួយជ្រោមជ្រែងពី មជ្ឈមណ្ឌលកិច្ចការសាធារណៈដោយផ្ទាល់។

# បំណាកស្រាយ ទី៩

## បរិបទគណនេយ្យភាពសង្គមនៅក្នុងប្រទេសកម្ពុជា

គណនេយ្យភាព គឺជាគោលការណ៍មួយនៃគោលការណ៍មូលដ្ឋានទាំងអស់សំរាប់វិមជ្ឈការ ប្រកបដោយភាពជោគជ័យ (Blunt & Turner, 2005) ចាប់តាំងពីបោះឆ្នោតអាណត្តិទី១ ក្នុងឆ្នាំ ២០០២ រដ្ឋាភិបាល និងទីភ្នាក់ងារផ្តល់ជំនួយបានធ្វើការប្រឹងប្រែងយ៉ាងខ្លាំងក្លា ដើម្បីពង្រឹងគណនេយ្យភាព ជាពិសេសទាក់ទងទៅនឹងអភិបាលកិច្ចល្អ ការផ្តល់សេវាកម្មល្អប្រសើរ ហើយនិងការធ្វើឱ្យប្រសើរឡើងនូវសមិទ្ធិផលសង្គម។ ដូច្នេះហើយគណនេយ្យភាពផុសចេញឡើងដោយមានការគិតគូរយ៉ាងខ្លាំង ហើយវាកំពុងកើនឡើងនូវលក្ខណៈសំខាន់ៗជាច្រើន នៅក្នុងកំណែទម្រង់អភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជា។ រដ្ឋាភិបាលសហគមន៍ផ្តល់ជំនួយ និងសង្គមស៊ីវិល ជាទូទៅទទួលស្គាល់ថា អភិបាលកិច្ចល្អ មិនអាចសំរេចផល និងមាននិរន្តរភាពបានទេ ប្រសិនបើគ្មានប្រព័ន្ធគណនេយ្យភាពដែលអាចដំណើរការបាន ហើយប្រព័ន្ធនោះត្រូវតែស៊ីគ្នានឹងបរិបទនៃស្ថាប័ន អភិបាលកិច្ច វប្បធម៌ ប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា។

អង្គការ CDRI ថ្មីនេះបានពិនិត្យឡើងវិញអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានផ្តល់យោបល់ថា រចនាសម្ព័ន្ធគណនេយ្យភាព និងការគ្រប់គ្រងបុគ្គលិករវាងរដ្ឋបាលឃុំ-សង្កាត់ ត្រូវតែធ្វើឱ្យប្រសើរឡើងក្នុងការធ្វើឱ្យស៊ីជំរៅ និងពង្រីកសមត្ថភាព ព្រមទាំងបញ្ជាក់ឱ្យច្បាស់នូវតួនាទី និងភារកិច្ចរបស់មេឃុំ ការចូលរួមនៅមូលដ្ឋាន និងគណនេយ្យភាពថ្នាក់ក្រោមដែលជាផ្នែកសំខាន់ ទោះបី ជាទូទៅបានទទួលស្គាល់ថា មិនមានដំណោះស្រាយងាយស្រួលណាមួយដើម្បីដោះស្រាយក៏ដោយ។ តាមរបាយការណ៍បានកត់សំគាល់ថា មិនទាន់មានយន្តការថ្មីៗ សំរាប់ឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់បង្ហាញពីការពេញចិត្ត និងការមិនពេញចិត្តចំពោះមន្ទីរនានាថ្នាក់ខេត្តឡើយ។ ក្រសួងនានាដែលជាថ្នាក់កណ្តាល ពិតជាមិនទាន់បញ្ចូលការវាយតំលៃពីខាងក្រៅទៅក្នុងប្រព័ន្ធត្រួតពិនិត្យ និងវាយតំលៃរបស់ពួកគេនៅឡើយ។ បញ្ហានេះអាចសន្និដ្ឋានថា មានការបិទបាំងគណនេយ្យភាពរវាងអ្នកផ្តល់សេវាកម្ម ទៅនិងអ្នកទទួលផល។

លោក Blair ឆ្នាំ ២០០០ កត់សំគាល់ថា ការប្តេជ្ញាចិត្តសំខាន់នៃវិមជ្ឈការតាមបែបប្រជាធិបតេយ្យ គឺថា "កសាងការចូលរួមពេញលេញ និងគណនេយ្យភាពនៅក្នុងអភិបាលកិច្ចមូលដ្ឋាន ធ្វើឱ្យមានការឆ្លើយតបចំពោះតម្រូវការ និងធ្វើឱ្យមានប្រសិទ្ធភាពបន្ថែមទៀតលើការផ្តល់សេវាកម្មនៅរដ្ឋាភិបាលថ្នាក់មូលដ្ឋាន" ។ នៅក្នុងបញ្ហាទាំងអស់ លោក Rusten et al ឆ្នាំ ២០០៤ បានគូសបញ្ជាក់ថា គោលដៅសំខាន់នៃវិមជ្ឈការក្នុងប្រទេសកម្ពុជា គឺ "កំពុងបង្កើត ប្រជាធិបតេយ្យចំរុះ បង្កើតនូវវប្បធម៌នៃការចូលរួមពេញលេញ និងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ" ។ ដូចគ្នានេះដែរ លោក Cohen & Peterson

នៅឆ្នាំ ១៩៩៩ បានសង្កត់ធ្ងន់ថា គណនេយ្យភាព គឺជាគោលការណ៍មួយនៃគោលការណ៍ថ្នាក់ក្រោមដ៏សំខាន់បំផុត ដើម្បីធ្វើឱ្យសម្រេចនូវគោលដៅវិមជ្ឈការ។ លោក Rudengrenel al ឆ្នាំ ២០០៥ បានរៀបចំការពិនិត្យឡើងវិញលើកម្មវិធីសិលាពាក់កណ្ដាលឆ្នាំ ហើយបានស្នើសុំយោបល់ឱ្យមានតម្រូវការលើការបង្កើតគណនេយ្យភាពសង្គម និងហិរញ្ញវត្ថុ។ តាមរបាយការណ៍ បញ្ជាក់ខ្លាំងថា ត្រូវមានការត្រួតពិនិត្យ និងថ្លឹងថ្លែងបន្ថែមទៀតនៅចន្លោះ និងនៅខាងក្រៅប្រព័ន្ធកម្មវិធីសិលាថ្មីៗនេះ។ របាយការណ៍ពិពណ៌នានូវគណនេយ្យភាពថ្នាក់ក្រោម ចាប់ពីក្រុមប្រឹក្សាឃុំដល់ម្ចាស់ឆ្នោតរបស់គេថា មានភាពទន់ខ្សោយ ជាពិសេសលើការបាត់បង់ព័ត៌មានអំពីការអនុវត្តរបស់ឃុំ។ ស្រដៀងគ្នានេះដែរ គណនេយ្យភាពថ្នាក់ក្រោមនៅថ្នាក់ខេត្ត គឺត្រូវបានបិទបាំងដោយសារខ្វះការសម្របសម្រួលក្នុងការធ្វើផែនការ និងការអនុវត្តរវាងមន្ទីរជំនាញ និងក្រុមប្រឹក្សាឃុំ។ រដ្ឋបាលថ្នាក់ខេត្ត គឺត្រូវបានគិតទុកថាជាចំណុចប្រសព្វសំខាន់នៃការកំណែទម្រង់ប្រកខ័ណ្ឌយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការថ្មី (រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ ២០០៥)។

*គោលគំនិតនៃពាក្យគណនេយ្យភាព គឺមិនងាយស្រួលយល់សំរាប់មនុស្សនៅតាមដងវិថីនោះទេ។ ប្រជាពលរដ្ឋមូលដ្ឋានចង់បានការបកស្រាយជាភាសារខ្មែរចំពោះពាក្យ "គណនេយ្យភាព" ហាក់ដូចជាមានបញ្ហាខ្លះស្រដៀងគ្នានឹងពាក្យ "គណនេយ្យ" ពួកគេមិនបានភ្ជាប់ទំនាក់ទំនងពាក្យដែលជាគុណតំលៃខ្មែរបុរាណថា អភិបាលកិច្ច ឬក៏ការទទួលខុសត្រូវ (ការទទួលខុសត្រូវចំពោះមុខ) ស្មោះត្រង់ចេះជួយទុក្ខធុរៈ ឬក៏បំរើប្រជាជន។ ដោយពិចារណាលើការលំបាកនេះ និងនិយមន័យមួយចំនួនធំដែលផ្ដល់ឱ្យឃើញថា មានប្រយោជន៍ខ្លាំងក្នុងការផ្ដោតលើគណនេយ្យភាពនៅក្នុងបរិបទនៃប្រទេសកម្ពុជា ដោយយោងលើទិដ្ឋភាពសំខាន់ ពីភាពអាចឆ្លើយតបបាន និងភាពអាចអនុវត្តបានបើគ្មានគណនេយ្យភាពណាមួយនោះវានឹងមិនអាចគ្រប់គ្រងបានទេ (លោក Schedler ឆ្នាំ ១៩៩៩)។*

*ភាពផ្សេងគ្នារវាងសញ្ញាណនៃពាក្យគណនេយ្យភាព នៅក្នុងអក្សរសាស្ត្រដ៏ទូលំទូលាយ និងគណនេយ្យភាពដែលត្រូវបានអនុវត្តនៅប្រទេសកម្ពុជា គឺមានការយល់ជាក់លាក់បាន។ យោងកម្មវត្ថុខាងលើនយោបាយ និងផ្ទាល់ខ្លួន ហើយនិងទំនាក់ទំនងនៃអំណាចដែលជុំរុញមានការគាំទ្រចំណងសាច់ញាតិ ព្រមទាំងដំណើរការសាមញ្ញដែលជុំរុញឱ្យមានឥទ្ធិពលទាំងនេះមានឥទ្ធិពលដោយផ្ទាល់ដល់សមត្ថភាពរូបវ័ន្តបុគ្គល គឺត្រូវមានការទទួលខុសត្រូវ។ គណនេយ្យភាពដែលជាការចង់បានរបស់រដ្ឋដែលកំណែទម្រង់រកឃើញថា ចង់ជុំរុញឱ្យមានការរីកចំរើននោះ គឺជាការចេញដំណើរដ៏ជាក់លាក់ពីឥឡូវដល់ពេលខាងមុខ។*

**ប្រភព** : CDRI ឆ្នាំ ២០០៥

នៅប្រទេសកម្ពុជា ការផ្តល់សេវាកម្មសង្គមជាមូលដ្ឋានជាតួនាទីយ៉ាងចំបងក្នុងអាណត្តិរបស់ក្រសួងនានា ដែល រដ្ឋបាលថ្នាក់ជាតិ ទោះយ៉ាងណាក៏ដោយ ច្បាប់គ្រប់គ្រងរដ្ឋបាលក្រុមប្រឹក្សាឃុំ-សង្កាត់ បានប្រតិភូកម្ម ការងារត្រួតពិនិត្យឬក៏មុខងារមើលការខុសត្រូវលើការផ្តល់សេវាកម្មមូលដ្ឋានទៅឱ្យក្រុមប្រឹក្សាឃុំ។ ដើម្បី បង្កើនការគាំទ្រដល់អង្គភាពនេះ គំរោងរបាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋ និងក្រុមស្រាវជ្រាវឃុំ មានការចងសម្ព័ន្ធខ្លាំងក្លាក្នុងការបង្ហាញលទ្ធផលនៃរបាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋ ហើយនិង ជំរុញឱ្យមានកំណែទំរង់លើការផ្តល់សេវាកម្ម។ នៅក្នុងន័យនេះ គំរោងរបាយការណ៍វាយតំលៃរបស់ប្រជា ពលរដ្ឋ គឺទំរង់ដែលមានការផ្លាស់ប្តូរមួយសំរាប់ភាពជាដៃគូរបស់ក្រុមប្រឹក្សាឃុំ និងសង្គមស៊ីវិល គណនេយ្យ ភាពត្រូវបានកំណត់ថា ជាកាតព្វកិច្ចនៃអ្នកកាន់អំណាចក្នុងការគិតគូរ ឬទទួលខុសត្រូវចំពោះសកម្មភាព របស់ខ្លួន។ អ្នកកាន់អំណាចមិនកំណត់តែមន្ត្រីរដ្ឋាភិបាលនោះទេ វារាប់បញ្ចូលទាំងអ្នកកាន់អំណាចខាង នយោបាយ ហិរញ្ញវត្ថុ ឬរូបភាពផ្សេងៗនៃអំណាច។ គណនេយ្យភាព គឺជាលទ្ធផលមួយនៃការព្រមព្រៀង គ្នាទាំងស្រុងលើផ្នែកសង្គមរវាងប្រជាពលរដ្ឋ និងក្រុមមនុស្សដែលគេបោះឆ្នោតឱ្យកាន់អំណាច។ មន្ត្រីរដ្ឋា ភិបាលនិងមន្ត្រីទទួលបន្ទុកថវិកាគួរតែមានគណនេយ្យភាព ហើយមិនគ្រាន់តែមានចំពោះការអនុវត្ត របស់គេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាកប្បកិរិយារបស់គេផងដែរ។ នៅក្នុងករណីជាច្រើន ផ្នែកផ្តល់គណ នេយ្យភាព ត្រូវបានគេគិតគូររយៈពេលយូរអង្វែង ដូចជាបណ្តាញសំរាប់តាមដានត្រួតពិនិត្យ និងវាយតំលៃ។ ទោះយ៉ាងណាក៏ដោយ ផ្នែកតម្រូវការគណនេយ្យភាពជាប់ពាក់ព័ន្ធជាមួយប្រជាពលរដ្ឋធ្វើការវាយតំលៃ ការអនុវត្ត និងការទទួលកាន់ការជាអ្នកផ្តល់សេវាកម្ម ហើយអ្នកទទួលសិទ្ធិត្រូវមានគណនេយ្យភាព អ្វីដែលខ្សោយធ្វើឱ្យល្អបំផុត អ្វីដែលគេមិនដឹង ត្រូវធ្វើឱ្យគេដឹងច្រើនបំផុត។

គណនេយ្យភាពសង្គមសំដៅចំពោះយន្តការ និងសកម្មភាពដែលមានទំហំធំទូលាយ ក្រៅពីការបោះឆ្នោត ជ្រើសរើស ប្រជាពលរដ្ឋ សហគមន៍ អង្គការសង្គមស៊ីវិល និងបណ្តាញផ្សព្វផ្សាយព័ត៌មានអាចជំរុញឱ្យ មន្ត្រីរដ្ឋាភិបាល និងមន្ត្រីទទួលបន្ទុកថវិកាមានគណនេយ្យភាព។ ក្នុងចំណោមយន្តការទាំងនេះ រួមមាន ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ការគ្រប់គ្រងថវិកាបែបចូលរួម ការតាម ដានចំណាយជាសាធារណៈ ហើយនិងការតាមដានត្រួតពិនិត្យរបស់ប្រជាពលរដ្ឋលើការផ្តល់សេវាកម្ម សាធារណៈ (ធនាគារពិភពលោកឆ្នាំ ២០០៣)។

គណនេយ្យភាពសង្គម គឺជាដំណើរការដែលពីពេលនេះទៅ ប្រជាពលរដ្ឋត្រូវចូលរួមក្នុងការវាយតំលៃ ការអនុវត្តលើគោលនយោបាយសាធារណៈ និងធ្វើឱ្យមានឥទ្ធិពលដល់ដំណើរការ លទ្ធផលផលប៉ះពាល់ នៃគោលនយោបាយទាំងនេះ ព្រមទាំងការចំណាយដែលអាចឆ្លើយតបបាន ហើយទាំងអស់នេះ ត្រូវបានគេ បែងចែកដើម្បីអនុវត្តវា។ យន្តការគណនេយ្យភាពសង្គម បង្កើតនូវអភិបាលកិច្ចល្អ កែលំអសេវាកម្ម

សាធារណៈ តាមរយៈការរៀបចំបង្កើតគោលនយោបាយគាំទ្រ ហើយត្រូវយល់ឃើញថា ជាដំណើរការពង្រឹងអំណាចរបស់ប្រជាពលរដ្ឋសាមញ្ញ ។

មានហេតុផលមួយចំនួន ដែលនាំឱ្យរដ្ឋាភិបាលមិនអាចផ្តល់សេវាកម្មសង្គមគ្រប់គ្រាន់ជូនប្រជាពលរដ្ឋនេះ មកពីខ្វះមូលនិធិ មិនមានការបែងចែកធនធាន ឬក៏ចាត់អាទិភាពខុស អំពើពុករលួយ និងទម្រង់ផ្សេងទៀតនៃការលេចធ្លាយ ឬ ខ្វះតម្រូវការ ឬការទាមទារដែលត្រូវបង្ហាញប្រាប់គេ។ យន្តការគណនេយ្យភាពសង្គមមានប្រយោជន៍ក្នុងការកែលំអលើការផ្តល់សេវាកម្មមូលដ្ឋានដោយមានការបង្កើតនិងការផ្តល់ព័ត៌មាន ឬការបង្ហាញពីតម្រូវការ ការពង្រឹងសំលេងរបស់ប្រជាពលរដ្ឋ ការបង្កើតឱ្យមានការពិភាក្សាគ្នា ហើយនិងរូបភាពផ្សេងៗនៃការភ្ជាប់ទំនាក់ទំនងជាមួយរដ្ឋាភិបាល។ ការផ្តួចផ្តើមគណនេយ្យភាពសង្គម ការផ្លាស់ប្តូរមានសារៈសំខាន់សំរាប់ការសំរេចចិត្តមានតម្លាភាព ការចូលរួមដើម្បីជួយក្នុងការកាត់បន្ថយភាពក្រីក្រ គំនិតផ្តួចផ្តើមគណនេយ្យភាពសង្គមចាប់ផ្តើមឱ្យមនុស្សមានការយល់ដឹងទៅលើសិទ្ធិ និងការទទួលខុសត្រូវនៅក្នុងលិទ្ធប្រជាធិបតេយ្យ។ ជាឧបករណ៍ នៅក្នុងព្រឹត្តិការណ៍រៀនសូត្រសំរាប់អង្គការក្រៅរដ្ឋាភិបាល និងក្រុមស្រាវជ្រាវឃុំ**គាំទ្រគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់** ជានិច្ចកាលត្រូវគូសបញ្ជាក់អំពីសារៈសំខាន់របស់ប្រជាពលរដ្ឋដែលត្រូវអនុវត្តសិទ្ធិ និងការទទួលខុសត្រូវរបស់គេ ជាពិសេសនៅក្នុងបរិបទកំណែទំរង់អភិបាលកិច្ចថ្មីរបស់ប្រទេសកម្ពុជា។ ការប្រឹងប្រែងឱ្យមានការយល់ដឹងពីសិទ្ធិទាំងនេះ ពេលនោះនឹងក្លាយជាគន្លឹះមួយសំរាប់ធ្វើជាចលនាជំរុញការអនុវត្តគំនិតផ្តួចផ្តើមគណនេយ្យភាពសង្គម ដូចជា របាយការណ៍វាយតំលៃរបស់ប្រជាពលរដ្ឋជាដើម។ ពេលនោះគណនេយ្យភាពសង្គមនឹងក្លាយជាដំណើរការពង្រឹងអំណាចដែលបានមកដោយសារប្រជាពលរដ្ឋមានការយល់ដឹងអំពីសិទ្ធិរបស់គេ ដើម្បីទាមទារហើយមានកាតព្វកិច្ចជួយជំរុញឱ្យមន្ត្រីរដ្ឋាភិបាល និងភ្នាក់ងាររបស់រដ្ឋមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។ តាមរយៈការលើកកំពស់ សំលេងរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ គណនេយ្យភាពសង្គម ជំរុញឱ្យមានការផ្លាស់ប្តូរវិជ្ជមានចំពោះរដ្ឋាភិបាល ដើម្បីឱ្យអាចឆ្លើយតបបានទៅនឹងតម្រូវការរបស់អ្នកក្រីក្រ។

គណនេយ្យភាពរបស់មន្ត្រីសាធារណៈ គឺជាទីពុំនាក់ដ៏សំខាន់របស់រដ្ឋាភិបាល និងការរៀបចំទុកជាមុនសំរាប់ប្រជាធិបតេយ្យប្រកបដោយប្រសិទ្ធភាព។ ផ្ទុយទៅវិញ ការជឿជាក់និងការគោរពរបស់ប្រជាជនចំពោះរដ្ឋាភិបាលនឹងអស់ភ្លាមៗ នៅពេលមន្ត្រីរដ្ឋាភិបាលមិនទទួលខុសត្រូវចំពោះពីតម្រូវការ និងការត្អូញត្អែររបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ គ្មានអ្វីដំណើរការទាល់តែសោះ ប្រសិនបើប្រជាជនគ្រាន់តែប្រកូកហៅ និងធ្វើការជំទាស់នៅតែតាមដងផ្លូវ។ យន្តការគណនេយ្យសង្គម គឺជាសកម្មភាពជាក់ស្តែង ដែលជំរុញលទ្ធភាពរបស់ប្រជាពលរដ្ឋ ដើម្បីធ្វើចលនាក្រោយពីការជំទាស់ឱ្យទៅជាការចូលរួមជាមួយនឹងមន្ត្រី

រដ្ឋាភិបាល និងអ្នកផ្តល់សេវាកម្មនៅក្នុងទម្រង់ជាក្រៅផ្លូវការ ចាត់ចែង និងបែបបស្លាបនា ដូចនេះនឹងបង្កើន ជោគវាសនានៃការជះឥទ្ធិពលទៅលើការផ្លាស់ប្តូរវិជ្ជាមាន។

## ឯកសារយោង


1. Ackerman (2004): Dimension of social accountability

2. Accountability International 2004

3. Jonathan Fox (2000): State-Society Synergy for Accountability

4. Kieng Sochivy, 2006: Assessment of current decentralization in Cambodia

5. Narayan 2000: Voice of the poor

6. Reiner Forster, SDV of World Bank 2005: Enhancing citizen voice and client focus in governance and service delivery: a presentation

7. Samuel Paul, "Citizens Report Cards: Case Study", Public Affairs Center, 2005.

8. South-Asia Social Accountability Network: www.sasanet.org

9. The Times of India: "On the citizen report card process", Bangalore, 8 November 1999

10. World Bank: Social development paper, an introduction to the concept and emerging practice